លឹម សុវណ្ណវិចិត្រ

# កម្រងលំហាត់ គណិតវិទ្យា

## កម្រិតវិទ្យាល័យ

## ភាគ ២- ពីជគណិត វិភាគ

សេរី ៥.០

មេសា ២០១១

ទំព័រទទេ

ទំព័រទទេ

លឹម សុវណ្ណវិចិត្រ

# កម្រងលំហាត់

# គណិតវិទ្យា

## កម្រិតវិទ្យាល័យ

## ភាគ ២- ពីជគណិត វិភាគ

ស៊េរី ៥.០

មេសា ២០១១

ភាគ១ - ទ្រឹស្តីនៃចំនួន

ភាគ២ - ពីជគណិត វិភាគ

ផ្សាយលើកទី១ : គណិតវិទ្យាអូឡាំពិច -វិសមភាព ២០០៨

ផ្សាយលើកទី២ : កំរងលំហាត់គណិតវិទ្យា -ពីជគណិត វិភាគ កក្កដា ២០០៩

ផ្សាយលើកទី៣ : កំរងលំហាត់គណិតវិទ្យា -ពីជគណិត វិភាគ សីហា ២០០៩

ផ្សាយលើកទី៤ : កម្រងលំហាត់គណិតវិទ្យា -ពីជគណិត វិភាគ មីនា ២០១០

ផ្សាយលើកទី៤.១ : កម្រងលំហាត់គណិតវិទ្យា -ពីជគណិត វិភាគ ធ្នូ ២០១០

ដោយ លឹម សុវណ្ណវិចិត្រ

ទំនាក់ទំនង

- វែបសាយថ៍ http://www.dahlina.com/
- អ៊ីមែល lsvichet@yahoo.com

# មាតិកា


១. និយមន័យ ទ្រឹស្តីបទ ........ 1

១.១ និមិត្តសញ្ញា ........ 1

១.២ ផលបូកស៊ីមេទ្រី និង ស៊ីគ្លិច ........ 2

១.៣ កន្សោមឆ្លុះឬស៊ីមេទ្រី ........ 3

១.៤ ពហុធាអូម៉ូសែន ........ 4

១.៥ អនុគមន៍ផត- ប៉ោង ........ 4

១.៦ ពហុធាស៊ីមេទ្រីបឋម ........ 6

១.៧ ច្បាប់ Viète ........ 6

១.៨ ឯកលក្ខណភាពញូតុន ........ 7

១.៩ អនុវត្តន៍ពេញ-ប្រកាន់-មួយទល់មួយ ........ 7

១.១០ ស្វ៊ីតនៃចំនួនសនិទាន ........ 15

១.១១ ភាពជាប់ ........ 17

១.១២ ទំនាក់ទំនងកំណើនលីនេអ៊ែអូម៉ូសែន $U_{n+2} = aU_{n+1} + bU_n$ ........ 17


## លំហាត់


២. អនុគមន៍ងាយ ........ 19

៣. អនុគមន៍អិចស្ប៉ូណង់ស្យែល និងលោការីត ........ 69

៤. ត្រីកោណមាត្រ ........ 83

៥. ពហុធា ........ 105

៦. សមីការអនុគមន៍ ........ 111


## ចម្លើយ


២. អនុគមន៍ងាយ ........ 121

៣. អនុគមន៍អិចស្ប៉ូណង់ស្យែល និងលោការីត........................................................ 281
៤. ត្រីកោណមាត្រ............................................................................................ 297
៥. ពហុធា ...................................................................................................... 349
៦. សមីការអនុគមន៍........................................................................................ 379

# ១

# និយមន័យ និង ទ្រឹស្តីបទ

## ១.១ និមិត្តសញ្ញា

$x \in [a;b]$ មានន័យថា $a \leq x \leq b$

$x \in (a;b)$ មានន័យថា $a < x < b$

$x \in [a;b)$ មានន័យថា $a \leq x < b$

$\binom{n}{m} = C_n^m = \frac{n!}{m!(n-m)!}$

$\mathbb{N}$ សំណុំចំនួនគត់ធម្មជាតិ ដែលមានទាំងលេខសូន្យ $\mathbb{N} = \{0;\ 1; 2; 3; \dots\}$

$\mathbb{N}^*$ សំណុំចំនួនគត់ធម្មជាតិមិនសូន្យ $\mathbb{N}^* = \{1; 2; 3; \dots\}$

$\mathbb{Z}$ សំណុំចំនួនគត់ $\mathbb{Z} = \{\dots; -3; -2;\ -1; 0; 1; 2; 3; \dots\}$

$\mathbb{Z}^*$ សំណុំចំនួនគត់មិនសូន្យ $\mathbb{Z}^* = \{\dots; -3; -2;\ -1; 1; 2; 3; \dots\}$

$\mathbb{Z}^+$ សំណុំចំនួនគត់វិជ្ជមានឬសូន្យ $\mathbb{Z}^+ = \{0; 1; 2; 3; \dots\}$

$\mathbb{R}$ សំណុំចំនួនពិត

$\mathbb{R}^+$ សំណុំចំនួនពិតមិនអវិជ្ជមាន $\mathbb{R}^+ = \{x | x \geq 0\}$

## សញ្ញាបូក

$$\sum_{i=1}^{n} x_i = x_1 + x_2 + \cdots + x_n$$

$$\sum_{1\le i<j\le n} x_i x_j = x_1x_2 + x_1x_3 + x_1x_4 + \cdots + x_1x_n + x_2x_3 + x_2x_4 + \cdots + x_2x_n + \cdots + x_{n-1}x_n$$

$$\sum_{1\le i<j\le 5} x_i x_j = x_1x_2 + x_1x_3 + x_1x_4 + x_1x_5 + x_2x_3 + x_2x_4 + x_2x_5 + x_3x_4 + x_3x_5 + x_4x_5$$

$$\sum_{1\le i<j\le 3} \frac{x_i}{x_i + x_j} = \frac{x_1}{x_1 + x_2} + \frac{x_1}{x_1 + x_3} + \frac{x_2}{x_2 + x_3}$$

$$\sum_{1\le i\ne j\le 3} x_i x_j = x_1x_2 + x_1x_3 + x_2x_1 + x_2x_3 + x_3x_1 + x_3x_2 = 2(x_1x_2 + x_1x_3 + x_2x_3)$$

# ១.២ និយមន័យ: ផលបូកស៊ីមេទ្រី និង ស៊ីគ្លិច

តាង $P(x,y,z)$ ជាអនុគមន៍មានបីអថេរ $x,y,z$ ។ តាង

$$\sum_{\text{cyclic}} P(x,y,z) = P(x,y,z) + P(y,z,x) + P(z,x,y)$$

$$\sum_{\text{sym}} P(x,y,z) = P(x,y,z) + P(x,z,y) + P(y,x,z) + P(y,z,x) + P(z,x,y) + P(z,y,x)$$

ឧទាហរណ៍

$$\sum_{\text{cyclic}} x^3y = \sum_{\text{cyclic}} x^3y\,z^0 = x^3yz^0 + y^3zx^0 + z^3xy^0 = x^3y + y^3z + z^3x$$

$$\sum_{\text{sym}} x^3 = \sum_{\text{sym}} x^3y^0z^0$$

$$= x^3y^0z^0 + x^3z^0y^0 + y^3x^0z^0 + y^3z^0x^0 + z^3x^0y^0 + z^3y^0x^0$$
$$= 2(x^3 + y^3 + z^3)$$

$$\sum_{\text{sym}} x^3y^2z = x^3y^2z + x^3z^2y + y^3x^2z + y^3z^2x + z^3x^2y + z^3y^2x$$

$$\sum_{\text{sym}} x^2y = \sum_{\text{sym}} x^2y^1z^0$$
$$= x^2y^1z^0 + x^2z^1y^0 + y^2x^1z^0 + y^2z^1x^0 + z^2x^1y^0 + z^2y^1x^0$$
$$= x^2y + x^2z + y^2x + y^2z + z^2x + z^2y$$

$$\sum_{\text{sym}} xyz = xyz + xzy + yxz + yzx + zxy + zyx = 6xyz$$

## ១.៣ កន្សោមមួយមានលក្ខណៈឆ្លុះ ឬ ស៊ីមេទ្រី

កន្សោមមួយ មានលក្ខណៈស៊ីមេទ្រី បើយើងឆ្លាស់អញ្ញាតណាមួយនឹងអញ្ញាតណាមួយផ្សេងទៀត កន្សោមនោះនៅដដែល ។ ឧទាហរណ៍ $P = x + y + z,\ (x, y, z) \in \mathbb{R}$ មានលក្ខណៈស៊ីមេទ្រីធៀបនឹង $x, y, z$ ដោយសារបើយើងជំនួស $x$ ដោយ $y$ និង $y$ ដោយ $x$ វិញ វានៅដដែល ។ បើយើងជំនួស $x$ ដោយ $z$ និង $z$ ដោយ $x$ វិញ វានៅដដែល ។ បើយើងជំនួស $y$ ដោយ $z$ និង $z$ ដោយ $y$ វិញ វានៅដដែល ។

ពហុធា $P = x^3 + y^3 + z$ មិនមានលក្ខណៈស៊ីមេទ្រីទេ ព្រោះ បើយើងជំនួស $z$ ដោយ $x$ និង $x$ ដោយ $z$ យើងទាញបាន $P' = z^3 + y^3 + x \neq x^3 + y^3 + z$ ។

ចំពោះកន្សោមស៊ីមេទ្រី យើងអាចសន្មតថា $x \geq y \geq z$ ឬ $x \leq y \leq z$ បាន បើទោះជាគេមិនប្រាប់បែបនេះក៏ដោយ ឬមួយជាទូទៅ $x, y, z$ មិនចាំបាច់ផ្ទៀងផ្ទាត់លក្ខខណ្ឌបែបនេះក៏ដោយ លើកលែងតែមានសម្មតិកម្មមកស្រាប់ផ្សេងពីនេះ ។ ហេតុអ្វីក៏យើងអាចសន្មតបានបែបនេះ? ។ ព្រោះ $x$ អាចដើរតួជំនួស $y, z$ បាន $y$ អាចដើរតួជំនួស $x, z$ បាន និង $z$ អាចដើរតួជំនួស $x, y$ បាន ។ បើមានមួយក្នុងចំនួនទាំងបីធំជាងគេ យើងតាងវា

ដោយ $x_1$ ចំនួនធំបន្ទាប់ដោយ $y_1$ និងតូចជាងគេដោយ $z_1$ ។ ដូច្នេះ $x_1 \geq y_1 \geq z_1$ ។ ដូច្នេះកន្សោមស៊ីមេទ្រី ដូចជា $P = x + y + z = x_1 + y_1 + z_1$ ។ ដូច្នេះកន្សោម $P$ នៅតែដដែលគ្រាន់តែថែមសន្ទស្សន៍ 1 ពីក្រោមតែប៉ុណ្ណោះ ។

## ១.៤ ពហុធាអូម៉ូសែន

ពហុធាអូម៉ូសែន ជាពហុធាមួយដែលមានតួនីមួយៗរបស់វា មានដឺក្រេសរុបស្មើគ្នា ។ ឧទាហរណ៍ $x^5 + 2x^3y^2 + 9xy^4$ ជាពហុធាអូម៉ូសែននៃ $x, y$ ព្រោះតួទីមួយមានដឺក្រេស្មើ 5 ; តួទីពីរមានដឺក្រេស្មើ $3 + 2 = 5$ និង តួទីបី មានដឺក្រេ $1 + 4 = 5$ ។

## ១.៥ អនុគមន៍ផត-អនុគមន៍ប៉ោង

អនុគមន៍មួយផតចន្លោះចំណុច $A$ និង $B$ បើ ខ្សែកោងអនុគមន៍នោះឋិតនៅក្រោមបន្ទាត់ភ្ជាប់*គ្រប់ចំណុចទាំងអស់*ឋិតនៅចន្លោះ $A$ និង $B$ ។ វាប៉ោងបើវានៅខាងលើ ។

* អនុគមន៍ $f$ មួយ ដែលកំណត់លើ $I \in \mathbb{R}$ ហៅថា ផត បើ ចំពោះគ្រប់ $\lambda \in [0;1]$ និង គ្រប់ $x, y \in I$ គេមាន

$$f[\lambda x + (1-\lambda)y] \leq \lambda f(x) + (1-\lambda) f(y)$$

* អនុគមន៍មួយផតលើ $[a, b]$ បើ $f''(x) > 0, \forall x \in [a, b]$

* បើ $f$ ផតចន្លោះ $A, B$ នោះ តម្លៃធំបំផុតរបស់ $f$ បើមិននៅត្រង់ $A$ គឺនៅត្រង់ $B$ : $f_{max} = \max(f_A, f_B)$

* បើ $f$ ប៉ោងចន្លោះ $A, B$ នោះ តម្លៃតូចបំផុតរបស់ $f$ បើមិននៅត្រង់ $A$ គឺនៅត្រង់ $B$ : $f_{min} = \min(f_A, f_B)$

### សម្គាល់

និយមន័យដែលប្រើជាអន្តរជាតិ គេកំណត់ភាពប៉ោងផតផ្ទុយពីការកំណត់របស់កម្ពុជា ។ ករណីដែលកម្ពុជាហៅថា ប៉ោង គេហៅថាផត (concave) ។ ករណីដែលកម្ពុជាហៅថា ផត គេហៅថាប៉ោង (convex) ។ ប៉ុន្តែ ទាំងកម្ពុជា និង អន្តរជាតិ បានកំណត់ហៅភាពប៉ោងផតដូចគ្នាចំពោះពហុកោណ ។




អនុគមន៍ផតចន្លោះ $AB$




អនុគមន៍ប៉ោងចន្លោះ $AB$




លក្ខណៈអនុគមន៍ផត

## ១.៦ ពហុធាស៊ីមេទ្រីបឋម

ពហុធាស៊ីមេទ្រីបឋមទី $k$ នៃ $x_1, x_2, \ldots, x_n$ តាងដោយ $e_k(x_1, x_2, \ldots, x_n)$ ជាផលបូកនៃផលគុណផ្សេងគ្នាទាំងអស់ដែលអាចមាននៃអថេរខុសៗគ្នាចំនួន $k$ ។ យើងមាន

$$
\begin{aligned}
&e_0(x_1, x_2, \ldots, x_n) = 1\\
&e_1(x_1, x_2, \ldots, x_n) = x_1 + x_2 + \cdots + x_n\\
&e_2(x_1, x_2, \ldots, x_n)\\
&\qquad = (x_1x_2 + x_1x_3 + \cdots + x_1x_n) + (x_2x_3 + x_2x_4 + \cdots + x_2x_n)\\
&\qquad + \cdots + x_{n-1}x_n\\
&\vdots\\
&e_n(x_1, x_2, \ldots, x_n) = x_1x_2 \ldots x_n
\end{aligned}
$$

ជាពិសេស $e_k(x_1, x_2, \ldots, x_n) = 0$ បើ $k > n$ ។

## ១.៧ ច្បាប់ Viète

តាង $p(X) = a_nX^n + a_{n-1}X^{n-1} + \cdots + a_1X + a_0$ ជាពហុធាដឺក្រេទី $n$ មានឫសចំនួន $n$ តាងដោយ $x_1, x_2, \ldots, x_n$ ។ ឫសទាំងនេះជាចំនួនពិតឬកុំផ្លិច ។ មេគុណ $a_0, a_1, \ldots, a_n$ អាចជាចំនួនពិតឬកុំផ្លិច ដោយ $a_n \neq 0$ ។ ច្បាប់ Viète ចែងថា

$$
\begin{cases}
x_1 + x_2 + \cdots + x_{n-1} + x_n = -\dfrac{a_{n-1}}{a_n}\\
(x_1x_2 + x_1x_3 + \cdots + x_1x_n) + (x_2x_3 + x_2x_4 + \cdots + x_2x_n) + \cdots + x_{n-1}x_n = \dfrac{a_{n-2}}{a_n}\\
\vdots\\
x_1x_2 \ldots x_n = (-1)^n \dfrac{a_0}{a_n}
\end{cases}
$$

ដោយប្រើពហុធាស៊ីមេទ្រីបឋម

$$\begin{cases} e_1(x_1,x_2,..,x_n) = -\dfrac{a_{n-1}}{a_n} \\ e_2(x_1,x_2,..,x_n) = \dfrac{a_{n-2}}{a_n} \\ \vdots \\ e_n(x_1,x_2,..,x_n) = (-1)^n \dfrac{a_0}{a_n} \end{cases}$$

# ១.៨ ឯកលក្ខណភាព ញូតុន ឬ រូបមន្ត Newton- Girard

តាង $p_k(x_1,x_2,\dots,x_n) = x_1^k + x_2^k + \cdots + x_n^k$ ។ឯកលក្ខណភាពញូតុនចែងថា

$$ke_k(x_1,x_2,\dots,x_n) = \sum_{i=1}^{k}(-1)^{i-1}e_{k-i}(x_1,x_2,\dots,x_n)p_i(x_1,x_2,\dots,x_n)$$

ដែល $e_k(x_1,x_2,\dots,x_n)$ ជាពហុធាស៊ីមេទ្រីបឋមទី $k$ នៃ $x_1,x_2,\dots,x_n$ ។

ចំពោះ $k = 1,2,3,4$ យើងមាន

$$\begin{aligned} &e_1 = p_1 \\ &2e_2 = e_1p_1 - p_2 \\ &3e_3 = e_2p_1 - e_1p_2 + p_3 \\ &4e_4 = e_3p_1 - e_2p_2 + e_1p_3 - p_4 \end{aligned}$$

# ១.៩ អនុវត្តន៍

## ១.៩.១ និយមន័យ

$f: X \to Y$ ហៅថា អនុគមន៍អនុវត្តពី $X$ ទៅ $Y$ បើគ្រប់ធាតុ $x \in X$ គេមានរូបភាព $f(x) \in Y$ យ៉ាងតិចមួយនិងតែមួយគត់ ។




រូបទី១ អនុវត្តន៍ពី $X$ ទៅ $Y$




រូបទី២ មិនមែនជាអនុវត្តន៍ពី $X$ ទៅ $Y$ ៖ រូបក) យើងមាន 3 ឱ្យរូបភាពពីរក្នុង $Y$ និងក្នុង រូបខ) 4 គ្មានរូបភាពក្នុង $Y$

យើងមានអនុវត្តន៍៣ប្រភេទ៖

- Surjective(អនុវត្តន៍ពេញ)
- Injective(អនុវត្តន៍ប្រកាន់)
- Bijective (អនុវត្តន៍មួយទល់មួយ)

## ១.៩.២ អនុវត្តន៍ពេញ

គេមាន $f: X \to Y$ ។ គេថា $f$ ជាអនុវត្តន៍ពេញពី $X$ ទៅ $Y$ ទាល់តែ $\forall y \in Y, \exists x \in X$ ដែល $y = f(x)$ ។




រូបទី៣ អនុវត្តន៍ពេញ




រូបទី៨ អនុវត្តន៍មិនពេញ៖ មិនអាចរកបាន $x \in X$ ដែល $f(x) = D$ បានទេ ។

ឧទាហរណ៍ ៖ $f(x) = x$ ជាអនុវត្តន៍ពេញពី $\mathbb{R}$ ទៅ $\mathbb{R}$ ។

ឧទាហរណ៍ ៖ $f(x) = x^2$ ជាអនុវត្តន៍ពេញពី $X = \mathbb{R}$ ទៅ $Y = \mathbb{R}+$ តែជាអនុវត្តន៍មិនពេញពី $X = \mathbb{R}$ ទៅ $Y = \mathbb{R}$ ព្រោះ ឧទាហរណ៍យើងមិនអាចរក $x$ ដែល $f(x) = -1$ បានទេ (យើងមាន $-1 \in Y$ ព្រោះ $Y = \mathbb{R}$) ។

## ១.៩.៣ អនុវត្តន៍ប្រកាន់

គេមាន $f: X \to Y$ ។ គេថា $f$ ជាអនុវត្តន៍ប្រកាន់ពី $X$ ទៅ $Y$ ទាល់តែ $\forall x, y \in X$ បើ $f(x) = f(y)$ នោះ $x = y$ ឬ បើ $x \neq y$ នោះ $f(x) \neq f(y)$ ។




រូបទី៥ អនុវត្តន៍ប្រកាន់




រូបទី៦ អនុវត្តន៍មិនប្រកាន់

ឧទាហរណ៍ ៖ $f(x) = x$ ជាអនុវត្តន៍ប្រកាន់ពី $\mathbb{R}$ ទៅ $\mathbb{R}$ ។

ឧទាហរណ៍ ៖ $f(x) = x^2$ ជាអនុវត្តន៍ប្រកាន់ពី $\mathbb{R}+$ ទៅ $\mathbb{R}+$ ។

$f(x) = x^2$ ជាអនុវត្តន៍មិនប្រកាន់ពី $\mathbb{R}$ ទៅ $\mathbb{R}$ ព្រោះ $-2 \neq 2$, តែ $f(-2) = f(2) = 4, \dots$ ។




$f(x) = x^2$ ជាអនុវត្តន៍មិនប្រកាន់ពី $\mathbb{R}$ ទៅ $\mathbb{R}+$ ព្រោះ $-2 \neq 2$, តែ $f(-2) = f(2) = 4, \ldots$ ។




## ១.៩.៤ អនុវត្តន៍មួយទល់មួយ

គេមាន $f: X \to Y$ ។ គេថា $f$ ជាអនុវត្តន៍មួយទល់មួយពី $X$ ទៅ $Y$ ទាល់តែ $\forall y \in Y$ មាន $x \in X$ មួយនិងតែមួយគត់ ដែល $f(x) = y$ ។




រូបទី៧ អនុវត្តន៍មួយទល់មួយ




រូបទី៨ អនុវត្តន៍មិនមែនមួយទល់មួយ

ឧទាហរណ៍ ៖ $f(x) = x$ ជាអនុវត្តន៍មួយទល់មួយពី $\mathbb{R}$ ទៅ $\mathbb{R}$ ។

ឧទាហរណ៍ ៖ $f(x) = x^2$ ជាអនុវត្តន៍មួយទល់មួយពី $\mathbb{R}+$ ទៅ $\mathbb{R}+$ ។

## ១.៩.៥ សង្ខេប




ជាអនុវត្តន៍ពេញ, ប្រកាន់ និងមួយទល់មួយ

ឧទា. $f:\mathbb{R}\to\mathbb{R}, f(x)=x$




ជាអនុវត្តន៍មិនពេញ,

ប្រកាន់

និងមិនមែនមួយទល់មួយ

ឧទា. $f:\mathbb{R}\to\mathbb{R},\ f(x)=e^x$




ជាអនុវត្តន៍ពេញ,

មិនប្រកាន់

និងមិនមែនមួយទល់មួយ

ឧទា. $f\colon \mathbb{R} \to \mathbb{R}+,\ f(x) = x^2$

## ១.១០ ទ្រឹស្តីបទស្វ៊ីតចំនួនសនិទាន

គ្រប់ចំនួនពិតទាំងអស់សុទ្ធតែជាលីមីតនៃស្វ៊ីតសនិទានកើនណាមួយ និងជាលីមីតនៃស្វ៊ីតសនិទានចុះណាមួយ ។

### សម្រាយបញ្ជាក់

យើងស្រាយបញ្ជាក់ទ្រឹស្តីគន្លឹះខ្ទះៗក្នុង 1,2,3 សិន បន្ទាប់មកនឹងស្រាយបញ្ជាក់សំណើក្នុងចំណុចទី4) ។

1) តាង $\lfloor a \rfloor$ ជាផ្នែកគត់នៃចំនួនពិត $a$ ។ យើងមាន

$$a = \lfloor a \rfloor + \{a\}, 0 \le \{a\} < 1, \{a\} < \lfloor a \rfloor$$
$$\lfloor a \rfloor \le a \le \lfloor a \rfloor + 1$$

ដូច្នេះ

$$1 = \frac{\lfloor a \rfloor}{a} + \frac{\{a\}}{a};$$
$$\lim_{a\to\infty} \frac{\{a\}}{a} = 0$$
$$\Rightarrow \lim_{a\to+\infty} \frac{\lfloor a \rfloor}{a} = 1$$
$$\Rightarrow \lim_{a\to-\infty} \frac{\lfloor a \rfloor}{a} = 1$$

2) ក្នុង 1) យក $a = 10^n x$ យើងទាញបាន

$$\lim_{n\to+\infty} \frac{\lfloor 10^n x \rfloor}{10^n} = x$$
$$\lim_{n\to+\infty} \frac{\lfloor 10^n x \rfloor + 1}{10^n} = x$$

3) ចំពោះចំនួនពិត $x$ យើងមាន

$$\lfloor 10x \rfloor \geq 10\lfloor x \rfloor$$
$$\lfloor 10x \rfloor - 10\lfloor x \rfloor - 9 \leq 0$$

ព្រោះ ៖ តាង $x = n + \frac{a_1}{10} + \frac{a_2}{100} + \cdots$ ដែល $0 \leq a_1, a_2, \ldots \leq 9$ និង $n$ ជាចំនួនគត់

យើងទាញបាន

$$10x = 10n + a_1 + \frac{a_2}{10} + \cdots$$
$$\lfloor x \rfloor = n; 10\lfloor x \rfloor = 10n$$
$$\lfloor 10x \rfloor = \left\lfloor 10n + a_1 + \frac{a_2}{10} + \cdots \right\rfloor = 10n + a_1 \leq 10n + 9$$
$$\Rightarrow \ \lfloor 10x \rfloor - 10\lfloor x \rfloor = a_1 \geq 0$$
$$\Rightarrow \ \lfloor 10x \rfloor - 10\lfloor x \rfloor - 9 = a_1 - 9 \leq 0$$

4) តាង $x$ ជាចំនួនពិតមួយ ។ ចំពោះគ្រប់ចំនួនគត់ $n > 0$ តាង

$$x_n = \frac{\lfloor 10^n x \rfloor}{10^n}; x'_n = \frac{\lfloor 10^n x \rfloor + 1}{10^n}$$

យើងមាន

$$\lfloor 10^n x \rfloor \leq 10^n x < \lfloor 10^n x \rfloor + 1 \ \Rightarrow x_n = \frac{\lfloor 10^n x \rfloor}{10^n} \leq x < x'_n = \frac{\lfloor 10^n x \rfloor + 1}{10^n}$$

យើងមាន $x_n, x'_n \in \mathbb{Q}$ និង

$$x_{n+1}-x_n=\frac{\lfloor 10^{n+1}x\rfloor}{10^{n+1}}-\frac{\lfloor 10^n x\rfloor}{10^n}=\frac{\lfloor 10^{n+1}x\rfloor-10\lfloor 10^n x\rfloor}{10^{n+1}}\geq 0$$

$$x'_{n+1}-x'_n=\frac{\lfloor 10^{n+1}x\rfloor+1}{10^{n+1}}-\frac{\lfloor 10^n x\rfloor+1}{10^n}=\frac{\lfloor 10^{n+1}x\rfloor+1-10\lfloor 10^n x\rfloor-10}{10^{n+1}}$$

$$=\frac{\lfloor 10^{n+1}x\rfloor-10\lfloor 10^n x\rfloor-9}{10^{n+1}}\leq 0$$

ដូច្នេះ $(x_n)$ ជាស៊ីតសនិទានកើន និង $(x'_n)$ ជាស៊ីតសនិទានចុះ ហើយតាម 2) យើងទាញបាន

$$\lim_{n\to+\infty} x_n = x;\ \lim_{n\to+\infty} x'_n = x$$

ដូច្នេះគ្រប់ចំនួនពិតសុទ្ធតែជាលីមីតនៃស៊ីតសនិទានកើននិងចុះ ឧទាហរណ៍ស៊ីតសនិទានកើនគឺ $x_n=\frac{\lfloor 10^n x\rfloor}{10^n}$ និង ស៊ីតសនិទានចុះគឺ $x'_n=\frac{\lfloor 10^n x\rfloor+1}{10^n}$ ។

## ១.១១ និយមន័យ : ភាពជាប់

តាង $f\colon \mathrm{I}\to\mathbb{R}$ ។ តាង $a\in \mathrm{I}$ ។ អនុគមន៍ $f$ ហៅថា ជាប់ត្រង់ $a$ បើ $\lim_{x\to a} f(x)=f(a)$ ។

## ១.១២ ទំនាក់ទំនងកំណើនលីនេអ៊ែរអូម៉ូសែន

តាង $(U_n)$ ជាស៊ីតមួយ និង $a,b$ ជាចំនួនពិតពីរ ដែល ចំពោះគ្រប់ចំនួនគត់ $n\in\mathbb{N}$ គេមាន

$$U_{n+2}=aU_{n+1}+b\,U_n$$

បើ សមីការ $r^2=ar+b$ មានឫសពីរ តាងដោយ $\alpha$ និង $\beta$ នោះ $(U_n)$ ជាចម្លើយរបស់សមីការស៊ីត បើនិងមានតែបើ $U_n=\lambda\,\alpha^n+\mu\,\beta^n$ ដែល $\lambda$ និង $\mu$ ជាចំនួនថេរ ។

បើ សមីការ $r^2 = ar + b$ មានឫសឌុប តាងដោយ $\alpha$ នោះ $(U_n)$ ជាចម្លើយរបស់សមីការស្ទីត បើនិងមានតែបើ $U_n = (\lambda n + \mu)\,\alpha^n$ ដែល $\lambda$ និង $\mu$ ជាចំនួនថេរ ។

## ស្រាយបញ្ជាក់

❶ បង្ហាញថា $U_n = \lambda\,\alpha^n + \mu\,\beta^n$ ផ្ទៀងផ្ទាត់សមីការស្ទីត (បើ...)

បើ $\alpha$ និង $\beta$ ជាឫសរបស់សមីការ $r^2 = ar + b$ នោះ

$$\alpha^2 = a\,\alpha + b \implies \alpha^{n+2} = a\,\alpha^{n+1} + b\,\alpha^n$$
$$\beta^2 = a\,\beta + b \implies \beta^{n+2} = a\,\beta^{n+1} + b\,\beta^n$$

$$\implies (\lambda\alpha^{n+2} + \mu\beta^{n+2}) = a(\lambda\alpha^{n+1} + \mu\beta^{n+1}) + b(\lambda\alpha^n + \mu\beta^n)$$
$$\iff U_{n+2} = aU_{n+1} + bU_n$$

❷ បង្ហាញថា បើ $U_n$ ជាចម្លើយ នោះវាត្រូវតែមានរាង $\lambda\,\alpha^n + \mu\,\beta^n$ (មានតែបើ...)

យើងមាន $U_3 = a\,U_2 + bU_1$ ។ បើយើងស្គាល់ $U_1$ និង $U_2$ នោះយើងអាចកំណត់បាន $U_3$ តែមួយបែបគត់ ។ ដូចគ្នា យើងទាញបាន $U_4, U_5, \dots, U_n$ មានតែមួយបែបគត់ ។ ករណីនេះ ដោយយើងដឹងថា $\lambda\,\alpha^n + \mu\,\beta^n$ ជាចម្លើយ ហើយចម្លើយមានតែមួយគត់ ដូច្នេះ ចម្លើយមានតែ $\lambda\,\alpha^n + \mu\,\beta^n$ មួយនេះគត់ ។

ករណីសមីការមានឫសឌុប យើងស្រាយបញ្ជាក់ដូចគ្នា ដោយដឹងថា $\alpha = a/2$ ។

# ២

# អនុគមន៍ងាយ

## ២.១ គណនា

**1.** គណនា $a^4+b^4+c^4$ ដោយដឹងថា $a+b+c=0$ និង $a^2+b^2+c^2=1$

គណនា

**2.** $$S_n = 1+3+6+\cdots+\frac{n(n+1)}{2}, n\in\mathbb{N}$$

**3.** $$S_n = 1^3+2^3+3^3+\cdots+n^3, n\in\mathbb{N}$$

**4.** តាង $S=(2+1)(2^2+1)(2^4+1)\dots(2^{1024}+1)+1$ ។

ចូរគណនា $S^{1/1024}$ ។

**5.** (កាណាដា ១៩៦៩)

គណនា $1.1!+2.2!+3.3!+\cdots+(n-1).(n-1)!+n.n!$

ដែល $n!=n.(n-1)\dots3.2.1$ ។

**6.** គណនា

$$S=\frac{1}{1!\,1999!}+\frac{1}{3!\,1997!}+\cdots+\frac{1}{1997!\,3!}+\frac{1}{1999!\,1!}$$

**7.** គណនាផលបូកខាងក្រោម

(a) $\frac{1}{1.2}+\frac{1}{2.3}+\frac{1}{3.4}+\cdots+\frac{1}{(n-1)n}$

(b) $\frac{1}{1.2.3}+\frac{1}{2.3.4}+\frac{1}{3.4.5}+\cdots+\frac{1}{(n-2)(n-1)n}$

(c) $$\frac{1}{1.2.3.4}+\frac{1}{2.3.4.5}+\frac{1}{3.4.5.6}+\cdots+\frac{1}{(n-3)(n-2)(n-1)n}$$

**8.** (ភ្នំពេញ ២០១១)

គណនាផលបូក

$$S=\frac{1}{2^1}-\frac{2}{2^2}+\frac{3}{2^3}-\frac{4}{2^4}+\cdots-\frac{2010}{2^{2010}}+\frac{2011}{2^{2011}}$$

**9.** គេឱ្យចំនួនពិត $u,v,s,t$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$u+v+s+t=u^7+v^7+s^7+t^7=0$$

ចូរគណនា $P=t(t+u)(t+v)(t+s)$

**10.** គណនា

$$\sqrt{a+b+c+2\sqrt{ac+bc}}+\sqrt{a+b+c-2\sqrt{ac+bc}}$$

ដែល $a\geq 0,b\geq 0,c\geq 0$ ។

**11.** គណនាតម្លៃរបស់

$$(1-ax)(1+ax)^{-1}(1+bx)^{\frac{1}{2}}(1-bx)^{-\frac{1}{2}}$$

នៅត្រង់

$$x=a^{-1}\left(2\frac{a}{b}-1\right)^{\frac{1}{2}},\quad (0<a<b<2a)$$

**12.** (ភ្នំពេញ ២០១១)

ក) រកតម្លៃនៃ $A=2011^3-2010.2011^2-2010^2.2011+2010^3$

ខ) រកតម្លៃនៃ $B=403^5-402^2(403^3+2.403^2+3.403+4)$

**13.** បើ $a+b+c=0$ ចូរគណនា

$$\left(\frac{b-c}{a}+\frac{c-a}{b}+\frac{a-b}{c}\right)\left(\frac{a}{b-c}+\frac{b}{c-a}+\frac{c}{a-b}\right)$$

**14.** សម្រួលកន្សោម

$$\left(1+\frac{1}{3}\right)\left(1+\frac{1}{9}\right)\left(1+\frac{1}{81}\right)\left(1+\frac{1}{3^8}\right)\ldots\left(1+\frac{1}{3^{2^n}}\right)$$

**15.** (JBMO 1997)

គេឱ្យចំនួនពិត $x,y$ ដែល

$$\frac{x^2+y^2}{x^2-y^2}+\frac{x^2-y^2}{x^2+y^2}=k$$

ចូរគណនា

$$\frac{x^8+y^8}{x^8-y^8}-\frac{x^8-y^8}{x^8+y^8}$$

ជាអនុគមន៍នៃ $k$ ។

**16.** (ភ្នំពេញ ២០១១)

តាង $u_0, u_1, u_2, \ldots, u_n$ ជាស្វ៊ីតនៃចំនួនពិត ដែលបំពេញទំនាក់ទំនងខាងក្រោម

$$(3-u_{n+1})(6+u_n)=18;\ \ u_0=3$$

គណនា

$$\sum_{k=0}^{2011}\frac{1}{u_k}$$

**17.** (រ៉ូម៉ានី ២០០២)

ចំពោះចំនួនគត់វិជ្ជមាន $n$ តាង $f(n)$ ជា

$$f(n)=\frac{4n+\sqrt{4n^2-1}}{\sqrt{2n+1}+\sqrt{2n-1}}$$

គណនា $f(1)+f(2)+f(3)+\cdots+f(40)$ ។

**18.** (ភ្នំពេញ ២០១១)

គេឱ្យ

$$f(n)=\frac{1}{\sqrt[3]{n^2+2n+1}+\sqrt[3]{n^2-1}+\sqrt[3]{n^2-2n+1}}, \forall n\in\mathbb{N}$$

គណនាផលបូក

$$S=f(1)+f(3)+f(5)+\cdots+f(10^6-3)+f(10^6-1)$$

## ២.២ សមភាព

ចូរបង្ហាញថា

**19.** $$1^2+2^2+3^2+\cdots+n^2=\frac{n(n+1)(2n+1)}{6}, n\in\mathbb{N}$$

**20.** $$\frac{1}{2}+\frac{2}{2^2}+\frac{3}{2^3}+\cdots+\frac{n}{2^n}=2-\frac{n+2}{2^n}, n\in\mathbb{N}$$

**21.** ចូរបង្ហាញថា បើ $n$ ជាចំនួនគត់ធម្មជាតិ នោះ

$$1.2+2.5+\cdots+n(3n-1)=n^2(n+1)$$

**22.** ចូរបង្ហាញថា បើ $n$ ជាចំនួនគត់ធម្មជាតិ នោះ

$$1^2+3^2+5^2+\cdots+(2n-1)^2=\frac{n(4n^2-1)}{3}$$

**23.** តាង $a,b,c$ ជាចំនួនពិត ខុសពី $-1$ និង $1$ ដែល $a+b+c=abc$ ។ ចូរបង្ហាញថា

$$\frac{a}{1-a^2}+\frac{b}{1-b^2}+\frac{c}{1-c^2}=\frac{4abc}{(1-a^2)(1-b^2)(1-c^2)}$$

**24.** (កាណាដា ១៩៦៩)

ចូរបង្ហាញថា បើ $a_1/b_1 = a_2/b_2 = a_3/b_3$ និង $p_1;p_2;p_3$ មិនសូន្យទាំងអស់ព្រមគ្នា នោះ

$$\left(\frac{a_1}{b_1}\right)^n=\frac{p_1a_1^n+p_2a_2^n+p_3a_3^n}{p_1b_1^n+p_2b_2^n+p_3b_3^n}$$

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

**25.** ចូរស្រាយបញ្ជាក់សមភាព

$$\begin{aligned}&a+b(1+a)+c(1+a)(1+b)+d(1+a)(1+b)(1+c)\\&+\cdots+l(1+a)(1+b)\dots(1+k)\\&=(1+a)(1+b)(1+c)\dots(1+l)-1\end{aligned}$$

ចូរពិនិត្យករណី $a=b=c=\cdots=l$ ។

**26.** ចូរបង្ហាញថា បើ $a+b+c=0$ នោះ $a^3+b^3+c^3=3abc$ ។

**27.** (JBMO សតលីស ២០០០)

ពិនិត្យស្ទីតនៃចំនួនគត់វិជ្ជមាន $x_n$ ដែល

$$x_{2n+1}=4x_n+2n+2$$

$$x_{3n+2} = 3x_{n+1} + 6x_n$$

ចំពោះគ្រប់ $n \geq 0$ ។ ចូរបង្ហាញថា

$$x_{3n+1} = x_{n+2} - 2x_{n+1} + 10x_n$$

ចំពោះគ្រប់ $n \geq 0$ ។

**28.** ចូរបង្ហាញថា

$$(n+1)(n+2)(n+3)\dots(2n-1)2n = 2^n.1.3.5\dots(2n-3)(2n-1)$$

**29.** ចូរបង្ហាញថា

$$1.2.3\dots p + 2.3\dots p(p+1) + \cdots + n(n+1)\dots(n+p-1) = \frac{n(n+1)(n+2)\dots(n+p)}{p+1}$$

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $p$ ។

**30.** បង្ហាញថា

$$\left(\frac{2+\sqrt{3}}{\sqrt{2}+\sqrt{2+\sqrt{3}}} + \frac{2-\sqrt{3}}{\sqrt{2}-\sqrt{2-\sqrt{3}}}\right)^2 = 2$$

**31.** គេឱ្យចំនួនពិតវិជ្ជមាន $A, B, C, D, a, b, c, d$ ផ្ទៀងផ្ទាត់

$$\frac{A}{a} = \frac{B}{b} = \frac{C}{c} = \frac{D}{d}$$

បង្ហាញថា

$$\sqrt{Aa} + \sqrt{Bb} + \sqrt{Cc} + \sqrt{Dd} = \sqrt{(a+b+c+d)(A+B+C+D)}$$

**32.** បង្ហាញថា

$$\sqrt[3]{ax^2 + by^2 + cz^2} = \sqrt[3]{a} + \sqrt[3]{b} + \sqrt[3]{c}$$

បើ $ax^3 = by^3 = cz^3$ និង

$$\frac{1}{x} + \frac{1}{y} + \frac{1}{z} = 1$$

# ២.៣ សមីការ

ដោះស្រាយសមីការ

**33.** $x^3 + 2x^2 - x - 2 = 0$

**34.** $x^3 - x^2 - 8x + 12 = 0$

**35.** $x^3 - 9x^2 + 27x - 27 = 0$

**36.** $x^3 + x^2 - 3 = 0$

**37.** $6x^3 + 7x^2 - 1 = 0$

**38.** $2x^3 + x^2 + 5x - 3 = 0$

**39.** $2x^4 - 5x^2 + 2 = 0$

**40.** $x^4 - 2x^2 - 3 = 0$

**41.** $(x-1)^4 + (x+1)^4 = 16$

**42.** $(2x-3)^4 + (2x-5)^4 = 2$

**43.** $\dfrac{1}{2x^2 - x + 1} + \dfrac{3}{2x^2 - x + 3} = \dfrac{10}{2x^2 - x + 7}$

**44.** $(x-a)x(x+a)(x+2a) = 3a^4$

**45.** $(6x+5)^2(3x+2)(x+1) = 35$

**46.** $x^2 + \dfrac{4}{x^2} - 8\left(x - \dfrac{2}{x}\right) - 4 = 0$

**47.** $4x^4 + 6x^3 - 10x^2 - 9x + 9 = 0$

**48.** $\dfrac{(x+1)^5}{x^5+1} = \dfrac{81}{11}$

**49.** $(x^2 - 6x - 9)^2 = x^3 - 4x^2 - 9x$

**50.** $x^2 + \dfrac{25x^2}{(x+5)^2} = 11$

**51.** $(x^2 - 16)(x-3)^2 + 9x^2 = 0$

**52.** $x^4 + 4x - 1 = 0$

**53.** $x^4 - 4x^3 - 1 = 0$

**54.** $x^4 - 2x^2 - 400x = 9999$

**55.** $(x^3 - 2x) - (x^2 + 2)a - 2a^2x = 0$

**56.** $(x^2 - a)^2 - 6x^2 + 4x + 2a = 0$

**57.** ដោះស្រាយសមីការ $x^4 - 4x^3 - 10x^2 + 37x - 14 = 0$ ដោយដឹងថាអង្គខាងឆ្វេងអាចដាក់ជាផលគុណដែលមានមេគុណជាចំនួនគត់បាន ។

**58.** សមីការ $x^3 + ax^2 + bx + c = 0$ ដែល $a, b, c$ ជាចំនួនគត់ មានឫសសនិទានមួយ តាងដោយ $x_1$ ។

ចូរបង្ហាញថា $x_1$ ជាចំនួនគត់ និងថា $c$ ចែកដាច់នឹង $x_1$ ។

**59.** សមីការ $x^4+ax^3+bx^2+cx+d=0$ ដែល $a,b,c,d$ ជាចំនួនគត់ មានឫសសនិទានមួយ តាងដោយ $x_1$ ។ ចូរបង្ហាញថា $x_1$ ជាចំនួនគត់ និងថា $d$ ចែកដាច់នឹង $x_1$ ។

**60.** សន្មតថា $x_1,x_2,x_3$ ជាឫសនៃសមីការ $ax^3+bx^2+cx+d=0, a\neq 0$ ។ ចូរបង្ហាញថា

$$x_1+x_2+x_3=-b/a$$
$$x_1x_2+x_2x_3+x_3x_1=c/a$$
$$x_1x_2x_3=-d/a$$

**61.** គេឱ្យសមីការ $x^3+px+q=0$ ។ ចូរគណនាផលបូកការេនៃឫសរបស់វា ។

**62*.** ដោះស្រាយសមីការ $x^3+3x-3=0$ ។

ចូររកឫសសនិទាននៃសមីការ

**63.** $x^4+2x^3-16x^2-2x+15=0$

**64.** $x^4-7x^3+5x^2+4x+12=0$

**65.** $x^4+x^3-5x-5=0$

**66.** $x^4+x^3-1=0$

**67.** $6x^4-x^3+5x^2-x-1=0$

ដោះស្រាយសមីការ

**68.** $\sqrt{x+10}+\sqrt{x-2}=6$

**69.** $\sqrt{x}-\sqrt{x+3}=1$

**70.** $\sqrt{15-x}+\sqrt{3-x}=6$

**71.** $\sqrt{\frac{20+x}{x}}+\sqrt{\frac{20-x}{x}}=\sqrt{6}$

**72.** $\sqrt{|x|+1}-\sqrt{|x|}=a$

**73.** $\sqrt{x^2+5x+3}-\sqrt{x^2+5x-2}=1$

**74.** $\sqrt{2x+3}-\sqrt{x+1}=1$

**75.** $\sqrt{2x+3}+\sqrt{x+1}=5$

**76.** $\sqrt{2x-3}+\sqrt{4x+1}=4$

**77.** $\sqrt{x+4}+\sqrt{2x+6}=7$

**78.** $\sqrt{2x-4}-\sqrt{x+5}=1$

**79.** $\sqrt{5x+7}-\sqrt{2x+3}=\sqrt{3x+4}$

**80.** $\sqrt{x^2+x+4}+\sqrt{x^2+x+1}=\sqrt{2x^2+2x+9}$

**81.** $\sqrt{x^2-9x+24}-\sqrt{6x^2-59x+149}=|5-x|$

**82.** $x+12\sqrt{x}-64=0$

**83.** $\dfrac{x-4}{\sqrt{x}+2}=x-8$

**84.** $(x-3)^2+3x-22=\sqrt{x^2-3x+7}$

**85.** $2x^2+3x-5\sqrt{2x^2+3x+9}+3=0$

**86.** $x\sqrt{x^2+15}-2=\sqrt{x}\sqrt[4]{x^2+15}$

**87.** $\sqrt{\dfrac{x+1}{x-1}}-\sqrt{\dfrac{x-1}{x+1}}=\dfrac{3}{2}$

**88.** $\sqrt{\dfrac{x+a}{x-a}}+2\sqrt{\dfrac{x-a}{x+a}}=3$

**89.** $\sqrt{2-x}+\dfrac{4}{\sqrt{2-x}+3}=2$

**90.** $4x^2+12x\sqrt{1+x}=27(1+x)$

**91.** $\sqrt{7-x}+\sqrt{x-3}=a$

**92*.** $\sqrt[4]{x-2}+\sqrt[4]{4-x}=2$

**93.** $\sqrt{x^2+ax-2a}=x+1$

**94.** $\sqrt{2x-1}-x+a=0$

**95.** $\sqrt{a^2-x\sqrt{x^2+a^2}}=a-x$

**96.** $\sqrt{x-\sqrt{x-a}}=a$

**97.** $\sqrt{x+\sqrt{a^2+2a-3}}+\sqrt{x+a+\sqrt{2-2a+2a^2-a^3}}=a\sqrt{1-x}$

**98.** $(x-1)^2+(y+5)^2=0$

**99.** $x^2+y^2-2x+6y+10=0$

**100.** $(x+y-a)^2+(y-1)^2+(x+3)^2=0$

**101*.** (ទួរគី ១៩៩៨)

តាង $\{a_n\}$ ជាស្វីតនៃចំនួនពិត កំណត់ដោយ $a_1=t$ និង

$$a_{n+1}=4a_n(1-a_n)$$

ចំពោះគ្រប់ $n\geq 1$ ។ តើតម្លៃរបស់ $t$ ខុសៗគ្នាចំនួនប៉ុន្មាន ដែល $a_{1998}=0$ ?

**102*.** (MOSP ២០០១)

ចូរកំណត់គ្រប់ត្រីធាតុនៃចំនួនពិត $(a,b,c)$ ដែល

$$a^2-2b^2=1, 2b^2-3c^2=1 \text{ និង } ab+bc+ca=1$$

**103***. (អន្តរជាតិ ១៩៦៣)

ដោះស្រាយសមីការ $\sqrt{x^2-p}+\ 2\sqrt{x^2-1}=x$ ដែល $p$ ជាប៉ារ៉ាម៉ែត្រ និងជាចំនួនពិត ។

**104***. (អន្តរជាតិឡុងលីស ១៩៦៧)

គេឱ្យសមីការ

$x^5+5\lambda x^4-x^3+(\lambda\alpha-4)x^2-(8\lambda+3)x+\lambda\alpha-2=0$

ក) កំណត់ $\alpha$ ដើម្បីឱ្យសមីការមានឫសដែលមិនអាស្រ័យនឹង $\lambda$ តែមួយគត់ ។

ខ) កំណត់ $\alpha$ ដើម្បីឱ្យសមីការមានឫសដែលមិនអាស្រ័យនឹង $\lambda$ តែពីរគត់ ។

**105***. (អន្តរជាតិ ១៩៥៩)

ចូរដោះស្រាយសមីការខាងក្រោម

ក) $\sqrt{x+\sqrt{2x-1}}+\sqrt{x-\sqrt{2x-1}}=\sqrt{2}$

ខ) $\sqrt{x+\sqrt{2x-1}}+\sqrt{x-\sqrt{2x-1}}=1$

គ) $\sqrt{x+\sqrt{2x-1}}+\sqrt{x-\sqrt{2x-1}}=2$

**106***. ដោះស្រាយសមីការ

$$\sqrt{x+3-4\sqrt{x-1}}+\sqrt{x+8-6\sqrt{x-1}}=1$$

**107***. ដោះស្រាយសមីការ

$$\sqrt{x+2\sqrt{x+2\sqrt{x+\cdots+2\sqrt{x+2\sqrt{3x}}}}}=x$$

(មានរ៉ាឌីកាល់ចំនួន $n$ ដង)

**108**. ដោះស្រាយសមីការ

$$\sqrt{x-3-2\sqrt{x-4}}+\sqrt{x-4\sqrt{x-4}}=a$$

**109**. ដោះស្រាយសមីការ $(a-x)^5+(x-b)^5=(a-b)^5;\ \ a\neq b$ ។

**110**. ដោះស្រាយសមីការខាងក្រោមចំពោះ $x\geq -1$

$$2x^2+4x=\sqrt{\frac{x+3}{2}}$$

**111**. គេឱ្យសមីការ $x^2-3x+1=m\sqrt{x^4+x^2+1}$ (*) ដែលក្នុងនោះ $m$ ជាប៉ារ៉ាម៉ែត្រ និង $x$ ជាអញ្ញាត ។

ក) ដោះស្រាយសមីការករណី $m=-\sqrt{3}/3$ ។

ខ) ចូរកំណត់តម្លៃ $m$ ដើម្បីឱ្យ សមីការ(*) មានឫសចំនួនមួយ ។

**112**. ដោះស្រាយសមីការ

$$\sqrt[3]{7x+1}-\sqrt[3]{x^2-x-8}+\sqrt[3]{x^2-8x-1}=2$$

**113**. ដោះស្រាយសមីការ

$$\frac{\sqrt{1+x^3}}{x^2+2}=\frac{2}{5}$$

**114**. ដោះស្រាយសមីការ

$$\cfrac{1}{1+\cfrac{1}{1+\cfrac{1}{1+\cfrac{\ddots}{1+\cfrac{1}{x}}}}}=x$$

ក្នុងកន្សោមនៃអង្គខាងឆ្វេង ប្រភាគមានចំនួន $n$ ជង ។

**115**. (អន្តរជាតិ សតលីស ១៩៦៨)

ចូរកំណត់ $(x_1,x_2,\dots,x_n)$ ដែលផ្ទៀងផ្ទាត់សមីការខាងក្រោម

$$1+\frac{1}{x_1}+\frac{x_1+1}{x_1x_2}+\frac{(x_1+1)(x_2+1)}{x_1x_2x_3}+\cdots+\frac{(x_1+1)\dots(x_{n-1}+1)}{x_1x_2\dots x_n}=0$$

**116**. (JBMO 1999)

តាង $a,b,c,x,y$ ជាចំនួនពិតប្រាំដែល $a^3+ax+y=0, b^3+bx+y=0$ និង $c^3+cx+y=0$ ។ បើ $a,b,c$ ជាចំនួនខុសគ្នាទាំងអស់ ចូរបង្ហាញថា ផលបូករបស់វាស្មើសូន្យ ។

**117**. (JBMO 2000)

តាង $x$ និង $y$ ជាចំនួនពិតវិជ្ជមាន ដែល

$$x^3+y^3+(x+y)^3+30xy=2000$$

ចូរបង្ហាញថា $x+y=10$ ។

**118**. (JBMO 2007)
តាង $a$ ជាចំនួនពិតវិជ្ជមាន ដែល $a^3=6(a+1)$ ។ ចូរបង្ហាញថា សមីការ
$x^2+ax+a^2-6=0$ គ្មានឫសជាចំនួនពិតទេ ។

**119**. ចូរបង្ហាញថា ត្រីធា $x^3+px+q$ ស្មើសូន្យ នៅត្រង់

$$x=\sqrt[3]{-\frac{q}{2}+\sqrt{\frac{q^2}{4}+\frac{p^3}{27}}}+\sqrt[3]{-\frac{q}{2}-\sqrt{\frac{q^2}{4}+\frac{p^3}{27}}}$$

**120**. ក) ដាក់ជាកត្តាផលគុណ $a^3+b^3+c^3-3abc$
ខ) ចូរបំលែងសមីការ $x^3+Ax^2+Bx+C=0$ ទៅជាសមីការ ដែលមាន
រាង $x^3+px+q=0$ ។ ចូរកំណត់ $p,q$ ជាអនុគមន៍នៃ $A,B,C$ ។
ខ) ដោះស្រាយសមីការ $x^3+px+q=0$

**121**. ដោះស្រាយសមីការ

$$\sqrt{x+\sqrt{4x+\sqrt{16x+\sqrt{\dots+\sqrt{4^{2008}x+3}}}}}-\sqrt{x}=1$$

**122**. (រុស្ស៊ី ២០១០)
តាង $a\neq b, a,b\in\mathbb{R}$ ដែលផ្ទៀងផ្ទាត់

$$(x^2+20ax+10b)(x^2+20bx+10a)=0$$

គ្មានឫស សម្រាប់ $x$ ។ បង្ហាញថា $20(b-a)$ មិនមែនជាចំនួនគត់ ។

# ២.៤ ប្រព័ន្ធសមីការ

ដោះស្រាយប្រព័ន្ធសមីការ

**123.** $\begin{cases}x^2-xy+3y^2+2x-5y-4=0\\x+2y=4\end{cases}$

**124.** $\begin{cases}2xy-y^2+5x+20=0\\3x+2y-3=0\end{cases}$

**125.** $\begin{cases} x^2 - 4y^2 = 200 \\ x + 2y = 100 \end{cases}$

**126.** $\begin{cases} x^2 + 9y^2 + 6xy - 6x - 18y - 40 = 0 \\ x + 30 = 2y \end{cases}$

**127.** $\begin{cases} x + y = 5 \\ xy = 6 \end{cases}$

**128.** $\begin{cases} x - y = 5 \\ xy = -4 \end{cases}$

**129.** $\begin{cases} x^2 + y^2 = 10 \\ x + y = 4 \end{cases}$

**130.** $\begin{cases} x^4 + y^4 = 17 \\ x + y = 3 \end{cases}$

**131.** $\begin{cases} \dfrac{1}{x^2} + \dfrac{1}{y^2} = 13 \\ \dfrac{1}{x} - \dfrac{1}{y} = 1 \end{cases}$

**132.** $\begin{cases} x^3 + y^3 = 7 \\ x + y = 1 \end{cases}$

**133.** $\begin{cases} x^5 + y^5 = 275 \\ x + y = 5 \end{cases}$

**134.** $\begin{cases} x^3 - y^3 = 63 \\ xy = 4 \end{cases}$

**135.** $\begin{cases} x + y + xy = -11 \\ x^2 + y^2 + xy = 13 \end{cases}$

**136.** $\begin{cases} x^2y - xy^2 = 30 \\ x + xy - y = 13 \end{cases}$

**137.** $\begin{cases} (x + 0{,}2)^2 + (y + 0{,}3)^2 = 1 \\ x + y = 0{,}9 \end{cases}$

**138.** $\begin{cases} x + y + \dfrac{x}{y} = \dfrac{1}{2} \\ \dfrac{(x + y)x}{y} = -\dfrac{1}{2} \end{cases}$

**139.** $\begin{cases} x^3y + x^3y^2 + 2x^2y^2 + x^2y^3 + xy^3 = 30 \\ x^2y + xy + x + y + xy^2 = 11 \end{cases}$

**140.** $\begin{cases} 2x^2 + xy - 45y^2 = 0 \\ 2x + 9y^2 = 4 \end{cases}$

**141.** $\begin{cases} x^2 - 5xy = 16 \\ 2xy + y^2 = 3 \end{cases}$

**142.** $\begin{cases} 2x^2 + y^2 + 3xy = 12 \\ (x + y)^2 - \dfrac{1}{2}y^2 = 7 \end{cases}$

**143.** $\begin{cases} x^3 + xy^2 = 10 \\ x^2y - y^3 = -3 \end{cases}$

**144.** $\begin{cases} 10x^2 + 5y^2 - 2xy - 38x - 6y + 41 = 0 \\ 3x^2 - 2y^2 + 5xy - 17x - 6y + 20 = 0 \end{cases}$

**145.** $\begin{cases} y^2(x^2-3)+xy+1=0 \\ y^2(3x^2-6)+xy+2=0 \end{cases}$

**146.** $\begin{cases} \dfrac{x}{y}(x+y-2)=\dfrac{2}{3} \\ \dfrac{y}{x}(x+y-1)=9 \end{cases}$ **147.** $\begin{cases} \dfrac{2}{x}+\dfrac{y}{3}=3 \\ \dfrac{x}{2}+\dfrac{3}{y}=\dfrac{3}{2} \end{cases}$

**148.** $\begin{cases} y^2-|xy|+2=0 \\ 8-x^2=(x+2y)^2 \end{cases}$ **149.** $\begin{cases} |xy-2|=6-x^2 \\ 2+3y^2=2xy \end{cases}$

**150.** $\begin{cases} x+2y-z=5 \\ 3x-4y+z=1 \\ x^2+y^2+z^2=6 \end{cases}$ **151.** $\begin{cases} 2u+v+w=6 \\ 3u+2v+w=9 \\ 3u^3+2v^3+w^3=27 \end{cases}$

**152.** $\begin{cases} x+y+z=2 \\ xy+yz+zx=-5 \\ x^2+y^2-z^2=12 \end{cases}$ **153.** $\begin{cases} xy+x+y=7 \\ yz+y+z=-3 \\ xz+x+z=-5 \end{cases}$

**154.** $\begin{cases} x^2-yz=14 \\ y^2-xz=28 \\ z^2-xy=-14 \end{cases}$ **155.** $\begin{cases} x^2+xy+y^2=3 \\ y^2+yz+z^2=7 \\ z^2+zx+x^2=19 \end{cases}$

**156.** $\begin{cases} xy+xz=8 \\ yz+xy=9 \\ xz+yz=-7 \end{cases}$ **157.** $\begin{cases} \dfrac{5xy}{x+y}=1 \\ \dfrac{7yz}{y+z}=1 \\ 6xz=x+z \end{cases}$

**158.** $\begin{cases} 4xy+y^2+2z^2=-3 \\ 4xz+x^2+2z^2=1 \\ 8yz+y^2+2z^2=1 \end{cases}$ **159**. $\begin{cases} y^3=9x^2-27x+27 \\ z^3=9y^2-27y+27 \\ x^3=9z^2-27z+27 \end{cases}$

**160.** $\begin{cases} \dfrac{7}{\sqrt{x-7}}-\dfrac{4}{\sqrt{y+6}}=\dfrac{5}{3} \\ \dfrac{5}{\sqrt{x-7}}+\dfrac{3}{\sqrt{y+6}}=\dfrac{13}{6} \end{cases}$

**161.** $\begin{cases} \dfrac{4}{\sqrt{x+y}-\sqrt{x-y}}-\dfrac{1}{\sqrt[4]{x-y}-\sqrt[4]{x+y}}=1 \\ \dfrac{2}{\sqrt{x+y}-\sqrt{x-y}}+\dfrac{4}{\sqrt[4]{x-y}-\sqrt[4]{x+y}}=\dfrac{9}{4} \end{cases}$

**162.** $\begin{cases} \sqrt{\dfrac{x+y}{2x-1}}+4\sqrt{\dfrac{2x-1}{x+y}}=5 \\ x=y+1 \end{cases}$

**163.** $\begin{cases}\sqrt{\dfrac{x-y}{x+y}}+\sqrt{\dfrac{x+y}{x-y}}=\dfrac{10}{3}\\ xy-2x-2y=2\end{cases}$

**164.** $\begin{cases}x+y+\sqrt{\dfrac{x+y}{x-y}}=\dfrac{12}{x-y}\\ xy=15\end{cases}$

**165.** $\begin{cases}y\sqrt{x^2+y^2}-2ay-3=0\\ x\sqrt{x^2+y^2}=2ax\end{cases}$

**166.** $\begin{cases}x+y=2\\ xy-z^2=1\end{cases}$

**167.** ចូរកំណត់តម្លៃ $a$ ដើម្បីឱ្យប្រព័ន្ធសមីការខាងក្រោមមានឫសតែមួយគត់

$$\begin{cases}\sqrt{y}=\dfrac{1}{\sqrt{x}}\\ y=ax+1\end{cases}$$

**168***. គេឱ្យប្រព័ន្ធសមីការ

$$\begin{cases}\dfrac{2}{3}x+\dfrac{4}{5}y+\dfrac{5}{6}z=61\\ x+y+z=79\end{cases}$$

ក) ចូរគណនាផលបូក $2y/5+z/2$ ;

ខ) ក្នុងចំណោមឫសជាចំនួនគត់ធម្មជាតិទាំងអស់របស់ប្រព័ន្ធ ចូរកំណត់ឫសដែលមានតម្លៃ $x$ ធំបំផុត ។

**169***. (អន្តរជាតិ ១៩៦១)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}x+y+z=a\\ x^2+y^2+z^2=b^2\\ xy=z^2\end{cases}$$

ដែល $a$ និង $b$ ជាចំនួនពិតដែលគេឱ្យ ។ ចូរកំណត់លក្ខខណ្ឌលើ $a$ និង $b$ ដើម្បីឱ្យចម្លើយវិជ្ជមាននិងមានតម្លៃខុសគ្នា ។

**170***. (អន្តរជាតិ ១៩៦៣)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x_5 + x_2 = yx_1 \\ x_1 + x_3 = yx_2 \\ x_2 + x_4 = yx_3 \\ x_3 + x_5 = yx_4 \\ x_4 + x_1 = yx_5 \end{cases}$$

ដែលប៉ារ៉ាម៉ែត្រ $y$ ជាចំនួនពិត ។

**171***. (អន្តរជាតិ ១៩៦៥)

គេឱ្យប្រព័ន្ធសមីការ

$$\begin{cases} a_{11}x_1 + a_{12}x_2 + a_{13}x_3 = 0 \\ a_{21}x_1 + a_{22}x_2 + a_{23}x_3 = 0 \\ a_{31}x_1 + a_{32}x_2 + a_{33}x_3 = 0 \end{cases}$$

ដែលមានមេគុណផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម

ក) $a_{11}, a_{22}, a_{33}$ ជាចំនួនពិតវិជ្ជមាន

ខ) មេគុណផ្សេងទៀតអវិជ្ជមានទាំងអស់

គ) សមីការនីមួយៗមានផលបូកមេគុណជាចំនួនវិជ្ជមាន ។

ចូរបង្ហាញថា $x_1 = x_2 = x_3 = 0$ ជាចម្លើយតែមួយគត់របស់ប្រព័ន្ធ ។

**172***. (អន្តរជាតិ ១៩៦៥)

ចូរកំណត់ចំនួនពិត $x_1, x_2, x_3, x_4$ ដែល

$$\begin{cases} x_1 + x_2x_3x_4 = 2 \\ x_2 + x_1x_3x_4 = 2 \\ x_3 + x_1x_2x_4 = 2 \\ x_4 + x_1x_2x_3 = 2 \end{cases}$$

**173***. (អន្តរជាតិ ១៩៦៦)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} |a_1 - a_2|x_2 + |a_1 - a_3|x_3 + |a_1 - a_4|x_4 = 1 \\ |a_2 - a_1|x_1 + |a_2 - a_3|x_3 + |a_2 - a_4|x_4 = 1 \\ |a_3 - a_1|x_1 + |a_3 - a_2|x_3 + |a_3 - a_4|x_4 = 1 \\ |a_4 - a_1|x_1 + |a_4 - a_2|x_3 + |a_4 - a_3|x_3 = 1 \end{cases}$$

ដែល $a_1, a_2, a_3$ និង $a_4$ ជាចំនួនពិតខុសគ្នាពីរៗ ។

**174***. (អន្តរជាតិ ឡុងលីស១៩៦៧)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x^2+x-1=y \\ y^2+y-1=z \\ z^2+z-1=x \end{cases}$$

**175.** (អន្តរជាតិ ឡុងលីស១៩៦៧)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} |x+y|+|1-x|=6 \\ |x+y+1|+|1-y|=4 \end{cases}$$

**176***. (អន្តរជាតិ ឡុងលីស១៩៦៧)

ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x_1+x_2+\cdots+x_n=a \\ x_1^2+x_2^2+\cdots+x_n^2=a^2 \\ \dots\dots \\ x_1^n+x_2^n+\cdots+x_n^n=a^n \end{cases}$$

**177.** (អន្តរជាតិ ឡុងលីស១៩៦៧)

តើក្នុងករណីណា ដែលប្រព័ន្ធ

$$\begin{cases} x+y+mz=a \\ x+my+z=b \\ mx+y+z=c \end{cases}$$

មានចម្លើយ? ចូរកំណត់លក្ខខណ្ឌដែលចម្លើយតែមួយគត់របស់ប្រព័ន្ធខាងលើ ជាស្វ៊ីតនព្វន្ត ។

**178***. (អន្តរជាតិ ១៩៦៧)

គេឱ្យស្វ៊ីត $(c_n)$ :

$$\begin{aligned} c_1 &= a_1+a_2+\cdots+a_8 \\ c_2 &= a_1^2+a_2^2+\cdots+a_8^2 \\ &\dots \quad \dots\dots \\ c_n &= a_1^n+a_2^n+\cdots+a_8^n \\ &\dots \quad \dots\dots \end{aligned}$$

ដែល $a_1, a_2, \dots, a_8$ ជាចំនួនពិត ដែលមិនសូន្យទាំងអស់គ្នា ។ ដោយដឹងថា ក្នុងចំណោម $(c_n)$ មានចំនួនដែលស្មើសូន្យច្រើនរាប់មិនអស់ ចូរកំណត់តម្លៃរបស់ $n$ ដើម្បីឱ្យ $c_n = 0$ ។

**179***. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x^2 = 2x - y \\ y^2 = 2y - z \\ z^2 = 2z - t \\ t^2 = 2t - x \end{cases}$$

**180***. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} x_1^2 + ax_1 + \left(\frac{a-1}{2}\right)^2 = x_2 \\ x_2^2 + ax_2 + \left(\frac{a-1}{2}\right)^2 = x_3 \\ \dots\dots\dots\dots\dots\dots\dots\dots \\ x_{1000}^2 + ax_{1000} + \left(\frac{a-1}{2}\right)^2 = x_1 \end{cases}$$

ដែល $a$ ជាចំនួនពិត ។

**181***. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} 2x_1 - 5x_2 + 3x_3 = 0 \\ 2x_2 - 5x_3 + 3x_4 = 0 \\ \dots\dots\dots\dots\dots \\ 2x_n - 5x_1 + 3x_2 = 0 \end{cases}$$

ដែល $n$ ជាចំនួនគត់ $\geq 3$ ។

**182***. តាង $(x, y, z)$ ជាចម្លើយរបស់ប្រព័ន្ធសមីការ

$$\begin{cases} x = y(4-y) \\ y = z(4-z) \\ z = x(4-x) \end{cases}$$

ចូរកំណត់តម្លៃរបស់ផលបូក $S = x + y + z$ ។

**183**. (កាណាដា ១៩៧០)

ដោះស្រាយសមីការ

$$\begin{cases} x + yz = 2 \\ y + zx = 2 \\ z + xy = 2 \end{cases}$$

**184**. (អន្តរជាតិ ១៩៦៨)

គេឱ្យប្រព័ន្ធសមីការ

$$\begin{cases} ax^2 + bx + c = y \\ ay^2 + by + c = z \\ az^3 + bz + c = x \end{cases}$$

ដែលក្នុងនោះ $a \neq 0$ ។ តាង $\Delta = (b-1)^2 - 4ac$ ។ ចូរបង្ហាញថាបើ $\Delta < 0$ នោះប្រព័ន្ធសមីការគ្មានឫស ។

**185**. ចូរកំណត់ $a \in \mathbb{R}$ ដើម្បីឱ្យប្រព័ន្ធ

$$\begin{cases} x^3 - ay^3 = \frac{1}{2}(a+1)^2 \\ x^3 + ax^2y + xy^2 = 1 \end{cases}$$

មានឫសផ្ទៀងផ្ទាត់ $x + y = 0$

**186**. ដោះស្រាយសមីការ

$$\begin{cases} (2-x)(3x-2z) = 3 - z & (1) \\ y^3 + 3y^2 = x^2 - 3x + 2 & (2) \\ y^2 + z^2 = 6z & (3) \\ z \leq 3 & (4) \end{cases}$$

**187**. គេឱ្យ $a, b, c > 0$ ។ដោះស្រាយសមីការ

$$\begin{cases} \frac{a}{x} - \frac{b}{z} = c - zx \\ \frac{b}{y} - \frac{c}{x} = a - xy \\ \frac{c}{z} - \frac{a}{y} = b - yz \end{cases}$$

**188**. ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases} 2x + x^2y = y \\ 2y + y^2z = z \\ 2z + z^2x = x \end{cases}$$

**189**. (ឥណ្ឌា ២០១០)

ចូរកំណត់ចំនួនពិតមិនសូន្យ $x, y, z$ ដែលផ្ទៀងផ្ទាត់ប្រព័ន្ធ

$$\begin{cases} (x^2 + xy + y^2)(y^2 + yz + z^2)(z^2 + zx + x^2) = xyz \\ (x^4 + x^2y^2 + y^4)(y^4 + y^2z^2 + z^4)(z^4 + z^2x^2 + x^4) = x^3y^3z^3 \end{cases}$$

**190**. (វៀតណាម ២០០៩)

ដោះស្រាយសមីការ ចំពោះគ្រប់ $(x, y) \in \mathbb{R}$

$$\begin{cases}\dfrac{1}{\sqrt{1+2x^2}}+\dfrac{1}{\sqrt{1+2x^2}}=\dfrac{2}{\sqrt{1+2xy}}\\ \sqrt{x(1-2x)}+\sqrt{y(1-2y)}=\dfrac{2}{9}\end{cases}$$

**191**. (វៀតណាម ២០០២)

ដោះស្រាយសមីការ

$$\begin{cases}\sqrt[3]{\dfrac{x^3-3x+(x^2-1)\sqrt{x^2-4}}{2}}+\sqrt[3]{\dfrac{x^3-3x-(x^2-1)\sqrt{x^2-4}}{2}}=\sqrt{x+2002}\\ x\ge 2\end{cases}$$

**192**. (វៀតណាម ២០០២)

គេឱ្យចំនួនពិតវិជ្ជមាន $a;b;c$ ដែលខុសគ្នាពីរៗ ។ ដោះស្រាយសមីការ

$$\begin{cases}x^2-yz=a\\ y^2-xz=b\\ z^2-xy=c\end{cases}$$

**193**. គេឱ្យប្រព័ន្ធ

$$\begin{cases}x+y+xy=m\\ x^2+y^2=m\end{cases}$$

1) ដោះស្រាយប្រព័ន្ធចំពោះ $m=5$ ។

2) ចូរកំណត់ $m$ ដើម្បីឱ្យប្រព័ន្ធមានឫស ។

**194**. (JBMO 2008)

ចូរគណនាគ្រប់ចំនួនពិត $a,b,c,d$ ដែល

$$\begin{cases}a+b+c+d=20\\ ab+ac+ad+bc+bd+cd=150\end{cases}$$

**195**. (អាមេរិច AIME 2010)

តាង $(a,b,c)$ ជាឫសពិតរបស់ប្រព័ន្ធសមីការ

$$\begin{cases}x^3-xyz=2\\ y^3-xyz=6\\ z^3-xyz=20\end{cases}$$

តម្លៃធំបំផុតរបស់ $a^3+b^3+c^3$ អាចសរសេរជារាង $m/n$ ដែល $m$ និង $n$ ជាចំនួនគត់វិជ្ជមានបឋមគ្នា ។ គណនា $m+n$ ។

**196**. តើប្រព័ន្ធសមីការខាងក្រោមមានឫសពិតចំនួនប៉ុន្មាន?

$$\begin{cases} x+y=2 \\ xy-z^2=1 \end{cases}$$

**197.** (Baltic Way 2010)

កំណត់ចំនួនពិត $(a,b,c,d)$ ដែលផ្ទៀងផ្ទាត់ប្រព័ន្ធសមីការ

$$\begin{cases} (b+c+d)^{2010}=3a \\ (a+c+d)^{2010}=3b \\ (a+b+d)^{2010}=3c \\ (a+b+c)^{2010}=3d \end{cases}$$

**198.** (អន្តរជាតិ សតលីស ១៩៩៥)

តាង $a,b$ និង $c$ ជាចំនួនពិតវិជ្ជមាន ។ ចូរកំណត់គ្រប់ចំនួនពិតវិជ្ជមាន $x,y$ និង $z$ ដែល

$$\begin{cases} x+y+z=a+b+c \\ 4xyz-(a^2x+b^2y+c^2z)=abc \end{cases}$$

**199.** កំណត់លក្ខខណ្ឌចំពោះ $\alpha_1,\alpha_2,\alpha_3,\alpha_4$ ដើម្បីឱ្យប្រព័ន្ធសមីការដែលមាន ៦ សមីការ មានអញ្ញាត ៤ ខាងក្រោមមានឫស ៖

$$\begin{cases} x_1+x_2=\alpha_1\alpha_2 \\ x_1+x_3=\alpha_1\alpha_3 \\ x_1+x_4=\alpha_1\alpha_4 \\ x_2+x_3=\alpha_2\alpha_3 \\ x_2+x_4=\alpha_2\alpha_4 \\ x_3+x_4=\alpha_3\alpha_4 \end{cases}$$

គណនាតម្លៃរបស់អញ្ញាត $x_1,x_2,x_3,x_4$ ក្នុងករណីនោះ ។

## ២.៥ វិសមភាព

ចូរបង្ហាញថា

**200.** $$\frac{1}{10\sqrt{2}}<\frac{1}{2}\frac{3}{4}\frac{5}{6}\cdots\frac{99}{100}<\frac{1}{10}$$

**201.** $$\frac{2^{100}}{10\sqrt{2}}<\binom{100}{50}<\frac{2^{100}}{10}$$

**202.** $$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n}\le\frac{1}{\sqrt{3n+1}},n\in\mathbb{N}$$

**203.** $\frac{1}{2}\frac{3}{4}\frac{5}{6}\cdots\frac{99}{100} < \frac{1}{12}$

**204.** ចូរបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n > 1$ វិសមភាពខាងក្រោមពិត

$$\frac{1}{n+1} + \frac{1}{n+2} + \cdots + \frac{1}{n+n} > \frac{13}{24}$$

**205.** ចូរបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ វិសមភាពខាងក្រោមពិត

$$2 < \left(1 + \frac{1}{n}\right)^n < 3$$

**206.** តើមួយណាធំជាង $(1{,}000001)^{1.000.000}$ ឬ $2$ ? ។

**207.** តើមួយណាធំជាង $1\,000^{1\,000}$ ឬ $1001^{999}$ ? ។

**208.** (a) តើមួយណាធំជាង ?

$$\frac{2{,}000\,000\,000\,04}{(1{,}000\,000\,000\,04)^2 + 2{,}000\,000\,000\,04};$$
$$\frac{2{,}000\,000\,000\,02}{(1{,}000\,000\,000\,02)^2 + 2{,}000\,000\,000\,02}$$

(b) បើ $a > b > 0$ ។ តើមួយណាធំជាង ?

$$\frac{1 + a + a^2 + \cdots + a^{n-1}}{1 + a + a^2 + \cdots + a^n};$$
$$\frac{1 + b + b^2 + \cdots + b^{n-1}}{1 + b + b^2 + \cdots + b^n}$$

**209.** (កាណាដា ១៩៦៩)

តើមួយណាធំជាង $\sqrt{c+1} - \sqrt{c}$ ឬ $\sqrt{c} - \sqrt{c-1}$ ចំពោះ $c \geq 1$? ។

**210.** ផលគុណនៃចំនួនពិតវិជ្ជមានចំនួន $n$ មានតម្លៃស្មើមួយ ។ ចូរបង្ហាញថាផលបូករបស់វា មិនមានតម្លៃតូចជាង $n$ ទេ ។

**211.** សន្មតថា $x_1, x_2, x_3, \ldots, x_n$ $(n \in \mathbb{N})$ជាចំនួនពិតមានសញ្ញាដូចគ្នា មានតម្លៃធំជាង $-1$ ។ ចូរបង្ហាញថា $(1 + x_1)(1 + x_2)\ldots(1 + x_n) \geq 1 + x_1 + x_2 + \cdots + x_n$ ។

**212.** ចូរបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n > 6$ វិសមភាពខាងក្រោមពិត

$$\left(\frac{n}{2}\right)^n > n! > \left(\frac{n}{3}\right)^n$$

**213.** គេឱ្យ $f(x) = ax^2 + 1998x + c$ ដែល $a; c \in \mathbb{Z}; |a| < 2000; |c| < 2000$ ហើយ $f$ មានឫសពីរផ្សេងគ្នាគឺ $x_1; x_2$ ។

ចូរបង្ហាញថា $|x_1 - x_2| \geq 1/998$ ។

**214.** គេឱ្យចំនួនពិតវិជ្ជមាន $a, b, x, y$ ផ្ទៀងផ្ទាត់

$$a + b = 1; ax + by = 2; ax^2 + by^2 = 3$$

ចូរបង្ហាញថា $4 < ax^3 + by^3 < 4{,}5$

**215.** គណនាតម្លៃតូចបំផុតនៃ

$$S = |x| + \left|\frac{2x - 1}{x + 3}\right|$$

**216.** ចូរកំណត់ $a, b, c$ ដើម្បីឱ្យ $f(x) = ax^2 + bx + c$ ផ្ទៀងផ្ទាត់ $|f(x)| \leq 1$ ចំពោះគ្រប់ $x \in [-1; 1]$ និងដែល $K = \frac{8}{3}a^2 + 2b^2$ មានតម្លៃធំបំផុត ។

**217.** គេឱ្យចំនួនពិតមិនអវិជ្ជមាន $a_1; a_2; a_3; a_4; a_5$ ដែល$a_1 + a_2 + a_3 + a_4 + a_5 = 1$ ។ ចូរបង្ហាញថា

$$\min_{i \neq j}(a_i - a_j)^2 \leq \frac{1}{100}; \quad \min_{i \neq j}|a_i^2 - a_j^2| \leq \frac{1}{36}$$

**218.** តាង $a, b, c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។ ចូរបង្ហាញថា

$$\frac{a}{b + c} + \frac{b}{c + a} + \frac{c}{a + b} < 2$$

ចំណាំ

បើជួបលក្ខខណ្ឌ $a, b, c$ ជារង្វាស់ជ្រុងត្រីកោណ ចូរសាកល្បងតាង

$$a = x + y, b = y + z, c = z + x$$

**219.** គេឱ្យ $a, b, c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។ ចូរបង្ហាញថា

$$3(ab + bc + ca) \leq (a + b + c)^2 < 4(ab + bc + ca)$$

**220.** តាង $a, b, c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។ ចូរបង្ហាញថា

$$(2a^2 + 2b^2 - c^2)(2b^2 + 2c^2 - a^2)(2c^2 + 2a^2 - b^2) \leq (2a^2 + bc)(2b^2 + ca)(2c^2 + ab)$$

**221.** ដោយដឹងថា $f(x) = ax^2 + bx + c \geq 0; \forall x \in \mathbb{R}; a < b$ ។

គណនា $\min F$ ដែល

$$F=\frac{a+b+c}{b-a}$$

**222.** (អន្តរជាតិ ១៩៦១)

តាង $a,b$ និង $c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ដែលមានក្រលាផ្ទៃ $S$ ។ ចូរបង្ហាញថា

$$a^2+b^2+c^2\geq 4S\sqrt{3}$$

តើពេលណាយើងមានសមភាព? ។

**223.** (អន្តរជាតិ ឡុងលីស១៩៦៧)

ចូរបង្ហាញថា គ្រប់គូវ៉ិចទ័រ $f$ និង $g$ ស្ថិតក្នុងប្លង់ , វិសមភាព

$$af^2+bfg+cg^2\geq 0$$

ពិត បើនិងមានតែបើ លក្ខខណ្ឌដូចតទៅនេះត្រូវបានផ្ទៀងផ្ទាត់ ៖

$$a\geq 0; c\geq 0; 4ac\geq b^2$$

**224.** គេឱ្យចំនួនគត់ $n\geq 2$ និង ចំនួនពិត $a_1;a_2;\dots;a_n$ ដែល $\sum_{i=1}^{n}a_i=0$ ។ ចូរបង្ហាញថា

$$\sum_{i<j}\left|a_i-a_j\right|\geq\frac{n}{2}\sum_{i=1}^{n}|a_i|$$

**225.** (អន្តរជាតិ ២000)

គេឱ្យ $a,b,c>0$ ដែល $abc=1$ ។ ចូរបង្ហាញថា

$$\left(a-1+\frac{1}{b}\right)\left(b-1+\frac{1}{c}\right)\left(c-1+\frac{1}{a}\right)\leq 1$$

**226.** (ហុងគ្រី ១៩៩៦)

តាង $a$ និង $b$ ជាចំនួនពិតវិជ្ជមាន ដែល $a+b=1$ ។ ចូរបង្ហាញថា

$$\frac{a^2}{a+1}+\frac{b^2}{b+1}\geq\frac{1}{3}$$

**227.** (JBMO 2009)

តាង $x,y,z$ ជាចំនួនពិត ដែល $0<x,y,z<1$ និង

$$xyz=(1-x)(1-y)(1-z)$$

ចូរបង្ហាញថាក្នុងចំណោម $(1-x)y, (1-y)z, (1-z)x$ មានយ៉ាងហោច ណាស់មួយដែលធំជាងឬស្មើ $1/4$ ។

**228.** (វៀតណាម 2011)

ចូរបង្ហាញថា បើ $x > 0$ និង $n \in \mathbb{N}^*$ នោះយើងមាន

$$\frac{x^n(x^{n+1}+1)}{x^n+1} \leq \left(\frac{x+1}{2}\right)^{2n+1}$$

**229.** (ទ្រឹស្តីបទ)

ចូរបង្ហាញថា

ក) ចំពោះគ្រប់ចំនួនពិត $a, b$ គេមាន $a^2+b^2 \geq 2ab$ និង $4ab \leq (a+b)^2$ វាស្មើគ្នា បើ $a=b$ និង ច្រាសមកវិញ ។

ខ) ចំពោះគ្រប់ចំនួនពិត $x > 0$ គេមាន $x + 1/x \geq 2$ ។ វាស្មើគ្នា បើ $x = 1$ និង ច្រាសមកវិញ ។

**230.** (JBMO សតលីស ២០០០)

តាង $x, y, a, b$ ជាចំនួនពិតវិជ្ជមានដែល $x \neq y, x \neq 2y, y \neq 2x, a \neq 3b$ និង

$$\frac{2x-y}{2y-x} = \frac{a+3b}{a-3b}$$

ចូរបង្ហាញថា

$$\frac{x^2+y^2}{x^2-y^2} \geq 1$$

**231.** (JBMO សតលីស ២០០០)

ចូរកំណត់គ្រប់ចំនួនពិត $(x, y, z)$ ដែល

$$2x\sqrt{y-1} + 2y\sqrt{z-1} + 2z\sqrt{x-1} \geq xy + xz + yz$$

**232.** (កាណាដា ១៩៧១)

តាង $x$ និង $y$ ជាចំនួនពិតវិជ្ជមាន ដែល $x + y = 1$ ។ ចូរបង្ហាញថា

$$\left(1+\frac{1}{x}\right)\left(1+\frac{1}{y}\right) \geq 9$$

**233.** គេឱ្យ២ចំនួនពិត $a,b$ មិនសូន្យ ។ ចូរកំណត់តម្លៃតូចបំផុតនៃ

$$\frac{a^6}{b^6}+\frac{a^4}{b^4}+\frac{a^2}{b^2}+\frac{b^6}{a^6}+\frac{b^4}{a^4}+\frac{b^2}{a^2}$$

**234.** (រុស្ស៊ី ១៩៩៥)

ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $x,y>0$

$$\frac{x}{x^4+y^2}+\frac{y}{x^2+y^4}\le\frac{1}{xy}$$

**235.** ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $x,y$ គេមាន

$$x^2+y^2+1>x\sqrt{y^2+1}+y\sqrt{x^2+1}$$

**236.** គេឱ្យ $x,y,z>0$ ។ ចូរបង្ហាញថា

$$\frac{x^2}{y^2}+\frac{y^2}{z^2}+\frac{z^2}{x^2}\ge\frac{x}{z}+\frac{y}{x}+\frac{z}{y}$$

**237.** ចូរបង្ហាញថា បើ $a+b=1$ ដែល $a$ និង $b$ ជាចំនួនវិជ្ជមាន នោះ

$$\left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2\ge\frac{25}{2}$$

ចូរកំណត់ $a$ និង $b$ ដើម្បីឱ្យអង្គទាំងពីរស្មើគ្នា ។

**238.** ចូរបង្ហាញថា បើ $a,b,c$ ជារង្វាស់ជ្រុងរបស់ត្រីកោណមួយ នោះគេមាន
$(a+b)(b+c)(c+a)\ge 8(a+b-c)(b+c-a)(c+a-b)$

**239.** គេឱ្យចំនួនពិតវិជ្ជមាន $x,y,z$ ។ ចូរបង្ហាញថា

$$\frac{x^2-z^2}{y+z}+\frac{y^2-x^2}{z+x}+\frac{z^2-y^2}{x+y}\ge 0$$

ចូរកំណត់ករណីសមភាព ។

**240.** (អាស៊ីប៉ាស៊ីភិច ១៩៩៦)

គេឱ្យ $a,b,c$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។ ចូរបង្ហាញថា

$$\sqrt{a+b-c}+\sqrt{b+c-a}+\sqrt{c+a-b}\le\sqrt{a}+\sqrt{b}+\sqrt{c}$$

**241.** (អាមេរិច ១៩៩៧)

គេឱ្យ $a, b, c > 0$ ។ ចូរបង្ហាញថា

$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{1}{abc}$$

**242.** (អន្តរជាតិសតលីស ១៩៩៦)

គេឱ្យ $a, b, c > 0$ ដែល $abc = 1$ ។ ចូរបង្ហាញថា

$$\frac{ab}{a^5+b^5+ab}+\frac{bc}{b^5+c^5+bc}+\frac{ca}{c^5+a^5+ca}\le 1$$

**243.** (វិសមភាពកូស៊ីស្វាត)

ចូរបង្ហាញថា គ្រប់ចំនួនពិត $a_1, a_2, \dots, a_n, b_1, b_2, \dots, b_n$ គេមាន

$$(a_1^2+\cdots+a_n^2)(b_1^2+\cdots+b_n^2)\ge(a_1b_1+\cdots+a_nb_n)^2$$

អង្គទាំង២ស្មើគ្នា បើ វ៉ិចទ័រ $(a_1, \dots, a_n)$ និង $(b_1, \dots, b_n)$ កូលីនេអ៊ែរនឹងគ្នា ។

## សម្គាល់

ក្នុងគណិតវិទ្យា វិសមភាពកូស៊ី–ស្វាត អ្នកខ្លះហៅថាវិសមភាពស្វាត វិសមភាពកូស៊ី ឬក៏ វិសមភាពកូស៊ី–ប៊ុន្យាកូវស្គី–ស្វាត (គឺហៅតាមឈ្មោះ អូគុស្តាំង លួីសកូស៊ី(Augustin Louis Cauchy), វិចទ័រ យ៉ាកូលេវិច ប៊ុន្យាកូវស្គី (Viktor Yakovlevich Bunyakovsky, គណិតវិទូរុស្ស៊ី,១៨០៤–១៨៨៩)និង ហ៊ែរម៉ាន អាម៉ានឌុស ស្វាត(Hermann Amandus Schwarz, គណិតវិទូអាល្លឺម៉ង់,១៨៤៣–១៩២១)) ។

**244.** ចូរបង្ហាញថា ចំពោះគ្រប់ $x_1, x_2, \dots, x_n > 0$ គេមាន

$$(x_1+x_2+\cdots+x_n)\left(\frac{1}{x_1}+\frac{1}{x_2}+\cdots+\frac{1}{x_n}\right)\ge n^2$$

**245.** ចូរបង្ហាញថា ចំពោះគ្រប់ $a, b, c > 0$ គេមាន

$$\frac{(a+2b+3c)^2}{a^2+2b^2+3c^2}\le 6$$

**246.** គេឱ្យចំនួនពិត $a, b, c$ វិជ្ជមានដាច់ខាត ដែល $a+b+c=1$ ។ ចូរបង្ហាញថា

$$\left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2+\left(c+\frac{1}{c}\right)^2\ge\frac{100}{3}$$

**247.** (អាមេរិច ១៩៧៨)

គេឱ្យចំនួនពិត $a, b, c, d, e$ ដែល

$$\begin{cases} a+b+c+d+e=8 \\ a^2+b^2+c^2+d^2+e^2=16 \end{cases}$$

ចូរកំណត់តម្លៃធំបំផុតរបស់ $e$ ។

**248.** (JBMO 2003)

គេឱ្យ $x, y, z > -1$ ។ ចូរបង្ហាញថា

$$\frac{1+x^2}{1+y+z^2}+\frac{1+y^2}{1+z+x^2}+\frac{1+z^2}{1+x+y^2} \geq 2$$

**249.** (JBMO 2004)

ចូរស្រាយបញ្ជាក់វិសមភាព

$$\frac{x+y}{x^2-xy+y^2} \leq \frac{2\sqrt{2}}{\sqrt{x^2+y^2}}$$

ពិតចំពោះគ្រប់ចំនួនពិត $x$ និង $y$ ដែលមិនស្មើសូន្យទាំងពីរព្រមគ្នា ។

**250.** (អូស្ត្រាលី ១៩៩៣)

គេឱ្យចំនួនគត់ $n > 1$, ចំនួនពិត $a_1, a_2, \dots, a_n > 0$ និង

$$s = a_1 + a_2 + \cdots + a_n$$

ចូរបង្ហាញថា

$$\sum_{i=1}^{n} \frac{s}{s-a_i} \geq \frac{n^2}{n-1}$$

$$\sum_{i=1}^{n} \frac{s-a_i}{a_i} \geq n(n-1)$$

$$\sum_{i=1}^{n} \frac{a_i}{s-a_i} \geq \frac{n}{n-1}$$

**251.** (ចិន ១៩៨៧ ១៩៨៨)

ក) គេឱ្យ $a_1, a_2, a_3 > 0$ ដែល $(a_1^2+a_2^2+a_3^2)^2 > 2(a_1^4+a_2^4+a_3^4)$ ។

ចូរបង្ហាញថា $a_1, a_2, a_3$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។

ខ) គេឱ្យចំនួនគត់ $n \geq 3$ និង $a_1, a_2, \dots, a_n > 0$ ដែល

$$(a_1^2+a_2^2+\cdots+a_n^2)^2 > (n-1)(a_1^4+a_2^4+\cdots+a_n^4)$$

ចូរបង្ហាញថា គ្រប់ $i,j,k$ ខុសគ្នាពីរៗ ចំនួន $a_i,a_j,a_k$ ជារង្វាស់ជ្រុងនៃត្រីកោណមួយ ។

**252.** គេឱ្យ $a_1,a_2,\ldots,a_n>0$ ។ តាង $S=a_1+a_2+\cdots+a_n$ និង

$$S_2=a_1^2+a_2^2+\cdots+a_n^2$$

បង្ហាញថា

$$\frac{S_2-a_1^2}{S_1-a_1}+\frac{S_2-a_2^2}{S_1-a_2}+\cdots+\frac{S_2-a_n^2}{S_1-a_n}\geq S_1$$

**253.** (សិង្ហបុរី ២០០០)

គេឱ្យ $a,b,c,d>0$ ដែល $a^2+b^2=(c^2+d^2)^3$ ។ ចូរបង្ហាញថា

$$\frac{c^3}{a}+\frac{d^3}{b}\geq 1$$

**254.** គេឱ្យ $x,y,z>1$ ដែល $1/x+1/y+1/z=2$ ។ ចូរបង្ហាញថា

$$\sqrt{x+y+z}\geq\sqrt{x-1}+\sqrt{y-1}+\sqrt{z-1}$$

**255.** (ឥណ្ឌា ២០០១)

គេឱ្យ $x,y,z>0$ ដែល $xyz\geq xy+yz+zx$ ។ ចូរបង្ហាញថា

$$xyz\geq 3(x+y+z)$$

**256.** គេឱ្យ $a,b,c$ ដែល $a+b+c=abc$ ។ ចូរបង្ហាញថា

$$\max(a,b,c)\geq\sqrt{3}$$

## ចំណាំ

បើជួបលក្ខខណ្ឌ $a,b,c>0$ និង $a+b+c=abc$ ចូរតាង

$$a=\tan x,b=\tan y,c=\tan z$$

ដូច្នេះ $x,y,z$ អាចចាត់ទុកជាមុំក្នុងរបស់ត្រីកោណស្រួចបាន មានន័យថា $x,y,z\in\left[0,\frac{\pi}{2}\right)$ និង $x+y+z=\pi$ ។

**257.** (អន្តរជាតិ ១៩៩៩)

គេឱ្យចំនួនគត់ $n\geq 2$ ។

ក) ចូរកំណត់ចំនួនថេរ $C$ តូចបំផុត ដែលចំពោះគ្រប់ចំនួនពិត $x_1, x_2, \dots, x_n \geq 0$; គេមាន

$$\sum_{1\leq i<j\leq n} x_i x_j\left(x_i^2 + x_j^2\right) \leq C\left(\sum_{i=1}^{n} x_i\right)^4$$

ខ) ចំពោះចំនួនថេរ $C$ នេះ ចូរកំណត់ករណីសមភាព ។

**258.** គេឱ្យចំនួនពិត $x, y, z, t$ ដែល

$$\begin{cases} x + y + z + t = 0 \\ x^2 + y^2 + z^2 + t^2 = 1 \end{cases}$$

ចូរគណនាតម្លៃធំបំផុតនិងតូចបំផុតនៃ $P = xy + yz + zt + tx$ ។

**259.** (អន្តរជាតិសតលីស ២០០១)

តាង $x_1, x_2, \dots, x_n$ ជាចំនួនពិត ។ ចូរបង្ហាញថា

$$\frac{x_1}{1 + x_1^2} + \frac{x_2}{1 + x_1^2 + x_2^2} + \cdots + \frac{x_n}{1 + x_1^2 + \cdots + x_n^2} < \sqrt{n}$$

**260.** (អ៊ីរ៉ង់ ១៩៩៨)

ចូរបង្ហាញថា ចំពោះគ្រប់ $x; y; z > 1$ ដែល $1/x + 1/y + 1/z = 2$ គេមាន

$$\sqrt{x + y + z} \geq \sqrt{x - 1} + \sqrt{y - 1} + \sqrt{z - 1}$$

**261.** (វិសមភាពតំរៀប)

គេឱ្យ $a_1 \leq a_2 \leq \cdots \leq a_n$ និង $b_1 \leq b_2 \leq \cdots \leq b_n$ ជាស៊ីតនៃចំនួនពិត កើនពីរ ។

តាង $\sigma$ ជាចំលាស់នៃ$\{1,2, \dots, n\}$ ។

ចូរបង្ហាញថា ផលបូក $S_\sigma = \sum_{i=1}^{n} a_i b_{\sigma(i)}$ មានតម្លៃធំបំផុត ពេល $\sigma(i) = i$ និង តូចបំផុតពេល $\sigma(i) = n - i$ ចំពោះគ្រប់ $i$ ។

មានន័យថា $S_\sigma$ មានតម្លៃធំបំផុតពេល ស៊ីតទាំង២រៀបតាមលំដាប់ដូចគ្នា ហើយតូចបំផុតបើរៀបតាមលំដាប់ផ្ទុយគ្នា ។

**262.** (អន្តរជាតិ ១៩៧៥)

គេឱ្យចំនួនពិត $x_1 \geq x_2 \geq \cdots \geq x_n$ និង $y_1 \geq y_2 \geq \cdots \geq y_n$ ។ តាង $(z_1, z_2, \dots, z_n)$ជាចំលាស់នៃ $(y_1, y_2, \dots, y_n)$ ។ ចូរបង្ហាញថា

$$\sum_{i=1}^{n}(x_i - y_i)^2 \le \sum_{i=1}^{n}(x_i - z_i)^2$$

**263.** ចូរគណនាតម្លៃតូចបំផុតរបស់

$$f(x) = \frac{\sin^3 x}{\cos x} + \frac{\cos^3 x}{\sin x}$$

ចំពោះ $x \in (0, \pi/2)$ ។

**264.** ចូរបង្ហាញថា ចំពោះគ្រប់ចំនួនពិត $a, b, c \ge 0$ គេមាន

$$a^3 + b^3 + c^3 \ge a^2b + b^2c + c^2a \ge 3abc$$

**265.** (អន្តរជាតិ ១៩៧៨)

គេឱ្យ $(a_k)_{k\in\mathbb{N}}$ ជាស្វ៊ីតនៃចំនួនគត់ធម្មជាតិមិនសូន្យ ហើយមានតួខុសគ្នាពីរៗ ។

ចូរបង្ហាញថា ចំពោះគ្រប់ $n \ge 1$ គេមាន

$$\sum_{k=1}^{n}\frac{a_k}{k^2} \ge \sum_{k=1}^{n}\frac{1}{k}$$

**266.** (ចិន ១៩៨៤/១៩៨៥)

គេឱ្យ $a_1, a_2, \ldots, a_n > 0$ ។ ចូរបង្ហាញថា

$$\frac{a_1^2}{a_2} + \frac{a_2^2}{a_3} + \cdots + \frac{a_{n-1}^2}{a_n} + \frac{a_n^2}{a_1} \ge a_1 + a_2 + \cdots + a_n$$

**267.** គេឱ្យចំនួនមិនអវិជ្ជមាន $p, q, x, y, z$ ។ ចូរបង្ហាញថា

$$\frac{x^{2000}}{py + qz} + \frac{y^{2000}}{pz + qx} + \frac{z^{2000}}{px + qy} \ge \frac{x^{1999} + y^{1999} + z^{1999}}{p + q}$$

**268.** (វិសមភាព Chebyshev)

ចំពោះគ្រប់ស្វ៊ីតកើននៃចំនួនពិតពីរ តាងដោយ $a_1 \le a_2 \le \cdots \le a_n$ និង

$b_1 \le b_2 \le \cdots \le b_n$ គេមាន

$$\frac{a_1 + a_2 + \cdots + a_n}{n}\frac{b_1 + b_2 + \cdots + b_n}{n} \le \frac{a_1b_1 + a_2b_2 + \cdots + a_nb_n}{n}$$

ផ្ទុយទៅវិញ បើ $b_1 \ge b_2 \ge \cdots \ge b_n$ នោះ

$$\frac{a_1 + a_2 + \cdots + a_n}{n}\frac{b_1 + b_2 + \cdots + b_n}{n} \ge \frac{a_1b_1 + a_2b_2 + \cdots + a_nb_n}{n}$$



Pafnuty Lvovich Chebyshev
គណិតវិទូរុស្ស៊ី,១៨២១–១៨៩៤

**269.** (វិសមភាពនៃសប៊ីត)

គេឱ្យ $a, b, c$ ជាចំនួនពិតវិជ្ជមាន ។ ចូរបង្ហាញថា
**735.** $\sin^2 x + 3\sin x\cos x + 2\cos^2 x = 0$

**736.** $2\cos^2 x + 3\sin 2x - 8\sin^2 x = 0$

**737.** $3\sin^2 x + 5\cos^2 x - 2\cos 2x - 4\sin 2x = 0$

**738.** $2\sin^2 x - 5\sin x\cos x - 8\cos^2 x = -2$

**739.** $\frac{1}{\cos x} = 4\sin x + 6\cos x$

**740.** $\sin^3 x + 4\cos^3 x = 0$

**741.** $\sin^2 x\,(1+\tan x) = 3\sin x\,(\cos x - \sin x) + 3$

**742.** $\sin^4 x + \sin^3 x\cos x + \sin^2 x\cos^2 x + \sin x\cos^3 x + \cos^4 x = 1$

**743.** $\frac{\sqrt{3}}{2}\cos x + \frac{1}{2}\sin x = \frac{\sqrt{3}}{2}$ **744.** $\sqrt{3}\sin x + \cos x = \sqrt{2}$

**745.** $\sin 5x = \sqrt{3}(1+\cos 5x)$ **746.** $\cos x + \sin x = 1$

**747.** $\sin x + \cos x\cot\frac{x}{2} = -\sqrt{3}$ **748.** $\sin|x|\tan 5x = \cos x$

**749.** $\left(\sin 2x + \sqrt{3}\cos 2x\right)^2 - 5 = \cos\left(\frac{\pi}{6} - 2x\right)$

**750.** $\cos 6x + \tan^2 x + \cos 6x\tan^2 x = 1$

**751.** $\frac{\tan 2x + \tan x}{1 - \tan 2x\tan x} = -1$ **752.** $\frac{\tan 3x - \tan 2x}{1 + \tan 3x\tan 2x} = 1$

**753.** $2\tan 3x - 3\tan 2x = \tan^2 2x\tan 3x$

**754.** $\cot x + \cot 15° + \cot(x + 25°) = \cot 15°\cot x\cot(x + 25°)$

**755.** $\sin x + \tan\frac{x}{2} = 0$ **756.** $1 + \cos x + \tan\frac{x}{2} = 0$

**757.** $\tan 2x + \cot x = 4\sin 2x$

**758.** $15\cot\frac{x}{2} + 130\sin x = \frac{53}{3}\tan\frac{x}{2}$

**759.** $\frac{59}{4}\cos x + 6\sin x\tan\frac{x}{2} = 4\tan x\cot\frac{x}{2}$

**760.** $2\sin^2\left(x - \frac{\pi}{4}\right) = 2\sin^2 x - \tan x$

**761.** $\cos 3x = -2\cos x$ **762.** $\cos 9x - 2\cos 6x = 2$

**763.** $\cos 4x = \cos^2 3x$ **764.** $3\sin\frac{x}{3} = \sin x$

**765.** $\sin 6x + 2 = 2\cos 4x$ **766.** $\sin\frac{3}{2}x + 3\sin x = 3\sin\frac{x}{2}$

**767.** $\sin\left(\frac{\pi}{4} + \frac{3}{2}x\right) = 2\sin\left(\frac{3\pi}{4} + \frac{x}{2}\right)$

**768.** $3\cos x + 3\sin x + \sin 3x - \cos 3x = 0$

**769.** $a\cos x + b\sin x = c,\ a^2 + b^2 \neq 0$

**770.** $\sin x + \sin\left(x + \frac{\pi}{4}\right) = 0$ **771.** $\sin 4x - \sin 2x = 0$

**772.** $\sin^2 x - \cos^2 x = \cos\frac{x}{2}$ **773.** $\cos 2x - \cos 6x = 0$

**774.** $\cos(3x - 4\pi) = \sin(\pi - x)$ **775.** $\sin \pi x^2 = \sin \pi(x^2 + 2x)$

**776.** $\sin\left(x - \frac{\pi}{6}\right) - \sin\left(x + \frac{2\pi}{3}\right) = \cos\left(x + \frac{\pi}{4}\right)$

**777.** $1 + \sin 2x = (\sin 3x - \cos 3x)^2$

**778.** $\cos 5x + \cos 7x = \cos(\pi + 6x)$

**779.** $\cos x - \cos 3x = 2\sqrt{3}\sin^2 x$

**780.** $\sin x + \sin 3x + 4\cos^3 x = 0$

**781.** $\cos x - \cos 2x = \sin 3x$

**782.** $\sin x + 2\sin 2x = -\sin 3x$

**783.** $\frac{\sin x + \sin 2x}{\sin 3x} = -1$ **784.** $\sqrt{2}\sin 10x + \sin 2x = \cos 2x$

**785.** $\cot x \sin 2x - \cos 2x = 1$

**786.** $\tan 2x \cos 3x + \sin 3x + \sqrt{2}\sin 5x = 0$

**787.** $2\sin\left(x + \frac{\pi}{3}\right) + 2\cos\left(\frac{x}{2} + \frac{\pi}{4}\right) = 3\sin\left(\frac{x}{4} + \frac{\pi}{8}\right) + \sqrt{3}\cos\left(\frac{x}{4} + \frac{\pi}{8}\right)$

**788.** $\sin x + \sin 2x + \sin 3x + \sin 4x = 0$

**789.** $\cos 9x - \cos 7x + \cos 3x - \cos x = 0$

**790.** $\cos 5x - \sin 5x = \sin 7x - \cos 7x$

**791.** $\sin 7x + \cos^2 2x = \sin^2 2x + \sin x$

**792.** $\cos 2x - \sin 3x - \cos 8x = \sin 10x - \cos 5x$

**793.** $\sin x + \sin 2x + \sin 3x = 1 + \cos x + \cos 2x$

**794.** $5\sin x + 6\sin 2x + 5\sin 3x + \sin 4x = 0$

**795.** $\operatorname{cosec} x - \operatorname{cosec} 2x = \operatorname{cosec} 4x$

**796.** $\tan 3x - \tan x = 0$ **797.** $\tan x + \tan 2x - \tan 3x = 0$

**798.** $\cos 3x \cos 6x = \cos 4x \cos 7x$

**799.** $\sin 2x \sin 6x = \cos x \cos 3x$

**800.** $\cos 3x \sin 7x = \cos 2x \sin 8x$

**801.** $\sin 5x \cos 3x = \sin 6x \sin 2x$

**802.** $\sin\left(\pi x + \frac{\pi}{4}\right)\sin\left(\pi x - \frac{\pi}{12}\right) = \frac{1}{2}$

**803.** $\sin^2 x + \sin^2 2x = \sin^2 3x$

**804.** $\cos^2 x + \cos^2 2x \cos^2 3x + \cos^2 4x = 2$

**805.** $\sin 7x + \sin 9x = 2\left[\cos^2\left(\frac{\pi}{4} - x\right) - \cos^2\left(\frac{\pi}{4} + 2x\right)\right]$

**806.** $\sin^2 2x + \sin^2 x = \frac{9}{16}$

**807.** $\sin x + \sin 2x + \sin 3x = \frac{1}{2}\cot\frac{x}{2}$

**808.** $\cos x + \cos 2x + \cos 3x = -0{,}5$

**809.** $\sin^3 x \cos 3x + \cos^3 x \sin 3x + 0{,}375 = 0$

**810.** $\cos^3 x \cos 3x + \sin^3 x \sin 3x = \frac{\sqrt{2}}{4}$

**811.** $\sin x \sin\left(\frac{\pi}{3} - x\right)\sin\left(\frac{\pi}{3} + x\right) = \frac{1}{8}$

**812.** $8\cos x \cos\left(\frac{\pi}{3} - x\right)\cos\left(\frac{\pi}{3} + x\right) + 1 = 0$

**813.** $\tan x \tan\left(x + \frac{\pi}{3}\right)\tan\left(x + \frac{2\pi}{3}\right) = \sqrt{3}$

**814.** $\sin 3x = 4\sin x \cos 2x$ **815.** $\sin 3x \cos x = 1{,}5\tan x$

**816.** $\tan x \cot 3x = 4$ **817.** $6\tan x + \frac{5}{\tan 3x} = \tan 2x$

**818.** $\sin x \cos x \sin 3x - \cos 3x \sin^2 x = 6\cot x$

**819.** $2\sin 3x \sin x + \left(3\sqrt{2} - 1\right)\cos 2x = 3$

**820.** $2\cos 4x + 5\cos 2x - 1 = 2\sin^2 x$

**821.** $2 + \cos 4x = 5\cos 2x + 8\sin^6 x$

**822.** $\tan^2 x + \cos 4x = 0$

**823.** $\tan x + \cot x - \cos 4x = 3$

**824.** $\sin 2x - 12(\sin x - \cos x) + 12 = 0$

**825.** $\frac{1}{\sin x} + \frac{1}{\sin\left(x - \frac{3\pi}{2}\right)} = 4\sin\left(x + \frac{5\pi}{4}\right)$

**826.** $1+\tan x = 2\sqrt{2}\sin x$

**827.** $\sin\left(x+\frac{\pi}{4}\right) = \frac{1}{\sqrt{2}}(1-\sin x\cos x)$

**828.** $\sin x + \sin^2 x + \cos^3 x = 0$

**829.** $\sin\frac{\sqrt{x}}{2} + \cos\frac{\sqrt{x}}{2} = \sqrt{2}\sin\sqrt{x}$

**830.** $\sin^2 x + 2\tan^2 x + \frac{4}{\sqrt{3}}\tan x - \sin x + \frac{11}{12} = 0$

**831.** $8\cos x + 6\sin x - \cos 2x - 7 = 0$

**832.** $\sin^4 x + \sin^4\left(\frac{x}{2}+\frac{\pi}{8}\right) + \cos^4 x = 0{,}5\sin^2 2x$

**833.** $\left(\cos\frac{x}{4} - 2\sin x\right)\sin x + \left(1+\sin\frac{x}{4} - 2\cos x\right)\cos x = 0$

**834.** $3\sin 3x = \cos 4x - \sin 9x - \cos 10x$

**835.** $\tan x + \frac{1}{9}\cot x = \sqrt{\frac{1}{\cos^2 x} - 1} - 1$

**836.** $\sin x + \sqrt{3}\cos x = \sqrt{2+\cos 2x + \sqrt{3}\sin 2x}$

**837.** $\sqrt{2\cos 2x + 2} = \frac{3}{\sqrt{1+4\cos 2x}}$

**838.** $\sqrt{\sin x} + \sqrt[4]{2}\cos x = 0$ **839.** $\sin x + \sqrt{\cos x} = 0$

**840.** $2\cos x = \sqrt{2+2\sin 2x}$ **841.** $\sqrt{\cos^2 x - \cos^2 3x} = \sin 2x$

**842.** $\sin x + \sqrt{3}\cos x = \sqrt{0{,}5 + \cos\left(\frac{\pi}{6} - x\right)}$

**843.** $\sqrt{1+4\sin x\cos x} = \cos x - \sin x$

**844.** $\sqrt{\cos 2x - \sin 4x} = \sin x - \cos x$

**845.** $\sqrt{\dfrac{1+\tan x}{1-\tan x}} = \sin x + \cos x$

**846.** $4\sin 3x + 3 = \sqrt{2\sin 3x + 2}$

**847.** $\sqrt{13 - 18\tan x} = 6\tan x - 3$

**848.** $\sqrt{1 + 8\sin 2x \cos^2 2x} = 2\sin(3x + \pi/4)$

**849.** $2\sqrt{3}\sin x = \dfrac{3\tan x}{2\sqrt{\sin x} - 1} - \sqrt{3}$

**850.** $\sqrt{\sqrt{3}\cos x + \sin x - 2} + \sqrt{\cot 3x + \sin^2 x - \dfrac{1}{4}} = \sin\dfrac{3x}{2} + \dfrac{1}{\sqrt{2}}$

**851.** $\log_5 \tan x = (\log_5 4)\log_4(3\sin x)$

**852.** $\log_9 \sin 2x = \log_3 \sqrt{\dfrac{\sin x}{5}}$ **853.** $2^{\cos 2x} = 3.2^{\cos^2 x} - 4$

**854.** $\cot 2^x = \tan 2^x + 2\tan 2^{x+1}$ **855.** $x^{3\sin 2x + 2} = \sqrt{x}$

**856.** តើសមីការ $1 + \cos 2x + \sin 2x = 0$ និងសមីការ

$$1 + \frac{1-\tan^2 x}{1+\tan^2 x} + \frac{2\tan x}{1+\tan^2 x} = 0$$

ដូចគ្នាដែរឬទេ?

**857.** ចូរកំណត់តម្លៃ $p$ ដើម្បីឱ្យសមីការ $\sqrt{p}\cos x - 2\sin x = \sqrt{2} + \sqrt{2-p}$ មានចម្លើយ ។

**858.** ចូរកំណត់តម្លៃ $a, b$ ដើម្បីឱ្យសមីការខាងក្រោមពិតចំពោះគ្រប់ $x$

$$a(\cos x - 1) + b^2 = \cos(ax + b^2) - 1$$

**859.** (អន្តរជាតិ ១៩៦១)

ដោះស្រាយសមីការ $\cos^n x - \sin^n x = 1$ ដែល $n$ ជាចំនួនគត់វិជ្ជមាន ។

**860.** (អន្តរជាតិ ១៩៦២)

ដោះស្រាយសមីការ

$$\cos^2 x + \cos^2 2x + \cos^2 3x = 1$$

**861.** ចូរកំណត់គ្រប់គូចំនួនពិត $(x, y)$ ដែល $0 < x < \pi/2$ ដែល

$$\frac{(\sin x)^{2y}}{(\cos x)^{\frac{y^2}{2}}} + \frac{(\cos x)^{2y}}{(\sin x)^{\frac{y^2}{2}}} = \sin 2x$$

**862.** ចូរកំណត់គ្រប់ $x \in (0, \pi/2)$ ដែល

$$\frac{\sqrt{3} - 1}{\sin x} + \frac{\sqrt{3} + 1}{\cos x} = 4\sqrt{2}$$

# ៤.៤ ប្រព័ន្ធសមីការ

ដោះស្រាយប្រព័ន្ធសមីការ

**863.** $\begin{cases} x - y = 6{,}5\pi \\ 3\cos^2 x - 12\cos y = -4 \end{cases}$

**864.** $\begin{cases} x + y = \dfrac{2}{3}\pi \\ \dfrac{\sin x}{\sin y} = 2 \end{cases}$

**865.** $\begin{cases} x + y = \pi/4 \\ \cos x + \cos y = a \end{cases}$

**866.** $\begin{cases} \sin 3x \cos 2y = 2^a - \cos 3x \sin 2y \\ \cos(x - y) = 0{,}5 \end{cases}$

**867.** $\begin{cases} \sin x \sin y = \dfrac{\sqrt{3}}{4} \\ \cos x \cos y = \dfrac{\sqrt{3}}{4} \end{cases}$

**868.** $\begin{cases} \tan x + \tan y = 2 \\ \cos x \cos y = 0{,}5 \end{cases}$

**869.** $\begin{cases} \sin x \cos y = \dfrac{1}{4} \\ 3\tan x = \tan y \end{cases}$

**870.** $\begin{cases} \tan x - 2\sin y = -2 \\ 5\tan x + 2\sin y = -4 \end{cases}$

**871.** $\begin{cases} 4\sin y - 6\sqrt{2}\cos x = 5 + 4\cos^2 y \\ \cos 2x = 0 \end{cases}$

**872.** $\begin{cases} \dfrac{1}{\sin x} - \cos y = \dfrac{a+3}{3} \\ \sin x \cos y = -\dfrac{a}{3} \end{cases}$

**873.** $\begin{cases}\dfrac{1}{\cos x}-\tan y=2a+2\\ \tan y+(a^2+2a)\cos x=0\end{cases}$

**874.** $\begin{cases}\sin^2(-2x)-\left(3-\sqrt{2}\right)\tan 5y=\left(3\sqrt{2}-1\right)/2\\ \left(3-\sqrt{2}\right)\sin(-2x)+\tan^2 5y=\left(3\sqrt{2}-1\right)/2\end{cases}$

**875.** ដោះស្រាយប្រព័ន្ធសមីការ

$$\begin{cases}\tan^2 x+\tan^2 y+\tan^2 z=m^2\\ \tan^3 x+\tan^3 y+\tan^3 z=m^3\end{cases}$$

# ៤.៥ វិសមភាព

**876.** ចូរបង្ហាញថា ចំពោះគ្រប់ $0\le x\le \frac{\pi}{2};\frac{\pi}{6}<\alpha<\frac{\pi}{3}$ គេមាន

$$\tan\left(\frac{\pi\sin x}{4\sin\alpha}\right)+\tan\left(\frac{\pi\cos x}{4\cos\alpha}\right)>1$$

**877.** គេឱ្យត្រីកោណមិនកែង $ABC$ ។ ចូរបង្ហាញថា

$$3\tan^2 A\tan^2 B\tan^2 C-5(\tan^2 A+\tan^2 B+\tan^2 C)\\ \le 9+\tan^2 B\tan^2 C+\tan^2 C\tan^2 A$$

**878.** ចូរបង្ហាញថា

$$\frac{1-\sin\frac{\pi}{14}}{2\sin\frac{\pi}{14}}>\sqrt{3\cos\frac{\pi}{7}}$$

**879.** គេឱ្យ $2n$ ចំនួនពិត $x_1;x_2;\dots;x_{2n}\in\left[\frac{\pi}{6},\frac{\pi}{2}\right]$ ចូរកំណត់តម្លៃតូចបំផុតនៃ $n\in\mathbb{N}^*$ ដែល

$$Y=\left(\sum_{i=1}^{2n}\sin x_i\right)\left(\sum_{i=1}^{2n}\frac{1}{\sin x_i}\right)=1800$$

**880.** គណនាតម្លៃធំបំផុតនៃ

$$T=\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}$$

ដែល $A,B,C$ ជាមុំបីនៃត្រីកោណមួយ ។

**881.** តាង $n$ ជាចំនួនគត់ធម្មជាតិ និងចំនួនពិត $x$ ដែល $0<(n+1)x<\pi/2$

ចូរបង្ហាញថា

$$(1-\cos^n x)(1+\cos^n x) < \tan nx \sin x$$

**882.** គេឱ្យ $A, B, C$ ជាមុំក្នុងនៃត្រីកោណមួយ ។ ចូរបង្ហាញថា

$$27\left(\tan\frac{A}{2}\tan^2\frac{B}{2}+\tan\frac{B}{2}\tan^2\frac{C}{2}+\tan\frac{C}{2}\tan^2\frac{A}{2}\right) < 4\left(\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}\right)$$

**883.** តាង $A, B, C$ ជាមុំនៃត្រីកោណ $ABC$ ។ គណនាតម្លៃធំបំផុតនៃ $\sin C$ បើ

$$\frac{\sin^2 A+\sin^2 B}{\sin^2 C}=m, \qquad m>\frac{1}{2}$$

**884.** គេឱ្យ អនុគមន៍ $f(x)$ ដែល $f(\tan 2x)=\tan^4 x+\cot^4 x$ ។ ចូរបង្ហាញថា

$$f(\sin x)+f(\cos x)\geq 196$$

**885.** គេឱ្យត្រីកោណ $ABC$ មាន $A>B>C$ ។ គណនាតម្លៃតូចបំផុតនៃ

$$y=\sqrt{\frac{x-\sin A}{x-\sin C}}+\sqrt{\frac{x-\sin B}{x-\sin C}}-1$$

**886.** (វៀតណាម ២០០២)

គេឱ្យ $\phi$ ជាចំនួនពិតផ្ទៀងផ្ទាត់

$$f(x)=\frac{2000}{2001}\cos 2x+\frac{2003}{2000}\cos(x-\phi)+1\geq 0; \quad \forall x\in\mathbb{R}$$

ចូរបង្ហាញថា $f(x)\leq 3; \ \forall x\in\mathbb{R}$ ។

**887.** តាង $0°<\theta<45°$ ។ ចូររៀប

$$t_1=(\tan\theta)^{\tan\theta}, \quad t_2=(\tan\theta)^{\cot\theta}$$
$$t_3=(\cot\theta)^{\tan\theta}, \quad t_4=(\cot\theta)^{\cot\theta}$$

តាមលំដាប់ចុះ ។

**888.** (អន្តរជាតិ សតលីស ១៩៦៧)

ស្រាយបញ្ជាក់វិសមភាពត្រីកោណមាត្រ

$$\cos x<1-\frac{x^2}{2}+\frac{x^4}{16}$$

ដែល $x\in(0,\pi/2)$ ។

**889.** ក្នុងត្រីកោណ $ABC$ មួយ ចូរបង្ហាញថា

$$\sin\frac{A}{2}\leq\frac{a}{b+c}$$

**890.** បង្ហាញថា

$$\left(1+\frac{a}{\sin x}\right)\left(1+\frac{b}{\cos x}\right)\geq\left(1+\sqrt{2ab}\right)^2$$

ចំពោះគ្រប់ចំនួនពិត $a, b, x$ ដែល $a, b \geq 0$ និង $0 < x < \pi/2$ ។

**891.** តាង $ABC$ ជាត្រីកោណមួយ ។ បង្ហាញថា

(a) $\tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2}=1$

(b) $\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}\leq\frac{\sqrt{3}}{9}$

**892.** តាង $ABC$ ជាត្រីកោណស្រួចមួយ ។ បង្ហាញថា

(a) $\tan A+\tan B+\tan C=\tan A\tan B\tan C$

(b) $\tan A\tan B\tan C\geq 3\sqrt{3}$

**893.** (ហុងកុង ២០០៨)

តាង $\alpha_1, \alpha_2, \ldots, \alpha_{2008}$ ជាចំនួនពិត ។ គណនាតម្លៃធំបំផុតនៃ

$$\sin\alpha_1\cos\alpha_2+\sin\alpha_2\cos\alpha_3+\cdots+\sin\alpha_{2007}\cos\alpha_{2008}+\sin\alpha_{2008}\cos\alpha_1$$

**894.** (Baltic Way 2010)

តាង $x$ ជាចំនួនពិត ដែល $0 < x < \pi/2$ ។ បង្ហាញថា

$$\cos^2 x\cot x+\sin^2 x\tan x\geq 1$$

# ៤.៦ វិសមីការ

ដោះស្រាយវិសមីការ

**895.** $2\sin^2 x+\sqrt{3}\sin x-3>0$

**896.** $\cos 2x+5\cos x+3\geq 0$

**897.** $\tan^2 x+\left(2-\sqrt{3}\right)\tan x-2\sqrt{3}<0$

**898.** $\cot^2 x+\cot x\geq 0$

**899.** $2\left(\sqrt{2}-1\right)\sin x-2\cos 2x+2-\sqrt{2}<0$

**900.** $\cos\pi x+\sin\left(\pi x-\frac{\pi}{4}\right)>0$

**901.** $\cos^3 x\sin 3x+\cos 3x\sin^3 x<\frac{3}{8}$

**902.** $\cos x\cos 2x\cos 3x\leq 0$

**903.** $\sin^4\frac{x}{3}+\cos^4\frac{x}{3}>\frac{1}{2}$

**904.** $\sin^6 x+\cos^6 x>\frac{5}{8}$

**905.** $8\sin^6 x-\cos^6 x>0$

**906.** $\tan x\tan 3x<-1$

**907.** $3\sin 2x-1>\sin x+\cos x$

**908.** $\sin 2x>\sqrt{2}\sin^2 x+\left(2-\sqrt{2}\right)\cos^2 x\,, 0<x<2\pi$

**909.** $|\sin x|>\cos^2 x$

**910.** $\sqrt{5-2\sin x}\geq 6\sin x-1$

**911.** $1-\cos x<\tan x-\sin x$

**912.** $9^{1+\sin^2\pi x}+30.9^{\cos^2\pi x}\leq 117$

**913.** (អន្តរជាតិ ឡុងលីស ១៩៦៧)

ចូរកំណត់ $x$ ដែលចំពោះគ្រប់ចំនួនគត់ $n>0$ គេមាន

$$\sin x+\sin 2x+\sin 3x+\cdots+\sin nx\leq\frac{\sqrt{3}}{2}$$

**914.** គេឱ្យវិសមីការ

$$x^2+2x(\cos y+\sin y)+1\geq 0$$

1) ចូរកំណត់$x$ ដើម្បីឱ្យវិសមីការពិតចំពោះគ្រប់ $y$ ។

2) ចូរកំណត់ $y$ ដើម្បីឱ្យវិសមីការពិតចំពោះគ្រប់ $x\geq 0$ ។

**915.** (អន្តរជាតិ ១៩៦៥)

ចូរកំណត់ចំនួនពិត $x\in[0,2\pi]$ ដែល

$$2\cos x\leq\left|\sqrt{1+\sin 2x}-\sqrt{1-\sin 2x}\right|\leq\sqrt{2}$$

# ៤.៧ ប្រព័ន្ធវិសមីការ

**916.** ចូរកំណត់ $m$ ដើម្បីឱ្យប្រព័ន្ធមានឫសតែមួយគត់

$$\begin{cases}(4-6m)\sin^3 x + 3(2m-1)\sin x + 2(m-2)\sin^2 x\cos x - (4m-3)\cos x = 0\\ 0 \le x \le \pi/4\end{cases}$$

# ៤.៨ អាំងតេក្រាល

**917.** ចូរកំណត់ចំនួនថេរ $A, B, C$ ដើម្បីឱ្យ

$$\sin x - \cos x + 1 = A(\sin x + 2\cos x + 3) + B(\cos x - 2\sin x) + C$$

ចូរគណនា

$$\int_0^{\frac{\pi}{2}} \frac{\sin x - \cos x + 1}{\sin x + 2\cos x + 3}\,dx$$

# ៥

# ពហុធា

**918.** កំណត់ពហុធា $P(x)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$P(u^2 - v^2) = P(u+v).P(u-v)$$

ចំពោះគ្រប់ $u, v \in \mathbb{R}$ ។

**919.** កំណត់ពហុធា $P(x)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$P(x+1) = P(x) + 2x + 1$$

ចំពោះគ្រប់ $x \in \mathbb{R}$ ។

**920.** កំណត់ពហុធា $P(x)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$P((x+1)^2) = P(x^2) + 2x + 1$$

ចំពោះគ្រប់ $x \in \mathbb{R}$ ។

**921.** (កាណាដា ១៩៧០)

គេឱ្យពហុធា

$$f(x) = x^n + a_1x^{n-1} + a_2x^{n-2} + \cdots + a_{n-1}x + a_n$$

ដែលមានមេគុណ $a_1, a_2, \dots, a_n$ ជាចំនួនគត់ ហើយដោយដឹងថាមានចំនួនគត់បួនផ្សេងគ្នា $a, b, c$ និង $d$ ដែល

$$f(a) = f(b) = f(c) = f(d) = 5$$

ចូរបង្ហាញថា គ្មានចំនួនគត់ $k$ មួយដែល $f(k) = 8$ ។

**922.** គេឱ្យពហុធាដឺក្រេទី $n \geq 1$ មានមេគុណមិនអវិជ្ជមាន និង $x_1, x_2, \dots, x_n \in \mathbb{R}^{+*}$

បង្ហាញថា

$$\left[P\left(\frac{x_2}{x_1}\right)\right]^2 + \left[P\left(\frac{x_3}{x_2}\right)\right]^2 + \cdots + \left[P\left(\frac{x_n}{x_{n-1}}\right)\right]^2 + \left[P\left(\frac{x_1}{x_n}\right)\right]^2 \geq n[P(1)]^2$$

**923**. (ភ្នំពេញ ២០១០)

គេឱ្យពហុធា $P(x) = (1 + x + x^2 + \cdots + x^{2010})^2 - x^{2010}$ ។

ចូរដាក់ $P(x)$ ជាផលគុណនៃពហុធាពីរ ។

**924**. គណនាផលបូកមេគុណរបស់ពហុធាដែលជាពន្លាតនៃ

$$(1 - 3x + 3x^2)^{743}(1 + 3x - 3x^2)^{744}$$

**925**. តើរវាង $(1 + x^2 - x^3)^{1000}$ និង $(1 - x^2 + x^3)^{1000}$ មួយណាមានមេគុណរបស់ $x^{20}$ ធំជាងគេ បន្ទាប់ពីពន្លាតហើយផ្តុំតួរួច?

**926**. ចូរបង្ហាញថាផលគុណ

$$(1 - x + x^2 - x^3 + \cdots - x^{99} + x^{100})(1 + x + x^2 + x^3 + \cdots + x^{99} + x^{100})$$

បន្ទាប់ពីពន្លាតនិងផ្តុំតួរួច តួដែលមានស្វ័យគុណសេសនឹងបាត់អស់ ។

**927**. គណនាមេគុណរបស់ $x^{50}$ នៅក្នុងពហុធាខាងក្រោម

a) $(1 + x)^{1000} + x(1 + x)^{999} + x^2(1 + x)^{998} + \cdots + x^{1000}$

b) $(1 + x) + 2(1 + x)^2 + 3(1 + x)^3 + \cdots + 1000(1 + x)^{1000}$

**928**. គណនាមេគុណរបស់ $x^2$ របស់ពហុធាខាងក្រោមក្រោយពន្លាតរួច

$$\underbrace{(\ldots(((x-2)^2-2)^2-2)^2-\cdots-2)^2}_{n \text{ ដង}}$$

**929**. គណនាសំណល់ពេលចែក $x + x^3 + x^9 + x^{27} + x^{81} + x^{243}$

a) ជាមួយ $x - 1$

b) ជាមួយ $x^2 - 1$

**930**. ពហុធាមួយសល់សំណល់ស្មើ 2 ពេលចែកនឹង $(x - 1)$ និង សល់សំណល់ស្មើ 1 ពេលចែកនឹង $(x - 2)$ ។ គណនាសំណល់ពេលចែកពហុធាមួយនោះនឹង $(x - 1)(x - 2)$ ។

**931**. បើពហុធា $x^{1951} - 1$ ចែកនឹង $x^4 + x^3 + 2x^2 + x + 1$ នោះគេទទួលបានផលចែកនិងសំណល់ ។ គណនាមេគុណរបស់ $x^{14}$ នៅក្នុងផលចែក ។

**932**. កំណត់សមីការដែលមានមេគុណជាចំនួនគត់ ហើយមានឫសមួយស្មើ

a) $\sqrt{2} + \sqrt{3}$

b) $\sqrt{2} + \sqrt[3]{3}$

**933.** ចូរបង្ហាញថា បើ $\alpha$ និង $\beta$ ជាឫសរបស់សមីការ $x^2+px+1=0$ និង $\gamma$ និង $\delta$ ជាឫសរបស់សមីការ $x^2+qx+1=0$ នោះ $(\alpha-\gamma)(\beta-\gamma)(\alpha+\delta)(\beta+\delta)=q^2-p^2$ ។

**934.** តាង $\alpha$ និង $\beta$ ជាឫសរបស់សមីការ $x^2+px+q=0$ និង $\gamma$ និង $\delta$ ជាឫសរបស់សមីការ $x^2+Px+Q=0$ ។ គណនា $(\alpha-\gamma)(\beta-\gamma)(\alpha-\delta)(\beta-\delta)$ ជាអនុគមន៍នៃ $p,q,P,Q$ ។

**935.** គេឱ្យពហុធាពីរ

$$x^2+ax+1=0$$
$$x^2+x+a=0$$

កំណត់មេគុណ $a$ ដើម្បីឱ្យសមីការទាំងពីរមានឫសរួមយ៉ាងតិចមួយ ។

**936.** ចូរកំណត់ចំនួនគត់ $a$ ដែលពហុធា $(x-a)(x-10)+1$ អាចសរសេរជារាង $(x+b)(x+c)$ បាន ចំពោះចំនួនគត់ $b$ និង $c$ ណាមួយ ។

**937.** (ភ្នំពេញ ២០១០)

រកតម្លៃ $p\in\mathbb{N}$ ផ្ទៀងផ្ទាត់សមីការ $(x-p)(x-2011)+1=(x+m)(x+n)$ ចំពោះគ្រប់ $x\in\mathbb{R}$ និងចំពោះតម្លៃ $m,n\in\mathbb{Z}$ ណាមួយ ។

**938.** កំណត់ចំនួនគត់មិនសូន្យខុសៗគ្នា $a,b$ និង $c$ ដែលពហុធាដឺក្រេទីបួនមានមេគុណជាចំនួនគត់ខាងក្រោម អាចដាក់ជាកត្តាផលគុណនៃពហុធាពីរដែលមានមេគុណជាចំនួនគត់

$$x(x-a)(x-b)(x-c)+1$$

**939.** តើចំនួនគត់ $a_1,a_2,\dots,a_n$ ខុសគ្នាពីរៗ ណាខ្លះដែលផ្ទៀងផ្ទាត់ពហុធាមានមេគុណជាចំនួនគត់ខាងក្រោមអាចបំបែកជាផលគុណនៃពហុធាពីរមានមេគុណជាចំនួនគត់?

(a) $(x-a_1)(x-a_2)(x-a_3)\dots(x-a_n)-1$
(b) $(x-a_1)(x-a_2)(x-a_3)\dots(x-a_n)+1$

**940.** ចូរបង្ហាញថា បើចំនួនគត់ $a_1,a_2,\dots,a_n$ សុទ្ធតែខុសគ្នាពីរៗ នោះពហុធា

$$(x-a_1)^2(x-a_2)^2\dots(x-a_n)^2+1$$

មិនអាចសរសេរជាផលគុណនៃពហុធាពីរទៀតដែលមានមេគុណជាចំនួនគត់បានទេ ។

**941.** ចូរបង្ហាញថាបើពហុធា
$P(x) = a_0x^7 + a_1x^6 + a_2x^5 + a_3x^4 + a_4x^3 + a_5x^2 + a_6x + a_7$
ដឺក្រេទី៧ មានមេគុណជាចំនួនគត់, មានតម្លៃ $+1$ ឬបើមិនអ៊ីចឹង $-1$ ចំពោះចំនួនគត់ x ប្រាំពីរផ្សេងគ្នា, នោះពហុធានេះមិនអាចបំបែកជាផលគុណនៃពហុធាពីរដែលមានមេគុណជាចំនួនគត់បានទេ ។

**942.** ចូរបង្ហាញថាបើពហុធា
$$P(x) = a_0x^n + a_1x^{n-1} + \cdots + a_{n-1}x + a_n$$
ដែលមានមេគុណជាចំនួនគត់ មានតម្លៃសេសចំពោះ $x = 0$ និង $x = 1$ នោះសមីការ $P(x) = 0$ មិនអាចមានឫសគត់បានទេ ។

**943.** ចូរបង្ហាញថាបើពហុធា
$$P(x) = a_0x^n + a_1x^{n-1} + \cdots + a_{n-1}x + a_n$$
ដែលមានមេគុណជាចំនួនគត់, មានតម្លៃដាច់ខាតស្មើ 1 ចំពោះចំនួនគត់ $x$ ពីរតាងដោយ $x = p$ និង $x = q$ $(p > q)$ និងបើសមីការ $P(x) = 0$ មានឫសសនិទាន $a$, នោះ $p - q$ ស្មើ 1 ឬ 2 និង $a = \frac{p+q}{2}$ ។

**944.** ចូរបង្ហាញថាពហុធាខាងក្រោមមិនអាចបំបែកជាកត្តាផលគុណរវាងពហុធាដែលមានមេគុណជាចំនួនគត់បានទេ

(ក) $x^{2222} + 2x^{2220} + 4x^{2218} + 6x^{2216} + 8x^{2214} + \cdots + 2218x^4 + 2220x^2 + 2222$;

(ខ) $x^{250} + x^{249} + x^{248} + \cdots + x^2 + x + 1$

**945.** តាង $P(x) = A(x)B(x)$ ដែលជា $P(x), A(x)$ និង $B(x)$ ជាពហុធាពីរដែលមានមេគុណជាចំនួនគត់ ។ ចូរបង្ហាញថា បើមេគុណរបស់ពហុធា $P(x)$ ជាចំនួនគូ និងចែកមិនដាច់នឹង 4 គ្រប់គ្នាទេ, នោះមានពហុធាមួយក្នុងចំណោម $A(x)$ និង $B(x)$ មានមេគុណទាំងអស់ជាចំនួនគូ និងពហុធាមួយទៀត មិនអាចមានមេគុណគូទាំងអស់បានទេ ។

**946.** ចូរបង្ហាញថាគ្រប់ឫសសនិទានទាំងអស់របស់ពហុធា

$$P(x) = x^n + a_1x^{n-1} + a_2x^{n-2} + \cdots + a_{n-1}x + a_n$$

ដែលមានគុណទាំងអស់ជាចំនួនគត់ និងមេគុណដំបូងស្មើ 1 , ជាចំនួនគត់ ។

**947.** ចូរបង្ហាញថា គ្មានពហុធា

$$P(x) = a_0x^n + a_1x^{n-1} + \cdots + a_{n-1}x + a_n$$

ដែល $P(0), P(1), P(2), \ldots.$ សុទ្ធតែជាចំនួនបឋមបានទេ ។

សម្គាល់ ៖ សំណើក្នុងសំនួរនេះត្រូវបានស្រាយបញ្ជាក់លើកដំបូងដោយ លេអុន ហាដ អយល័រ ។ គាត់បានរកឃើញផងដែរនូវពហុធាដែលមានតម្លៃជាចំនួនបឋមចំពោះចំនួនគត់បន្តបន្ទាប់គ្នាមួយចំនួន ។ ដូចជា $P(x) = x^2 - 79x + 1601$ ដែល $P(0), P(1), \ldots, P(79)$ សុទ្ធតែជាចំនួនបឋម ។

**948.** ក) ចូរបង្ហាញថា បើពហុធា

$$P(x) = x^n + A_1x^{n-1} + A_2x^{n-2} + \cdots + A_{n-1}x + A_n$$

មានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ , នោះគេអាចសរសេរពហុធានេះជាផលបូកនៃបណ្ដាពហុធា

$$P_0(x) = 1, P_1(x) = x, P_2(x) = \frac{x(x-1)}{1.2}, \ldots, P_n(x) = \frac{x(x-1)(x-2)\ldots(x-n+1)}{1.2.3\ldots n}$$

ដែលពហុធាទាំងនេះមានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$, ក្រោមទម្រង់

$$P(x) \equiv b_nP_n(x) + b_{n-1}P_{n-1}(x) + \cdots + b_1P_1(x) + b_0P_0(x)$$

បាន ដែល $b_0, b_1, \ldots, b_n$ ជាចំនួនគត់ ។

ខ) ចូរបង្ហាញបើពហុធាដឺក្រេទី $n$ , $P(x)$ មានតម្លៃគត់ចំពោះ $x = 0,1,2, \ldots, n$ នោះវាមានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ។

គ) ចូរបង្ហាញថាបើពហុធា $P(x)$ មានដឺក្រេ $n$ មានតម្លៃគត់ ចំពោះគ្រប់ចំនួនគត់ $x$ ចំនួន $n+1$ តជាប់គ្នា, នោះពហុធានេះមានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ។

ឃ) ចូរបង្ហាញថាបើពហុធា $P(x)$ មានដឺក្រេ $n$ មានតម្លៃគត់ចំពោះ $x = 0,1,4,9,16,\dots,n^2$ នោះវាមានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ដែលជាចំនួនការេ (តែមិនបាច់គត់ចំពោះគ្រប់ចំនួនគត់ $x$ ក៏បាន) ។

ចូររកឧទាហរណ៍ពហុធាដែលមានតម្លៃជាចំនួនគត់ ចំពោះគ្រប់ចំនួនគត់ការេ $x$, តែចំពោះតម្លៃ $x$ ផ្សេងទៀត, មានតម្លៃសនិទាន (មិនទាំងអស់ទេ) ។

**949**. (វៀតណាម ២០០២)

ចូរកំណត់ពហុធាមានដឺក្រេទាបបំផុត មានមេគុណជាចំនួនគត់ និងមានឫសមួយស្មើ $1 - \sqrt[3]{2} + \sqrt[3]{4}$

**950**. (វៀតណាម ២០០២)

តើពហុធា

$$1 + x + \frac{x^2}{2} + \cdots + \frac{x^n}{n}$$

មានឫសពិតចំនួនប៉ុន្មាន?

**951**. (អន្តរជាតិ សតលីស ១៩៩៦)

តាង $P(x)$ ជាពហុធានៃចំនួនពិតមួយ កំណត់ដោយ $P(x) = ax^3 + bx^2 + cx + d$ ។ ចូរបង្ហាញថា បើ $|P(x)| \le 1$ ចំពោះគ្រប់ $x$ ដែល $|x| \le 1$ នោះ

$$|a| + |b| + |c| + |d| \le 7$$

**952**. a) ដាក់ជាកត្តាផលគុណ

$$(a + b + c)^3 - a^3 - b^3 - c^3$$

b) ចូរបង្ហាញថា

$$(a + b + c)^{333} - a^{333} - b^{333} - c^{333}$$

ចែកដាច់នឹង $(a + b + c)^3 - a^3 - b^3 - c^3$

**953**. បំបែកជាផលគុណកត្តា $a^{10} + a^5 + 1$

# ៦

# សមីការអនុគមន៍

**954**. ចូរកំណត់គ្រប់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$f(f(x)+1) = 1 - x$$
$$f\big(f(x)\big) = x$$

ចំពោះគ្រប់ $x \in \mathbb{R}$ ។

**955**. ចូរកំណត់គ្រប់អនុគមន៍ $f$ កើនដាច់ខាតលើ $\mathbb{R}$ ដែលចំពោះគ្រប់ $x \in \mathbb{R}$ គេមាន

$$f\big(f(x)\big) = x$$

**956.** គេឱ្យអនុគមន៍$f: \mathbb{N}^* \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់

a) $f(1) = 2$

b) ចំពោះគ្រប់ $n > 1$

$$f(1) + f(2) + \cdots + f(n) = n^2 f(n)$$

ចូរកំណត់ $f(n)$ ។

**957.** (អូស្ត្រាលី ១៩៩០)

ចូរកំណត់គ្រប់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលចំពោះគ្រប់ $x, y \in \mathbb{R}$ គេមាន

$$f(2x) = f\left(\sin\left(\frac{\pi}{2}x + \frac{\pi}{2}y\right)\right) + f\left(\sin\left(\frac{\pi}{2}x - \frac{\pi}{2}y\right)\right)$$
$$f(x^2 - y^2) = (x+y)f(x-y) + (x-y)f(x+y)$$

**958.** គេឱ្យចំនួនគត់វិជ្ជមាន $n$ ។ ចូរកំណត់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់

$$f\big(xf(y)\big) = x^n f\big(f(y)\big)$$

ចំពោះគ្រប់ $x, y \in \mathbb{R}$ ។

**959.** គេឱ្យថេរចំនួនពិតបី $a, b, c$ ដែលមិនសូន្យទាំងបីព្រមគ្នា ។ ចូរកំណត់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែល

$$af(x^2 + yz) + bf(y^2 + zx) + cf(z^2 + xy) = 0$$

ចំពោះគ្រប់ $x, y, z \in \mathbb{R}$ ។

**960.** ចូរកំណត់លក្ខខណ្ឌលើចំនួនពិតវិជ្ជមាន $p, q$ ដើម្បីឱ្យគេអាចរកបាននូវអនុគមន៍ $f: \mathbb{R}^+ \to \mathbb{R}^+$ ដែល

$$f\big(xf(y)\big) = x^p y^q$$

ចំពោះគ្រប់ $x, y \in \mathbb{R}^+$ ។

**961.** ចូរកំណត់គ្រប់អនុគមន៍ $f: \mathbb{Z} \to \mathbb{Z}$ ដែល

$$f(m+19) \geq f(m) + 19$$
$$f(m+99) \leq f(m) + 99$$

ចំពោះគ្រប់ $m \in \mathbb{Z}$ ។

**962.** ចូរកំណត់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលផ្ទៀងផ្ទាត់

$$xf(x+y) + yf(y-x) = f^2(x) + f^2(y)$$

ចំពោះគ្រប់ $x, y \in \mathbb{R}$ ។

**963.** ចូរកំណត់អនុគមន៍ $f: \mathbb{Z} \to \mathbb{Z}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

1) $f(1) = 1$
2) $f(x+y)[f(x) - f(y)] = f(x-y)[f(x) + f(y)]$

ចំពោះគ្រប់ $x, y \in \mathbb{Z}$ ។

**964.** (កាណាដា ១៩៦៩)

តាង $f$ ជាអនុគមន៍មួយដែលមានលក្ខណៈដូចតទៅនេះ

a) $f(n)$ មានន័យចំពោះគ្រប់ ចំនួនគត់វិជ្ជមាន $n$ ;

b) $f(n)$ ជាចំនួនគត់;

c) $f(2) = 2$;

d) $f(mn) = f(m)f(n)$ ចំពោះគ្រប់ $m$ និង $n$ ;

e) $f(m) > f(n)$ ចំពោះគ្រប់ $m > n$ ។

ចូរបង្ហាញថា $f(n) = n$ ។

**965.** គេឱ្យ $f(x)$ ជាអនុគមន៍ដែលផ្ទៀងផ្ទាត់

$$0 < 2f^2(xy) \leq f(x)f(y^3) + f(x^3)f(y), \quad \forall x, y \in \mathbb{R}$$
$$f(1999) > 0$$

ចូរបង្ហាញថា $f(2000) > 0$ ។

**966.** (អន្តរជាតិ ២០១០)

ចូរកំណត់គ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែលផ្ទៀងផ្ទាត់ ចំពោះគ្រប់ $x,y\in\mathbb{R}$ គេមាន

$$f(\lfloor x\rfloor y)=f(x)\lfloor f(y)\rfloor$$

ដែល $\lfloor a\rfloor$ តាងឱ្យចំនួនគត់ធំបំផុតតែមិនធំជាង $a$ ។

**967.** (អន្តរជាតិ ១៩៦៨)

តាង $a$ ជាចំនួនពិតមួយ ។ តាង $f:\mathbb{R}\to\mathbb{R}$ ជាអនុគមន៍មួយ ដែល $\forall x\in\mathbb{R}$ គេមាន

$$f(x+a)=\frac{1}{2}+\sqrt{f(x)-\left(f(x)\right)^2}$$

ក) ចូរបង្ហាញថា $f$ ជាអនុគមន៍ខួប

ខ) ចំពោះ $a=1$ ចូរឱ្យឧទាហរណ៍មួយនៃអនុគមន៍បែបនេះ ។

**968.** (ស្លូវេនៀ ១៩៩៩)

ចូរកំណត់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែល

$$f\left(x-f(y)\right)=1-x-y$$

**969.** ចូរកំណត់គ្រប់ $f:\mathbb{R}\to\mathbb{R}$ ដែល

$$\frac{f(x)-f(y)}{x-y}=a$$

ដែល $a$ ជាចំនួនពិតថេរ និង $x\neq y$ ។

**970.** ចូរកំណត់គ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែល $\forall x,y\in\mathbb{R}$

$$f(x+y)=x+f(y)$$

**971.** ចូរកំណត់គ្រប់អនុគមន៍ $f:\mathbb{Q}\to\mathbb{R}$ ដែល $\forall x,y\in\mathbb{Q}$

$$f(x+y)=f(x)+f(y)$$

**972.** ចូរកំណត់គ្រប់អនុគមន៍ជាប់ (ដូចគ្នាករណី ជាអនុគមន៍ម៉ូណូតូន) $f:\mathbb{R}\to\mathbb{R}$ ដែល ចំពោះគ្រប់ $x,y\in\mathbb{R}$ គេមាន

$$f(x+y)=f(x)+f(y)$$

**973.** (សមីការ Jensen)

ចូរកំណត់គ្រប់អនុគមន៍ជាប់ $f:\mathbb{R}\to\mathbb{R}$ ដែលចំពោះគ្រប់ចំនួនពិត $x,y$

$$f\left(\frac{x+y}{2}\right)=\frac{f(x)+f(y)}{2}$$

**974.** (ស៊ុយអែត ១៩៦២)

ចូរកំណត់គ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែលចំពោះគ្រប់ចំនួនពិត $x$ និង គ្រប់ចំនួនសនិទាន $r$ គេមាន

$$|f(x)-f(r)|\le 7(x-r)^2$$

**975.** ចូរកំណត់គ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែល

(i) ចំពោះគ្រប់ចំនួនពិត $x,y$ គេមាន

$$f(x+y)+f(x-y)=2f(x)f(y)$$

(ii) $\lim_{x\to\infty} f(x)=0$

**976.** ចូរបង្ហាញថា អនុគមន៍ $f:\mathbb{Z}\to\mathbb{Z}$ ជាអនុគមន៍អាភីន បើចំពោះគ្រប់ចំនួនគត់ $n$ គេមាន

$$f(n+1)-f(n)=f(n)-f(n-1)$$

និងច្រាសមកវិញ ។

**977.** (អន្តរជាតិ សតលីស ១៩៨៨)

ចូរកំណត់គ្រប់អនុគមន៍ $f:\mathbb{N}^*\to\mathbb{N}^*$ ដែលចំពោះគ្រប់ $m,n\in\mathbb{N}^*$ :

$$f\big(f(n)+f(m)\big)=n+m$$

**978.** (Putnam 1963)

ចូរកំណត់អនុគមន៍ $f:\mathbb{N}\to\mathbb{N}$ កើនដាច់ខាត ដែល $f(2)=2$ និងចំពោះគ្រប់ចំនួនគត់ $m,n$ ដែលបឋមនឹងគ្នា

$$f(mn)=f(m)f(n)$$

**979.** (រ៉ូម៉ានី ១៩៨៦)

តាង $f:\mathbb{N}\to\mathbb{N}$ ជាអនុវត្តន៍ពេញ និង $g:\mathbb{N}\to\mathbb{N}$ ជាអនុវត្តន៍ប្រកាន់ ដែលចំពោះគ្រប់ $n\in\mathbb{N}$ គេមាន $f(n)\ge g(n)$ ។ ចូរបង្ហាញថា $f\equiv g$ ។

**980.** តាង $f:\mathbb{N}\to\mathbb{N}$ ជាអនុវត្តន៍មួយទល់មួយ ។ ចូរបង្ហាញថាមានចំនួនគត់ធម្មជាតិចំនួនបី $a,b,c$ ដែល $a<b<c$ និង $f(a)+f(c)=2f(b)$ ។

**981.** (ប៊ុលការី ១៩៩៧)

ចូរកំណត់គ្រប់អនុគមន៍ជាប់ $f:\mathbb{R}\longrightarrow\mathbb{R}$ ដែលចំពោះគ្រប់ចំនួនពិត $x$

$$f(x)=f\left(x^2+\frac{1}{4}\right)$$

**982.** ចូរកំណត់អនុគមន៍ f: ℝ → ℝ ដែលចំពោះគ្រប់ចំនួនពិត x

$$f(x^3+x)\le x\le f^3(x)+f(x)$$

**983.** តាង $f:\mathbb{R}\to\mathbb{R}$ ជាអនុគមន៍ជាប់ ដែលចំពោះគ្រប់ចំនួនពិត $x,y$ ៖

$$f(x+y)f(x-y)=[f(x)]^2$$

ចូរបង្ហាញថា $f\equiv 0$ ឬមិនអ៊ីចឹងទេ $f$ មិនមានតម្លៃសូន្យ ។

**984.** (អន្តរជាតិ សតលីស ១៩៩៦)

តាង $f:\mathbb{R}\to\mathbb{R}$ ដែលចំពោះគ្រប់ចំនួនពិត $x$ គេមាន $|f(x)|\le 1$ និង

$$f\left(x+\frac{13}{42}\right)+f(x)=f\left(x+\frac{1}{6}\right)+f\left(x+\frac{1}{7}\right)$$

ចូរបង្ហាញថា $f$ ជាអនុគមន៍ខួប ។

**985.** (អន្តរជាតិ ឡុងលីស 1989)

តាង f: ℕ → ℕ ជាអនុគមន៍ដែលផ្ទៀងផ្ទាត់

(i) $f$ ជាអនុគមន៍កើនដាច់ខាត

(ii) $f(mn)=f(m)f(n)$ ចំពោះគ្រប់ $m,n\in\mathbb{N}$

(iii) បើ m ≠ n ផ្ទៀងផ្ទាត់ $m^n=n^m$ នោះ $f(m)=n$ ឬ $f(n)=m$

គណនា $f(30), f\left(30^{30^{30^{30}}}\right)$

**986.** (ភ្នំពេញ ២០១០)

តាង $f:\mathbb{R}\longrightarrow\mathbb{R}$ ជាអនុគមន៍ ដែល $f(0)=1$ និង

$$\forall x,y\in\mathbb{R}, f(xy+1)=f(x)f(y)-f(y)-x+2$$

គណនា $f(2010)$ ។

**987.** (ភ្នំពេញ ២០១០)

គេឱ្យអនុគមន៍ $f$ ដោយ $f:\mathbb{N}\times\mathbb{N}\longrightarrow\mathbb{Z}$ ផ្ទៀងផ្ទាត់ទំនាក់ទំនងខាងក្រោម

$$\begin{cases} f(1,1) = 2 \\ f(m+1,n) = f(m,n) + m \ ; \ \forall m,n \in \mathbb{N} \\ f(m,n+1) = f(m,n) - n \end{cases}$$

ចូរកំណត់គ្រប់ចំនួនគត់វិជ្ជមាន $(a,b)$ ដែល $f(a,b) = 2013$ ។

**988.** (អន្តរជាតិ ១៩៨១; កម្ពុជា ២០០៩)

អនុគមន៍ $f(x;y)$ មួយផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងបីខាងក្រោមចំពោះគ្រប់ចំនួនគត់មិនអវិជ្ជមាន $x$ និង :

(i) $f(0;y) = 1 + y$

(ii) $f(x+1;0) = f(x;1)$

(iii) $f(x+1;y+1) = f\big(x; f(x+1;y)\big)$

ក. គណនា $f(1;n)$, $f(2;n)$ និង $f(3;n)$ ជាអនុគមន៍នៃ $n$

ខ. គណនា $f(4;2009)$

**989.** (អាយឡិន្ត ១៩៩៩)

តាង $f: \mathbb{N}^* \to \mathbb{N}^*$ ដែល

(i) ចំពោះគ្រប់ចំនួនគត់ $a$ និង $b$ ដែលបឋមរវាងគ្នា គេមាន

$$f(ab) = f(a)f(b)$$

(ii) ចំពោះគ្រប់ចំនួនបឋម $p, q$ គេមាន $f(p+q) = f(p) + f(q)$

ចូរបង្ហាញថា $f(2) = 2, f(3) = 3$ និង $f(1999) = 1999$ ។

**990.** (អន្តរជាតិ សតលីស ២០០៩)

តាង $f$ ជាអនុវត្តន៍ពីសំណុំចំនួនគត់វិជ្ជមានទៅសំណុំចំនួនគត់វិជ្ជមាន ដែលផ្ទៀងផ្ទាត់គ្រប់ $x$ និង $y$ គេមានត្រីកោណមិនសូន្យដែលមានរង្វាស់ជ្រុង $x, f(y), f(y+f(x)-1)$ ។

១) ចូរបង្ហាញថា $f(1) = 1$ ។

២) ចូរបង្ហាញថា $f\big(f(z)\big) = z$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $z$ ។

៣) តាង $w \geq z \geq 2$ និង $M = \max\{f(1), f(2), \dots, f(w)\}$ ។ ចូរបង្ហាញថា ចំពោះគ្រប់ $t \geq 1$ គេមាន

$$f(t) \leq \frac{z-1}{w}t + M$$

៤) ចូរបង្ហាញថា $f(z) \leq z$ ចំពោះគ្រប់ $z \geq 1$ ។

៥) ចូរកំណត់ $f(z)$ ជាអនុគមន៍នៃ $z$ ។

**991.** (អន្តរជាតិ ឡុងលីស ១៩៨៧)

តាង $f: \mathbb{R}^{+*} \to \mathbb{R}$ ជាអនុគមន៍មួយដែល ចំពោះគ្រប់ចំនួនពិត $x > 0$ គេមាន $f(x) = f(1/x)$ ។ ចូរបង្ហាញថា មានអនុគមន៍ $u: [1; +\infty[ \to \mathbb{R}$ ដែល

$$u\left(\frac{x+\frac{1}{x}}{2}\right) = f(x)$$

ចំពោះគ្រប់ចំនួនពិត $x > 0$ ។

**992.** (កូរ៉េ ១៩៩៩)

ចូរកំណត់គ្រប់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែល ចំពោះគ្រប់ចំនួនពិត $x \neq \pm 1$ :

$$f\left(\frac{x-3}{x+1}\right) + f\left(\frac{3+x}{1-x}\right) = x$$

**993.** (អន្តរជាតិ ១៩៨២)

តាង $f: \mathbb{N}^* \to \mathbb{N}$ ជាអនុគមន៍ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម ៖

(i) ចំពោះគ្រប់ចំនួនគត់ $m, n > 0$ គេមាន

$$f(m+n) - f(m) - f(n) \in \{0,1\}$$

(ii) $f(2) = 0; f(3) > 0$ និង $f(9\,999) = 3\,333$

គណនា $f(1982)$ ។

**994.** (អន្តរជាតិ សតលីស ១៩៩១)

គេមានអនុគមន៍ $f: \mathbb{Z} \to \mathbb{Z}$ និង $g: \mathbb{Z} \to \mathbb{Z}$ ដែល ៖

(i) $f\Big(m + f\big(f(n)\big)\Big) = -f\big(f(m+1)\big) - n$ ចំពោះគ្រប់ចំនួនគត់ $m, n$

(ii) $g$ ជាអនុគមន៍ពហុធា មានមេគុណជាចំនួនគត់ និង $g(n) = g\big(f(n)\big)$

ចំពោះគ្រប់ចំនួនគត់ $n$ ។

គណនា $f(1991)$ និង កំណត់រាងទូទៅរបស់ $g$ ។

**995.** (អ៊ីរ៉ង់ ១៩៩៩)

ចូរកំណត់គ្រប់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលចំពោះគ្រប់ចំនួនពិត $x, y$

$$f(f(x) + y) = f(x^2 - y) + 4yf(x)$$

**996.** (អន្តរជាតិ ១៩៩២)

ចូរកំណត់គ្រប់អនុគមន៍ $f: \mathbb{R} \to \mathbb{R}$ ដែលចំពោះគ្រប់ចំនួនពិត $x, y$ គេមាន

$$f\big(x^2 + f(y)\big) = y + \big(f(x)\big)^2$$

**997.** (ស្វីស ១៩៩៩)

ចូរកំណត់គ្រប់អនុគមន៍ $f: \mathbb{R} \to \mathbb{R}^*$ ដែលចំពោះគ្រប់ចំនួនពិតមិនសូន្យ $x$

$$\frac{1}{x} f(-x) + f\left(\frac{1}{x}\right) = x$$

**998.** (វៀតណាម ១៩៩៩)

តាង $f: [0,1] \to \mathbb{R}$ ជាអនុគមន៍ជាប់ ដែលផ្ទៀងផ្ទាត់

(i) $f(0) = f(1) = 0$

(ii) $\forall x, y \in [0,1]; \quad 2f(x) + f(y) = 3f\left(\frac{2x+y}{3}\right)$

ចូរបង្ហាញថា $f(x) = 0$ ចំពោះគ្រប់ $x \in [0,1]$ ។

**999.** (អូទ្រីស-ប៉ូឡូញ ១៩៩៧)

ចូរបង្ហាញថា គ្មានអនុគមន៍ $f: \mathbb{Z} \to \mathbb{Z}$ ដែល ចំពោះគ្រប់ចំនួនគត់ $x, y$

$$f\big(x + f(y)\big) = f(x) - y$$

**1000.** (អន្តរជាតិ ១៩៨៦)

ចូរកំណត់គ្រប់អនុគមន៍ $f$ អនុវត្តន៍ពីសំណុំចំនួនពិតមិនអវិជ្ជមាន ទៅសំណុំចំនួនពិតមិនអវិជ្ជមាន ដែល

(i) $f\big(xf(y)\big)\, f(y) = f(x + y)$

(ii) $f(2) = 0$ តែ $f(x) \neq 0$ ចំពោះ $0 \leq x < 2$

**1001.** (អន្តរជាតិ សតលីស ១៩៨៧)

តាង $f$ ជាអនុគមន៍មួយដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

(i) បើ $x > y$ និង $f(y) - y \geq v \geq f(x) - x$ នោះ $f(z) = v + z$ ចំពោះចំនួនពិតខ្លះឋិតនៅចន្លោះ $x$ និង $y$ ។

(ii) សមីការ $f(x)=0$ មានឫសយ៉ាងតិចមួយ ហើយក្នុងចំណោមឫសនៃសមីការនេះ មានឫសមួយដែលមិនតូចជាងឫសណាមួយផ្សេងទៀត ។

(iii) $f(0)=1$

(iv) $f(1987)\leq 1988$

(v) $f(x)f(y)=f(xf(y)+yf(x)-xy)$

គណនា $f(1987)$ ។

**1002.** (អន្តរជាតិ ១៩៨៧)

តើមានអនុគមន៍ $f:\mathbb{N}^*\to\mathbb{N}^*$ ដែល $f\big(f(n)\big)=n+1987$ ចំពោះគ្រប់ចំនួនគត់ $n>0$ ដែរឬទេ?

**1003.** (ក្រូអាត ១៩៩៦)

គេឱ្យ $t\in(0,1)$ ។ ចូរកំណត់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែលជាប់ត្រង់ 0 និងដែលចំពោះគ្រប់ចំនួនពិត $x$ :

$$f(x)-2f(tx)+f(t^2x)=x^2$$

**1004.** (អន្តរជាតិ សតលីស ១៩៩២)

គេឱ្យចំនួនពិត $a,b>0$ ។ ចូរបង្ហាញថា មានអនុគមន៍ $f:\mathbb{R}^+\to\mathbb{R}^+$ តែមួយគត់ ដែលចំពោះគ្រប់ចំនួនពិត $x\geq 0$

$$f\big(f(x)\big)+af(x)=b(a+b)x$$

**1005.** ចូរកំណត់គ្រប់អនុគមន៍ $f:[0,1]\to[0,1]$ ដែលចំពោះគ្រប់ចំនួនពិត $x\in[0,1]$ គេមាន

$$f\big(2x-f(x)\big)=x$$

**1006.** (អន្តរជាតិ ១៩៨៣)

ចូរកំណត់គ្រប់អនុគមន៍ $f:\mathbb{R}^{+*}\to\mathbb{R}^{+*}$ ដែលផ្ទៀងផ្ទាត់

(i) ចំពោះគ្រប់ចំនួនពិត $x,y$ : $f\big(xf(y)\big)=yf(x)$

(ii) $\lim_{x\to+\infty}f(x)=0$

**1007.** (ភ្នំពេញ ២០១១)

រកអនុគមន៍ $f:\mathbb{R}-\{2/3\}\to\mathbb{R}$ ដែលបំពេញសមីការអនុគមន៍ខាងក្រោម ៖

$$\frac{1}{2}f\left(\frac{2x}{3x-2}\right)+f(x)=503x$$

**1008.** តាង $I$ ជាចន្លោះ $\left[-\frac{\pi}{4},\frac{\pi}{4}\right]$ ។ ចូរកំណត់អនុគមន៍ $f$ កំណត់លើ $[-1,1]$ ដែល $f(\sin 2x)=\sin x+\cos x$ ។ ចូរសម្រួល $f(\tan^2 x)$ ចំពោះ $x\in I$ ។

# ២

# អនុគមន៍ងាយ

## ២.១ គណនា

**1.** ▲ យើងមាន

$$\begin{aligned}
&a^2+b^2+c^2=1 \Rightarrow a^2+b^2=1-c^2\\
&a+b+c=0 \Leftrightarrow a+b=-c\\
&\qquad\Rightarrow (a+b)^2=c^2 \Leftrightarrow a^2+b^2+2ab=c^2;\\
&\qquad\Rightarrow 1-c^2+2ab=c^2 \Rightarrow ab=\frac{2c^2-1}{2}\\
a^4+b^4+c^4&=(a^2+b^2)^2+c^4-2(ab)^2\\
&=(1-c^2)^2+c^4-2\left(\frac{2c^2-1}{2}\right)^2\\
&=c^4-2c^2+1-2c^4+2c^2-\frac{1}{2}=\frac{1}{2}
\end{aligned}$$

**2.** $n(n+1)(n+2)/6$

**3.** $(n(n+1)/2)^2$▲ យើងមាន

$$\begin{aligned}
(1+1)^4&=2^4=1^4+4.1^3.1+6.1^2.1^2+4.1.1^3+1^4\\
(2+1)^4&=3^4=2^4+4.2^3.1+6.2^2.1^2+4.2.1^3+1^4\\
&\dots\\
(n+1)^4&=n^4+4.n^3.1+6.n^2.1^2+4.n.1^3+1^4
\end{aligned}$$

បូកសមភាពទាំងអស់នេះចូលគ្នា យើងទាញបានផលបូកដែលចង់បាន ។

**4.** ▲ គុណ $S$ នឹង $(2-1)$ យើងទាញបាន

$$\begin{aligned}
S&=(2-1)(2+1)(2^2+1)(2^4+1)\dots(2^{1024}+1)+1\\
&=(2^2-1)(2^2+1)(2^4+1)\dots(2^{1024}+1)+1
\end{aligned}$$

$$= (2^4-1)(2^4+1)\dots(2^{1024}+1)+1$$

$$\vdots$$

$$= (2^{1024}-1)(2^{1024}+1)+1$$

$$= 2^{2048}-1+1 = 2^{2048}$$

ដូច្នេះ $S^{1/1024} = 4$ ។

**5.** ▲ យើងមាន $k.k! = (k+1)! - k!$ ចំពោះ $k = 1,2,3\dots$ ។ ដូច្នេះ

$$1.1! + 2.2! + 3.3! + \cdots + (n-1).(n-1)! + n.n!$$
$$= (2!-1!) + (3!-2!) + (4!-3!) + \cdots + (n! - (n-1)!) + \big((n+1)! - n!\big)$$
$$= (n+1)! - 1$$

**6.** ▲ យើងមាន

$$S.2000! = \binom{2000}{1} + \binom{2000}{3} + \cdots + \binom{2000}{1997} + \binom{2000}{1999}$$
$$= \frac{1}{2}\sum_{i=1}^{2000}\binom{2000}{i} = \frac{1}{2}(1+1)^{2000} = 2^{1999}$$
$$S = \frac{2^{1999}}{2000!}$$

**7.** ▲(a) ដោយប្រើសមភាព

$$\frac{1}{k(k-1)} = \frac{1}{k} - \frac{1}{k+1}$$

យើងទទួលបាន

$$\frac{1}{1.2} = 1 - \frac{1}{2},$$
$$\frac{1}{2.3} = \frac{1}{2} - \frac{1}{3},$$
$$\frac{1}{3.4} = \frac{1}{3} - \frac{1}{4},$$
$$\vdots$$
$$\frac{1}{(n-1)n} = \frac{1}{n-1} - \frac{1}{n}$$

បូកសមភាពទាំងនេះ បញ្ចូលគ្នា យើងទាញបាន

$$\frac{1}{1.2} + \frac{1}{2.3} + \cdots + \frac{1}{(n-1)n} = 1 - \frac{1}{n}$$

(b) ដោយប្រើសមភាព

$$\frac{1}{k(k+1)(k+2)}=\frac{1}{2}\left[\frac{1}{k(k+1)}-\frac{1}{(k+1)(k+2)}\right]$$

យើងទាញបាន

$$\frac{1}{1.2.3}=\frac{1}{2}\left(\frac{1}{1.2}-\frac{1}{2.3}\right),$$
$$\frac{1}{2.3.4}=\frac{1}{2}\left(\frac{1}{2.3}-\frac{1}{3.4}\right),$$
$$\frac{1}{3.4.5}=\frac{1}{2}\left(\frac{1}{3.4}-\frac{1}{4.5}\right),$$
$$\cdots$$
$$\frac{1}{(n-2).(n-1).n}=\frac{1}{2}\left(\frac{1}{(n-2).(n-1)}-\frac{1}{(n-1).n}\right),$$

បូកសមភាពទាំងនេះបញ្ចូលគ្នា យើងទទួលបាន

$$\frac{1}{1.2.3}+\frac{1}{2.3.4}+\frac{1}{3.4.5}+\cdots+\frac{1}{(n-2)(n-1)n}=\frac{1}{2}\left[\frac{1}{2}-\frac{1}{(n-1)n}\right]$$

(c) ដោយប្រើសមភាព

$$\frac{1}{k(k+1)(k+2)(k+3)}=\frac{1}{3}\left[\frac{1}{k(k+1)(k+2)}-\frac{1}{(k+1)(k+2)(k+3)}\right]$$

យើងទាញបាន

$$\frac{1}{1.2.3.4}=\frac{1}{3}\left(\frac{1}{1.2.3}-\frac{1}{2.3.4}\right),$$
$$\frac{1}{2.3.4.5}=\frac{1}{3}\left(\frac{1}{2.3.4}-\frac{1}{3.4.5}\right),$$
$$\frac{1}{3.4.5.6}=\frac{1}{3}\left(\frac{1}{3.4.5}-\frac{1}{4.5.6}\right),$$
$$\cdots$$
$$\frac{1}{(n-3)(n-2)(n-1)n}=\frac{1}{3}\left[\frac{1}{(n-3)(n-2)(n-1)}-\frac{1}{(n-2)(n-1)n}\right]$$

បូកសមភាពទាំងនេះបញ្ចូលគ្នា យើងទទួលបាន

$$\frac{1}{1.2.3.4}+\frac{1}{2.3.4.5}+\frac{1}{3.4.5.6}+\cdots+\frac{1}{(n-3)(n-2)(n-1)n}$$
$$=\frac{1}{3}\left[\frac{1}{6}-\frac{1}{(n-2)(n-1)n}\right]$$

**8.** ▲យើងមាន

$$S=\frac{1}{2^1}-\frac{2}{2^2}+\frac{3}{2^3}-\frac{4}{2^4}+\cdots-\frac{2010}{2^{2010}}+\frac{2011}{2^{2011}}$$

$$\frac{1}{2}S = \frac{1}{2^2} - \frac{2}{2^3} + \frac{3}{2^4} - \frac{4}{2^5} + \cdots - \frac{2010}{2^{2011}} + \frac{2011}{2^{2012}}$$

$$\Rightarrow S + \frac{1}{2}S = \frac{1}{2} - \frac{1}{2^2} + \frac{1}{2^3} - \frac{1}{2^4} + \cdots - \frac{1}{2^{2010}} + \frac{1}{2^{2011}} + \frac{2011}{2^{2012}}$$

$$= \frac{1}{2^2} + \frac{1}{2^4} + \cdots + \frac{1}{2^{2010}} + \frac{1}{2^{2012}} + \frac{2012}{2^{2012}}$$

$$= \frac{1}{2^2}\left(1 + \frac{1}{2^2} + \frac{1}{2^4} + \cdots + \frac{1}{2^{2010}}\right) + \frac{2012}{2^{2012}}$$

$$= \frac{1}{2^2}\frac{1 - \left(\frac{1}{2^2}\right)^{1006}}{1 - \frac{1}{2^2}} + \frac{2012}{2^{2012}}$$

$$= \frac{1}{3}\left(1 - \frac{1}{2^{2012}}\right) + \frac{2012}{2^{2012}}$$

$$= \frac{2^{2012} + 6035}{3.2^{2012}}$$

$$\Rightarrow S = \frac{2^{2012} + 6035}{9.2^{2011}}$$

**9.** ▲ សន្មតថា $u, v, s, t$ ជាឫសបួននៃពហុធា

$$f(x) = x^4 - ax^3 + bx^2 - cx + d$$

តាមទ្រឹស្តីបទវៀែត យើងទាញបាន

$$u + v + s + t = a; uv + vs + st + tu + us + vt = b; uvs + vst + stu = c, uvst = d$$

ដោយ $u + v + s + t = 0$ នោះ $a = 0$ ។ ដូច្នេះ $f(x) = x^4 + bx^2 - cx + d$ ។

តាង

$$S_n = u^n + v^n + s^n + t^n$$

យើងមាន

$$S_1 = u + v + s + t = 0;$$
$$S_2 = u^2 + v^2 + s^2 + t^2 = (u + v + s + t)^2 - 2(uv + vs + st + tu + us + vt) = -2b$$

ដើម្បីគណនា $S_3$ យើងពិនិត្យករណី២ខាងក្រោម ។

- ករណី $u, v, s, t$ សុទ្ធតែខុសពីសូន្យទាំងអស់ ។ ដូច្នេះ

$$u^3 + bu - c + \frac{d}{u} = 0; \;\; v^3 + bv - c + \frac{d}{v} = 0$$

$$s^3+bs-c+\frac{d}{s}=0;\ t^3+bt-c+\frac{d}{t}=0$$
$$\Longrightarrow\quad S_3+bS_1-4c+d\left(\frac{1}{u}+\frac{1}{v}+\frac{1}{s}+\frac{1}{t}\right)=0$$
$$\Longrightarrow\quad S_3-4c+d\frac{c}{d}=0$$
$$\Longrightarrow\quad S_3=3c$$

- ករណីក្នុងចំណោម $u,v,s,t$ មានមួយស្មើសូន្យ ។ សន្មតថាជា $u$ ។ ដូច្នេះ $d=0$ ហើយ

$$f(x)=x^4+bx^2-cx=x(x^3+bx-c)$$

ដូច្នេះ $v,s,t$ ជាឫសនៃសមីការ $x^3+bx-c=0$ ។ ដូច្នេះ

$$v^3+bv-c=0;s^3+bs-c=0;t^3+bt-c=0$$
$$\Longrightarrow S_3+b(u+v+s+t)-3c=0;$$
$$\Longrightarrow S_3=3c$$

ក្នុងករណីទាំងពីរ យើងមាន $S_3=3c$ ។

យើងមាន

$$u^4+bu^2-cu+d=0;v^4+bv^2-cv+d=0;$$
$$s^4+bs^2-cs+d=0;t^4+bt^2-ct+d=0$$
$$\Longrightarrow S_4+bS_2-cS_1+d=0$$
$$\Longrightarrow S_4=2b^2-4d$$

យើងមាន $x^4+bx^2-cx+d=0$ ដោយគុណអង្គទាំងពីរនឹង $x^n$ យើងទាញបាន

$$x^{n+4}+bx^{n+2}-cx^{n+1}+dx^n=0$$
$$\Longrightarrow\quad S_{n+4}+bS_{n+2}-cS_{n+1}+dS_n=0$$

យើងទាញបាន

$$S_5=-bS_3+cS_2+dS_1=-5bc$$
$$S_7=-bS_5+cS_4-dS_3=7c(b^2-d)$$

ដោយ $S_7=0$ នោះ $c=0$ ឬ $b^2=d$ ។

- ករណី $b^2=d$ យើងទាញបាន

$$0\le S_4=2b^2-4d=-2b^2\le 0\ \Longrightarrow b=0\ \Longrightarrow d=0$$
$$\Longrightarrow S_4=0\ \Longrightarrow u=v=s=t=0\ \Longrightarrow P=0$$

- ករណី $c=0$ នោះ $u,v,s,t$ ជាឫសទាំងបួននៃសមីការ $x^4+bx^2+d=0$

  ដូច្នេះវាត្រូវតែ $t=-u$ ឬ $t=-v$ ឬ $t=-s$ ។ ដូច្នេះ $P=0$ ។

**10.** ▲ តាង

$$S=\sqrt{a+b+c+2\sqrt{ac+bc}}+\sqrt{a+b+c-2\sqrt{ac+bc}}$$
$$A=a+b+c$$
$$B=4ac+4bc$$
$$\begin{aligned}A^2-B&=(a+b+c)^2-4ac-4bc\\&=a^2+b^2+c^2+2ab-2bc-2ac\\&=(a+b-c)^2\end{aligned}$$
$$S^2=2(a+b+c)+2\sqrt{A^2-B}$$

បើ $a+b-c>0$ នោះ $\sqrt{A^2-B}=a+b-c$ និង

$$S^2=2(a+b+c)+2(a+b-c)=4(a+b)$$
$$\Longrightarrow S=2\sqrt{a+b}$$

បើ $a+b-c<0$ នោះ $\sqrt{A^2-B}=c-a-b$ និង

$$S^2=2(a+b+c)+2(-a-b+c)=4c$$
$$\Longrightarrow S=2\sqrt{c}$$

បើ $a+b=c$ នោះ $S=2\sqrt{a+b}=2\sqrt{c}$ ។

**11.** ▲ យើងមាន

$$x=a^{-1}\left(2\frac{a}{b}-1\right)^{\frac{1}{2}}\ \Longrightarrow ax=\sqrt{\frac{2a-b}{b}}$$

ដូច្នេះ

$$\begin{aligned}\frac{1-ax}{1+ax}=\frac{1-\sqrt{\frac{2a-b}{b}}}{1+\sqrt{\frac{2a-b}{b}}}&=\frac{\left(1-\sqrt{\frac{2a-b}{b}}\right)^2}{1-\frac{2a-b}{b}}\\&=\frac{b}{2(b-a)}\left(1-2\sqrt{\frac{2a-b}{b}}+\frac{2a-b}{b}\right)\\&=\frac{a-b\sqrt{\frac{2a-b}{b}}}{b-a}\end{aligned}$$

និង

$$\sqrt{\frac{1+bx}{1-bx}}=\sqrt{\frac{1+\frac{b}{a}\sqrt{\frac{2a-b}{b}}}{1-\frac{b}{a}\sqrt{\frac{2a-b}{b}}}}=\frac{1+\frac{b}{a}\sqrt{\frac{2a-b}{b}}}{\sqrt{1-\frac{b^2}{a^2}.\frac{2a-b}{b}}}$$

$$=\frac{a+b\sqrt{\frac{2a-b}{b}}}{\sqrt{a^2-2ab+b^2}}=\frac{a+b\sqrt{\frac{2a-b}{b}}}{\sqrt{(b-a)^2}}$$

$$=\frac{a+b\sqrt{\frac{2a-b}{b}}}{b-a}$$

(ព្រោះ $b-a>0$) ។ ដូច្នេះ

$$\frac{1-ax}{1+ax}.\sqrt{\frac{1+bx}{1-bx}}=\frac{a-b\sqrt{\frac{2a-b}{b}}}{b-a}.\frac{a+b\sqrt{\frac{2a-b}{b}}}{b-a}$$

$$=\frac{a^2-b^2\frac{2a-b}{b}}{(b-a)^2}=\frac{a^2-2ab+b^2}{(b-a)^2}=1$$

**12.** ▲ ក) យើងមាន

$$\begin{aligned}A&=2011^3-2010.2011^2-2010^2.2011+2010^3\\&=2011^2(2011-2010)+2010^2(2010-2011)\\&=2011^2-2010^2\\&=(2011-2010)(2011+2010)\\&=4021\end{aligned}$$

ខ) យើងមាន

$$\begin{aligned}B&=403^5-402^2(403^3+2.403^2+3.403+4)\\&=403^5-(403-1)^2(403^3+2.403^2+3.403+4)\\&=403^5-(403^2-2.403+1)(403^3+2.403^2+3.403+4)\\&=403^5-(403^5+2.403^4+3.403^3+4.403^2-2.403^4-4.403^3-6.403^2\\&\qquad-8.403+403^3+2.403^2+3.403+4)\\&=-(-5.403+4)\\&=2011\end{aligned}$$

**13.▲** យើងមាន

$$\frac{b-c}{a}+\frac{c-a}{b}+\frac{a-b}{c}=\frac{b^2c-bc^2+ac^2-a^2c+a^2b-ab^2}{abc}$$
$$=\frac{c^2(a-b)+ab(a-b)-(ac+bc)(a-b)}{abc}$$
$$=\frac{(a-b)(c^2+ab-ac-bc)}{abc}$$
$$=\frac{(a-b)[c(c-a)-b(c-a)]}{abc}=\frac{(a-b)(c-b)(c-a)}{abc}$$
$$=-\frac{(a-b)(b-c)(c-a)}{abc}\quad(*)$$

តាង $a'=b-c, b'=c-a$ និង $c'=a-b$ ។ ដូច្នេះ

$$b'-c'=c-a-(a-b)=b+c-2a$$

តាមលក្ខខណ្ឌ $a+b+c=0$ យើងទាញបាន $b'-c'=-3a$ ។ ដូច្នេះ

$$a=-\frac{b'-c'}{3}$$

ដូចគ្នា យើងទាញបាន

$$b=-\frac{c'-a'}{3}$$
$$c=-\frac{a'-b'}{3}$$

ដូច្នេះ

$$\frac{a}{b-c}+\frac{b}{c-a}+\frac{c}{a-b}=-\frac{1}{3}\left(\frac{b'-c'}{a'}+\frac{c'-a'}{b'}+\frac{a'-b'}{c'}\right)$$

តាម (*) យើងទាញបាន

$$\frac{a}{b-c}+\frac{b}{c-a}+\frac{c}{a-b}=-\frac{1}{3}\left[-\frac{(a'-b')(b'-c')(c'-a')}{a'b'c'}\right]$$
$$=\frac{1}{3}\frac{(-3c)(-3a)(-3b)}{(b-c)(c-a)(a-b)}=-9\frac{abc}{(a-b)(b-c)(c-a)}$$

ដូច្នេះ យើងទាញបានថា បើ $a+b+c=0$ នោះ

$$\left(\frac{b-c}{a}+\frac{c-a}{b}+\frac{a-b}{c}\right)\left(\frac{a}{b-c}+\frac{b}{c-a}+\frac{c}{a-b}\right)=9$$

**14.▲** តាង

$$P=\left(1+\frac{1}{3}\right)\left(1+\frac{1}{9}\right)\left(1+\frac{1}{81}\right)\left(1+\frac{1}{3^8}\right)\dots\left(1+\frac{1}{3^{2^n}}\right)$$

គុណ $P$ នឹង $\left(1-\frac{1}{3}\right)$ យើងទទួលបាន

$$\begin{aligned}P\left(1-\frac{1}{3}\right) &= \left[\left(1-\frac{1}{3}\right)\left(1+\frac{1}{3}\right)\right]\left(1+\frac{1}{9}\right)\left(1+\frac{1}{81}\right)\left(1+\frac{1}{3^8}\right)\dots\left(1+\frac{1}{3^{2^n}}\right)\\ &= \left[\left(1-\frac{1}{9}\right)\left(1+\frac{1}{9}\right)\right]\left(1+\frac{1}{81}\right)\left(1+\frac{1}{3^8}\right)\dots\left(1+\frac{1}{3^{2^n}}\right)\\ &= \left[\left(1-\frac{1}{81}\right)\left(1+\frac{1}{81}\right)\right]\left(1+\frac{1}{3^8}\right)\dots\left(1+\frac{1}{3^{2^n}}\right)=\cdots\\ &= \left(1-\frac{1}{3^{2^n}}\right)\left(1+\frac{1}{3^{2^n}}\right)=1-\frac{1}{3^{2^{n+1}}}\end{aligned}$$

ដូច្នេះ

$$P=\frac{3}{2}\left(1-\frac{1}{3^{2^{n+1}}}\right)$$

**15.** ▲ យើងមាន

$$\begin{aligned}k &= \frac{x^2+y^2}{x^2-y^2}+\frac{x^2-y^2}{x^2+y^2}\\ &= \frac{2x^4+2y^4}{x^4-y^4}\\ \Rightarrow \frac{k}{2} &= \frac{x^4+y^4}{x^4-y^4}\\ \Rightarrow \frac{k}{2}+\frac{2}{k} &= \frac{x^4+y^4}{x^4-y^4}+\frac{x^4-y^4}{x^4+y^4}\\ &= 2\frac{x^8+y^8}{x^8-y^8}\\ \Rightarrow \frac{x^8+y^8}{x^8-y^8} &= \frac{k}{4}+\frac{1}{k}=\frac{k^2+4}{4k}\\ \Rightarrow \frac{x^8+y^8}{x^8-y^8}-\frac{x^8-y^8}{x^8+y^8} &= \frac{k^2+4}{4k}-\frac{4k}{k^2+4}\\ &= \frac{k^4+8k^2+16-16k^2}{4k(k^2+4)}\\ &= \frac{k^4-8k^2+16}{4k(k^2+4)}\\ &= \frac{(k^2-4)^2}{4k(k^2+4)}\end{aligned}$$

**16.** ▲ តាង $t_k=1/u_k$ ។ ដូច្នេះ $t_0=1/3$ និង

$$\begin{aligned}&\left(3-\frac{1}{t_{n+1}}\right)\left(6+\frac{1}{t_n}\right)=18 \iff \frac{3}{t_n}-\frac{6}{t_{n+1}}-\frac{1}{t_nt_{n+1}}=0\\ &\iff 3t_{n+1}-6t_n-1=0 \quad (*)\end{aligned}$$

$$\Leftrightarrow t_{n+1} = 2t_n + \frac{1}{3}$$

ដូច្នេះ

$$\begin{aligned} t_1 &= 2t_0 + \frac{1}{3} \quad \times 2^{n-1} \\ t_2 &= 2t_1 + \frac{1}{3} \quad \times 2^{n-2} \\ &\dots \\ t_{n-2} &= 2t_{n-3} + \frac{1}{3} \quad \times 2^2 \\ t_{n-1} &= 2t_{n-2} + \frac{1}{3} \quad \times 2^1 \\ t_n &= 2t_{n-1} + \frac{1}{3} \quad \times 2^0 \end{aligned}$$

គុណសមភាពទី១ ទី២ .... ទី $(n-2)$ ទី $(n-1)$ និង ទី $n$ នឹង $2^{n-1}, 2^{n-2}, \dots, 2^2, 2^1, 2^0$ រួចបូកសមភាពទទួលបានបញ្ចូលគ្នា យើងទទួលបាន

$$\begin{aligned} t_n &= 2^n t_0 + \frac{1}{3}(1 + 2 + 2^2 + \dots + 2^{n-1}) \\ &= \frac{1}{3}.2^n + \frac{1}{3}(1 + 2 + 2^2 + \dots + 2^{n-1}) \\ &= \frac{1}{3}(1 + 2 + 2^2 + \dots + 2^{n-1} + 2^n) \\ &= \frac{1}{3}\frac{2^{n+1} - 1}{2 - 1} = \frac{1}{3}(2^{n+1} - 1) \end{aligned}$$

ម្យ៉ាងវិញទៀត តាមសមភាព (*) ដោយ យក $n = 0,1,2,\dots$ យើងទទួលបាន

$$\begin{aligned} 3(t_1 - t_0) &= 3t_0 + 1 \\ 3(t_2 - t_1) &= 3t_1 + 1 \\ 3(t_3 - t_2) &= 3t_2 + 1 \\ &\dots \\ 3(t_{n+1} - t_n) &= 3t_n + 1 \end{aligned}$$

បូកសមភាពទាំងនេះបញ្ចូលគ្នា យើងទទួលបាន

$$3S_n + n + 1 = 3(t_{n+1} - t_0)$$
$$\Rightarrow S_n = \frac{2^{n+2} - n - 3}{3}$$

ដែល

$$S_n = t_0 + t_1 + t_2 + \dots + t_n = \sum_{k=0}^{n} \frac{1}{u_k}$$

យក $n = 2011$ យើងទទួលបាន

$$\sum_{k=0}^{2011}\frac{1}{u_k} = \frac{2^{2013}-2014}{3}$$

**17.** ▲ យើងមាន

$$\begin{aligned} f(n) &= \frac{4n+\sqrt{4n^2-1}}{\sqrt{2n+1}+\sqrt{2n-1}} \\ &= \frac{\sqrt{(2n+1)^2}+\sqrt{(2n-1)^2}+\sqrt{4n^2-1}}{\sqrt{2n+1}+\sqrt{2n-1}} \\ &= \frac{\left(\sqrt{2n+1}-\sqrt{2n-1}\right)\left(\sqrt{(2n+1)^2}+\sqrt{(2n-1)^2}+\sqrt{4n^2-1}\right)}{\left(\sqrt{2n+1}+\sqrt{2n-1}\right)\left(\sqrt{2n+1}-\sqrt{2n-1}\right)} \\ &= \frac{\left(\sqrt{2n+1}\right)^3-\left(\sqrt{2n-1}\right)^3}{2} \end{aligned}$$

ដូច្នេះ

$$\begin{aligned} &f(1)+f(2)+\cdots+f(40) \\ &\qquad = \frac{\left(\sqrt{3^3}-\sqrt{1^3}\right)+\left(\sqrt{5^3}-\sqrt{3^3}\right)+\cdots+\left(\sqrt{81^3}-\sqrt{79^3}\right)}{2} \\ &\qquad = \frac{\sqrt{81^3}-\sqrt{1^3}}{2} = 364 \end{aligned}$$

**18.** ▲ យើងមាន

$$\begin{aligned} f(n) &= \frac{1}{\sqrt[3]{n^2+2n+1}+\sqrt[3]{n^2-1}+\sqrt[3]{n^2-2n+1}} \\ &= \frac{1}{\left(\sqrt[3]{n+1}\right)^2+\sqrt[3]{n+1}.\sqrt[3]{n-1}+\left(\sqrt[3]{n-1}\right)^2} \\ &= \frac{\sqrt[3]{n+1}-\sqrt[3]{n-1}}{\left(\sqrt[3]{n+1}-\sqrt[3]{n-1}\right)\left(\left(\sqrt[3]{n+1}\right)^2+\sqrt[3]{n+1}.\sqrt[3]{n-1}+\left(\sqrt[3]{n-1}\right)^2\right)} \\ &= \frac{1}{2}\left(\sqrt[3]{n+1}-\sqrt[3]{n-1}\right) \end{aligned}$$

ដូច្នេះ

$$\begin{aligned} f(1) &= \frac{1}{2}\left(\sqrt[3]{2}-0\right) \\ f(3) &= \frac{1}{2}\left(\sqrt[3]{4}-\sqrt[3]{2}\right) \\ f(5) &= \frac{1}{2}\left(\sqrt[3]{6}-\sqrt[3]{4}\right) \end{aligned}$$

$$\ldots$$
$$f(10^6-3)=\frac{1}{2}\left(\sqrt[3]{10^6-2}-\sqrt[3]{10^6-4}\right)$$
$$f(10^6-1)=\frac{1}{2}\left(\sqrt[3]{10^6}-\sqrt[3]{10^6-2}\right)$$
ដូច្នេះ ដោយបូកសមភាពខាងលើបញ្ចូលគ្នា យើងទទួលបាន
$$S=\frac{1}{2}.\sqrt[3]{10^6}=50$$

# ២.២ សមភាព

**19.** ▲ ចំពោះ $n=1$ យើងទាញបាន $1^2=1.2.3/6$ ពិត ។ សន្មតថាពិតដល់ $k$ មានន័យថា $1^2+2^2+\cdots+k^2=k(k+1)(2k+1)/6$ ។ យើងទាញបាន
$$\begin{aligned}1^2+2^2+\cdots+k^2+(k+1)^2&=k(k+1)(2k+1)/6+(k+1)^2\\&=(k+1)(k+1+1)(2(k+1)+1)/6\end{aligned}$$
ដូច្នេះតាមវិចារដោយកំណើន យើងទាញបានសមមភាពពិតចំពោះគ្រប់ $n\in\mathbb{N}$ ។

**20.** ● ស្រាយបញ្ជាក់តាមកំណើន ។

**21.** ● ស្រាយបញ្ជាក់តាមកំណើន ។

**22.** ● ស្រាយបញ្ជាក់តាមកំណើន ។

**23.** ▲ តាង $a=\tan x, b=\tan y, c=\tan z$ ដែល $x,y,z\neq k\pi/4$ ចំពោះគ្រប់ចំនួនគត់ $k$ ។ លក្ខខណ្ឌ $a+b+c=abc$ ក្លាយជា $\tan(x+y+z)=0$ ។យើងមាន
$$\tan(2x+2y+2z)=\frac{2\tan(x+y+z)}{1-\tan^2(x+y+z)}=0$$
ដូច្នេះ
$$\begin{aligned}&\tan 2x+\tan 2y+\tan 2z=\tan 2x\tan 2y\tan 2z\\ \Longrightarrow\ &\frac{2\tan x}{1-\tan^2 x}+\frac{2\tan y}{1-\tan^2 y}+\frac{2\tan z}{1-\tan^2 z}\\ &=\frac{2\tan x}{1-\tan^2 x}\frac{2\tan y}{1-\tan^2 y}\frac{2\tan z}{1-\tan^2 z}\end{aligned}$$

ដូច្នេះសមភាពពិត ។

**24.** ▲ តាង $k = a_1/b_1 = a_2/b_2 = a_3/b_3$ នោះ

$$\begin{aligned} p_1a_1^n + p_2a_2^n + p_3a_3^n &= k^n(p_1b_1^n + p_2b_2^n + p_3b_3^n) \\ &= \left(\frac{a_1}{b_1}\right)^n (p_1b_1^n + p_2b_2^n + p_3b_3^n) \end{aligned}$$

នាំឱ្យសមភាពពិត ។

**25.** ▲ អង្គខាងឆ្វេងនៃសមភាពបូក 1 ស្មើនឹង

$$\begin{aligned} &[(1+a) + b(1+a)] + c(1+a)(1+b) + d(1+a)(1+b)(1+c) + \cdots \\ &\qquad + l(1+a)(1+b)\dots(1+k) \\ &= [(1+a)(1+b) + c(1+a)(1+b)] + d(1+a)(1+b)(1+c) + \cdots \\ &\qquad + l(1+a)(1+b)\dots(1+k) \\ &= [(1+a)(1+b)(1+c) + d(1+a)(1+b)(1+c)] + \cdots \\ &\qquad + l(1+a)(1+b)\dots(1+k) \\ &= \cdots = (1+a)(1+b)(1+c)\dots(1+l) \end{aligned}$$

ដូច្នេះសមភាពពិត ។

ករណី $a = b = c = \cdots = l$ យើងទាញបាន

$$a + a(1+a) + a(1+a)^2 + a(1+a)^3 + \cdots + a(1+a)^{n-1} = (1+a)^n - 1$$

ដែល $n$ ជាចំនួននៃចំនួនគត់ $a, b, c, \dots, l$ ។ តាង $1 + a = x \Rightarrow a = x - 1$ យើងទាញបាន

$$(x-1)(1 + x + x^2 + \cdots + x^{n-1}) = x^n - 1$$

**26.** ▲ យើងមាន

$$\begin{aligned} 0 &= (a+b+c)^3 \\ &= a^3 + b^3 + c^3 + 3a^2b + 3a^2c + 3b^2a + 3b^2c + 3c^2a \\ &\quad + 3c^2b + 6abc \\ &= a^3 + b^3 + c^3 + 3ab(a+b) + 3ac(a+c) + 3bc(b+c) + 6abc \\ &= a^3 + b^3 + c^3 - 3abc - 3abc - 3abc + 6abc \\ &= a^3 + b^3 + c^3 - 3abc \end{aligned}$$

ដូច្នេះ $a^3 + b^3 + c^3 = 3abc$ ។

**27.** ▲ យើងមាន

$$\begin{aligned} x_{6n+5} = x_{2(3n+2)+1} &= 4x_{3n+2} + 2(3n+2) + 2 \\ &= 4(3x_{n+1} + 6x_n) + 6n + 6 \\ &= 6(2x_{n+1} + 4x_n + n + 1) \\ x_{6n+5} = x_{3(2n+1)+2} &= 3x_{2n+2} + 6x_{2n+1} \\ &= 3x_{2n+2} + 6(4x_n + 2n + 2) \end{aligned}$$

$$= 3(x_{2n+2} + 8x_n + 4n + 4)$$
$$\Longrightarrow \quad x_{2n+2} + 8x_n + 4n + 4 = 2(2x_{n+1} + 4x_n + n + 1)$$
$$\Leftrightarrow \quad x_{2(n+1)} = 4x_{n+1} - 2(n+1)$$
$$\Leftrightarrow \quad x_{2n} = 4x_n - 2n$$

ចំពោះ $n = 0$ យើងទាញបាន $x_0 = 0$ ។

$$x_{2n+1} = 4x_n + 2n + 2;\ x_{2n} = 4x_n - 2n$$
$$\Longrightarrow x_{2n+1} - x_{2n} = 4n + 2 \Longrightarrow x_{n+1} - x_n = 2(n+1)$$

ជំនួស $n$ ដោយ $0, 1, 2, \dots, n-1$ យើងទទួលបាន

$$x_1 - x_0 = 2(1)$$
$$x_2 - x_1 = 2(2)$$
$$\dots$$
$$x_n - x_{n-1} = 2(n)$$

បូកសមភាពទាំងនេះចូលគ្នា យើងទទួលបាន

$$x_n = 2(1 + 2 + \cdots + n) = n(n+1)$$

ដូច្នេះ

$$x_{3n+1} = (3n+1)(3n+2) = 9n^2 + 9n + 2$$
$$x_{n+2} - 2x_{n+1} + 10x_n = (n+2)(n+3) - 2(n+1)(n+2) + 10n(n+1)$$
$$= n^2 + 5n + 6 - 2n^2 - 6n - 4 + 10n^2 + 10n$$
$$= 9n^2 + 9n + 2$$

ដូច្នេះ $x_{3n+1} = x_{n+2} - 2x_{n+1} + 10x_n$ ពិត ។

**28.** ▲ តាង $A = (n+1)(n+2)(n+3)\dots(2n-1)2n$ និង $B = 2^n.1.3.5\dots(2n-3)(2n-1)$ ។ យើងមាន

$$n!.A = 1.2.3\dots n.A = (2n)!$$
$$n!.B = (2^n.n!).[1.3.5\dots(2n-1)]$$
$$= (2.4.6\dots 2n)[1.3.5\dots(2n-1)] = (2n)!$$

ដូច្នេះ $A = B$ ពិត ។

**29.** ▲ យើងនឹងស្រាយបញ្ជាក់តាមវិចារដោយកំណើនតាម $n$ ។ ចំពោះ $n = 1$ យើងមាន

$$1.2.3\dots p = \frac{1.2.3\dots p(p+1)}{p+1}$$

ពិត ។ ពេលនេះសន្មតថា សំណើពិតរហូតដល់ $n$ គឺ

$$1.2.3\ldots p+2.3\ldots p(p+1)+\cdots+n(n+1)\ldots(n+p-1)=\frac{n(n+1)(n+2)\ldots(n+p)}{p+1}$$

ពិត ។ យើងនឹងបង្ហាញថា សំណើពិតរហូតដល់ $n+1$ ។ យើងមាន

$$\begin{aligned}1.2.3\ldots p&+2.3\ldots p(p+1)+\cdots+n(n+1)\ldots(n+p-1)\\&+(n+1)\ldots(n+p)\\&=\frac{n(n+1)(n+2)\ldots(n+p)}{p+1}+(n+1)\ldots(n+p)\\&=\frac{n(n+1)\ldots(n+p)+(p+1)(n+1)\ldots(n+p)}{p+1}\\&=\frac{(n+1)\ldots(n+p)(n+p+1)}{p+1}\end{aligned}$$

ដូច្នេះសំណើពិតរហូតដល់ $n+1$ ។ មានន័យថា សមភាពពិតចំពោះគ្រប់ $n$ ។

**30.** ▲ យើងមាន

$$2+\sqrt{3}=\left(\sqrt{\frac{3}{2}}\right)^2+2.\sqrt{\frac{3}{2}}.\frac{1}{\sqrt{2}}+\left(\frac{1}{\sqrt{2}}\right)^2=\left(\sqrt{\frac{3}{2}}+\frac{1}{\sqrt{2}}\right)^2=\frac{1}{2}\left(\sqrt{3}+1\right)^2$$

$$2-\sqrt{3}=\frac{1}{2}\left(\sqrt{3}-1\right)^2$$

$$\begin{aligned}\frac{2+\sqrt{3}}{\sqrt{2}+\sqrt{2+\sqrt{3}}}&=\frac{\frac{1}{2}\left(\sqrt{3}+1\right)^2}{\sqrt{2}+\frac{1}{\sqrt{2}}\left(\sqrt{3}+1\right)}=\frac{\left(\sqrt{3}+1\right)^2}{\sqrt{2}\left(3+\sqrt{3}\right)}=\frac{\left(\sqrt{3}+1\right)^2}{\sqrt{2}\sqrt{3}\left(\sqrt{3}+1\right)}\\&=\frac{\sqrt{3}+1}{\sqrt{6}}\end{aligned}$$

$$\begin{aligned}\frac{2-\sqrt{3}}{\sqrt{2}-\sqrt{2-\sqrt{3}}}&=\frac{\frac{1}{2}\left(\sqrt{3}-1\right)^2}{\sqrt{2}-\frac{1}{\sqrt{2}}\left(\sqrt{3}-1\right)}=\frac{\left(\sqrt{3}-1\right)^2}{\sqrt{2}\left(3-\sqrt{3}\right)}=\frac{\left(\sqrt{3}-1\right)^2}{\sqrt{2}\sqrt{3}\left(\sqrt{3}-1\right)}\\&=\frac{\sqrt{3}-1}{\sqrt{6}}\end{aligned}$$

ដូច្នេះ

$$\begin{aligned}\left(\frac{2+\sqrt{3}}{\sqrt{2}+\sqrt{2+\sqrt{3}}}+\frac{2-\sqrt{3}}{\sqrt{2}-\sqrt{2-\sqrt{3}}}\right)^2&=\left(\frac{\sqrt{3}+1}{\sqrt{6}}+\frac{\sqrt{3}-1}{\sqrt{6}}\right)^2\\&=\left(\frac{2\sqrt{3}}{\sqrt{6}}\right)^2=2\end{aligned}$$

**31.** ▲ តាង

$$\frac{A}{a}=\frac{B}{b}=\frac{C}{c}=\frac{D}{d}=\lambda$$
$$\Longrightarrow A=a\lambda, B=b\lambda, C=c\lambda, D=d\lambda$$

ដូច្នេះ

$$\sqrt{Aa}+\sqrt{Bb}+\sqrt{Cc}+\sqrt{Dd}=\sqrt{\lambda}(a+b+c+d)$$
$$A+B+C+D=\lambda(a+b+c+d)$$

និង

$$\begin{aligned}\sqrt{(a+b+c+d)(A+B+C+D)}&=\sqrt{(a+b+c+d).\lambda(a+b+c+d)}\\&=\sqrt{\lambda}(a+b+c+d)\end{aligned}$$

ដូច្នេះសមភាពពិត ។

**32.** ▲ តាង $A=\sqrt[3]{ax^2+by^2+cz^2}$ ។ យើងមាន

$$\begin{aligned}A=\sqrt[3]{\frac{ax^3}{x}+\frac{by^3}{y}+\frac{cz^3}{z}}&=\sqrt[3]{\frac{ax^3}{x}+\frac{ax^3}{y}+\frac{ax^3}{z}}\\&=\sqrt[3]{ax^3\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}\right)}=x\sqrt[3]{a}\end{aligned}$$

ព្រោះ $ax^3=by^3=cz^3$ និង $1/x+1/y+1/z=1$ ។

ដូចគ្នា យើងទាញបានថា $A=x\sqrt[3]{a}=y\sqrt[3]{b}=z\sqrt[3]{c}$ ។ ដូច្នេះ

$$\frac{A}{x}=\sqrt[3]{a},\quad \frac{A}{y}=\sqrt[3]{b},\quad \frac{A}{z}=\sqrt[3]{c}$$

បូកសមភាពទាំងនេះ បញ្ចូលគ្នា យើងទទួលបាន

$$\frac{A}{x}+\frac{A}{y}+\frac{A}{z}=\sqrt[3]{a}+\sqrt[3]{b}+\sqrt[3]{c}$$
$$\Leftrightarrow A\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}\right)=\sqrt[3]{a}+\sqrt[3]{b}+\sqrt[3]{c}$$
$$\Leftrightarrow A=\sqrt[3]{a}+\sqrt[3]{b}+\sqrt[3]{c}$$

ពិត ។

# ២.៣ សមីការ

**33.** $\{-2;-1;1\}$. **34.** $\{-3;2\}$. **35.** $\{3\}$.
**36.** $\{1\}$. **37.** $\{-1;-1/2;1/3\}$. **38.** $\{1/2\}$.
**39.** $\{-\sqrt{2};-1/\sqrt{2};1/\sqrt{2};\sqrt{2}\}$. ● តាង $x^2=y$ ។
**40.** $\{-\sqrt{3};\sqrt{3}\}$. **41.** $\{-1;1\}$.
**42.** ▲ តាង $2x-3=y+c$ និង $2x-5=y-c$ ។យើងទាញបាន $c=1$ ។ ជំនួសចូលសមីការ យើងទាញបាន $(y+1)^4+(y-1)^4=2$ សមមូលនឹង $y^4+6y^2=0$ ។ យើងទាញបាន $y=0$ នាំ ឱ្យ $x=2$ ។
**43.** $\{-1/2;1\}$.
**44.** $\{-a(\sqrt{13}+1)/2;a(\sqrt{13}-1)/2 \mid a\in\mathbb{R}\}$. ● តាង $x^2+ax=y$ ។
**45.** $\{-(\sqrt{21}+5)/6;(\sqrt{21}-5)/6\}$
**46.** $\{-\sqrt{2};4-\sqrt{18};\sqrt{2};4+\sqrt{18}\}$. ● តាង $x-\frac{2}{x}=y$ ។ សមីការសមមូលនឹង $y^2-8y=0$ ។
**47.** $\{-3/2;-(\sqrt{7}+1)/4;(\sqrt{7}-1)/4;1\}$. ● ចែកអង្គទាំងពីរនឹង $x^2$ បន្ទាប់មកតាង $2x-3/x=y$ ។
**48.** $\{1/2;2\}$
**49.** $\{-1;9;(5-\sqrt{61})/2;(5+\sqrt{61})/2\}$. ● ចែកអង្គទាំងពីរនឹង $x^2$ បន្ទាប់មកតាង $x-9/x=y$ ។
**50.** $\{(1-\sqrt{21})/2;(1+\sqrt{21})/2\}$. ● ដកអង្គទាំងពីរនឹង $10x^2/(x+5)$ យើងទាញបាន

$$\left(\frac{x^2}{x+5}\right)^2+10\frac{x^2}{x+5}-11=0$$

**51.** $\{-\sqrt{7}-1;\sqrt{7}-1\}$. ● បង្រួមសមីការជារាង

$$\left(\frac{x^2}{x-3}\right)^2-6\frac{x^2}{x-3}-16=0$$

**52.** $\left\{-\left(\sqrt{2\sqrt{2}-1}+1\right)/\sqrt{2}\,;\left(\sqrt{2\sqrt{2}-1}-1\right)/\sqrt{2}\right\}$.● បង្រួមសមីការជា $(x^2+1)^2-2(x-1)^2=0$ ។

**53.** $\left\{\sqrt{2}/\left(\sqrt{2\sqrt{2}-1}+1\right);\sqrt{2}/\left(\sqrt{2\sqrt{2}-1}-1\right)\right\}$. ● តាង $x=1/y$ ។

**54.** $\{-9;11\}$. ● បូក $4x^2+400x+1$ ទៅអង្គទាំងពីរនៃសមីការ ។

**55.** $\{-a;a-\sqrt{a^2+2};a+\sqrt{a^2+2}|a\in\mathbb{R}\}$. ▲ យើងទាញរក $a$ យើងទាញបាន $a=(x^2-2)\,/2x$ ឬ $a=-x$ ។ ទាញរក $x$ យើងទាញបានចម្លើយ ។

**56.** $\{-1-\sqrt{3+a};-1+\sqrt{3+a}\}$ ចំពោះ $a\in[-3;-1)$; $\{-1-\sqrt{3+a};-1+\sqrt{3+a};-1-\sqrt{1+a};-1+\sqrt{1+a}\}$ ចំពោះ $a\in[-1;\infty)$; គ្មានឫសចំពោះ $a\in(-\infty;-3)$ .▲ ដោះស្រាយរក $a$ ដោយសន្មតថា $x$ ជាប៉ារ៉ាម៉ែត្រ : $a^2-2(x^2-1)a+x^4-6x^2+4x=0$; យើងទាញបាន $a=x^2+2x-2$ ឬ $a=x^2-2x$ ។

**57.** $\{(-1-\sqrt{29})/2\,;(5-\sqrt{17})/2\,;(-1+\sqrt{29})/2\,;(5+\sqrt{17})/2\}$.▲ យើងសរសេរអង្គខាងឆ្វេងនៃសមីការជា $(x^2+ax+c)(x^2+bx+d)=0$ ដូច្នេះ $x^4+(a+b)x^3+(ab+c+d)x^2+(bc+ad)x+cd\equiv x^4-4x^3-10x^2+37x-14$ ។ យើងទាញបាន

$$\begin{cases}a+b=-4\\ab+c+d=-10\\bc+ad=37\\cd=-14\end{cases}$$

ដោយដឹងថា $a,b,c,d$ ជាចំនួនគត់ នោះ ពីសមីការចុងក្រោយគេ យើងទាញបាន $(c;d)=\{(-1;14);(1;-14);(-2;7);(2;-7)\}$ ។ យើងផ្ទៀងផ្ទាត់ឃើញថា $(c;d)=(2;-7)$ ផ្ទៀងផ្ទាត់ ។ យើងទាញបាន $a=-5;b=1$ ។ ដូច្នេះសមីការសមមូលនឹង $x^2-5x+2=0$ ឬ $x^2+x-7=0$ ។

**58.** ▲ សន្មតថា $x_1=p/q$ ដែល $p\in\mathbb{Z},q\in\mathbb{N}$ និង $p$ និង $q$ ជាចំនួនបឋមនឹងគ្នា ។ ដូច្នេះ

$$\frac{p^3}{q^3}+a\frac{p^2}{q^2}+b\frac{p}{q}+c=0 \iff p(p^2+apq+bq^2)=-cq^3$$

អង្គខាងស្តាំនៃសមភាពនេះចែកដាច់នឹង $q$ ។ អង្គខាងឆ្វេងចែកដាច់នឹង $q$ នាំឱ្យនិងមានតែ $q\equiv 1$ តែប៉ុណ្ណោះ ព្រោះ $p^2+apq+bq^2$ ចែកមិនដាច់នឹង $q$ ។ ដូច្នេះសមភាពមានរាង $p(p^2+ap+b)=-c$ យើងទាញបាន $c$ ជាពហុគុណនៃ $p=x_1$ ។

**59.**

**60.** ● ប្រើសមភាព $ax^3+bx^2+cx+d=a(x-x_1)(x-x_2)(x-x_3)$ .

**61.** $-2p$ .

**62.** $\left\{\sqrt[3]{(\sqrt{13}+3)/2}-\sqrt[3]{(\sqrt{13}-3)/2}\right\}$ ● តាង $x=y-1/y$ ។ សមីការទៅជា

$$y^3-\frac{1}{y^3}-3\left(y-\frac{1}{y}\right)+3\left(y-\frac{1}{y}\right)-3=0 \iff y^3-\frac{1}{y^3}-3=0$$

តាង $y^3=t$ យើងទាញបាន $t^2-3t-1=0$ ។

**63.** $\{-5;-1;1;3\}$. **64.** $\{2;6\}$. **65.** $\{-1\}$.

**66.** គ្មានឫសសនិទាន

**67.** $\{-1/3\,;1/2\}$ .

**68.** ▲ គុណអង្គទាំងពីរនៃសមីការនឹង $\sqrt{x+10}-\sqrt{x-2}\neq 0$ យើងទាញបាន

$$\begin{cases}\sqrt{x+10}+\sqrt{x-2}=6\\ \sqrt{x+10}-\sqrt{x-2}=2\end{cases}$$

បូកអង្គទាំងពីរចូលគ្នា យើងទាញបាន $x=6$ ។

**69.** សមីការគ្មានឫស ។

**70.** $\{-1\}$. **71.** $\{12\}$.

**72.** $\{-(1/a-a)^2/4\,;(1/a-a)^2/4\}$ ចំពោះ $a\in(0;1]$ ហើយគ្មានឫសចំពោះតម្លៃ $a$ ផ្សេងទៀត ។

**73.** $\{-6;1\}$. **74.** $\{-1;3\}$. **75.** $\{3\}$.
**76.** $\{2\}$ **77.** $\{5\}$. **78.** $\{20\}$.
**79.** $\{-4/3\}$. **80.** $\{-1;0\}$. **81.** $\{5\}$.
**82.** $\{16\}$. **83.** $\{9\}$.

**84.** $\{-3;6\}$. ● តាង $y=\sqrt{x^2-3x+7}$ ។

**85.** $\{-9/2;3\}$.

**86.** $\{1\}$. ● តាង $y=\sqrt{x}\sqrt[4]{x^2+15}$ ។

**87.** $\{5/3\}$.

**88.** $\{5a/3\}$ ចំពោះ $a\neq 0$; $(-\infty;0)\cup(0;\infty)$ ចំពោះ $a=0$ ។

**89.** $\{1\}$. **90.** $\{3;9\left(9-\sqrt{97}\right)/8\}$.

**91.** $\left\{5\pm a\sqrt{8-a^2/2}\right\}$ ចំពោះ $a\in\left[2;2\sqrt{2}\right]$; គ្មានឫសចំពោះតម្លៃ $a$ ផ្សេងពីនេះ ។

▲ តាង $u=\sqrt{7-x}, v=\sqrt{x-3}$ ។ យើងមានប្រព័ន្ធសមីការ

$$\begin{cases} u+v=a \\ 7-x+x-3=u^2+v^2=4,(u\geq 0, v\geq 0) \end{cases}$$

ដោះស្រាយប្រព័ន្ធសមីការនេះ យើងទាញបាន

$$\begin{cases} u_1=\dfrac{a+\sqrt{8-a^2}}{2} \\ v_1=\dfrac{a-\sqrt{8-a^2}}{2} \end{cases} \qquad \begin{cases} u_2=\dfrac{a-\sqrt{8-a^2}}{2} \\ v_2=\dfrac{a+\sqrt{8-a^2}}{2} \end{cases}$$

**92.** ▲ តាង $\sqrt[4]{x-2}=u\geq 0, \sqrt[4]{4-x}=v\geq 0$ យើងទាញបានប្រព័ន្ធ

$$\begin{cases} u+v=2 \\ u^4+v^4=2 \end{cases}$$

លើកសមីការទីមួយជាស្វ័យគុណ៤ និងប្រើសមីការទី២ យើងទាញបាន $uv(2(u+v)^2-uv)=7$ ហើយដោយ $u+v=2$ យើងទាញបាន $(uv)^2-8(uv)+7=0$ ។ ដូច្នេះ $(uv)_1=1;(uv)_2=7$ ។ ដូច្នេះយើងទាញបានប្រព័ន្ធសមីការ

$$\begin{cases} u+v=2 \\ uv=1 \end{cases} \qquad \begin{cases} u+v=2 \\ uv=7 \end{cases}$$

ប្រព័ន្ធសមីការទីមួយមានឫស $u=v=1$ ។ ត្រូវនឹង $x=3$ ។ ប្រព័ន្ធទី២គ្មានឫស ។

**93.** $\{(2a+1)/(a-2)\}$ ចំពោះ$a\in(-\infty;3]\cup(2;\infty)$; $\emptyset$ចំពោះ$a\in(1/3\,;2]$.

**94.** $\left\{a+1+\sqrt{2a};a+1-\sqrt{2a}\right\}$ ចំពោះ $a\in[0;1/2]$, $\left\{a+1+\sqrt{2a}\right\}$ ចំពោះ $a\in(1/2\,;\infty)$, $\emptyset$ ចំពោះ $a\in(-\infty;0)$.

**95.** $(-\infty;0)$ ចំពោះ $a=0$, $\{0;3a/4\}$ ចំពោះ $a\in(0;\infty)$, $\emptyset$ ចំពោះ $a\in(-\infty;0)$.

**96.** $\{a^2+a;a^2-a+1\}$ ចំពោះ $a\in[0;1]$, $\{a^2+a\}$ ចំពោះ $a\in(1;\infty)$, $\emptyset$ ចំពោះ $a\in(-\infty;0)$.

**97.** $\{0\}$ ចំពោះ $a=1$, $\emptyset$ ចំពោះ $a\neq 1$.

**98.** $\{(1;-5)\}$. **99.** $\{(1;-3)\}$.

**100.** $\{(-3;1)\}$ ចំពោះ $a\in\{-2\}$; $\emptyset$ ចំពោះ $a\notin\{-2\}$.

**101.** ▲ តាង $f(x)=4x(1-x)=1-(2x-1)^2$ ។ យើងឃើញថា បើ $0\le f(x)\le 1$ នោះ $0\le x\le 1$ ។ ដូច្នេះ បើ $\mathrm{a}_{1998}=0$ នោះ ត្រូវតែ $0\le t\le 1$ ។ ឥលូវ យើងយក $0\le\theta\le\pi/2$ ដែល $\sin\theta=\sqrt{t}$ ។ យើងសង្កេតឃើញថា ចំពោះគ្រប់ $\phi\in\mathbb{R}$ យើងមាន

$$f(\sin^2\phi)=4\sin^2\phi\,(1-\sin^2\phi)=4\sin^2\phi\cos^2\phi=\sin^2 2\phi$$

ដោយ $a_1=\sin^2\theta$ នោះ យើងទាញបាន

$$a_2=\sin^2 2\theta\,,a_3=\sin^2 4\theta\,,\cdots,a_{1998}=\sin^2 2^{1997}\theta$$

ដូច្នេះ $a_{1998}=0$ ទាល់តែនិងនាំឱ្យ $\sin 2^{1997}\theta=0$ ។ មានន័យថា $\theta=k\pi/2^{1997}$ ចំពោះចំនួនគត់ $k$ ខ្លះ ហើយ តម្លៃរបស់ $t$ ដែល $a_{1998}=0$ ស្មើនឹង $\sin^2(k\pi/2^{1997})$ ដែល $k\in\mathbb{Z}$ ។ ដូច្នេះយើងមានតម្លៃរបស់ $t$ បែបនេះ ចំនួន $2^{1996}+1$ គឺមានតម្លៃ $\sin^2(k\pi/2^{1997})$ ចំពោះ $k=0,1,2,\cdots,2^{1996}$ ។

**102.** ▲ ដោយ $a^2-2b^2=1$ នោះ $a\neq 0$ ។ ដោយ $2b^2-3c^2=1$ នោះ $b\neq 0$ ។ បើ $c=0$ នោះ $b=1/\sqrt{2}$ និង $a=\sqrt{2}$ ។ $(a,b,c)=\left(\sqrt{2},1/\sqrt{2},0\right)$ ជាចម្លើយមួយរបស់ប្រព័ន្ធសមីការ ។ យើងនឹងបង្ហាញថា គ្មានចម្លើយណាផ្សេងទៀតទេ ។ យើងសន្មតថា មានចំនួនពិត $(a,b,c)$ ដោយ $abc\neq 0$ ផ្ទៀងផ្ទាត់សមីការ ។ យើងឃើញថា បើ $(a,b,c)$ ជាចម្លើយ នោះ $(-a,-b,-c)$ ក៏ជាចម្លើយដែរ ។ ដូច្នេះត្រូវតែមានចំនួនវិជ្ជមានពីរក្នុងចំណោម$(a,b,c)$ ឬ $(-a,-b,c)$ ។ សន្មតថា $a,b$ វិជ្ជមាន ។ តាង $a=\cot A\,,b=\cot B$ និង $c=\cot C$ ដែល $0<A,B<\pi/2\,,0<C<\pi$ ។ ដោយ $ab+bc+ca=1$ នោះ

$$\cot A\cot B+\cot B\cot C+\cot C\cot A=1$$

$$\cot C=\frac{1-\cot A\cot B}{\cot A+\cot B}=-\cot(A+B)=\cot(\pi-A-B)$$

$$A+B+C=\pi$$

ដូច្នេះ $A, B, C$ ជាមុំក្នុងត្រីកោណ ។ យើងមាន

$$a^2+1=2(b^2+1)=3(c^2+1)$$

$$\Longrightarrow\ \frac{1}{\sin^2 A}=\frac{2}{\sin^2 B}=\frac{3}{\sin^2 C}$$

$$\Longrightarrow\ \frac{1}{\sin A}=\frac{\sqrt{2}}{\sin B}=\frac{\sqrt{3}}{\sin C}$$

តាមច្បាប់ស៊ីនុស យើងទាញបានថា ជ្រុងឈមនឹងមុំ $A, B, C$ មានរង្វាស់ $k, k\sqrt{2}, k\sqrt{3}$ រៀងគ្នា ចំពោះចំនួនពិតវិជ្ជមាន $k$ ខ្លះ ។ ដូច្នេះត្រីកោណ $ABC$ កែងត្រង់ $C$ នាំឱ្យ $c=\cot C=0$ ផ្ទុយពីសន្មត ដែល $c\neq 0$ ។ ដូច្នេះការសន្មតរបស់យើងខុស ហើយ $(a,b,c)=\left(\sqrt{2},1/\sqrt{2},0\right)$ ជាចម្លើយតែមួយគត់របស់ប្រព័ន្ធ ។

**103.** $\left\{(4-p)/\left(2\sqrt{4-2p}\right)\right\}$ ចំពោះ $4/3\leq p\leq 2$. ▲ យើងមាន $x\geq 0$ ។ លើកអង្គទាំងពីរជាការេយើងទាញបាន

$$5x^2-p-4+4\sqrt{(x^2-1)(x^2-p)}=x^2$$
$$\Leftrightarrow 4\sqrt{(x^2-1)(x^2-p)}=(p+4)-4x^2$$

បើ $4x^2\leq p+4$ យើងលើកអង្គទាំងពីរនៃសមីការជាការេម្តងទៀត យើងទាញបាន

$$-16(p+1)x^2+16p=-8(p+4)x^2+(p+4)^2$$
$$\Leftrightarrow x^2=\frac{(4-p)^2}{4(4-2p)}\ \Longrightarrow\ x=\frac{4-p}{2\sqrt{4-2p}}$$

ដើម្បីឱ្យតម្លៃនេះជាចម្លើយនៃសមីការទាល់តែ $p\leq 2$ និង

$$\frac{(4-p)^2}{4-2p}=4x^2\leq p+4$$

សមមូលនឹង $4/3\leq p\leq 2$ ។ ក្រៅពីនេះសមីការគ្មានចម្លើយ ។

**104.** ▲ យើងសរសេរសមីការដែលឱ្យជារាង

$$x^5-x^3-4x^2-3x-2+\lambda(5x^4+\alpha x^2-8x+\alpha)=0$$

ឫសរបស់សមីការនេះមិនអាស្រ័យនឹង $\lambda$ នាំឱ្យនិងបើ វាជាឫសរួមរបស់សមីការ

$$x^5-x^3-4x^2-3x-2=0 \text{ និង } 5x^4+\alpha x^2-8x+\alpha=0$$

សមីការទីមួយសមមូលនឹង $(x-2)(x^2+x+1)^2=0$ ហើយមានឫសផ្សេងគ្នាចំនួនបី $x_1=2;\ x_{2,3}=\left(-1\pm i\sqrt{3}\right)/2$ ។

ក) ចំពោះ $\alpha = -64/5$ យើងមាន $x_1 = 2$ ជាឫសតែមួយគត់ ដែលមិនអាស្រ័យនឹង $\lambda$

ខ) ចំពោះ $\alpha = -3$ យើងមានឫសចំនួនពីរដែលមិនអាស្រ័យនឹង $\lambda$ គឺ $x_1 = \omega$ និង $x_2 = \omega^2$ ។

**105.** ▲ លក្ខខណ្ឌ $2x-1\geq 0, \Rightarrow x \geq 1/2$ និង $x \geq \sqrt{2x-1} \Rightarrow (x-1)^2 \geq 0$ ពិតជានិច្ច ។ យើងមាន $\sqrt{x+\sqrt{2x-1}}+\sqrt{x-\sqrt{2x-1}} = c \Leftrightarrow c^2 = 2x + 2|x-1| = \begin{cases} 2, & 1/2 \leq x \leq 1 \\ 4x-2, & x \geq 1 \end{cases}$

ក) $c^2 = 2$ ។ សមីការមានឫស $\frac{1}{2} \leq x \leq 1$ ។

ខ) $c^2 = 1$ ។ សមីការគ្មានឫស ។

គ) $c^2 = 4$ ។ សមីការទៅជា $4x-2=4, \Rightarrow x = 3/2$ ។

**106.** $\{[5;10]\}$ ▲ យើងមាន

$$x+3-4\sqrt{x-1} = x-1-4\sqrt{x-1}+4 = \left(\sqrt{x-1}\right)^2 - 4\sqrt{x-1}+4 = \left(\sqrt{x-1}-2\right)^2$$

$$x+8-6\sqrt{x-1} = x-1-6\sqrt{x-1}+9 = \left(\sqrt{x-1}-3\right)^2$$

ដូច្នេះសមីការទៅជា

$$\sqrt{\left(\sqrt{x-1}-2\right)^2}+\sqrt{\left(\sqrt{x-1}-3\right)^2} = 1 \Rightarrow \left|\sqrt{x-1}-2\right| + \left|\sqrt{x-1}-3\right| = 1$$

បើ $\sqrt{x-1} \geq 3$ នោះ

$$\sqrt{x-1}-2+\sqrt{x-1}-3 = 1 \Rightarrow x = 10$$

បើ $\sqrt{x-1}-2 \geq 0$ និង $\sqrt{x-1}-3 \leq 0 \Rightarrow 5 \leq x \leq 10$នោះ

$$\sqrt{x-1}-2-\sqrt{x-1}+3 = 1 \Rightarrow 1 = 1$$

បើ $\sqrt{x-1}-2 \leq 0 \Rightarrow x \leq 5$ នោះ

$$-\sqrt{x-1}+2-\sqrt{x-1}+3 = 1 \Rightarrow x = 5$$

**107.** $\{0;3\}$▲ តាង

$$3x = x+2x = y_1^2$$
$$x+2y_1 = y_2^2$$
$$x+2y_2 = y_3^2$$
$$\dots\dots\dots\dots\dots$$

$$x + 2y_{n-2} = y_{n-1}^2$$
$$x + 2y_{n-1} = y_n^2$$

ដែល $y_1, y_2, \dots, y_n$ ជាចំនួនពិតវិជ្ជមាន ។ សមីការដែលឱ្យមានរាង

$$y_n = x$$

យើងនឹងបង្ហាញថា $y_1 = x$ ។ សន្មតថា $x > y_1$ ។ ដូច្នេះ $y_1 > y_2 > \cdots > y_n$ ។ មានន័យថា បើ $x > y_1$ នោះ $x > y_n$ ផ្ទុយពីសមីការ $x = y_n$ ។ ដូចគ្នាចំពោះករណី $x < y_1$ ។ ដូច្នេះ $x = y_1$ ។ ដោយ $y_1^2 = 3x$ នោះ $3x = x^2$ យើងទាញបាន $x = 0; x = 3$ ។

**108.** ▲ សមីការសមមូលនឹង

$$\left|\sqrt{x-4} - 1\right| + \left|\sqrt{x-4} - 2\right| = a$$

តាង $y = \sqrt{x-4} \geq 0$ ។ សមីការទៅជា $|y-1| + |y-2| = a$ ។ បើ $a = 0$ នោះ $y = 1$ និង $y = 2$ មិនអាច ។ ដូច្នេះ $a > 0$ ។

បើ $0 \leq y < 1$ នោះ $1 - y + 2 - y = a; \Rightarrow y = (3-a)/2$ ។ ដោយ $0 \leq y = (3-a)/2 < 1$ នោះ $1 < a \leq 3$ ។ យើងទាញបាន $x = 4 + \left(\frac{3-a}{2}\right)^2$ ។

បើ $1 \leq y \leq 2$ នោះ $y - 1 - y + 2 = a; \Rightarrow a = 1$ ។ $1 \leq y \leq 2$ ត្រូវនឹង $5 \leq x \leq 8$ ។

បើ $y > 2$ នោះ $y - 1 + y - 2 = a; \Rightarrow y = (a+3)/2$ ។ $y > 2 \Rightarrow a > 1$ ។ យើងទាញបាន $x = 4 + \left(\frac{a+3}{2}\right)^2$

ជាសរុប

បើ $a < 1$ សមីការគ្មានឫស ។

បើ $a = 1$ សមីការមានឫស $5 \leq x \leq 8$ ។

បើ $1 < a \leq 3$ សមីការមានឫស $x = 4 + \left(\frac{3-a}{2}\right)^2$ ឬ $x = 4 + \left(\frac{a+3}{2}\right)^2$ ។

បើ $a > 3$ សមីការមានឫស $x = 4 + \left(\frac{a+3}{2}\right)^2$ ។

**109.** ▲ តាង $u = a - x; v = x - b$ ។ ដូច្នេះ $u^5 + v^5 = (a-b)^5; u + v = a - b$ ។ យើងមាន

$$u^5 + v^5 = (u+v)\{[(u+v)^2 - 2uv]^2 - uv(u+v)^2 + u^2v^2\}$$

$$\Leftrightarrow (a-b)^5 = (a-b)\{[(a-b)^2 - 2uv]^2 - uv(a-b)^2 + u^2v^2\}$$
$$\Leftrightarrow (a-b)^4 = (a-b)^4 + 5u^2v^2 - 5uv(a-b)^2$$
$$\Leftrightarrow 5(uv)^2 - 5uv(a-b)^2 = 0$$

ដូច្នេះ $uv = 0$ ឬ $uv = a - b$ ។

ករណី $uv = 0$ នោះ $u = 0$ ឬ $v = 0$ ។ បើ $u = 0$ នោះ $x = a$ ។បើ $v = 0$ នោះ $x = b$ ។

ករណី $uv = a - b$ នោះ យើងមាន

$$\begin{cases} u + v = a - b \\ uv = a - b \end{cases}$$

$(u, v)$ ជាឫសនៃសមីការ $t^2 - (a-b)t + (a-b) = 0$ គ្មានឫស ។

ដូច្នេះសមីការមានឫសពីរ គឺ $x_1 = a; x_2 = b$ ។

**110.** ▲ តាង

$$y = \sqrt{\frac{x+3}{2}} - 1 \Rightarrow y \geq 0; y + 1 = \sqrt{\frac{x+3}{2}}$$
$$\Rightarrow 2y^2 + 4y + 2 = x + 3$$
$$\Rightarrow x = 2y^2 + 4y - 1$$

ដូច្នេះ ចំពោះ $x \geq -1$ យើងទាញបានថា អនុគមន៍ $y = 2x^2 + 4x - 1$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $y = \sqrt{\frac{x+3}{2}} - 1$ ម្យ៉ាងវិញទៀត អនុគមន៍ $y = 2x^2 + 4x - 1$ កើនលើ $(-1; \infty)$ (អនុគមន៍ទាំងពីរឆ្លុះគ្នាធៀបនឹងបន្ទាត់ $y = x$) ដូច្នេះ

$$2x^2 + 4x - 1 = \sqrt{\frac{x+3}{2}} - 1$$
$$\Leftrightarrow 2x^2 + 4x - 1 = x$$
$$\Leftrightarrow 2x^2 + 3x - 1 = 0$$
$$\Rightarrow \quad x = \frac{-3 + \sqrt{17}}{4}$$

**111.** ▲ យើងមាន

$$x^4 + x^2 + 1 = (x^2 + x + 1)(x^2 - x + 1) > 0$$
$$x^2 - 3x + 1 = 2(x^2 - x + 1) - (x^2 + x + 1)$$

តាង

$$t=\sqrt{\frac{x^2-x+1}{x^2+x+1}}$$

សមីការទៅជា

$$2t^2-mt-1=0 \quad (1)$$

ពី $t=\sqrt{\frac{x^2-x+1}{x^2+x+1}}$ យើងទាញបាន

$$\begin{aligned} t^2(x^2+x+1)&=x^2-x+1\\ (t^2-1)x^2+(t^2+1)x+t^2-1&=0 \quad (2)\\ \Delta&=(t^2+1)^2-4(t^2-1)^2\\ &=(3-t^2)(3t^2-1)\geq 0\\ \Rightarrow \frac{\sqrt{3}}{3}&\leq t\leq\sqrt{3} \end{aligned}$$

ក) ករណី $m=-\sqrt{3}/3$

ពី (១) យើងទាញបាន

$$t_1=-\frac{3}{2\sqrt{3}};t_2=\frac{1}{\sqrt{3}}$$

យើងយក $t=1/\sqrt{3}$ ។ ពី (២) យើងទាញបាន $x=1$ ។

ខ) ក្នុងសមីការ(១) យើងមាន $\Delta=m^2+8>0$ ដូច្នេះ(១)មានឫសពីរ $t_1;t_2$ ។ ដោយ $t_1t_2=-1/2<0$ នោះ $t_1<0<t_2$ ។ មានតែឫស $t_2$ មួយគត់ ដែលអាចឱ្យសមីការ(២) មានឫស ព្រោះ $\sqrt{3}/3\leq t\leq\sqrt{3}$ ។ សមីការ(*) មានឫសតែមួយគត់ បើ សមីការ(២)មានឫសតែមួយគត់ដែរ ។

បើ $t=1$ នោះ (១)នាំឱ្យ $m=1$ ហើយ (២) នាំឱ្យ $x=0$ ។

បើ $t^2-1\neq 0$ នោះ $\Delta=(3-t^2)(3t^2-1)=0 \Rightarrow t_1=\sqrt{3}/3\,;t_2=\sqrt{3}$ ។

បើ $t=\sqrt{3}/3\,;(1)\Rightarrow m=-\sqrt{3}/3 \Rightarrow x=1$

បើ $t=\sqrt{3};(1)\Rightarrow m=5\sqrt{3}/3 \Rightarrow x=1$

ដូច្នេះ $m=\{-\sqrt{3}/3\,;\ 1;5\sqrt{3}/3\}$ ។

**112.** ▲ តាង $y=\sqrt[3]{7x+1};z=-\sqrt[3]{x^2-x-8};t=\sqrt[3]{x^2-8x-1}$ ។ ដូច្នេះ

$$y+z+t=2$$

$$\Longrightarrow \quad (y+z+t)^3 = 8 \quad (1)$$

យើងមាន

$$y^3+z^3+t^3 = (7x+1)-(x^2-x-8)+(x^2-8x-1) = 8 \quad (2)$$

ពី (១) និង (២) យើងទាញបាន

$$(y+z+t)^3-(y^3+z^3+t^3) = 3(y+z)(z+t)(t+y) = 0$$

$$\Longrightarrow \left[\begin{array}{l} y+z=0 \\ z+t=0 \\ t+y=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} y=-z \\ z=-t \\ t=-y \end{array}\right.$$

$$\sqrt[3]{7x+1} = \sqrt[3]{x^2-x-8} \quad \Leftrightarrow \quad 7x+1 = x^2-x-8 \Leftrightarrow x=-1\ ; x=9$$

$$\sqrt[3]{x^2-x-8} = \sqrt[3]{x^2-8x-1} \quad \Leftrightarrow \quad x^2-x-8 = x^2-8x-1$$

$$\Leftrightarrow \quad x = 1\sqrt[3]{7x+1} = -\sqrt[3]{x^2-8x-1}$$

$$\Leftrightarrow \quad 7x+1 = -(x^2-8x-1)$$

$$\Leftrightarrow x=0; x=1$$

**113.** ▲ តាង $u=\sqrt{x+1}\geq 0; v=\sqrt{x^2-x+1}>0$ ។ សមីការសមមូលនឹង

$$5uv = 2(v^2+v^2) \Leftrightarrow 5\frac{u}{v} = 2\left(\frac{u}{v}\right)^2$$

$$\Leftrightarrow \left[\begin{array}{l} \frac{u}{v}=2 \\ \frac{u}{v}=\frac{1}{2} \end{array}\right.$$

$$\frac{u}{v}=2 \quad \Leftrightarrow \quad \sqrt{x+1} = 2\sqrt{x^2-x+1}$$

$$\Leftrightarrow \left\{\begin{array}{c} x>-1 \\ 4x^2-5x+3=0 \end{array}\right. : \text{ គ្មានឫស}$$

$$\frac{u}{v}=\frac{1}{2} \quad \Leftrightarrow 2\sqrt{x+1} = \sqrt{x^2-x+1}$$

$$\Leftrightarrow \left\{\begin{array}{l} x>-1 \\ x=\dfrac{5\pm\sqrt{37}}{2} \end{array}\right.$$

សមីការមានឫសពីរ $x = \left(5\pm\sqrt{37}\right)/2$ ។

**114.** ▲ យើងមាន

$$1+\frac{1}{x} = \frac{x+1}{x};$$

$$1+\frac{1}{\frac{x+1}{x}} = 1+\frac{x}{x+1} = \frac{2x+1}{x+1};$$

$$1+\cfrac{1}{\cfrac{2x+1}{x+1}}=1+\frac{x+1}{2x+1}=\frac{3x+2}{2x+1};$$
$$1+\cfrac{1}{\cfrac{3x+2}{2x+1}}=1+\frac{2x+1}{3x+2}=\frac{5x+3}{3x+2};$$
$$\dots$$

ជាបញ្ចប់យើងទទួលបានសមីការដែលមានរាង

$$\frac{ax+b}{cx+d}=x \quad (*)$$

ដែល $a, b, c, d$ ជាចំនួនគត់ដែលអាស្រ័យនឹងចំនួនគត់ $n$ ។ សមីការ (*) សមមូលនឹងសមីការដឺក្រេទីពីរ $ax+b=x(cx+d)$ ដែលមានឫសយ៉ាងច្រើនចំនួនពីរ ។

យើងដឹងថា បើ

$$1+\frac{1}{x}=x$$

នោះយើងអាចសម្រួលតួនីមួយៗក្នុងប្រភាគនៃអង្គខាងឆ្វេងរបស់សមីការម្តងមួយៗ ដូចខាងក្រោម

$$1+\frac{1}{x}\longrightarrow x$$
$$1+\frac{1}{x}\longrightarrow x$$
$$\dots.$$

ទីបំផុតយើងទទួលបាន $x=x$ ។ ដូច្នេះ បើ $1+\frac{1}{x}=x$ នោះសមីការផ្ទៀងផ្ទាត់ ។ ករណីនេះ យើងទាញបាន

$$1+\frac{1}{x}=x \iff x^2-x-1=0$$
$$\Longrightarrow \quad x_{1,2}=\frac{1\pm\sqrt{5}}{2}$$

ដោយសមីការដែលត្រូវដោះស្រាយមានឫសតែពីរ ហើយ $x_{1,2}=\left(1\pm\sqrt{5}\right)/2$ ផ្ទៀងផ្ទាត់សមីការនោះ ដូច្នេះមានន័យថា សមីការមានឫសពីរនេះគឺ $x_{1,2}=\left(1\pm\sqrt{5}\right)/2$ ។

**115.** ▲ តាង $y_i=1/x_i$ ។ យើងបំលែងសមីការជា

$$0=1+y_1+(1+y_1)y_2+\cdots+(1+y_1)\dots(1+y_{n-1})y_n$$

$= (1 + y_1)(1 + y_2) \dots (1 + y_n)$
ចម្លើយរបស់សមីការនេះគឺ $(y_1, \dots, y_n)$ ដែល $y_i \neq 0$ ចំពោះគ្រប់ $i$ និង $y_j = -1$ ចំពោះសន្ទស្សន៍ $j$ យ៉ាងហោចណាស់មួយ ។ យើងទាញបានឫសសមីការដើម ជា $(x_1, \dots, x_n)$ ដែល $x_i \neq 0$ ចំពោះគ្រប់ $i$ និង $x_j = -1$ ចំពោះសន្ទស្សន៍ $j$ យ៉ាងហោចណាស់មួយ ។

**116.** ▲ដោយ $a, b, c$ ជាចំនួនពិតខុសៗគ្នា ដូច្នេះពួកវាជាឫសពិតនៃសមីការ $t^3 + xt + y = 0$ ។ ផលបូកឫសទាំងបីនៃសមីការនេះស្មើសូន្យ ។ ដូច្នេះ $a + b + c = 0$ ។

**117.** ▲សមមូលភាពសមមូលនឹង

$$[x^3 + y^3 - 10^3 + 30xy] + [(x + y)^3 - 10^3] = 0$$

ដោយដឹងថា

$$\begin{aligned} x^3 + y^3 - 10^3 + 30xy &= (x + y)^3 - 10^3 - 3xy(x + y) + 30xy \\ &= (x + y - 10)[(x + y)^2 + 10(x + y) + 100] \\ &\quad - 3xy(x + y - 10) \\ &= (x + y - 10)[(x + y)^2 + 10(x + y) + 100 - 3xy] \end{aligned}$$

$$(x + y)^3 - 10^3 = (x + y - 10)[(x + y)^2 + 10(x + y) + 100]$$

$$\begin{aligned} &[x^3 + y^3 - 10^3 + 30xy] + [(x + y)^3 - 10^3] \\ &= (x + y - 10)[2(x + y)^2 + 20(x + y) + 200 - 3xy] \\ &= (x + y - 10)[2x^2 + 2y^2 + 20(x + y) + xy + 200] \end{aligned}$$

យើងមាន $2x^2 + 2y^2 + 20(x + y) + xy + 200 > 0$ ព្រោះ $x, y$ វិជ្ជមាន ។ ដូច្នេះ ផលគុណ $(x + y - 10)[2x^2 + 2y^2 + 20(x + y) + xy + 200]$ ស្មើសូន្យទាល់តែ $x + y = 10$ ។

**118.** ▲យើងមាន $\Delta = a^2 - 4(a^2 - 6) = 3(8 - a^2)$ ។ សមីការមានឫសពិតទាល់តែ

$$\Delta \geq 0 \Rightarrow a \leq 2\sqrt{2}$$

ករណី $a \leq 2\sqrt{2}$ យើងទាញបាន

$$a^3 = 6(a + 1)$$

$$\Longrightarrow 6 = a(a^2-6)$$

តាង $y = a(a^2-6)$ ។ យើងមាន $y' = 3a^2 - 6 = 3(a-\sqrt{2})(a+\sqrt{2})$ ។ ចំពោះ $a \le 2\sqrt{2}$ យើងទាញបាន $6 = y \le 2\sqrt{2}(8-6) = 4\sqrt{2}$ មិនពិត ។

| $a$ | | $-\sqrt{2}$ | | | | $\sqrt{2}$ | |
|---|---|---|---|---|---|---|---|
| $y'$ | $+$ | | $-$ | ¦ | $-$ | | $+$ |
| $y$ | ↗ | | ↘ | ○ | ↘ | | ↗ |

**119.** ▲ តាង

$$\sqrt[3]{-\frac{q}{2}+\sqrt{\frac{q^2}{4}+\frac{p^3}{27}}} = u, \qquad \sqrt[3]{-\frac{q}{2}-\sqrt{\frac{q^2}{4}+\frac{p^3}{27}}} = v$$

ដូច្នេះ $x = u + v$ ។ ដូច្នេះ

$$x^3 = (u+v)^3 = u^3 + v^3 + 3uv(u+v) = u^3 + v^3 + 3uvx$$

តែ

$$u^3 + v^3 = -q, \qquad uv = -\frac{p}{3}$$

ដូច្នេះ

$$x^3 = -q + 3\left(-\frac{p}{3}\right)x \iff x^3 + px + q = 0$$

ពិត ។

**120.** ▲ ក) យើងមាន

$$\begin{aligned}
&a^3 + b^3 + c^3 - 3abc \\
&= (a+b)^3 + c^3 - 3ab(a+b) - 3abc \\
&= (a+b+c)[(a+b)^2 - (a+b)c + c^2] - 3ab(a+b+c) \\
&= (a+b+c)[(a+b)^2 - (a+b)c + c^2 - 3ab] \\
&= (a+b+c)(a^2 + b^2 + c^2 - ab - bc - ca)
\end{aligned}$$

ខ) តាង $x = y + t$ ។ ជំនួសចូលសមីការ $x^3 + Ax^2 + Bx + C = 0$ យើងទាញបាន

$$\begin{aligned}
&y^3 + 3ty^2 + 3t^2y + t^3 + A(y^2 + 2yt + t^2) + B(y+t) + C = 0 \\
&\iff y^3 + (3t+A)y^2 + (3t^2 + 2At + B)y + t^3 + At^2 + Bt \\
&+ C = 0
\end{aligned}$$

ដូច្នេះ បើយើងយក $3t + A = 0 \Rightarrow t = -A/3$ នោះ យើងទាញបានសមីការ

$$y^3 + \left(3\frac{A^2}{9} - 2\frac{A^2}{3} + B\right)y + \left(-\frac{A^3}{27} + \frac{A^3}{9} - \frac{AB}{3} + C\right) = 0$$

$$\Leftrightarrow y^3 + \left(-\frac{A^2}{3} + B\right)y + \left(\frac{2}{27}A^3 - \frac{1}{3}AB + C\right) = 0$$

ដូច្នេះ សមីការ $x^3 + Ax^2 + Bx + C = 0$ អាចបំលែងទៅជា សមីការ

$y^3 + px + q = 0$ ដែល

$$p = -\frac{A^2}{3} + B;\ \ q = \frac{2}{27}A^3 - \frac{1}{3}AB + C$$

គ) ដំបូងយើងកំណត់ $a, b$ ដែល $x^3 + px + q = x^3 + a^3 + b^3 - 3abx$ ។ ដូច្នេះ យើងមាន

$$a^3 + b^3 = q;\ ab = -\frac{p}{3} \ \Leftrightarrow\ a^3 + b^3 = q; a^3b^3 = -\frac{p^3}{27}$$

ដូច្នេះ $a^3$ និង $b^3$ ជាឫសនៃសមីការ $z^2 - qz - \frac{p^3}{27} = 0$ ។ ដូច្នេះ យើងទាញបាន

$$a = \sqrt[3]{\frac{q}{2} + \sqrt{\frac{q^2}{4} + \frac{p^3}{27}}},\ \ b = \sqrt[3]{\frac{q}{2} - \sqrt{\frac{q^2}{4} + \frac{p^3}{27}}}$$

យើងឃើញថា បើ $\frac{q^2}{4} + \frac{p^3}{27} \geq 0$ នោះ $a, b$ ជាចំនួនពិត តែបើ $\frac{q^2}{4} + \frac{p^3}{27} < 0$ នោះ $a, b$ ជាចំនួនកុំផ្លិច ។

យើងមាន

$$x^3 + a^3 + b^3 - 3abx = (x + a + b)(x^2 + a^2 + b^2 - xa - ab - bx)$$

យើងទាញបាន ឫសរបស់សមីការដឺក្រេទី៣ កំណត់ដោយ

$$x_1 = -a - b = -\sqrt[3]{\frac{q}{2} + \sqrt{\frac{q^2}{4} + \frac{p^3}{27}}}, -\sqrt[3]{\frac{q}{2} - \sqrt{\frac{q^2}{4} + \frac{p^3}{27}}}$$

និង ឫសរបស់សមីការ

$$x^2 - (a + b)x + a^2 + b^2 - ab = 0$$

ដែលមានឫស

$$x_2 = \frac{a+b}{2} + \frac{(a-b)\sqrt{3}}{2} i,$$
$$x_3 = \frac{a+b}{2} - \frac{(a-b)\sqrt{3}}{2} i$$

ឧទាហរណ៍ ដោះស្រាយសមីការ $x^3 - 6x + 4 = 0$ ។

យើងមាន

$$p = -6, q = 4, \frac{q^2}{4} + \frac{p^3}{27} = -4 = (2i)^2$$
$$a = \sqrt[3]{2+2i} = \sqrt[3]{2\sqrt{2}\left(\frac{\sqrt{2}}{2} + i\frac{\sqrt{2}}{2}\right)}$$
$$= \sqrt{2}\,\left(\cos\left(\frac{\pi}{4} + 2k\pi\right) + i\sin\left(\frac{\pi}{4} + 2k\pi\right)\right)^{\frac{1}{3}}$$
$$= \sqrt{2}\left(\cos\left(\frac{\pi}{12} + \frac{2k\pi}{3}\right) + i\sin\left(\frac{\pi}{12} + \frac{2k\pi}{3}\right)\right)$$
$$b = \sqrt[3]{2-2i} = \sqrt{2}\,\left(\cos\frac{-\pi}{4} + i\sin\frac{-\pi}{4}\right)^{\frac{1}{3}}$$
$$= \sqrt{2}\left(\cos\left(-\frac{\pi}{12} + \frac{2l\pi}{3}\right) + i\sin\left(-\frac{\pi}{12} + \frac{2l\pi}{3}\right)\right)$$

ដែល $k, l \in \mathbb{Z}$ ។

យើងឃើញថា $a, b$ អាចមានតម្លៃច្រើនយ៉ាង ដើម្បីឱ្យសមភាព $x^3 + px + q = x^3 + a^3 + b^3 - 3abx$ ពិត ។ តែ យើងអាចជ្រើសរើសយកគូ $a, b$ ណាក៏បាន ។ យើងយក

$$a = \sqrt{2}\left(\cos\frac{\pi}{12} + i\sin\frac{\pi}{12}\right);\ \ b = \sqrt{2}\left(\cos\frac{\pi}{12} - i\sin\frac{\pi}{12}\right)$$

ដូច្នេះសមីការដឺក្រេទី៣ $x^3 - 6x + 4 = 0$ សមមូលនឹង

$$\left(x + \sqrt{2}\cos\frac{\pi}{12} + \sqrt{2}\cos\frac{\pi}{12}\right)\left(x^2 - 2\sqrt{2}\cos\frac{\pi}{12}x + 4\left(\cos^2\frac{\pi}{12} - \sin^2\frac{\pi}{12}\right) - 2\right) = 0$$

សមីការនេះមានឫស

$$\Leftrightarrow \left[\begin{array}{l} x_1 = -2\sqrt{2}\cos\frac{\pi}{12} \\ x_2 = \sqrt{2}\cos\frac{\pi}{12} - \frac{\sqrt{6}}{2}\sin\frac{\pi}{12} \\ x_3 = \sqrt{2}\cos\frac{\pi}{12} + \frac{\sqrt{6}}{2}\sin\frac{\pi}{12} \end{array}\right.$$

**121.** ▲ តាង $y_1 = \sqrt{4x + \sqrt{16x + \sqrt{\ldots + \sqrt{4^{2008}x + 3}}}}$ ដូច្នេះ

$$\sqrt{x + y_1} - \sqrt{x} = 1 \implies \sqrt{x + y_1} = \sqrt{x} + 1 \implies y_1 = 2\sqrt{x} + 1$$

តាង $y_2 = \sqrt{16x + \sqrt{\ldots + \sqrt{4^{2008}x + 3}}}$ ដូច្នេះ

$$y_1 = \sqrt{4x + y_2} \implies \sqrt{4x + y_2} = 2\sqrt{x} + 1 \implies y_2 = 2^2\sqrt{x} + 1$$

...

ធ្វើរបៀបដូចគ្នានេះ ជាបន្តបន្ទាប់ យើងទទួលបាន $y_{2007} = 2^{2007}\sqrt{x} + 1$ ដែល

$$y_{2007} = \sqrt{4^{2007}x + \sqrt{4^{2008}x + 3}}$$

ដូច្នេះ

$$\sqrt{4^{2007}x + \sqrt{4^{2008}x + 3}} = 2^{2007}\sqrt{x} + 1$$
$$\implies \sqrt{4^{2008}x + 3} = 2^{2008}\sqrt{x} + 1$$
$$\implies 3 = 2^{2009}\sqrt{x} + 1$$
$$\implies x = \frac{1}{2^{4016}}$$

**122.** ▲ សន្មតថា $20(b - a)$ ជាចំនួនគត់ និង $b > a$ ។ ដូច្នេះ

$$20(b - a) > 0 \iff 20(b - a) \geq 1$$
$$\implies b - a \geq \frac{1}{20}$$
$$\implies a \leq b - \frac{1}{20}$$

ដើម្បីឱ្យសមីការ

$$(x^2 + 20ax + 10b)(x^2 + 20bx + 10a) = 0$$

គ្មានឫស នោះត្រូវតែ

$$\Delta = 100b^2 - 10a < 0 \implies 10b^2 < a$$
$$\implies 10b^2 < a \leq b - \frac{1}{20}$$
$$\implies 10b^2 - b + \frac{1}{20} < 0$$

តែ $10b^2 - b + 1/20 > 0$ ចំពោះគ្រប់ $b$ ព្រោះ $\Delta = 1 - 4(10)(1/20) = -1 < 0$ ។ ដូច្នេះ ការសន្មតមិនអាចពិត មានន័យថា $20(b - a)$ មិនអាចជាចំនួនគត់ទេ ។

# ២.៤ ប្រព័ន្ធសមីការ

**123.** $\{(-4/9\,;20/9);(2;1)\}$. **124.** $\{(-1;3);(71/21\,;-25/7)\}$.

**125.** $\{(51;24{,}5)\}$.

**126.** $\{\,(-19{,}6\,;5{,}2);\ (-14;8)\}$ .● ដាក់អង្គខាងឆ្វេងនៃសមីការទីមួយជារាង $(x+3y)^2-6(x+3y)-40$ ហើយតាង $x+3y=t$ ។

**127.** $\{(2;3);(3;2)\}$. **128.** $\{(4;-1);(1;-4)\}$.
**129.** $\{(1;3);(3;1)\}$. **130.** $\{(1;2);(2;1)\}$
**131.** $\{(-1/2\,;-1/3);(1/3;1/2)\}$. **132.** $\{(-1;2);(2;-1)\}$
**133.** $\{(3;2);(2;3)\}$ **134.** $\{(-1;-4);(4;1)\}$.
**135.** $\{(-3;4);(4;-3)\}$.
**136.** $\{(5+\sqrt{28};-5+\sqrt{28});(5-\sqrt{28};-5-\sqrt{28});(5;2);(-2;-5)\}$.
**137.** $\{(0{,}6;0{,}3);(0{,}4;0{,}5)\}$. **138.** $\{(-1;2);(-1/4\,;-1/4)\}$
**139.** $\left\{\begin{matrix}(2;1);(1;2);\left((5+\sqrt{21})/2\,;(5-\sqrt{21})/2\right);\\ \left((5-\sqrt{21})/2\,;(5+\sqrt{21})/2\right)\end{matrix}\right\}$.● តាង $x+y=u, xy=v$ បន្ទាប់មក $-u+v=z$ និង $uv=t$ ។

**140.** $\left\{\begin{matrix}\left(-(25+5\sqrt{61})/9\,;(5+\sqrt{61})/9\right);\\ \left((-25+5\sqrt{61})/9\,;(5-\sqrt{61})/9\right);(-6;-4/3);(3/2;1/3)\end{matrix}\right\}$. ● តាង $x=yt$ .

**141.** $\{(-1;3);(1;-3);\left(16/\sqrt{11};1/\sqrt{11}\right);\left(-16/\sqrt{11}\,;-1/\sqrt{11}\right)\}$.

**142.** $\{(1;2);(-1;-2);(\sqrt{2};\sqrt{2});(-\sqrt{2};-\sqrt{2})\}$.

**143.** $\left\{\begin{matrix}\left((2+\sqrt{19})/\sqrt[3]{14+4\sqrt{19}}\,;-3/\sqrt[3]{14+4\sqrt{19}}\right);\\ \left((-2+\sqrt{19})/\sqrt[3]{-14+4\sqrt{19}}\,;3/\sqrt[3]{-14+4\sqrt{19}}\right);(2;-1)\end{matrix}\right\}$.

**144.** $\{(2;1)\}$. ▲ គុណសមីការទីពីរនឹង 2 រួចបូកចូលសមីការទីមួយ បន្ទាប់មកគុណសមីការទីពីរជាដែលនឹង $-2$ រួចបូកចូលសមីការទីមួយចាស់ យើងទាញបានប្រព័ន្ធថ្មី

$$\begin{cases}16x^2+8xy+y^2-72x-18y+81=0\\4x^2-12xy+9y^2-4x+6y+1=0\end{cases}$$
$$\Leftrightarrow\begin{cases}(4x+y)^2-18(4x+y)+81=0\\(2x-3y)^2-2(2x-3y)+1=0\end{cases}$$
$$\Leftrightarrow\begin{cases}4x+y=9\\2x-3y=1\end{cases}$$

**145.** $\{(0;1/\sqrt{3});(0;-1/\sqrt{3});(1;1);(-1;-1)\}$.

**146.** $\{(2/7\,;-9/7);(1;3)\}$.

**147.** $\{(2;6);(1;3)\}$. **148.** $\{(2\sqrt{2};-\sqrt{2});(-2\sqrt{2};\sqrt{2})\}$.

**149.** $\{(\sqrt{6};\sqrt{6}/3);(-\sqrt{6};-\sqrt{6}/3)\}$

**150.** $\{(2;1;-1);(31/15\,;17/15\,;-2/3)\}$.

**151.** $\{(1;2;2);(2;1;1)\}$

**152.** $\left\{\begin{matrix}(3;-2;1);(-2;3;1);\left((3+\sqrt{17})/2\,;(3-\sqrt{17})/2\,;-1\right);\\ \left((3-\sqrt{17})/2\,;(3+\sqrt{17})/2\,;-1\right)\end{matrix}\right\}$.

**153.** $\{(3;1;-2);(-5;-3;0)\}$.

**154.** $\{(3;5;-1);(-3;-5;1)\}$

**155.** $\left\{\begin{matrix}(2;-1;3);(-2;1;-3);\left(-7/\sqrt{13}\,;5/\sqrt{13}\,;-11/\sqrt{13}\right);\\ \left(7/\sqrt{13}\,;-5/\sqrt{13}\,;11/\sqrt{13}\right)\end{matrix}\right\}$.

**156.** $\{(-4;-3;1);(4;3;-1)\}$. **157.** $\{(1/2;1/3;1/4)\}$ .

**158.** $\{(-1;1;0);(1;-1;0)\}$. **159.** $\{(3;3;3)\}$.

**160.** $\{(16;30)\}$. **161.** $\{(41;40)\}$.

**162.** $\{(c;c-1)|c\in\mathbb{R}\setminus\{1/2\}\}$. **163.** $\{(-1/2\,;-2/5);(5;4)\}$.

**164.** $\left\{\left(\sqrt{(3\sqrt{109}+9)/2}\,;\sqrt{(3\sqrt{109}-9)/2}\right);(-5;-3)\right\}$.

**165.** $\{(0;a+\sqrt{a^2+3})\}$ ចំពោះ $a\in(-\infty;\sqrt{3})$; $\{(0;a+\sqrt{a^2+3});(0;-a-\sqrt{a^2-3});\ (0;-a+\sqrt{a^2-3})\}$ ចំពោះ $a\in[\sqrt{3};\infty)$ ។

**166.** $\{(1;1;0)\}$. ▲ សមីការទីមួយ យើងទាញបាន $x=2-y$ ។ ជំនួសចូលសមីការទីពីរ យើងទាញបាន

$$\begin{gathered}2y-y^2-z^2=1\\ \Rightarrow\ \ z^2+(y-1)^2=0\\ \Rightarrow z=0;y=1\end{gathered}$$

**167.** $\{-1/4\}\cup[0;\infty)$.

**168.** ក) 25. ▲ គុណសមីការទីមួយនឹង $\alpha$ និងសមីការទីពីរនឹង $\beta$ ដែល $\alpha\beta\neq 0$ បន្ទាប់មកបូកចូលគ្នា យើងទាញបាន ៖

$$\left(\frac{2\alpha}{3}+\beta\right)x+\left(\frac{4\alpha}{5}+\beta\right)y+\left(\frac{5\alpha}{6}+\beta\right)z=61\alpha+79\beta$$

យើងយក $2\alpha/3+\beta=0;4\alpha/5+\beta=2/5\,;\ 5\alpha/6+\beta=1/2$ ។ យើងទាញបាន $\alpha=3,\beta=-2$ ។ ដូច្នេះ $2/5\,y+z/2=61\alpha+79\beta=15$ ។

ខ) $\{(27;10;42)\}$. ▲ ដោយសារ $x,y,z$ ជាចំនួនគត់ធម្មជាតិ នោះ $x=3k;y=5l;z=6m$ ដែល $k;l;m\in\mathbb{N}$ ។ ប្រព័ន្ធសមីការសមមូលនឹង

$$\begin{cases}4l+5m=61-2k\\5l+6m=79-3k\end{cases}$$

យើងទាញបាន $l=29-3k$ និង $m=2k-11$ ។ ដោយ $k;l;m\in\mathbb{N}$នោះ

$$\begin{cases}k>0\\29-3k>0\\2k-11>0\end{cases}$$

យើងទាញបាន $k=9$ ។

**169.** ▲ ចំពោះ $a=0$ យើងទាញបាន $(x,y,z)=(0,0,0)$ ។ ចំពោះ $a\neq 0$ យើងទាញបាន $(x,y,z)\in\{(t_1,t_2,z_0);(t_2,t_1,z_0)\}$ ដែល

$$z_0=\frac{a^2-b^2}{2a};\ t_{1,2}=\frac{a^2+b^2\pm\sqrt{(3a^2-b^2)(3b^2-a^2)}}{4a}$$

ដើម្បីឱ្យចម្លើយវិជ្ជមាននិងខុសគ្នា លក្ខខណ្ឌចាំបាច់នឹងគ្រប់គ្រាន់គឺ $3b^2>a^2>b^2$ និង $a>0$ ។

**170.** ▲ បូកសមីការទាំងអស់បញ្ចូលគ្នា យើងទាញបាន $2(x_1+x_2+x_3+x_4+x_5)=y(x_1+x_2+x_3+x_4+x_5)$ ។ បើ $y=2$ នោះយើងទាញបាន $x_1-x_2=x_2-x_3=\cdots=x_5-x_1$ ដូច្នេះ $x_1=x_2=\cdots=x_5$ ជាចម្លើយរបស់ប្រព័ន្ធ ។ បើ $y\neq 2$ នោះ $x_1+x_2+x_3+x_4+x_5=0$ ។ បូកសមីការទីបីខាងដើមចូលគ្នា យើងទាញបាន $x_2=y(x_1+x_2+x_3)$ ។ ដោយ $x_1+x_3=yx_2$ នោះ $x_2=(y^2+y)x_2,\Rightarrow(y^2+y-1)x_2=0$ ។ បើ $y^2+y-1\neq 0$ នោះ $x_2=0$ ដូចគ្នា យើងទាញបាន $x_1=x_2=\cdots=x_5=0$ ។ បើ $y^2+y-1=0$ នោះ បូកសមីការទីមួយនិងទីពីរ យើងទាញបាន $x_5+x_2+x_1+x_3=yx_1+yx_2\Rightarrow x_3+x_5=yx_1+yx_2-x_2-x_1\Rightarrow x_3+x_5=-y^2x_2-y^2x_1\Rightarrow x_3+x_5=-y(x_1+x_3)-y(x_5+x_2)\Rightarrow x_3+x_5=yx_4$ ។ ដូចគ្នា យើងទាញបានសមីការទី៥ ។ មានន័យថា សមីការទី៤និងទី៥ អាស្រ័យលីនេអ៊ែរនឹងសមីការបីខាងលើ ។ យក $x_1=u;x_5=v$ ។ យើងទាញបាន $x_2=yu-v;x_3=y^2u-yv-u;x_4=y^3u-y^2v-2yu+v$ ។

**171.** ▲ សន្មតថា $(x_1, x_2, x_3)$ ជាចម្លើយរបស់ប្រព័ន្ធ ។ យើងអាចសន្មតថា $|x_1| \ge |x_2| \ge |x_3|$ ។ សន្មតថា $|x_1| > 0$ ។ ពីសមីការទីមួយ យើងទាញបាន

$$0 = |x_1|.\left|a_{11} + a_{12}\frac{x_2}{x_1} + a_{13}\frac{x_3}{x_1}\right| \ge |x_1|.(a_{11} - |a_{12}| - |a_{13}|) > 0$$

មិនអាច ។ ដូច្នេះ $|x_1| = 0$ នាំឱ្យ $x_1 = x_2 = x_3 = 0$ ។

**172.** ▲ បើមានចំនួនណាមួយស្មើសូន្យ ឧបមាថា $x_1 = 0$ នោះ $x_1 + x_2x_3x_4 = 2 \Longrightarrow x_2x_3x_4 = 2; x_2 + x_1x_3x_4 = 2 \Longrightarrow x_2 = 2; \dots; x_3 = x_4 = 2$ មិនអាច ។ ដូច្នេះគ្មានចំនួនណាមួយអាចស្មើសូន្យបានទេ ។ តាង $x_1x_2x_3x_4 = p$ ។ សម្មតិកម្មសមមូលនឹង $x_i + p/x_i = 2, i = 1,2,3,4$ ។ សមីការ $x + p/x = 2$ មានឫសយ៉ាងច្រើនចំនួនពីរ តាងដោយ $y$ និង $z$ ។ ដូច្នេះ $x_i$ នីមួយៗអាចស្មើ $y$ ឬស្មើ $z$ ។ យើងមានបីករណី ៖

❶ $x_1 = x_2 = x_3 = x_4 = y$ ។ ដូច្នេះ $y + y^3 = 2$ នាំឱ្យ $y = 1$ ។

❷ $x_1 = x_2 = x_3 = y, x_4 = z$ ។ ដូច្នេះ $z + y^3 = y + y^2z = 2$ ។ យើងទាញបាន $(y; z) = \{(-1; 3); (1; 2)\}$

❸ $x_1 = x_2 = y, x_3 = x_4 = z$ ។ ករណីនេះយើងទាញបាន $y = z = 1$ ។

ដូច្នេះឫស $(x_1; x_2; x_3; x_4)$ គឺ $\{(1; 1; 1; 1); (-1; -1; -1; 3)\}$ និងចំលាស់របស់វា ។

**173.** ▲ តាង $L_1 = |a_1 - a_2|x_2 + |a_1 - a_3|x_3 + |a_1 - a_4|x_4$ និងដូចគ្នាចំពោះ $L_2, L_3$ និង $L_4$ ។ សន្មតថា $a_1 < a_2 < a_3 < a_4$ ។ នៅក្នុងករណីនេះ

$$\begin{aligned} 2|a_1 - a_2||a_2 - a_3|x_2 &= |a_3 - a_2|L_1 - |a_1 - a_3|L_2 + |a_1 - a_2|L_3 \\ &= |a_3 - a_2| - |a_1 - a_3| + |a_1 - a_2| = 0 \\ 2|a_2 - a_3||a_3 - a_4|x_3 &= |a_4 - a_3|L_2 - |a_2 - a_4|L_3 + |a_2 - a_3|L_4 \\ &= |a_4 - a_3| - |a_2 - a_4| + |a_2 - a_3| = 0 \end{aligned}$$

ដូច្នេះ យើងទាញបាន $x_2 = x_3 = 0$ ហើយនាំឱ្យ $x_1 = x_4 = 1/|a_1 - a_4|$ ។ ឫសនេះផ្ទៀងផ្ទាត់ប្រព័ន្ធសមីការដែលឱ្យ ។ ចម្លើយផ្សេងទៀតជាចំលាស់នៃចម្លើយមួយនេះ ។

**174.** ▲ បើមួយក្នុងចំណោម $x, y, z$ ស្មើ 1 ឬ $-1$ នោះ $(-1, -1, -1)$ និង $(1,1,1)$ ។ ប្រព័ន្ធគ្មានចម្លើយផ្សេងពីនេះទេ ។ តាង $f(t) = t^2 + t - 1$ ។ បើក្នុងចំណោម $x, y, z$

មានមួយធំជាង 1 សន្មតថា $x > 1$ យើងមាន $x < f(x) = y < f(y) = y < f(y) = z < f(z) = x$ មិនអាច ។ ដូច្នេះ $x, y, z \leq 1$ ។

ឥលូវសន្មតថា មានមួយក្នុងចំណោម $x, y, z$ សន្មតថា $x$ មានតម្លៃតូចជាង $-1$ ។ ដោយ $\min f = -5/4$ នោះ យើងមាន $x = f(z) \in [-5/4; -1)$ ។ ដោយ

$f([-5/4; -1)) = (-1; -11/16) \subseteq (-1; 0)$ និង $f((-1; 0)) = [-5/4; -1)$

ដូច្នេះ $y = f(x) \in (-1; 0), z = f(y) \in [-5/4; -1)$ និង $x = f(z) \in (-1,0)$

ផ្ទុយពីការសន្មត ។ ដូច្នេះ $-1 \leq x, y, z \leq 1$ ។

បើ $-1 < x, y, z < 1$ នោះ $x > f(x) = y > f(y) = z > f(z) = x$ មិនអាច ។

**175.** $(-2; -1); (-14/3; 13/3)$.

**176.** ▲ តាង $S_k = x_1^k + x_2^k + \cdots + x_n^k$ និង តាង $\sigma_k, k = 1,2, \ldots, n$ ជាពហុធាស៊ីមេទ្រីបឋមទី$k$ នៃ $x_1, x_2, \ldots, x_n$ ។ ប្រព័ន្ធសមីការដែលឱ្យ $S_k = a^k, k = 1,2, \ldots, n$ ។

តាមរូបមន្តញូតុន យើងទាញបាន

$$k\sigma_k = S_1\sigma_{k-1} - S_2\sigma_{k-2} + \cdots + (-1)^k S_{k-1}\sigma_1 + (-1)^{k-1} S_k, k = 1,2, \ldots, n$$

$$\sigma_1 = a$$

$$k\sigma_2 = S_1\sigma_1 + (-1)^1 S_2 = a.a - a^2 = 0, \sigma_2 = 0$$

$$\ldots$$

$$\Longrightarrow \sigma_1 = a; \;\; \sigma_k = 0 \text{ ចំពោះ } k = 2, \ldots, n$$

តាមទ្រឹស្តីបទវៀត $x_1, x_2, \ldots, x_n$ ជាឫសនៃពហុធា $x^n - ax^{n-1}$ មានន័យថា ឫសទាំងនោះស្មើនឹង $a, 0, \ldots, 0$ និងចំលាស់ទាំងអស់ ។

**177.** ▲ បើ $m \notin \{-2; 1\}$ នោះប្រព័ន្ធមានឫសតែមួយគត់

$$x = \frac{b + a - (1+m)c}{(2+m)(1-m)}; y = \frac{a + c - (1+m)b}{(2+m)(1-m)}; z = \frac{b + c - (1+m)a}{(2+m)(1-m)}$$

ចំនួន $x, y, z$ ជាស៊ីតនព្វន្ត បើនិងមានតែបើ $a, b, c$ ជាស៊ីតនព្វន្តដែរ ។

បើ $m = 1$ នោះប្រព័ន្ធមានចម្លើយ បើនិងមានតែបើ $a = b = c$ ។ ករណី $m = -2$ ប្រព័ន្ធមានចម្លើយ បើនិងមានតែបើ $a + b + c = 0$ ។ នៅក្នុងករណីទាំងពីរនេះ ប្រព័ន្ធមានចម្លើយច្រើនរាប់មិនអស់ ។

**178.** ▲ យើងមាន $c_n > 0$ ចំពោះគ្រប់ $n$ គូ ។ ដូច្នេះ $c_n = 0$ អាចបានតែចំពោះ $n$ សេសតែប៉ុណ្ណោះ ។ សន្មតថា $a_1 \leq a_2 \leq \cdots \leq a_8$ ហើយថា $a_1 \leq 0 \leq a_8$ ។ បើ $|a_1| < |a_8|$ នោះមាន $n_0$ ដែលចំពោះគ្រប់ចំនួនសេស $n > n_0$ យើងមាន $7|a_1|^n < a_8^n$ ។ ដូច្នេះ $a_1^n + a_2^n + \cdots + a_8^n > 7a_1^n + a_8^n > 0$ ផ្ទុយពីលក្ខខណ្ឌដែលថា $c_n = 0$ ចំពោះតំលៃ $n$ ច្រើនរាប់មិនអស់ ។ ដូចគ្នាករណី $|a_1| > |a_8|$ ក៏មិនអាចដែរ ។ យើងទាញបាន $a_1 = -a_8$ ។ តាមរបៀបដូចគ្នា យើងទាញបាន $a_2 = -a_7; a_3 = -a_6$ និង $a_4 = -a_5$ ។ ហើយ $c_n = 0$ ចំពោះគ្រប់ចំនួនសេស $n$ ។

**179.** ▲ តាង $X = 1 - x; Y = 1 - y; Z = 1 - z; T = 1 - t$ ។ យើងទាញបាន

$$\begin{cases} X^2 = Y \\ Y^2 = Z \\ Z^2 = T \\ T^2 = X \end{cases}$$

យើងទាញបាន $X^4 = Y^2 = Z \implies X^8 = Z^2 = T \implies X^{16} = T^2 = X \implies X(X^{15} - 1) = 0$ ។ យើងទាញបាន

- $X = 0; \implies Y = Z = T = 0 \implies x = y = z = t = 1$

- $X = 1; \implies Y = Z = T = 1 \implies x = y = z = t = 0$

**180.** ▲ បូកសមីការទាំងអស់បញ្ចូលគ្នា យើងទាញបាន

$$0 = \sum_{i=1}^{1000} \left( x_i^2 + 2\left(\frac{a-1}{2}\right) x_i + \left(\frac{a-1}{2}\right)^2 \right) = \sum_{i=1}^{1000} \left( x_i + \frac{a-1}{2} \right)^2$$

យើងទាញបាន $x_1 = x_2 = \cdots = x_{1000} = (a-1)/2$ ។

**181.** ▲ តាង $t_1 = x_1 - x_2; t_2 = x_2 - x_3; \ldots; t_n = x_n - x_1$ ។ ប្រព័ន្ធសមីការសមមូលនឹង

$$\begin{cases} 2t_1 = 3t_2 \\ 2t_2 = 3t_3 \\ \quad \ldots\ldots \\ 2t_n = 3t_1 \end{cases}$$

គុណអង្គនឹងអង្គនៃសមីការ យើងទាញបាន $2^n t_1 t_2 \dots t_n = 3^n t_1 t_2 \dots t_n \Rightarrow$ $t_1 t_2 \dots t_n = 0$ ។ ដូច្នេះត្រូវមាន $t_i$ មួយដែលស្មើសូន្យ ។ ហើយដោយ $2t_i = 3t_{i+1}$ នោះ យើងទាញបាន $t_1 = t_2 = \dots = t_n = 0$ ហើយ $x_1 = x_2 = \dots = x_n$ ។

**182.** ▲ យើងមាន $3S = x^2 + y^2 + z^2 \geq 0 \Rightarrow S = x + y + z \geq 0$ ។ ដូច្នេះក្នុងចំណោម $x, y, z$ ត្រូវតែមានមួយជាចំនួនមិនអវិជ្ជមាន ។ សន្មតថា $x \geq 0$ ។ យើងទាញបាន

$$y(4 - y) = x \geq 0 \Rightarrow 0 \leq y \leq 4$$

ដូចគ្នាយើងទាញបាន $0 \leq x, y, z \leq 4$ ។ តាង $x = 4\sin^2\alpha$ ដែល $0 \leq \alpha \leq \frac{\pi}{2}$ ។ យើងទាញបាន $z = 4\sin^2 2\alpha\,; y = 4\sin^2 4\alpha$ ។ ហើយ $x = 4\sin^2 8\alpha$ ។ ដូច្នេះ

$$4\sin^2 8\alpha = 4\sin^2\alpha \Rightarrow \cos 16\alpha = \cos 2\alpha$$

នាំឱ្យ

1) $16\alpha = 2\alpha + 2k\pi \Rightarrow \alpha = \frac{k\pi}{7}\ (k \in \mathbb{Z});$

$$0 \leq \alpha \leq \frac{\pi}{2} \Rightarrow k = \{0; 1; 2; 3\}$$

- $k = 0$

$$x = y = 0; \Rightarrow S = 0$$

-$k = 1; 2; 3$

$$\Rightarrow S = 4\left(\sin^2\frac{\pi}{7} + \sin^2\frac{2\pi}{7} + \sin^2\frac{3\pi}{7}\right) = 7$$

2) $16\alpha = -2\alpha + 2k\pi \Rightarrow \alpha = \frac{k\pi}{9}\ (k \in \mathbb{Z});$

$$0 \leq \alpha \leq \frac{\pi}{2} \Rightarrow k = \{0; 1; 2; 3; 4\}$$

- $k = 0$

$$x = y = 0; \Rightarrow S = 0$$

- $k = 1; 2; 4$

$$\Rightarrow S = 4\left(\sin^2\frac{\pi}{9} + \sin^2\frac{2\pi}{9} + \sin^2\frac{4\pi}{9}\right) = 6$$

- $k = 3$

$$\Rightarrow S = 4\left(\sin^2\frac{\pi}{3} + \sin^2\frac{2\pi}{3} + \sin^2\frac{4\pi}{3}\right) = 9$$

**183.** $\{(1;1;1);(-2;-2;-2)\}$ ▲ យកសមីការទីមួយដកសមីការទីពីរ សមីការទីពីរដកសមីការទីបី យើងទាញបាន

$$(x-y)(1-z)=0; \quad (1)$$
$$(y-z)(1-x)=0 \quad (2)$$

$(1) \Longrightarrow \ x=y$ ឬ $z=1$

$(2) \Longrightarrow \ y=z$ ឬ $x=1$

យើងទាញបានបួនករណី

$$(x=y=z);(x=y;x=1);(z=1;y=z);(z=1;x=1)$$

ករណីទាំងបួននេះ ត្រូវនឹង $x=y=z=1$ ឬ $x=y=z=-2$ ។

**184.** ▲ យើងសិក្សាករណី $a>0$ ព្រោះ $a\neq 0$ ។ ករណី $a<0$ គុណអង្គសមីការនឹងសញ្ញាដក ។

បូកសមីការទាំងបីនៃប្រព័ន្ធបញ្ចូលគ្នា យើងទាញបាន

$$[ax^2+(b-1)x+c]+[ay^2+(b-1)y+c]+[az^2+(b-1)z+c]=0$$

តាង $f(t)=at^2+(b-1)t+c$ ។ យើងមាន

$$f(x)+f(y)+f(z)=0 \qquad (*)$$

បើ $\Delta=(b-1)^2-4ac<0$ នោះ $f(t)>0$ ចំពោះគ្រប់ $t\in\mathbb{R}$ ព្រោះ $a>0$ ។

ដូច្នេះ

$$f(x)+f(y)+f(z)>0$$

ផ្ទុយពីសមីការ(*) ។

**185.** ▲ ជំនួស $y=-x$ ចូលក្នុងប្រព័ន្ធ យើងទាញបាន

$$\begin{cases} x^3+ax^3=\frac{1}{2}(a+1)^2 & (1)\\ 2x^3-ax^3=1 & (2)\end{cases}$$

សមីការទី២ យើងទាញបាន $x\neq 0$ ។ បូកសមីការទាំងពីរចូលគ្នា យើងទាញបាន

$$3x^3=\frac{1}{2}(a+1)^2+1>0; \Rightarrow x>0$$

យកសមីការទី១ចែកនឹងសមីការទី២ យើងទាញបាន

$$\frac{a+1}{2-a}=\frac{1}{2}(a+1)^2 \ \Rightarrow a=0;\ -1;1$$

ចំពោះ $a = 0$ យើងមាន

$$\begin{cases} x^3 = \dfrac{1}{2} \\ x^3 + xy^2 = 1 \end{cases} \Leftrightarrow \begin{cases} x = \dfrac{1}{\sqrt[3]{2}} \\ y = \pm\dfrac{1}{\sqrt[3]{2}} \end{cases}$$

ឫសដែលផ្ទៀងផ្ទាត់គឺ $x = 1/\sqrt[3]{2}\,; y = -1/\sqrt[3]{2}$ ។

ចំពោះ $a = -1$ យើងទាញបាន

$$\begin{cases} x^3 + y^3 = 0 \\ x^3 - x^2y + xy^2 = 1 \end{cases} \Rightarrow \begin{cases} x = \dfrac{1}{\sqrt[3]{3}} \\ y = -\dfrac{1}{\sqrt[3]{3}} \end{cases}$$

ចំពោះ $a = 1$ យើងទាញបាន

$$\begin{cases} x^3 - y^3 = 2 \\ x^3 + x^2y + xy^2 = 1 \end{cases} \Rightarrow \begin{cases} x^3 - y^3 = 2 \\ 2x^3 + 2x^2y + 2xy^2 = 2 \end{cases}$$
$$\Rightarrow x^3 + 2x^2y + 2xy^2 + y^3 = 0$$
$$\Rightarrow (x+y)(x^2 - xy + y^2) + 2xy(x+y) = 0$$
$$\Rightarrow (x+y)(x^2 + xy + y^2) = 0$$
$$\Rightarrow x + y = 0$$
$$\Rightarrow x = 1; y = -1$$

ដូច្នេះ $a = \{-1; 0; 1\}$ ប្រព័ន្ធមានឫសផ្ទៀងផ្ទាត់ លក្ខខណ្ឌ ។

**186.** ▲ប្រព័ន្ធសមមូលនឹង

$$\begin{cases} 3x^2 - 2(3+z)x + 3z + 3 = 0 \quad (1) \\ y^3 + 3y^2 = x^2 - 3x + 2 \quad (2) \\ y^2 = -z^2 + 6z \quad (3) \\ z \le 3 \quad (4) \end{cases}$$

សមីការ(១) មានឫស បើ $\Delta' = (3+z)^2 - 3(3z+3) \ge 0 \quad \Rightarrow z \le 0\,; z \ge 3$ (៥) ។ សមីការទីពីរមានឫសបើ $-z^2 + 6z \ge 0 \quad \Rightarrow 0 \le z \le 6$ (៦) ។ ពី(៤) (៥)(៦)យើងទាញបាន $z = 0; z = 3$ ។

បើ $z = 0$ នោះ តាម(៣) យើងទាញបាន $y = 0;$ និងពី(២) យើងទាញបាន $x = 1; x = 2$ ។ ផ្ទៀងផ្ទាត់តាម(១) យើងទាញបាន $x = 1$ ។

បើ $z=3$ នោះ តាម(៣) យើងទាញបាន $y=\pm 3$ ។ ពី(១) យើងទាញបាន $x=2$ ។

ចំពោះ $x=2$ ផ្ទៀងផ្ទាត់តាម(២) យើងទាញបាន $y=-3$ ។ ដូច្នេះ

$$(x;y;z)=\{(1;0;0);(2;-3;3)\}$$

**187.** ▲ គុណសមីការទីមួយទីពីរនិងទីបី នឹង $c,a,b$ រៀងគ្នា យើងទាញបាន

$$\begin{cases}\dfrac{ac}{x}-\dfrac{bc}{z}=c^2-czx\\ \dfrac{ab}{y}-\dfrac{ac}{x}=a^2-axy\\ \dfrac{bc}{z}-\dfrac{ab}{y}=b^2-byz\end{cases}$$

បូកសមីការទាំងបីបញ្ចូលគ្នា យើងទាញបាន

$$a^2+b^2+c^2=axy+bzy+cxz \qquad (1)$$

បំបាត់ភាគបែងនៃប្រព័ន្ធដើម

$$\begin{cases}az-bx=cxz-z^2x^2\\ bx-cy=axy-x^2y^2\\ cy-az=bzy-y^2z^2\end{cases}$$

បូកបញ្ចូលគ្នា យើងទាញបាន

$$x^2y^2+y^2z^2+z^2x^2=axy+bzy+cxz \qquad (2)$$

បូក(១)នឹង(២) យើងទាញបាន

$$\begin{aligned}&a^2+b^2+c^2+x^2y^2+y^2z^2+z^2x^2=2(axy+bzy+cxz)\\ \Longrightarrow\ &(xy-a)^2+(zy-b)^2+(xz-c)^2=0\\ \Longrightarrow\ &\begin{cases}xy=a\\ zy=b\\ xz=c\end{cases}\end{aligned}$$

$$\Longrightarrow\quad (x;y;z)=\left\{\left(\sqrt{\frac{ac}{b}};\sqrt{\frac{ab}{c}};\sqrt{\frac{bc}{a}}\right);\left(-\sqrt{\frac{ac}{b}};-\sqrt{\frac{ab}{c}};-\sqrt{\frac{bc}{a}}\right)\right\}$$

**188.** ▲ ប្រព័ន្ធមានឫសងាយ $(0;0;0)$ ។ បើ $x=\pm 1$ នោះ $\pm 2+y=y$ មិនអាច ។

ដូចគ្នាយើងទាញបាន $x\neq\pm 1; y\neq\pm 1; z\neq\pm 1$ ។ យើងមាន

$$\begin{cases}2x+x^2y=y\\2y+y^2z=z\\2z+z^2x=x\end{cases}\Leftrightarrow\begin{cases}y=\dfrac{2x}{1-x^2}\quad(4)\\z=\dfrac{2y}{1-y^2}\quad(5)\\x=\dfrac{2z}{1-z^2}\quad(6)\end{cases}$$

តាង $x=\tan\alpha\neq\pm1\ \Rightarrow\alpha\neq\pm\frac{\pi}{4}+k\frac{\pi}{2},k\in\mathbb{Z}$ ។ ពី(៤) យើងទាញបាន $y=\tan2\alpha$ និងពី(៥) យើងទាញបាន $z=\tan4\alpha$ ហើយជាចុងក្រោយ $x=\tan8\alpha=\tan\alpha$ ។ ដូច្នេះ

$$8\alpha=\alpha+n\pi\ \Rightarrow\ \alpha=n\frac{\pi}{7}\ ;(n\in\mathbb{Z})$$

ដូច្នេះប្រព័ន្ធមានឫស $(x;y;z)=\{(\tan n\pi/7\,;\tan n\,2\pi/7\,;\tan n\,4\pi/7)|n\in\mathbb{Z}\}$

**189.** ▲តាមវិសមភាពកូស៊ីស្វាត

$$(x^4+x^2y^2+y^4)(1+1+1)\geq(x^2+xy+y^2)^2$$
$$(y^4+y^2z^2+z^4)(1+1+1)\geq(y^2+yz+z^2)^2$$
$$(z^4+z^2x^2+x^4)(1+1+1)\geq(z^2+zx+x^2)^2$$
$$\Rightarrow27(x^4+x^2y^2+y^4)(y^4+y^2z^2+z^4)(z^4+z^2x^2+x^4)$$
$$\geq[(x^2+xy+y^2)(y^2+yz+z^2)(z^2+zx+x^2)]^2$$
$$=[xyz]^2$$
$$\Rightarrow27\,x^3y^3z^3\geq x^2y^2z^2$$

$$\Rightarrow xyz\geq\frac{1}{27}\qquad(1)$$

សញ្ញាស្មើកើតមានពេល $|x|=|y|=|z|$ ។ យើងឃើញថា ផលគុណ $xyz$ វិជ្ជមាន ។ តាមវិសមភាពកូស៊ី

$$x^4+x^2y^2+y^4\geq3\sqrt[3]{x^6y^6}=3x^2y^2$$
$$y^4+y^2z^2+z^4\geq3y^2z^2$$
$$z^4+z^2x^2+x^4\geq3z^2x^2$$
$$\Rightarrow\ (x^4+x^2y^2+y^4)(y^4+y^2z^2+z^4)(z^4+z^2x^2+x^4)\geq27x^4y^4z^4$$
$$\Rightarrow x^3y^3z^3\geq27\,x^4y^4z^4$$

ដោយ $xyz>0$ នោះ

$$\Rightarrow xyz\leq\frac{1}{27}\qquad(2)$$

សញ្ញាស្មើកើតមានពេល $|x|=|y|=|z|$ ។

តាម (1) និង (2) យើងទាញបាន $xyz = 1/27$ និង $|x| = |y| = |z|$ ។

ករណីចំនួនទាំងបីសុទ្ធតែវិជ្ជមាន យើងទាញបាន $x = y = z = 1/3$ ។

ករណីមានពីរ អវិជ្ជមាន សន្មតថា $x, y$ អវិជ្ជមាន ។ យើងទាញបាន $z = 1/3, x = y = -1/3$ ។ ជំនួសចូលសមីការទីមួយនៃប្រព័ន្ធ យើងទាញបាន

$$\left[\left(-\frac{1}{3}\right)^2 + \left(-\frac{1}{3}\right)\left(-\frac{1}{3}\right) + \left(-\frac{1}{3}\right)^2\right]\left[\left(-\frac{1}{3}\right)^2 + \left(-\frac{1}{3}\right)\left(\frac{1}{3}\right) + \left(\frac{1}{3}\right)^2\right]\left[\left(\frac{1}{3}\right)^2 + \left(\frac{1}{3}\right)\left(-\frac{1}{3}\right) + \left(-\frac{1}{3}\right)^2\right] = \frac{1}{27}$$

$$\Leftrightarrow \frac{1}{3}.\frac{1}{9}.\frac{1}{9} = \frac{1}{27}$$

មិនផ្ទៀងផ្ទាត់ ។ ដូច្នេះប្រព័ន្ធសមីការមានឫស $(x, y, z) = (1/3, 1/3, 1/3)$ ។

**190.** ▲ក) យើងនឹងស្រាយបញ្ជាក់វិសមភាព

$$\frac{1}{\sqrt{1+a^2}} + \frac{1}{\sqrt{1+b^2}} \le \frac{2}{\sqrt{1+ab}}; \ \forall a, b \in \left[0; \frac{1}{\sqrt{2}}\right]$$

លើកអង្គទាំងពីរជាការេ យើងទាញបាន

$$\frac{2}{\sqrt{1+a^2}\sqrt{1+b^2}} + \frac{1}{1+a^2} + \frac{1}{1+b^2} - \frac{4}{1+ab} \le 0 \qquad (*)$$

យើងមានវិសមភាព

$$\sqrt{(1+a^2)(1+b^2)} \ge 1 + ab$$
$$\Rightarrow \frac{2}{\sqrt{(1+a^2)(1+b^2)}} \le \frac{2}{1+ab}$$
$$\Rightarrow \frac{2}{\sqrt{(1+a^2)(1+b^2)}} - \frac{2}{1+ab} \le 0 \qquad (**)$$

យើងមានវិសមភាព

$$\frac{1}{1+a^2} + \frac{1}{1+b^2} - \frac{2}{1+ab} = \frac{(a-b)^2(ab-1)}{(1+ab)(1+a^2)(1+b^2)} \le 0 \quad (***)$$

ព្រោះ $\forall a, b \in \left[0; \frac{1}{\sqrt{2}}\right]$ និង $ab < 1$ ។ តាម(**) និង (***) យើងទាញបាន (*) ពិត ។

ខ) ដែនកំណត់របស់សមីការ

$$\begin{cases} 0 \le x \le \dfrac{1}{2} \\ 0 \le y \le \dfrac{1}{2} \end{cases}$$

$\Longrightarrow\quad \sqrt{2}x,\sqrt{2}y\in\left[0;\frac{1}{\sqrt{2}}\right],\sqrt{2}x.\sqrt{2}y<1$ ។ ជំនួស $a=\sqrt{2}x,b=\sqrt{2}y$ ចូលក្នុង វិសមភាព (*) យើងទាញបាន

$$\frac{1}{\sqrt{1+2x^2}}+\frac{1}{\sqrt{1+2x^2}}\le\frac{2}{\sqrt{1+2xy}}$$

អង្គទាំងពីរស្មើគ្នាទាល់តែ $x=y$ ។ ជំនួសចូលសមីការទីពីរ យើងទាញបាន

$$x=y=\frac{9+\sqrt{73}}{36};\ \ x=y=\frac{9-\sqrt{73}}{36}$$

**191.** ▲ តាង

$$A=\sqrt[3]{\frac{x^3-3x+(x^2-1)\sqrt{x^2-4}}{2}}+\sqrt[3]{\frac{x^3-3x-(x^2-1)\sqrt{x^2-4}}{2}}$$

យើងមាន $A^3=x^3-3x+3AB$ ដែល

$$B=\sqrt[3]{\frac{x^3-3x+(x^2-1)\sqrt{x^2-4}}{2}}.\sqrt[3]{\frac{x^3-3x-(x^2-1)\sqrt{x^2-4}}{2}}$$

$$=\sqrt[3]{\frac{(x^3-3x)^2-(x^2-1)^2(x^2-4)}{4}}=1$$

ដូច្នេះ $\quad A^3-x^3-3x+3A=0$

$$\Leftrightarrow(A-x)(A^2+Ax+x^2-3)=0$$

ដោយ $A>0;x\ge 2;x^2-3>0$ នោះ $A=x$ ។ ដូច្នេះ

$$\begin{cases}x=\sqrt{x+2002}\\x\ge 2\end{cases}\ \Leftrightarrow\ \begin{cases}x^2-x-2002=0\\x\ge 2\end{cases}$$

$$\Longrightarrow\quad x=\frac{1+\sqrt{8009}}{2}$$

**192.** ▲ យើងមាន $\quad a^2-bc=(x^2-yz)^2-(y^2-xz)(z^2-xy)=$ $x(x^3+y^3+z^3-3xyz)$

$$b^2-ca=y(x^3+y^3+z^3-3xyz)$$
$$c^2-ab=z(x^3+y^3+z^3-3xyz)$$

តាង $k=x^3+y^3+z^3-3xyz$ ។ យើងមាន

$$(a^2-bc)^2-(b^2-ca)(c^2-ab)=a(a^3+b^3+c^3-3abc)$$
$$\Longrightarrow\quad k^2(x^2-yz)=a(a^3+b^3+c^3-3abc)$$
$$\Longrightarrow k=\pm\sqrt{a^3+b^3+c^3-3abc}$$

ដូច្នេះប្រព័ន្ធមានឫស

$$x=\frac{a^2-bc}{k};y=\frac{b^2-ca}{k};z=\frac{c^2-ab}{k}$$

**193.▲** តាង $S=x+y;P=xy$ ។ យើងមាន

$$\begin{cases} S+P=m \\ S^2-2P=m \end{cases}$$

1) ចំពោះ $m=5$ យើងមាន

$$\begin{cases} S+P=5 \\ S^2-2P=5 \end{cases}$$
$$\Rightarrow \ S=\left[\begin{matrix}-5 \\ 3\end{matrix}\right.$$

ចំពោះ $S=-5; \Rightarrow P=10$ ។ យើងមាន $\Delta=S^2-4P=25-40=-15<0$

គ្មានឫស ។

ចំពោះ $S=3; \Rightarrow P=2$ នាំឱ្យ

$$\begin{cases} x=2 \\ y=1 \end{cases};\begin{cases} x=1 \\ y=2 \end{cases}$$

2) សមីការទី១នាំឱ្យ $P=m-S$ ជំនួសចូលសមីការទី២ យើងទាញបាន

$$S^2+2S-3m=0 \quad (*)$$

ដើម្បីឱ្យវាមានឫស នោះចាំបាច់ត្រូវតែ

$$\Delta'=1+3m\geq 0 \ \Rightarrow m\geq -\frac{1}{3}$$

ក្នុងករណីនេះ(*) មានឫសពីរ $S_1;S_2$ ដែល

$$S_1=-1-\sqrt{1+3m};\ S_2=-1+\sqrt{1+3m}$$

ក) ចំពោះ $S=S_1 \ \Rightarrow P=m-S$ ។ លក្ខខណ្ឌ $S^2\geq 4P$ សមមូលនឹង

$$\left(1+\sqrt{1+3m}\right)^2\geq 4\left(m+1+\sqrt{1+3m}\right) \ \Rightarrow \ -(m+2)\geq 2\sqrt{1+3m}$$

គ្មានឫសព្រោះ $m\geq -\frac{1}{3} \ \Rightarrow m+2>0$ ។

ខ) ចំពោះ $S=S_2 \ \Rightarrow P=m-S$ ។ លក្ខខណ្ឌ $S^2\geq 4P$ សមមូលនឹង

$$\left(-1+\sqrt{1+3m}\right)^2\geq 4\left(m+1-\sqrt{1+3m}\right) \ \Rightarrow \ 2\sqrt{1+3m}\geq m+2>0$$
$$\Rightarrow 4(1+3m)\geq m^2+4m+4 \ \Rightarrow 0\geq m^2-8m \ \Rightarrow 0\leq m\leq 8$$

**194.▲** យើងមាន

$$(a+\ b+c+d)^2\ =a^2+b^2+c^2+d^2+2(ab+ac+ad+bc+bd+cd)$$
$$\Rightarrow 20^2=a^2+b^2+c^2+d^2+2(150)$$

$\Longrightarrow\ a^2+b^2+c^2+d^2=100$

តែ

$$\begin{aligned}100 &= \frac{1}{3}[(a^2+b^2)+(a^2+c^2)+(a^2+d^2)+(b^2+c^2)+(b^2+d^2)\\ &\qquad +(c^2+d^2)]\\ &\geq \frac{2}{3}[ab+ac+ad+bc+bd+cd]\\ &= \frac{2}{3}(150)=100\end{aligned}$$

ដូច្នេះ អង្គទាំងពីរស្មើគ្នាបើនិងមានតែ $a=b=c=d\ \Longrightarrow a=b=c=d=5$ ។

**195.** ▲ ជំនួស $a,b,c$ ចូលក្នុងប្រព័ន្ធសមីការ

$$\begin{cases}a^3-abc=2\\ b^3-abc=6\\ c^3-abc=20\end{cases}\quad (*)$$

តាង $abc=p$ យើងទាញបាន

$$a=\sqrt[3]{2+p};b=\sqrt[3]{6+p};c=\sqrt[3]{20+p}$$

ដូច្នេះ

$$\begin{aligned}&p=abc=\sqrt[3]{2+p}.\sqrt[3]{6+p}.\sqrt[3]{20+p}\\ &\Longrightarrow p^3=(2+p)(6+p)(20+p)\\ &\Longrightarrow p=\left\{-4;\ -\frac{15}{7}\right\}\end{aligned}$$

រួចបូកសមភាព (*) ចូលគ្នា យើងទទួលបាន

$$a^3+b^3+c^3=28+3abc=28+3p$$

ចំពោះ $p=-15/7$ ( $a^3+b^3+c^3$ ធំបំផុត) យើងមាន

$$a^3+b^3+c^3=28+3\left(-\frac{15}{7}\right)=\frac{151}{7}=\frac{m}{n}$$

ដូច្នេះ $m+n=151+7=158$ ។

**196.** ▲ ពីសមីការទីមួយ យើងមាន $x=2-y$ ជំនួសចូលសមីការទីពីរ យើងទទួលបាន

$$\begin{aligned}&2y-y^2-z^2=1\ \Leftrightarrow z^2+y^2-2y+1=0\\ &\Leftrightarrow z^2+(y-1)^2=0\end{aligned}$$

តួនីមួយៗក្នុងសមីការក្រោយនេះ សុទ្ធតែជាចំនួនមិនអវិជ្ជមាន ដូច្នេះតួនីមួយៗ ត្រូវតែស្មើសូន្យ ។ ដូច្នេះ $z = 0$ និង $y = 1$ នាំឱ្យ $x = 1$ ។

ដូច្នេះប្រព័ន្ធសមីការមានចម្លើយមួយគត់ គឺ $(x, y, z) = (1,1,0)$ ។

**197.** ▲ ប្រព័ន្ធសមីការមានលក្ខណៈឆ្លុះធៀបនឹង $a, b, c, d$ មានន័យថា បើយើងជំនួស $a$ ដោយ $b$ និង $b$ ដោយ $a$ យើងទទួលបានប្រព័ន្ធសមីការដដែល ។ល។ ដូច្នេះយើងអាចសន្មតថា $a \geq b \geq c \geq d$ សិន បាន ។ យើងឃើញថា $a, b, c, d \geq 0$ ។ដូច្នេះ

$$\begin{aligned}&(b + c + d)^{2010} \leq (a + c + d)^{2010} \leq (a + b + d)^{2010} \leq (a + b + c)^{2010}\\ &\Rightarrow 3a \leq 3b \leq 3c \leq 3d\\ &\Rightarrow a \leq b \leq c \leq d\end{aligned}$$

តែ $a \geq b \geq c \geq d$ ដូច្នេះ មានតែ $a = b = c = d$ ។ យើងទាញបាន

$$(3a)^{2010} = 3a \Rightarrow a = 0; a = \frac{1}{3}$$

ដូច្នេះប្រព័ន្ធសមីការមានឫស $(a, b, c, d) = \{(0,0,0,0); (1/3, 1/3, 1/3, 1/3)\}$ ។

**198.** ▲❶ វិធីទី១

សមីការទីពីរសមមូលនឹង

$$\frac{a^2}{yz} + \frac{b^2}{zx} + \frac{c^2}{xy} + \frac{abc}{xyz} = 4$$

តាង

$$x_1 = \frac{a}{\sqrt{yz}}, y_1 = \frac{b}{\sqrt{zx}}, z_1 = \frac{c}{\sqrt{xy}}$$

ដូច្នេះ

$$x_1^2 + y_1^2 + z_1^2 + x_1y_1z_1 = 4 \quad (*)$$

ដូច្នេះ $0 < x_1, y_1, z_1 < 2$ ។ យើងចាត់ទុកសមីការ (*) ជាសមីការដឺក្រេទី២អញ្ញាត $z_1$ ។ យើងមាន

$$\begin{aligned}\Delta &= (x_1y_1)^2 - 4(x_1^2 + y_1^2 - 4) = 16 - 4x_1^2 - 4y_1^2 + (x_1y_1)^2\\ &= (4 - x_1^2)(4 - y_1^2)\end{aligned}$$

តាង $x_1 = 2\sin u, y_1 = 2\sin v$ ដូច្នេះ $0 < u, v < \pi/2$ ។ ដូច្នេះ

$$\Delta = 16\cos^2 u \cos^2 v$$

$$\Rightarrow z_1 = \frac{-x_1y_1 \pm \sqrt{\Delta}}{2} = \frac{-4\sin u \sin v \pm 4\cos u \cos v}{2}$$

តែ $z > 0$ ដូច្នេះ

$$z_1 = \frac{-4\sin u \sin v + 4\cos u \cos v}{2} = 2(\cos u \cos v - \sin u \sin v)$$

ដូច្នេះ

$$a = x_1\sqrt{yz} = 2\sqrt{yz}\sin u$$
$$b = y_1\sqrt{zx} = 2\sqrt{zx}\sin v$$
$$c = z_1\sqrt{yx} = 2\sqrt{yx}(\cos u \cos v - \sin u \sin v)$$

តាមសម្មតិកម្ម

$x + y + z = a + b + c$

$\Rightarrow x + y + z = 2\sqrt{yz}\sin u + 2\sqrt{zx}\sin v + 2\sqrt{yx}(\cos u \cos v - \sin u \sin v)$

$\Leftrightarrow x(\cos^2 v + \sin^2 v) + y(\cos^2 u + \sin^2 u) + z$

$\qquad = 2\sqrt{yz}\sin u + 2\sqrt{zx}\sin v + 2\sqrt{yx}(\cos u \cos v - \sin u \sin v)$

$\Leftrightarrow x\cos^2 v + 2\sqrt{xy}\cos u \cos v + y\cos^2 u + x\sin^2 v + y\sin^2 u + z$

$\qquad - 2\sqrt{yz}\sin u - 2\sqrt{zx}\sin v + 2\sqrt{yx}\sin u \sin v = 0$

$\Leftrightarrow \left(\sqrt{x}\cos v - \sqrt{y}\cos u\right)^2 + \left(\sqrt{x}\sin v + \sqrt{y}\sin u - \sqrt{z}\right)^2 = 0$

ដូច្នេះ

$$\begin{cases} \sqrt{x}\cos v = \sqrt{y}\cos u & (1) \\ \sqrt{z} = \sqrt{x}\sin v + \sqrt{y}\sin u & (2) \end{cases}$$

សមីការ (2) នាំឱ្យ

$$\sqrt{z} = \sqrt{x}\sin v + \sqrt{y}\sin u = \sqrt{x}.\frac{y_1}{2} + \sqrt{y}.\frac{x_1}{2} = \frac{1}{2}\left(\sqrt{x}.\frac{b}{\sqrt{zx}} + \sqrt{y}.\frac{a}{\sqrt{yz}}\right)$$

$$\Rightarrow z = \frac{a+b}{2}$$

ដូចគ្នា យើងទាញបាន

$$x = \frac{b+c}{2}; y = \frac{c+a}{2}$$

ដូច្នេះប្រព័ន្ធសមីការមានឫសតែមួយគត់គឺ

$$(x, y, z) = \left(\frac{b+c}{2}, \frac{a+c}{2}, \frac{a+b}{2}\right)$$

❷ វិធីទី២

តាង

$$x=\frac{b+c}{2}-u; y=\frac{c+a}{2}-v; z=\frac{a+b}{2}-w$$
$$\Rightarrow u<\frac{b+c}{2};\ \ v<\frac{c+a}{2};\ \ w<\frac{a+b}{2}$$

តាមសម្មតិកម្ម

$$x+y+z=a+b+c\ \Rightarrow u+v+w=0$$

និង

$$abc+a^2x+b^2y+c^2z=4xyz$$
$$\Leftrightarrow abc+a^2\left(\frac{b+c}{2}-u\right)+b^2\left(\frac{c+a}{2}-v\right)+c^2\left(\frac{a+b}{2}-w\right)$$
$$=4\left(\frac{b+c}{2}-u\right)\left(\frac{c+a}{2}-v\right)\left(\frac{a+b}{2}-w\right)$$
$$\Leftrightarrow abc+\frac{1}{2}a^2b+\frac{1}{2}a^2c-a^2u+\frac{1}{2}b^2c+\frac{1}{2}ab^2-b^2v+\frac{1}{2}ac^2+\frac{1}{2}bc^2-c^2w$$
$$=\frac{1}{2}(b+c-2u)(c+a-2v)(a+b-2w)$$
$$\Leftrightarrow 2abc+a^2b+a^2c-2a^2u+b^2c+ab^2-2b^2v+ac^2+bc^2-2c^2w$$
$$=(bc+ab-2bv+c^2+ac-2cv-2cu-2au+4uv)(a+b-2w)$$
$$\Leftrightarrow 2abc+a^2b+a^2c-2a^2u+b^2c+ab^2-2b^2v+ac^2+bc^2-2c^2w$$
$$=abc+b^2c-2bcw+a^2b+ab^2-2abw-2abv-2b^2v+4bvw+ac^2+bc^2-2c^2w+a^2c+abc-2acw-2acv-2bcv+4cvw-2acu-2bcu+4cuw-2a^2u-2abu+4auw+4auv+4buv-8uvw$$
$$\Leftrightarrow 0=-2bcw-2abw-2abv+4bvw-2acw-2acv-2bcv+4cvw-2acu-2bcu+4cuw-2abu+4auw+4auv+4buv-8uvw$$
$$\Leftrightarrow 0=-2bc(u+v+w)-2ab(u+v+w)+4bvw-2ac(u+v+w)+4cvw+4cuw+4auw+4auv+4buv-8uvw$$
$$\Leftrightarrow 0=4bvw+4cvw+4cuw+4auw+4auv+4buv-8uvw$$
$$\Leftrightarrow 0=4bv(u+w)+4cw(u+v)+4au(v+w)-8uvw$$
$$\Leftrightarrow 0=-4bv^2-4cw^2-4au^2-8uvw$$
$$\Leftrightarrow 0=au^2+bv^2+cw^2+2uvw\qquad(*)$$

សមភាពនេះអាចពិតទៅរួច ទាល់តែ $uvw\le 0$ ។ ដូច្នេះក្នុងចំណោម $u,v,w$ ត្រូវតែមានយ៉ាងណាស់ពីរ ដែលមានតម្លៃមិនអវិជ្ជមាន, សន្មតថា $u,v\ge 0$ ។ ជំនួស $w=-u-v$ ចូលក្នុងសមភាព(*) យើងទាញបាន

$$au^2+bv^2+c(-u-v)^2+2uv(-u-v)=0$$

$$\Leftrightarrow au^2+bv^2+cu^2+cv^2+2cuv-2u^2v-2uv^2=0$$
$$\Leftrightarrow (a+c-2v)u^2+(b+c-2u)v^2+2cuv=0$$

ដោយ $a+c-2v>0; b+c-2u>0; c>0$ ដូច្នេះ មានតែ $u=v=0$ ។

យើងទាញបាន

$$x=\frac{b+c}{2}; y=\frac{a+c}{2}; z=\frac{a+b}{2}$$

**199.** ▲ យកសមីការទី ១ ដកសមីការទី ២ និង សមីការទី ៥ ដកសមីការទី ៦ យើងទទួលបាន

$$\begin{cases}x_2-x_3=\alpha_1(\alpha_2-\alpha_3)\\ x_2-x_3=\alpha_4(\alpha_2-\alpha_3)\end{cases}$$
$$\Rightarrow \alpha_1(\alpha_2-\alpha_3)=\alpha_4(\alpha_2-\alpha_3)$$
$$\Rightarrow (\alpha_1-\alpha_4)(\alpha_2-\alpha_3)=0 \quad (1)$$

យកសមីការទី ២ ដកសមីការទី ៤ និង សមីការទី ៣ ដកសមីការទី ៥ យើងទទួលបាន

$$\begin{cases}x_1-x_2=\alpha_3(\alpha_1-\alpha_2)\\ x_1-x_2=\alpha_4(\alpha_1-\alpha_2)\end{cases}$$
$$\Rightarrow \alpha_3(\alpha_1-\alpha_2)=\alpha_4(\alpha_1-\alpha_2)$$
$$\Rightarrow (\alpha_1-\alpha_2)(\alpha_3-\alpha_4)=0 \quad (2)$$

សមីការ (1) នាំឱ្យ $\alpha_1=\alpha_4$ ឬ $\alpha_2=\alpha_3$ (អាចថា $\alpha_1=\alpha_4$ និង $\alpha_2=\alpha_3$ ដែរ) ។

យើងសន្មតថា $\alpha_2=\alpha_3=\alpha$ ។ ជំនួសចូល (2) យើងទទួលបាន

$$(\alpha_1-\alpha)(\alpha-\alpha_4)=0$$

ដូច្នេះ $\alpha_1=\alpha$ ឬ $\alpha_4=\alpha$ ។ ដូច្នេះ បើ $\alpha_2=\alpha_3=\alpha$ និង $\alpha_1=\alpha$ ឬមិនអ៊ីចឹងទេ $\alpha_4=\alpha$ នោះ (1) និង (2) ក្លាយជាសមភាព មានន័យថាសមីការទាំង៦ របស់ប្រព័ន្ធសមីការ ត្រូវគ្នា (សមីការ ៤ ផ្ទៀងផ្ទាត់សមីការទី៥ និង ទី៦ ផ្សេងទៀត) ដូច្នេះប្រព័ន្ធមានឫស ។ ដូច្នេះដើម្បីឱ្យប្រព័ន្ធសមីការ មានឫស ចាំបាច់ត្រូវតែមានប៉ារ៉ាម៉ែត្រយ៉ាងតិច ៣ ក្នុងចំណោម $\alpha_1,\alpha_2,\alpha_3,\alpha_4$ ដែលត្រូវតែស្មើគ្នា ។

ពេលនេះយើងសន្មតថា $\alpha_1=\alpha_2=\alpha_3=\alpha$ និង $\alpha_4=\beta$ ។ ដោយ $x_2-x_3=\alpha_1(\alpha_2-\alpha_3)$ និង $x_1-x_2=\alpha_3(\alpha_1-\alpha_2)$ នោះ $x_1=x_2=x_3$ ។

តាង $x_1=x_2=x_3=x$ និង $x_4=y$ ។ ដូច្នេះប្រព័ន្ធសមីការទៅជា

$$\begin{cases} 2x = \alpha^2 \\ 2x = \alpha^2 \\ x + y = \alpha\beta \\ 2x = \alpha^2 \\ x + y = \alpha\beta \\ x + y = \alpha\beta \end{cases} \Leftrightarrow \begin{cases} 2x = \alpha^2 \\ x + y = \alpha\beta \end{cases}$$

ដូច្នេះ

$$x = \frac{\alpha^2}{2}$$
$$y = \alpha\left(\beta - \frac{\alpha}{2}\right)$$

ដូច្នេះមានបីក្នុងចំណោម $x_1, x_2, x_3, x_4$ ដែលស្មើ $\alpha^2/2$ និងមួយទៀត ស្មើនឹង $\alpha(\beta - \alpha/2)$ ។

# ២.៥ វិសមភាព

**200.** ▲ តាង $A = \frac{1}{2}.\frac{3}{4}.\frac{5}{6}\dots.\frac{99}{100}; B = \frac{2}{3}.\frac{4}{5}.\frac{6}{7}\dots\frac{98}{99}$ ។ ដោយ

$$\frac{2}{3} > \frac{1}{2}; \frac{4}{5} > \frac{3}{4}; \frac{6}{7} > \frac{5}{6}; \dots; \frac{98}{99} > \frac{97}{98}; 1 > \frac{99}{100}$$

នោះ $B > A$ ។ យើងមាន

$$AB = \left(\frac{1}{2}.\frac{2}{3}\right)\left(\frac{3}{4}.\frac{4}{5}\right)\left(\frac{5}{6}.\frac{6}{7}\right)\dots\left(\frac{98}{99}.\frac{99}{100}\right) = \frac{1}{100}$$

ដូច្នេះ $A^2 < AB = \frac{1}{100} \Rightarrow A < \frac{1}{10}$ ។

បន្ទាប់មកទៀត

$$B < 2A = \frac{3}{4}.\frac{5}{6}.\frac{7}{8}\dots\frac{99}{100}$$

ព្រោះ $\frac{2}{3} < \frac{3}{4}; \frac{4}{5} < \frac{5}{6}; \frac{6}{7} < \frac{7}{8}; \dots; \frac{98}{99} < \frac{99}{100}$ ។ ដូច្នេះ

$$A.2A > AB = \frac{1}{100} \quad \Rightarrow A > \frac{1}{10\sqrt{2}}$$

**201.** ▲ យើងមាន

$$\frac{1}{2^{100}} C_{100}^{50} = \frac{1.2.3 \dots 100}{2^{50}(1.2.3 \dots 50).2^{50}(1.2.3 \dots 50)}$$

$$= \frac{1.2.3\ldots100}{(2.4.6\ldots100)(2.4.6\ldots100)} = \frac{1.3.5..99}{2.4.6\ldots100}$$

ហើយតាមសំនួរ **200.** យើងទាញបានវិសមភាពពិត ។

**202.** ▲ ដំបូងយើងនឹងបង្ហាញថា ចំពោះគ្រប់ $n \geq 1$ យើងមាន

$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n} \leq \frac{1}{\sqrt{3n+1}}$$

ចំពោះ $n = 1$ យើងមាន $\frac{1}{2} = \frac{1}{\sqrt{3.1+1}}$ ។ បន្ទាប់មកទៀតសន្មតថាពិតដល់ $n$ មានន័យថា

$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n} \leq \frac{1}{\sqrt{3n+1}}$$

យើងគុណអង្គសង្ខាងនៃវិសមភាពនេះនឹង $\frac{2n+1}{2n+2}$ យើងទាញបាន

$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n}\cdot\frac{2n+1}{2n+2} \leq \frac{2n+1}{(2n+2)\sqrt{3n+1}}$$

យើងមាន

$$\left[\frac{2n+1}{(2n+2)\sqrt{3n+1}}\right]^2 = \frac{(2n+1)^2}{12n^3+28n^2+20n+4}$$
$$= \frac{(2n+1)^2}{(12n^3+28n^2+19n+4)+n}$$
$$= \frac{(2n+1)^2}{(2n+1)^2(3n+4)+n} < \frac{1}{3n+4}$$
$$\Rightarrow \frac{2n+1}{(2n+2)\sqrt{3n+1}} < \frac{1}{\sqrt{3n+4}}$$
$$\Rightarrow \frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n}\cdot\frac{2n+1}{2n+2} < \frac{1}{\sqrt{3n+4}}$$

**203.** ▲ អនុវត្តន៍វិសមភាពក្នុងសំនួរទី **202.** ចំពោះ $n = 50$ យើងទាញបាន

$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2n-1}{2n} < \frac{1}{\sqrt{3n+1}}$$
$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{2\times50-1}{2\times50} < \frac{1}{\sqrt{3\times50+1}}$$
$$\frac{1}{2}\cdot\frac{3}{4}\cdot\frac{5}{6}\cdots\frac{99}{100} < \frac{1}{\sqrt{151}} = \frac{1}{12{,}288} < \frac{1}{12}$$

ពិត ។

**204.** ● ស្រាយបញ្ជាក់តាមវិចារដោយកំណើន ។

**205.** ▲ ជាដំបូង យើងនឹងបង្ហាញថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $k \leq n$ យើងមាន

$$1+\frac{k}{n}\le\left(1+\frac{1}{n}\right)^k<1+\frac{k}{n}+\frac{k^2}{n^2}$$

ចំពោះ $k=1$ វិសមភាពពិត ។ សន្មតថាវិសមភាពពិតចំពោះតម្លៃ $k$ ណាមួយ ។ យើងមាន

$$\left(1+\frac{1}{n}\right)^{k+1}=\left(1+\frac{1}{n}\right)^k\left(1+\frac{1}{n}\right)\ge\left(1+\frac{k}{n}\right)\left(1+\frac{1}{n}\right)$$
$$=1+\frac{k+1}{n}+\frac{k}{n^2}>1+\frac{k+1}{n}$$

ពិត (មិនចាំបាច់ទាល់តែ $k\le n$ ទេ) ។

យើងមាន

$$\left(1+\frac{1}{n}\right)^{k+1}=\left(1+\frac{1}{n}\right)^k\left(1+\frac{1}{n}\right)<\left(1+\frac{k}{n}+\frac{k^2}{n^2}\right)\left(1+\frac{1}{n}\right)$$
$$=1+\frac{k+1}{n}+\frac{k^2+2k+1}{n^2}-\frac{k+1}{n^2}+\frac{k^2}{n^3}$$
$$=1+\frac{k+1}{n}+\frac{(k+1)^2}{n^2}-\frac{n(k+1)-k^2}{n^3}$$
$$<1+\frac{k+1}{n}+\frac{(k+1)^2}{n^2}$$

ព្រោះ $n(k+1)>k^2$ បើ $n\ge k$ ។ ដូច្នេះដោយយក $k=n$ យើងទាញបាន

$$2=1+\frac{1}{n}<\left(1+\frac{1}{n}\right)^n<1+\frac{n}{n}+\frac{n^2}{n^2}=3$$

**206.** ▲ តាមសំនួរ **205**. យើងទាញបាន

$$(1{,}000\,001)^{1\,000\,000}=\left(1+\frac{1}{1\,000\,000}\right)^{1\,000\,000}>2$$

**207.** ▲យើងមាន

$$\frac{1001^{999}}{1000^{1000}}=\left(\frac{1001}{1000}\right)^{1000}.\frac{1}{1001}=\left(1+\frac{1}{1000}\right)^{1000}.\frac{1}{1001}$$
$$<\frac{3.1}{1001}<1$$

(តាមសំនួរ **205**.) ។ ដូច្នេះ $1000^{1\,000}>1001^{999}$ ។

**208.** ▲ តាង $a=1{,}000\,000\,000\,04$ និង $b=1{,}000\,000\,000\,02$ ។ ដូច្នេះ អ្វីដែលយើងត្រូវប្រៀបធៀប គឺ

$A=\frac{a+1}{a^2+a+1}$ និង $B=\frac{b+1}{b^2+b+1}$ ។

$$\frac{1}{A}=\frac{a^2+a+1}{a+1}=1+\frac{a^2}{a+1}=1+\frac{1}{\frac{a+1}{a^2}}=1+\frac{1}{\frac{1}{a}+\frac{1}{a^2}}$$

$$\frac{1}{B}=1+\frac{1}{\frac{1}{b}+\frac{1}{b^2}}$$

យើងមាន $a>b$ ដូច្នេះ

$$\frac{1}{a^2}+\frac{1}{a}<\frac{1}{b^2}+\frac{1}{b}\ \Rightarrow \frac{1}{\frac{1}{a}+\frac{1}{a^2}}>\frac{1}{\frac{1}{b}+\frac{1}{b^2}}\ \Rightarrow \frac{1}{A}>\frac{1}{B}\ \Rightarrow A<B$$

(b) តាង

$$A=\frac{1+a+a^2+\cdots+a^{n-1}}{1+a+a^2+\cdots+a^n}$$
$$B=\frac{1+b+b^2+\cdots+b^{n-1}}{1+b+b^2+\cdots+b^n}$$

យើងមាន

$$\frac{1}{A}=1+\frac{a^n}{1+a+a^2+\cdots+a^{n-1}}=1+\frac{1}{\frac{1+a+a^2+\cdots+a^{n-1}}{a^n}}$$
$$=1+\frac{1}{\frac{1}{a^n}+\frac{1}{a^{n-1}}+\cdots+\frac{1}{a}};$$
$$\frac{1}{B}=1+\frac{1}{\frac{1}{b^n}+\frac{1}{b^{n-1}}+\cdots+\frac{1}{b}}$$

ដូច្នេះ

$$\frac{1}{A}>\frac{1}{B}\ \Rightarrow B>A$$

**209.** ▲យើងមាន

$$\begin{aligned}&\sqrt{c+1}-\sqrt{c}<\sqrt{c}-\sqrt{c-1}\\ \Leftrightarrow\ &\sqrt{c+1}-\sqrt{c-1}<2\sqrt{c}\\ \Leftrightarrow\ &\left(\sqrt{c+1}-\sqrt{c-1}\right)^2<4c\\ \Leftrightarrow\ &\sqrt{c^2-1}<c\end{aligned}$$

ពិត ។

**210.** ▲តាងចំនួនពិតទាំងនោះដោយ $x_1, x_2, \dots, x_n$ ដែល $x_1 x_2 \dots x_n = 1$ ។ យើងត្រូវបង្ហាញថា $x_1 + x_2 + \cdots + x_n \geq n$ ។ ចំពោះ $n = 1$ វិសមភាពពិត ។ សន្មតថាពិតចំពោះ $n = k$ មានន័យថា ចំពោះគ្រប់ចំនួនពិត $x_1, x_2, \dots, x_k$ ដែល $x_1 x_2 \dots x_k = 1$ យើងមាន $x_1 + x_2 + \cdots + x_k \geq k$ ។ ចំពោះ $n = k + 1$ បើ $x_1 = x_2 = \cdots = x_{k+1} = 1$ នោះ$x_1 + x_2 + \cdots + x_{k+1} \geq k + 1$ វិសមភាពពិត ។ ករណីផ្សេងពីនេះ ដោយសារ ផលគុណនៃចំនួនទាំងនេះមានតម្លៃស្មើមួយ ហើយចំនួនទាំងនេះមិនមានតំលៃស្មើមួយដូចគ្នាទាំងអស់ ដូច្នេះមានចំនួនខ្លះតូចជាងមួយចំនួនខ្លះធំជាងមួយ ។ សន្មត $x_1 < 1, x_{k+1} > 1$ ។ តាង $y_1 = x_1 x_{k+1}$ ។ យើងមាន $y_1 x_2 \dots x_k = 1$ ដូច្នេះ $y_1 + x_2 + \cdots + x_k \geq k$ ។ យើងមាន

$$\begin{aligned} x_1 + x_2 + \cdots + x_{k+1} &= (y_1 + x_2 + \cdots + x_k) - y_1 + x_1 + x_{k+1} \\ &\geq k - y_1 + x_1 + x_{k+1} = (k+1) - 1 - x_1 x_{k+1} + x_1 + x_{k+1} \\ &= k + 1 + (x_{k+1} - 1)(1 - x_1) > k + 1 \end{aligned}$$

វិសមភាពពិតដល់ $k + 1$ ។

**211.** ▲ ស្រាយបញ្ជាក់តាមកំណើន ។ ចំពោះ $n = 1$ វិសមភាពពិត ។ សន្មតថាពិតចំពោះ $n = k$ មានន័យថា $(1 + x_1)(1 + x_2) \dots (1 + x_k) \geq 1 + x_1 + x_2 + \cdots + x_k$ ។ គុណអង្គទាំងពីរនៃវិសមភពនឹង $(1 + x_{k+1})$ យើងទាញបាន $(1 + x_1)(1 + x_2) \dots (1 + x_k)(1 + x_{k+1}) \geq (1 + x_1 + x_2 + \cdots + x_k)(1 + x_{k+1})$ ។ យើងមាន $(1 + x_1 + x_2 + \cdots + x_k)(1 + x_{k+1}) \geq (1 + x_1 + x_2 + \cdots + x_k) + x_{k+1} \Leftrightarrow (x_1 + x_2 + \cdots + x_k)x_{k+1} \geq 0$ ពិតព្រោះ $x_1, x_2, \dots, x_{k+1}$ មានសញ្ញាដូចគ្នា ។ ដូច្នេះ $(1 + x_1)(1 + x_2) \dots (1 + x_k)(1 + x_{k+1}) \geq (1 + x_1 + x_2 + \cdots + x_k) + x_{k+1}$ ។

**212.** ▲ ចំពោះ $n = 6$ យើងមាន $2^6 = 64 < 6! = 720 < 3^6 = 729$

សន្មតថាវិសមភាពពិតចំពោះ ចំនួនគត់ធម្មជាតិ $n$ មួយ ។ យើងនឹងបង្ហាញថា ពិតចំពោះ $n + 1$ ដែរ ។ យើងមាន

$$\left(\frac{n}{2}\right)^n > n! > \left(\frac{n}{3}\right)^n$$
$$\Rightarrow (n+1)\left(\frac{n}{2}\right)^n > (n+1)! > (n+1)\left(\frac{n}{3}\right)^n$$

ដូច្នេះ យើងគ្រាន់តែបង្ហាញថា

$$\left(\frac{n+1}{2}\right)^{n+1} > (n+1)\left(\frac{n}{2}\right)^n \text{ និង } \left(\frac{n}{3}\right)^n (n+1) > \left(\frac{n+1}{3}\right)^{n+1}$$

ជាការស្រេច ។ វិសមភាពទាំងពីរសមមូលនឹង

$$\frac{\left(\frac{n+1}{2}\right)^{n+1}}{\left(\frac{n}{2}\right)^n} > n+1 > \frac{\left(\frac{n+1}{3}\right)^{n+1}}{\left(\frac{n}{3}\right)^n}$$

$$\Leftrightarrow \frac{\frac{1}{2}\left(\frac{n+1}{2}\right)^n}{\left(\frac{n}{2}\right)^n} > 1 > \frac{\frac{1}{3}\left(\frac{n+1}{3}\right)^n}{\left(\frac{n}{3}\right)^n}$$

$$\Leftrightarrow \frac{1}{2}\left(1+\frac{1}{n}\right)^n > 1 > \frac{1}{3}\left(1+\frac{1}{n}\right)^n$$

$$\Leftrightarrow 2 < \left(1+\frac{1}{n}\right)^n < 3$$

ពិត តាមសំនួរ **205.** ។

**213.** ▲ យើងមាន $\Delta' = 999^2 - ac > 0$; $\Delta' \in \mathbb{Z}$ ព្រោះ $a, c \in \mathbb{Z}$ និង $|x_1 - x_2| = \frac{2\sqrt{\Delta'}}{|a|}$ ។

បើ $\Delta' \geq 2$ នោះ

$$|x_1 - x_2| = \frac{2\sqrt{\Delta'}}{|a|} > \frac{2\sqrt{\Delta'}}{2000} \geq \frac{2\sqrt{2}}{2000} > \frac{1}{998}$$

បើ $\Delta' = 1$ នោះ $ac = 999^2 - 1 = 998.1000 = 2^4.5^3.449$ ។ យើងមាន $2^2.5^3.449 = 1996 < 2000$ ជាតួចែកមួយនៃ $2^4.5^3.449 = ac \Rightarrow$ តួចែកធំបំផុតនៃ $ac = 2^4.5^3.449$ ហើយដែលតូចជាង 2000 ស្មើនឹង 1996 ។ ដូច្នេះ $a \leq 1996$ (ហេតុអ្វីបានយកតួចែកតូចជាង2000 ? ព្រោះ $|a| < 2000, |c| < 2000$) ។ យើងទាញបាន

$$|x_1 - x_2| = \frac{2\sqrt{\Delta'}}{|a|} = \frac{2}{|a|} \geq \frac{1}{998}$$

**214.** ▲ លក្ខខណ្ឌដែលឱ្យ នាំឱ្យ $x \neq y$ និង

$$a = \frac{y-2}{y-x}; b = \frac{2-x}{y-x}$$

ជំនួសចូលលក្ខខណ្ឌទីបី យើងទាញបាន

$$3 = ax^2 + by^2 = \frac{(y-2)x^2}{y-x} + \frac{(2-x)y^2}{y-x} = 2(x+y) - xy \quad (1)$$

តាង $C = ax^3 + by^3 > 0$ ។ យើងមាន

$$\begin{aligned} C &= \frac{y-2}{y-x}x^3 + \frac{2-x}{y-x}y^3 \\ &= -xy(x+y) + 2(x^2+xy+y^2) \\ &= -xy\,(x+y) + 2(x+y)^2 - 2xy \\ &= (x+y)[-xy + 2(x+y)] - 2xy \\ &= 3(x+y) - 2xy; \qquad \text{តាម } (1) \end{aligned}$$

ដូច្នេះ

$$\begin{cases} 2(x+y) - xy = 3 \\ 3(x+y) - 2xy = C \end{cases}$$

យើងទាញបាន $x + y = 6 - C; xy = 9 - 2C$ ។

យើងមាន $(x+y)^2 > 4xy \implies (6-C)^2 > 4(9-2C) \implies C > 4$ ។

យើងមាន $xy > 0 \implies 9 - 2C > 0; \implies C < 4{,}5$ ។

**215.** ▲ ● ករណី $x < -3$ នោះ

$$S = |x| + \left|\frac{2x-1}{x+3}\right| > |x| > 3$$

● ករណី $-3 < x < 0$

ករណីនេះ $\frac{2x-1}{x+3} < 0$ ដូច្នេះ

$$S \geq \frac{2x-1}{x+3} = -2 + \frac{7}{x+3} > -2 + \frac{7}{3} = \frac{1}{3}$$

● ករណី $x > 1/2$

យើងមាន

$$S = |x| + \left|\frac{2x-1}{x+3}\right| \geq |x| > \frac{1}{2}$$

● ករណី $0 \leq x \leq 1/2$

ករណីនេះយើងមាន $S \geq 1/3$ ព្រោះ

$$S = x - \frac{2x-1}{x+3} = \frac{x^2+x+1}{x+3}$$

$$S \geq \frac{1}{3} \Leftrightarrow \quad \frac{x^2+x+1}{x+3} \geq \frac{1}{3}$$
$$\Leftrightarrow 3x^2+3x+3 \geq x+3 \quad \Leftrightarrow x \geq 0$$

ពិត ។ សញ្ញាស្មើកើតមាន ពេល $x = 0$ ។

ដូច្នេះ $\min S = 1/3$ ពេល $x = 0$ ។

**216.** ▲ សន្មតថា $a \geq 0$ ។ បើ $a < 0$ នោះគុណពហុធា $f(x)$ នឹង $(-1)$ យើងទាញបានពហុធាដែលមេគុណវិជ្ជមាន ហើយនៅតែផ្ទៀងផ្ទាត់សម្មតិកម្មដដែល ។ យើងសន្មតផងដែរថា $b \geq 0$ ។ បើ $b < 0$ នោះយើងយក $f(-x)$ ព្រោះសម្មតិកម្មស៊ីមេទ្រីធៀបនឹង $x$ ។

ជំនួស $x = 0; x = \pm 1$ ចូល$f(x)$ យើងទាញបាន

$$\begin{cases} -1 \leq c \leq 1 \ (1) \\ -1 \leq a+b+c \leq 1 \ (2) \\ -1 \leq a-b+c \leq 1 \ (3) \end{cases}$$

(2) និង(3) នាំឱ្យ

$$\begin{cases} -1-c \leq a+b \leq 1-c \\ -1-c \leq a-b \leq 1+c \end{cases}$$

ដោយ $a \geq 0; b \geq 0; |c| \leq 1$ នោះ

$$\begin{cases} 0 \leq a+b \leq 2 \\ -2 \leq a-b \leq 2 \end{cases}$$
$$\Rightarrow \begin{cases} a^2+2ab+b^2 \leq 4 \\ a^2-2ab+b^2 \leq 4 \end{cases}$$
$$\Rightarrow \ a^2+b^2 \leq 4 \quad (4)$$

យើងមាន

$$K = \frac{8}{3}(a^2+b^2) - \frac{2}{3}b^2 \leq \frac{8}{3}(a^2+b^2) \leq \frac{8}{3}.4 = \frac{32}{3}$$

$K$ មានតំលៃធំបំផុតពេល $b = 0; a^2+b^2 = 4 \Rightarrow b = 0; a = \pm 2$ ។

បើ $b = 0; a = 2; (2) \Rightarrow c = -1$ ។

បើ $b = 0; a = -2; (2) \Rightarrow c = 1$ ។

ដូច្នេះ $(a,b,c) = \{(2;0;-1);(-2;0;1)\}$ ។

**217.** ▲ សន្មតថា $a_1 \le a_2 \le a_3 \le a_4 \le a_5$ ។ សន្មតថា $\min_{i\neq j}\left(a_i - a_j\right)^2 > \frac{1}{100}$ នោះ

$$a_2 - a_1 > \frac{1}{10} \Rightarrow a_2 > \frac{1}{10}$$
$$a_3 - a_2 > \frac{1}{10} \Rightarrow a_3 > \frac{2}{10}$$
$$a_4 - a_3 > \frac{1}{10} \Rightarrow a_4 > \frac{3}{10}$$
$$a_5 - a_4 > \frac{1}{10} \Rightarrow a_2 > \frac{4}{10}$$
$$\Rightarrow a_1 + a_2 + a_3 + a_4 + a_5 > \frac{1+2+3+4}{10} = 1$$

មិនត្រឹមត្រូវ ។

សន្មតថា $\min_{i\neq j}\left|a_i^2 - a_j^2\right| > \frac{1}{36}$ នោះ

$$a_2^2 - a_1^2 > \frac{1}{36} \Rightarrow a_2 > \frac{1}{6}$$
$$a_3^2 - a_2^2 > \frac{1}{36} \Rightarrow a_3 > \frac{\sqrt{2}}{6}$$
$$a_4^2 - a_3^2 > \frac{1}{36} \Rightarrow a_4 > \frac{\sqrt{3}}{6}$$
$$a_5^2 - a_4^2 > \frac{1}{36} \Rightarrow a_5 > \frac{\sqrt{4}}{6}$$
$$\Rightarrow a_1 + a_2 + a_3 + a_4 + a_5 > \frac{1+\sqrt{2}+\sqrt{3}+\sqrt{4}}{10} > 1$$

មិនត្រឹមត្រូវ ។

**218.** ▲ ❶ ដំណោះស្រាយទី១

យើងមាន

$$\frac{a}{b+c} + \frac{b}{c+a} + \frac{c}{a+b}$$
$$= \frac{2a}{(b+c)+(b+c)} + \frac{2b}{(c+a)+(c+a)} + \frac{2c}{(a+b)+(a+b)}$$
$$< \frac{2a}{a+(b+c)} + \frac{2b}{b+(c+a)} + \frac{2c}{c+(a+b)} = 2$$

❷ ដំណោះស្រាយទី២

តាង $a = x + y; b = y + z; c = z + x$ ។

$$a+b>c \Leftrightarrow x+y+y+z>z+x \Rightarrow y>0$$
$$a+c>b \Leftrightarrow x+y+z+x>y+z \Rightarrow x>0$$
$$b+c>a \Leftrightarrow y+z+z+x>x+y \Rightarrow z>0$$

ដូច្នេះ យើងបំលែង លក្ខខណ្ឌ $a,b,c$ ជារង្វាស់ជ្រុងត្រីកោណមក $x,y,z>0$ ។

យើងមាន

$$\frac{x+y}{y+z+z+x}+\frac{y+z}{z+x+x+y}+\frac{z+x}{x+y+y+z}$$
$$<\frac{x+y}{y+z+x}+\frac{y+z}{z+x+y}+\frac{z+x}{x+y+z}=2$$

ពិត ។

**219.** ▲ តាង $a=x+y; b=y+z; c=z+x$ នោះ $x;y;z>0$ ។

វិសមភាពខាងឆ្វេងសមមូលនឹង

$$\begin{aligned} & (a+b+c)^2 \geq 3(ab+bc+ca) \\ \Leftrightarrow\ & 4(x+y+z)^2 \geq 3[(x+y)(y+z)+(y+z)(z+x)+(z+x)(x+y)] \\ \Leftrightarrow\ & x^2+y^2+z^2 \geq xy+yz+zx \\ \Leftrightarrow\ & \frac{1}{2}[(x-y)^2+(y-z)^2+(z-x)^2] \geq 0 \end{aligned}$$

ពិត ។ អង្គទាំងពីរស្មើគ្នាពេល $x=y=z$ មានន័យថា $a=b=c$ ។

ដូចគ្នាវិសមភាពខាងស្តាំសមមូលនឹង $xy+yz+zx>0$ ពិត ព្រោះ $x,y,z>0$ ។

**220.** ▲ យើងមាន

$$\begin{aligned} & a^2+b^2>2ab \\ & a+b>c \quad \Rightarrow a^2+b^2+2ab>c^2 \\ \Rightarrow\ & a^2+b^2+(a^2+b^2)>a^2+b^2+2ab>c^2 \\ \Rightarrow\ & 2a^2+2b^2-c^2>0 \end{aligned}$$

ដូចគ្នាយើងទាញបាន

$$2b^2+2c^2-a^2>0$$
$$2c^2+2a^2-b^2>0$$

យើងនឹងបង្ហាញថា

$$(2a^2+2b^2-c^2)(2c^2+2a^2-b^2) \leq (2a^2+bc)^2$$

យើងមាន

$$\begin{aligned} & (2a^2+bc)^2-(2a^2+2b^2-c^2)(2c^2+2a^2-b^2) \\ & =4a^2bc-2a^2(b^2+c^2)-4b^2c^2+2b^4+2c^4 \\ & =2(b^2-c^2)^2-2a^2(b-c)^2 \end{aligned}$$

$$= 2(b-c)^2(b+c+a)(b+c-a) \geq 0$$

ដូចគ្នាយើងទាញបាន

$$0 < (2a^2+2b^2-c^2)(2c^2+2a^2-b^2) \leq (2a^2+bc)^2$$
$$0 < (2b^2+2c^2-a^2)(2a^2+2b^2-c^2) \leq (2b^2+ac)^2$$
$$0 < (2c^2+2a^2-b^2)(2b^2+2c^2-a^2) \leq (2c^2+ab)^2$$

គុណអង្គនឹងអង្គយើងទាញបានវិសមភាព ។ អង្គទាំងពីរស្មើគ្នាពេល $a = b = c$ ។

**221.** ▲យើងទាញបាន

$$a \geq 0; b^2 - 4ac \leq 0 \implies b^2 \leq 4ac = 4.2a.\frac{c}{2} \leq \left(2a + \frac{c}{2}\right)^2$$
$$\implies 2b \leq 4a + c$$
$$\implies 2b - 4a \leq c$$
$$\implies 3b - 3a \leq a + b + c$$
$$\implies \frac{a+b+c}{b-a} \geq 3$$
$$\implies \min F = 3$$

**222.** ▲ យើងមាន

$$S = bc\sin\frac{\alpha}{2}$$
$$a^2 = b^2 + c^2 - 2bc\cos\alpha$$
$$\frac{\sqrt{3}\sin\alpha + \cos\alpha}{2} = \cos(\alpha - 60°)$$

យើងមាន

$$a^2+b^2+c^2 \geq 4S\sqrt{3} \iff b^2+c^2 \geq bc\left(\sqrt{3}\sin\alpha + \cos\alpha\right)$$
$$\iff (b-c)^2 + 2bc(1-\cos(\alpha-60°)) \geq 0$$

យើងមានសមភាពទាល់តែ $b = c$ និង $\alpha = 60°$ មានន័យថា ត្រីកោណជាត្រីកោណសម័ង្ស ។

**223.** ▲ សន្មតថា $a \geq 0; c \geq 0; 4ac \geq b^2$ ។ បើ $a = 0$ នោះ $b = 0$ ហើយវិសមភាពទៅជា $cg^2 \geq 0$ ។ បើ $a > 0$ នោះ

$$af^2 + bfg + cg^2 = a\left(f + \frac{b}{2a}g\right)^2 + \frac{4ac-b^2}{4a}g^2 \geq 0$$

ឥឡូវយើងសន្មតថា $af^2 + bfg + cg^2 \geq 0$ ចំពោះគ្រប់គូរ៉ិចទ័រ $f, g$ ។ ជំនួស $f$ ដោយ $tg$ $(t \in \mathbb{R})$ យើងទាញបាន $(at^2 + bt + c)g^2 \geq 0$ ពិតចំពោះគ្រប់ចំនួនពិត $t$ ដូច្នេះនាំឱ្យ $a \geq 0, c \geq 0, 4ac \geq b^2$ ។

**224.** ▲ យើងមាន

$$-a_i = \sum_{j=1;j\neq i}^{n} a_j$$

$$n\,|a_i| = |(n-1)a_i - (-a_i)| = \left|\sum_{j=1;j\neq i}^{n}(a_i - a_j)\right|$$

$$= \left|\sum_{i\neq j}(a_i - a_j)\right| \leq \sum_{i\neq j}|a_i - a_j|$$

$$\Rightarrow \quad n\sum_{i=1}^{n}|a_i| \leq 2\sum_{i<j}|a_i - a_j|$$

$\Rightarrow$ វិសមភាពពិត ។

ចំពោះ $a_1 = a_2 = \cdots = a_{n-1} = x$ និង $a_n = -(n-1)x$ យើងទាញបានអង្គទាំង២ ស្មើគ្នា ។ ដូច្នេះវិសមភាពជាវិសមភាពតូចជាងឬស្មើ ។

**225.** ▲ ❶ ដំណោះស្រាយទី១

ជាដំបូងយើងសន្មតថា កត្តានីមួយៗនៃអង្គខាងស្តាំរបស់វិសមភាពមានតម្លៃវិជ្ជមានឬសូន្យ ។

យើងមាន

$$b - 1 + \frac{1}{c} = b\left(1 - \frac{1}{b} + \frac{1}{bc}\right) = b\left(1 - \frac{1}{b} + a\right)$$

$$\Rightarrow \left(a - 1 + \frac{1}{b}\right)\left(b - 1 + \frac{1}{c}\right) = b\left[a - \left(1 - \frac{1}{b}\right)\right]\left[a + \left(1 - \frac{1}{b}\right)\right]$$

$$= b\left[a^2 - \left(1 - \frac{1}{b}\right)^2\right]$$

$$\leq ba^2$$

ដូចគ្នា យើងទាញបាន

$$\left(b - 1 + \frac{1}{c}\right)\left(c - 1 + \frac{1}{a}\right) \leq cb^2$$

$$\left(a - 1 + \frac{1}{b}\right)\left(c - 1 + \frac{1}{a}\right) \leq ac^2$$

$$\Rightarrow \left[\left(a - 1 + \frac{1}{b}\right)\left(b - 1 + \frac{1}{c}\right)\left(c - 1 + \frac{1}{a}\right)\right]^2 \leq (abc)^2 = 1$$

ពិត ។

ករណីមានកត្តាណាមួយអវិជ្ជមាន ឧទាហរណ៍ $a-1+\frac{1}{b}<0$ នោះ $a<1$ ហើយ $b>1$ ។ ក្នុងករណីនេះ $b-1+\frac{1}{c}>0$ និង $c-1+\frac{1}{a}>0$ ។ ដូច្នេះបើមានកត្តាណាមួយអវិជ្ជមាន នោះ មានតែកត្តាមួយនោះប៉ុណ្ណោះ ដែលអវិជ្ជមាន ដូច្នេះផលគុណនៃកត្តាទាំងបីនេះអវិជ្ជមាន ដូច្នេះតូចជាង១ ។

❷ ដំណោះស្រាយទី២

វិសមភាពដែលឱ្យសមមូលនឹង

$$\left(a-(abc)^{\frac{1}{3}}+\frac{(abc)^{\frac{2}{3}}}{b}\right)\left(b-(abc)^{\frac{1}{3}}+\frac{(abc)^{\frac{2}{3}}}{c}\right)\left(c-(abc)^{\frac{1}{3}}+\frac{(abc)^{\frac{2}{3}}}{a}\right)\leq abc$$

ជំនួស $a=x^3;b=y^3;c=z^3$ ដែល $x,y,z>0$ យើងទាញបាន

$$\left(x^3-xyz+\frac{(xyz)^2}{y^3}\right)\left(y^3-xyz+\frac{(xyz)^2}{z^3}\right)\left(z^3-xyz+\frac{(xyz)^2}{x^3}\right)\leq x^3y^3z^3$$

$$\Leftrightarrow\quad (x^2y-y^2z+z^2x)(y^2z-z^2x+x^2y)(z^2x-x^2y+y^2z)\leq x^3y^3z^3$$

$$\Leftrightarrow\quad 3x^3y^3z^3+\sum_{\text{cyclic}}x^6y^3\geq\sum_{\text{cyclic}}x^4y^4z+\sum_{\text{cyclic}}x^5y^2z^2$$

$$\Leftrightarrow\quad 3(x^2y)(y^2z)(z^2x)+\sum_{\text{cyclic}}(x^2y)^3\geq\sum_{\text{sym}}(x^2y)^2(y^2z)$$

តាង $u=x^2y;v=y^2z;w=z^2x$ ។ យើងមាន $u,v,w>0$

$$\Longrightarrow\quad 3uvw+\sum_{\text{cyclic}}u^3\geq\sum_{\text{sym}}u^2v$$

$$\Leftrightarrow\quad \sum_{\text{cyclic}}u(u-v)(u-w)\geq 0$$

ពិត តាមវិសមភាព Schur ។

**226.▲** ដោយប្រើលក្ខខណ្ឌ $a+b=1$ យើងបំលែងវិសមភាពដែលឱ្យ ទៅជាវិសមភាពអូម៉ូសែន

$$\frac{1}{3} \leq \frac{a^2}{(a+b)(a+(a+b)} + \frac{b^2}{(a+b)\big(b+(a+b)\big)} \Leftrightarrow a^2b+ab^2 \leq a^3+b^3$$
$$\Leftrightarrow (a-b)^2(a+b) \geq 0$$

ពិត ។ សមភាពកើតមាន ពេល $a=b=1/2$ ។

**227.▲** សន្មតផ្ទុយមកវិញថា $(1-x)y<1/4, (1-y)z<1/4,$ $(1-z)x<1/4$ ។ យើងទាញបាន

$$(1-x)(1-y)(1-z)xyz = x^2y^2z^2 < \frac{1}{64}$$
$$\Rightarrow xyz < \frac{1}{8} \qquad (1)$$

និង

$$(1-x)y+(1-y)z+(1-z)x < \frac{3}{4}$$
$$x+y+z-xy-yz-zx < \frac{3}{4} \qquad (2)$$

តាមសម្មតិកម្ម យើងមាន

$$\begin{aligned} xyz &= (1-x)(1-y)(1-z) \\ &= (1-y-x+xy)(1-z) \\ &= 1-z-y+yz-x+xz+xy-xyz \end{aligned}$$
$$\Rightarrow x+y+z-xy-yz-zx = 1-2xyz \qquad (3)$$

ជំនួស(3) ចូលក្នុង(2) យើងទាញបាន

$$1-2xyz < \frac{3}{4}$$
$$\Rightarrow xyz > \frac{1}{8} \qquad (4)$$

យើងឃើញថា (1) ផ្ទុយនឹង(4) ។ ដូច្នេះការសន្មតថា $(1-x)y<\frac{1}{4}, (1-y)z<\frac{1}{4},$ $(1-z)x<\frac{1}{4}$ មិនអាចពិតទេ ។ វាត្រូវតែមានមួយដែលស្មើ1/4 ឬធំជាង ។

**228.▲** ចំពោះ $n=1$ យើងមាន

$$\frac{x(x^2+1)}{x+1} \leq \left(\frac{x+1}{2}\right)^3 \Leftrightarrow 8x(x^2+1) \leq (x+1)^4$$
$$\Leftrightarrow 8x^3+8x \leq x^4+4x^3+6x^2+4x+1$$

$$\Leftrightarrow x^4-4x^3+6x^2-4x+1\ge 0$$
$$\Leftrightarrow (x-1)^4\ge 0$$

ពិត ។ អង្គទាំងពីរស្មើគ្នា ពេល $x=1$ ។

សន្មតថា សមភាពពិតរហូតដល់ $n$ គឺ

$$\frac{x^n(x^{n+1}+1)}{x^n+1}\le\left(\frac{x+1}{2}\right)^{2n+1} \qquad (1)$$

យើងនឹងបង្ហាញថា

$$\frac{x^{n+1}(x^{n+2}+1)}{x^{n+1}+1}\le\left(\frac{x+1}{2}\right)^{2n+3} \qquad (2)$$

ពិត ។

គុណ (1) នឹង $\left(\frac{x+1}{2}\right)^2$ យើងទទួលបាន

$$\frac{x^n(x^{n+1}+1)}{x^n+1}\left(\frac{x+1}{2}\right)^2\le\left(\frac{x+1}{2}\right)^{2n+3}$$

យើងនឹងបង្ហាញថា (2) ពិត ដោយគ្រាន់តែបង្ហាញថា

$$\frac{x^{n+1}(x^{n+2}+1)}{x^{n+1}+1}\le\frac{x^n(x^{n+1}+1)}{x^n+1}\left(\frac{x+1}{2}\right)^2 \qquad (3)$$

ជាការគ្រប់គ្រាន់ ។ វិសមភាព (3) សមមូលនឹង

$$4x^{n+1}(x^{n+2}+1)(x^n+1)\le(x^{n+1}+1)x^n(x^{n+1}+1)(x+1)^2$$
$$\Leftrightarrow 4x^{n+1}(x^{2n+2}+x^{n+2}+x^n+1)\le x^n(x^{2n+2}+2x^{n+1}+1)(x^2+2x+1)$$
$$\Leftrightarrow 4(x^{2n+3}+x^{n+3}+x^{n+1}+x)$$
$$\le x^{2n+4}+2x^{2n+3}+x^{2n+2}+2x^{n+3}+4x^{n+2}+2x^{n+1}+x^2+2x+1$$
$$\Leftrightarrow x^{2n+4}-2x^{2n+3}+x^{2n+2}-2x^{n+3}+4x^{n+2}-2x^{n+1}+x^2-2x+1\ge 0$$
$$\Leftrightarrow x^{2n+2}(x^2-2x+1)-2x^{n+1}(x^2-2x+1)+(x^2-2x+1)\ge 0$$
$$\Leftrightarrow (x-1)^2(x^{2n+2}-2x^{n+1}+1)\ge 0$$
$$\Leftrightarrow (x-1)^2(x^{n+1}-1)^2\ge 0$$

ពិតជានិច្ច ហើយអង្គទាំងពីរស្មើគ្នា ពេល $x=1$ ។

**229.**

**230.** ▲ យើងមាន

$$\frac{2x-y}{2y-x}=\frac{a+3b}{a-3b}\ \Leftrightarrow\frac{2x-y}{a+3b}=\frac{2y-x}{a-3b}=\frac{2x-y+2y-x}{a+3b+a-3b}=\frac{x+y}{2a}=k$$
$$\frac{2x-y}{2y-x}=\frac{a+3b}{a-3b}\ \Leftrightarrow\frac{2x-y}{a+3b}=\frac{2y-x}{a-3b}=\frac{2x-y-2y+x}{a+3b-a+3b}=\frac{x-y}{2b}=k$$

$\Rightarrow x+y=2ka; x-y=2kb \ \Rightarrow x=k(a+b)\,; y=k(a-b)$ ។ ដូច្នេះ

$$\frac{x^2+y^2}{x^2-y^2}=\frac{k^2(a+b)^2+k^2(a-b)^2}{k^2(a+b)^2-k^2(a-b)^2}=\frac{a^2+b^2}{2ab}\geq 1$$

**231.** ▲ យើងមាន $x,y,z\geq 1$ ។ វិសមភាពដែលឱ្យសមមូលនឹង

$$\begin{aligned}&\left(xy-2x\sqrt{y-1}\right)+\left(yz-2y\sqrt{z-1}\right)+\left(zx-2z\sqrt{x-1}\right)\leq 0\\ &\Leftrightarrow\ x\left(y-1-2\sqrt{y-1}+1\right)+y\left(z-1-2\sqrt{z-1}+1\right)\\ &\qquad +z\left(x-1-2\sqrt{x-1}+1\right)\leq 0\\ &\Leftrightarrow x\left(\sqrt{y-1}-1\right)^2+y\left(\sqrt{z-1}-1\right)^2+z\left(\sqrt{x-1}-1\right)^2\leq 0\end{aligned}$$

ដោយ $x,y,z$ សុទ្ធតែវិជ្ជមាន ដូច្នេះ $\sqrt{y-1}-1=0;\ \sqrt{z-1}-1=0;\ \sqrt{x-1}-1=0\ \Rightarrow x=y=z=2$ ។

**232.** ▲ ដោយ $0<x<1$ នោះវិសមភាពដែលឱ្យ អាចសរសេរជា

$$\begin{aligned}&\left(1+\frac{1}{x}\right)\left(1+\frac{1}{1-x}\right)\geq 9\\ &(x+1)(1-x+1)\geq 9x(1-x)\\ &2+x-x^2\geq 9x-9x^2\\ &(2x-1)^2\geq 0\end{aligned}$$

ពិត ។

**233.** ▲ យើងមាន

$$\begin{aligned}&\frac{a^6}{b^6}+\frac{a^4}{b^4}+\frac{a^2}{b^2}+\frac{b^6}{a^6}+\frac{b^4}{a^4}+\frac{b^2}{a^2}=\left(\frac{a^6}{b^6}+\frac{b^6}{a^6}\right)+\left(\frac{a^4}{b^4}+\frac{b^4}{a^4}\right)+\left(\frac{a^2}{b^2}+\frac{b^2}{a^2}\right)\\ &\geq 2+2+2=6\end{aligned}$$

អង្គទាំង២ស្មើគ្នា លុះត្រាតែ $a=b$ ។

**234.** ▲ យើងមាន

$$\begin{aligned}\frac{x}{x^4+y^2}+\frac{y}{x^2+y^4}&\leq\frac{x}{2\sqrt{x^4y^2}}+\frac{y}{2\sqrt{x^2y^4}}\\ &\leq\frac{x}{2x^2y}+\frac{y}{2xy^2}=\frac{1}{xy}\end{aligned}$$

**235.** ▲ យើងមាន

$$\begin{aligned}&0\leq\left(x-\sqrt{y^2+1}\right)^2+\left(y-\sqrt{x^2+1}\right)^2\\ &\Rightarrow x^2+y^2+1\geq x\sqrt{y^2+1}+y\sqrt{x^2+1}\end{aligned}$$

អង្គទាំង២ស្មើគ្នា បើ

$$\begin{cases} x = \sqrt{y^2+1} \\ y = \sqrt{x^2+1} \end{cases}$$

$\Longrightarrow x^2 + y^2 = x^2 + y^2 + 2$ មិនអាច ។ ដូច្នេះអង្គទី១ធំជាងអង្គទី២ដាច់ខាត មានន័យថា

$$x^2 + y^2 + 1 > x\sqrt{y^2+1} + y\sqrt{x^2+1}$$

**236.** ▲ យើងមាន

$$\frac{x^2}{y^2} + \frac{y^2}{z^2} + \frac{z^2}{x^2} \geq \frac{x}{z} + \frac{y}{x} + \frac{z}{y}$$

$$\Leftrightarrow \left(\frac{x}{y}\right)^2 - 2\frac{x}{z} + \left(\frac{y}{z}\right)^2 + \left(\frac{y}{z}\right)^2 - 2\frac{y}{x} + \left(\frac{z}{x}\right)^2 + \left(\frac{z}{x}\right)^2 - 2\frac{z}{y} + \left(\frac{x}{y}\right)^2 \geq 0$$

$$\Leftrightarrow \left(\frac{x}{y} - \frac{y}{z}\right)^2 + \left(\frac{y}{z} - \frac{z}{x}\right)^2 + \left(\frac{z}{x} - \frac{x}{y}\right)^2 \geq 0$$

ពិតជានិច្ច ។ អង្គទាំង២ស្មើគ្នា មានតែ$x = y = z$ ។

**237.** ▲ យើងមាន

$$\frac{x^2+y^2}{2} \geq \left(\frac{x+y}{2}\right)^2$$

ព្រោះ សមភាពនេះសមមូលនឹង

$$\frac{x^2+y^2}{2} \geq \frac{x^2+y^2}{4} + \frac{2xy}{4} \Leftrightarrow \frac{x^2+y^2}{4} - \frac{2xy}{4} \geq 0 \Leftrightarrow (x-y)^2 \geq 0$$

ពិត ។ ដូច្នេះ ដោយយក

$$x = a + \frac{1}{a};\ \ y = b + \frac{1}{b}$$

យើងទាញបាន

$$\begin{aligned} \frac{\left(a+\frac{1}{a}\right)^2 + \left(b+\frac{1}{b}\right)^2}{2} &\geq \frac{1}{4}\left(a + \frac{1}{a} + b + \frac{1}{b}\right)^2 \\ &= \frac{1}{4}\left(1 + \frac{1}{a} + \frac{1}{b}\right)^2 \\ &= \frac{1}{4}\left(1 + \frac{a+b}{ab}\right)^2 = \frac{1}{4}\left(1 + \frac{1}{ab}\right)^2 \end{aligned}$$

យើងមាន

$$(a-b)^2 \geq 0 \ \Rightarrow a^2+b^2 \geq 2ab \ \Rightarrow a^2+b^2+2ab \geq 4ab \ \Rightarrow (a+b)^2 \geq 4ab \ \Rightarrow ab \leq \frac{(a+b)^2}{4} = \frac{1}{4} \ \Rightarrow \frac{1}{ab} \geq 4 \ \Rightarrow 1+\frac{1}{ab} \geq 5$$

ដូច្នេះ

$$\frac{\left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2}{2} \geq \frac{1}{4}5^2 = \frac{25}{4}$$
$$\Rightarrow \left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2 \geq \frac{25}{2}$$

សមភាពកើតមានពេល $a=b=1/2$ ។

**238.** ▲ តាង $a=x+y, b=y+z, c=z+x$ នោះ $x,y,z>0$ ។

វិសមភាពសមមូលនឹង

$$(x+2y+z)(x+y+2z)(2x+y+z) \geq 64xyz$$

យើងមាន

$$\begin{aligned} x+2y+z &= (x+y)+(y+z) \\ &\geq 2\sqrt{xy}+2\sqrt{yz} \\ &\geq 4(xy^2z)^{1/4} \end{aligned}$$

ដូចគ្នា

$$x+y+2z \geq 4(xyz^2)^{\frac{1}{4}}$$
$$2x+y+z \geq 4(x^2yz)^{1/4}$$

ដូច្នេះ

$$(x+2y+z)(x+y+2z)(2x+y+z) \geq 64(xy^2z.xyz^2.x\text{^}2yz)^{\frac{1}{4}} = 64xyz$$

ពិត ។

**239.** ▲ តាង $a=x+y; b=y+z; c=z+x$ នោះ $a;b;c>0$ ។ យើងមាន

$$\begin{aligned} \frac{x^2-z^2}{y+z}+\frac{y^2-x^2}{z+x}+\frac{zx^2-y^2}{x+y} &= \frac{(a-b)c}{b}+\frac{(b-c)a}{c}+\frac{(c-a)b}{a} \\ &= \frac{ac}{b}+\frac{ba}{c}+\frac{bc}{a}-a-b-c \end{aligned}$$

តែថា

$$\frac{1}{2}\left(\frac{ac}{b}+\frac{ba}{c}\right) = a\frac{b^2+c^2}{2bc} \geq a$$

ទៅជាស្មើគ្នា ទាល់តែ $b = c$ ។ ដូចគ្នាដែរ

$$\frac{1}{2}\left(\frac{ac}{b}+\frac{bc}{a}\right) \geq c$$
$$\frac{1}{2}\left(\frac{ba}{c}+\frac{bc}{a}\right) \geq b$$

បូកអង្គនៃវិសមភាពទាំងនេះបញ្ចូលគ្នា យើងទាញបាន $\frac{ac}{b}+\frac{ba}{c}+\frac{bc}{a}-a-b-c \geq 0$ ។ ដូច្នេះវិសមភាពពិត ។ សញ្ញាស្មើកើតមានពេល $a = b = c$ មានន័យថា $x = y = z$ ។

**240.** ▲ តាង $x = a+b-c, y = b+c-a, z = c+a-b$ ។

ដូច្នេះ $x, y, z > 0$ និង $a = \frac{x+z}{2}, b = \frac{y+x}{2}, c = \frac{z+y}{2}$ ។ យើងមាន

$$2(x+y) = (x+y)+(x+y) \geq x+y+2\sqrt{xy} = \left(\sqrt{x}+\sqrt{y}\right)^2$$
$$\Rightarrow \sqrt{x}+\sqrt{y} \leq \sqrt{2}.\sqrt{x+y}$$

ដោយអង្គទាំងពីរស្មើគ្នា បើ $x = y$ ។

ដូច្នេះ

$$\sqrt{a+b-c}+\sqrt{b+c-a} = \sqrt{x}+\sqrt{y} \leq \sqrt{2}.\sqrt{x+y} = 2\sqrt{b}$$

ដូចគ្នា

$$\sqrt{b+c-a}+\sqrt{c+a-b} \leq 2\sqrt{c}$$
$$\sqrt{c+a-b}+\sqrt{a+b-c} \leq 2\sqrt{a}$$

បូកអង្គនិងអង្គនៃវិសមភាព យើងទាញបានវិសមភាពពិត ។

សមភាពកើតមាន លុះត្រាតែ $x = y = z$ មានន័យថា $a = b = c$ ។

**241.** ▲ ❶ ដំណោះស្រាយទី ១

យើងមាន $(a-b)(a^2-b^2) \geq 0 \Rightarrow a^3+b^3 \geq ab(a+b)$ ដោយអង្គទាំងពីរស្មើគ្នា ទាល់តែ និងមានតែ $a = b$ ។ ដូច្នេះ

$$\frac{1}{a^3+b^3+abc} \leq \frac{1}{ab(a+b)+abc} = \frac{c}{abc(a+b+c)}$$
$$\frac{1}{b^3+c^3+abc} \leq \frac{a}{abc(a+b+c)}$$

$$\frac{1}{c^3+a^3+abc} \le \frac{b}{abc(a+b+c)}$$

ដូច្នេះ

$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc} \le \frac{c+b+a}{abc(a+b+c)} = \frac{1}{abc}$$

❷ ដំណោះស្រាយទី ២

វិសមភាពនេះសមមូលនឹង

$$\begin{aligned} &\sum_{\text{sym}}(a^3+b^3+abc)(b^3+c^3+abc)abc \\ &\qquad \le 2(a^3+b^3+abc)(b^3+c^3+abc)(c^3+a^3+abc) \\ \Leftrightarrow\ & \sum_{\text{sym}}(a^7bc+3a^4b^4c+4a^5b^2c^2+a^3b^3c^3) \\ &\qquad \le \sum_{\text{sym}}(a^3b^3c^3+2a^6b^3+3a^4b^4c+a^7bc+2a^5b^2c^2) \\ \Leftrightarrow\ & \sum_{\text{sym}}(2a^6b^3-2a^5b^2c^2) \ge 0 \\ \Leftrightarrow\ & \sum_{\text{sym}} a^6b^3c^0 \ge \sum_{\text{sym}} a^5b^2c^2 \end{aligned}$$

ពិតតាមវិសមភាព Muirhead ព្រោះ $(6;3;0)$ លុបលើ $(5;2;2)$ ។ ស្ទីត $(6;3;0)$ លុបលើ $(5;2;2)$ ព្រោះ $6>5; 6+3=9>5+2=7; 6+3+0=5+2+2$ ។

**242.** ▲ យើងមាន

$$\begin{aligned} a^5+b^5 &= (a+b)(a^4-a^3b+a^2b^2-ab^3+b^4) \\ &= (a+b)[(a-b)(a^3-b^3)+a^2b^2] \\ &\ge (a+b)a^2b^2 \end{aligned}$$

ព្រោះ $(a-b)(a^3-b^3) \ge 0$ ។

$$\begin{aligned} \Rightarrow \frac{ab}{a^5+b^5+ab} &\le \frac{ab}{(a+b)a^2b^2+ab} \\ &= \frac{1}{ab(a+b)+1} \\ &= \frac{1}{ab(a+b)+abc} \end{aligned}$$

$$= \frac{1}{ab(a+b+c)}$$
$$= \frac{c}{a+b+c}$$

តាមរបៀបដូចគ្នា ចំពោះតួផ្សេងទៀត ។ យើងទាញបាន

$$\frac{ab}{a^5+b^5+ab}+\frac{bc}{b^5+c^5+bc}+\frac{ca}{c^5+a^5+ca}$$
$$\le \frac{c}{a+b+c}+\frac{a}{a+b+c}+\frac{b}{a+b+c}=1$$

សមភាពកើតមានពេល $a=b=c$ ។

**243.▲** តាង

$$A=\left(\sum_{i=1}^{n} a_i^2\right)\left(\sum_{i=1}^{n} b_i^2\right)$$
$$B=\left(\sum_{i=1}^{n} a_i b_i\right)^2$$
$$A-B=\sum_{i=1}^{n} a_i^2 b_i^2+\sum_{i\neq j} a_i^2 b_j^2-\left[\sum_{i=1}^{n} a_i^2 b_i^2+2\sum_{1\le i<j\le n} a_i b_i a_j b_j\right]$$
$$=\sum_{i\neq j} a_i^2 b_j^2-2\sum_{1\le i<j\le n} a_i b_i a_j b_j$$
$$=\left[\sum_{1\le i<j\le n} a_i^2 b_j^2+\sum_{1\le i<j\le n} a_j^2 b_i^2\right]-2\sum_{1\le i<j\le n} a_i b_i a_j b_j$$
$$=\sum_{1\le i<j\le n}\left(a_i^2 b_j^2+a_j^2 b_i^2-2a_i b_i a_j b_j\right)$$
$$=\sum_{1\le i<j\le n}\left(a_i b_j-a_j b_i\right)^2\ge 0$$

$\Longrightarrow$ សំណើពិត ។

**244.▲** តាមវិសមភាពកូស៊ី– ស្វាត

$$(x_1+x_2+\cdots+x_n)\left(\frac{1}{x_1}+\frac{1}{x_2}+\cdots+\frac{1}{x_n}\right)\ge\left(\sum_{i=1}^{n}\sqrt{x_i}.\frac{1}{\sqrt{x_i}}\right)^2=n^2$$

**245.▲** តាមវិសមភាពកូស៊ីស្វាត

$$(a+b+b+c+c+c)^2 \le (1+1+1+1+1+1)(a^2+b^2+b^2+c^2+c^2+c^2)$$
$$\Rightarrow \frac{(a+2b+3c)^2}{a^2+2b^2+3c^2} \le 6$$

**246.▲** តាមវិសមភាពកូស៊ីស្វាត

$$\Rightarrow 3\left[\left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2+\left(c+\frac{1}{c}\right)^2\right] \ge \left[\left(a+\frac{1}{a}\right)+\left(b+\frac{1}{b}\right)+\left(c+\frac{1}{c}\right)\right]^2$$
$$=\left(a+b+c+\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)\right)^2=\left(1+\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)\right)^2$$
$$\ge \left(1+\frac{3}{(abc)^{\frac{1}{3}}}\right)^2$$ តាមវិសមភាពកូស៊ី
$$\ge \left(1+\frac{9}{a+b+c}\right)^2$$ តាមវិសមភាពកូស៊ី
$$=(1+9)^2=100$$
$$\Rightarrow \left(a+\frac{1}{a}\right)^2+\left(b+\frac{1}{b}\right)^2+\left(c+\frac{1}{c}\right)^2 \ge \frac{100}{3}$$

**247.▲** តាមវិសមភាពកូស៊ី– ស្វាត

$$(a+b+c+d)^2 \le (1+1+1+1)(a^2+b^2+c^2+d^2) = 4(a^2+b^2+c^2+d^2)$$
$$\Rightarrow \quad (8-e)^2 \le 4(16-e^2)$$
$$\Rightarrow \quad e(5e-16) \le 0$$
$$\Rightarrow \quad 0 \le e \le \frac{16}{5}$$

ដើម្បីឱ្យ $e=16/5$ លក្ខខណ្ឌគឺ $a=b=c=d$ និង $a+b+c+d=24/5 \Rightarrow$ $a=b=c=d=6/5$ ។

**248.▲** យើងមាន

$$(1-y)^2 \ge 0 \quad \Rightarrow \frac{1+y^2}{2} \ge y$$
$$\Rightarrow \quad 0 \le 1+y+z^2 \le \frac{1+y^2}{2}+(1+z^2)$$
$$\Rightarrow \frac{1+x^2}{1+y+z^2} \ge \frac{1+x^2}{\frac{1+y^2}{2}+(1+z^2)} = \frac{2(1+x^2)}{1+y^2+2(1+z^2)}$$

ដូចគ្នាយើងទាញបាន

$$\frac{1+y^2}{1+z+x^2} \geq \frac{2(1+y^2)}{1+z^2+2(1+x^2)}$$

$$\frac{1+z^2}{1+x+y^2} \geq \frac{2(1+z^2)}{1+x^2+2(1+y^2)}$$

យើងគ្រាន់តែបង្ហាញថា

$$\frac{2(1+x^2)}{1+y^2+2(1+z^2)}+\frac{2(1+y^2)}{1+z^2+2(1+x^2)}+\frac{2(1+z^2)}{1+x^2+2(1+y^2)} \geq 2$$

តាង $a=1+x^2; b=1+y^2; c=1+z^2$ ។ ដូច្នេះ វិសមភាពសមមូលនឹង

$$\frac{2a}{b+2c}+\frac{2b}{c+2a}+\frac{2c}{a+2b} \geq 2$$

$$\Leftrightarrow \quad \frac{a}{b+2c}+\frac{b}{c+2a}+\frac{c}{a+2b} \geq 1$$

តាមវិសមភាពកូស៊ីស្វាត

$$[(ab+2ac)+(cb+2ab)+(ac+2bc)]\left[\frac{a}{b+2c}+\frac{b}{c+2a}+\frac{c}{a+2b}\right] \geq (a+b+c)^2 \ (*)$$

ហើយ

$$(a+b+c)^2 \geq 3(ab+bc+ca)$$

ព្រោះ

$$\Leftrightarrow a^2+b^2+c^2+2(ab+bc+ca) \geq 3(ab+bc+ca)$$

$$\Leftrightarrow \ a^2+b^2+c^2 \geq ab+bc+ca$$

$$\Leftrightarrow \frac{1}{2}\left[(a-b)^2+(b-c)^2+(c-a)^2\right] \geq 0$$

ពិត ។ ដូច្នេះ (*) នាំឱ្យ

$$3(ab+bc+ca)\left[\frac{a}{b+2c}+\frac{b}{c+2a}+\frac{c}{a+2b}\right] \geq (a+b+c)^2 \geq 3(ab+bc+ca)$$

$$\Rightarrow \ \frac{a}{b+2c}+\frac{b}{c+2a}+\frac{c}{a+2b} \geq 1$$

អង្គទាំងពីរស្មើគ្នាពេល $a=b=c$ ។

**249.▲** យើងនឹងស្រាយបញ្ជាក់វិសមភាពក្នុងករណី $x, y \geq 0$ សិន ។ ក្នុងករណីនេះ វិសមភាពសមមូលនឹង

$$(x+y)\sqrt{x^2+y^2} \le 2\sqrt{2}(x^2-xy+y^2)$$

តាមវិសមភាពកូស៊ីស្វាត យើងមាន

$$(x+y)^2 \le (1+1)(x^2+y^2)$$
$$\Longrightarrow (x+y) \le \sqrt{2}\sqrt{x^2+y^2}$$

$\Longrightarrow\ (x+y)\sqrt{x^2+y^2} \le \sqrt{2}(x^2+y^2)$

យើងគ្រាន់តែបង្ហាញថា $\sqrt{2}(x^2+y^2) \le 2\sqrt{2}(x^2-xy+y^2)$

$$\Leftrightarrow\ x^2+y^2 \le 2(x^2-xy+y^2)$$
$$\Leftrightarrow x^2-2xy+y^2 \ge 0$$
$$\Leftrightarrow (x-y)^2 \ge 0$$

ពិត ។ អង្គទាំងពីរស្មើគ្នាពេល $x=y$ ។

បើ $x+y \le 0$ នោះយើងអាចមានករណី $x,y$ តូចជាងសូន្យទាំងពីរ ឬ មានមួយតូចជាងសូន្យ មួយទៀតធំជាងសូន្យ ។ បើវាតូចជាងឬស្មើសូន្យទាំងពីរនោះ $(x-y)^2 \ge 0 \Rightarrow x^2+y^2-xy \ge xy \ge 0$ នោះអង្គខាងឆ្វេងអវិជ្ជមាន តែអង្គខាងស្តាំវិជ្ជមាន ។ ដូច្នេះវិសមភាពពិត ។ បើមានមួយតូចជាងសូន្យ មួយធំជាងសូន្យនោះ $x^2-xy+y^2>0$ នោះអង្គខាងឆ្វេងអវិជ្ជមាន តែអង្គខាងស្តាំវិជ្ជមាន ។

បើ $x+y>0$ តែ $y \le 0$ នោះ $x+y \le x+|y|$ និង $x^2-xy+y^2 \ge x^2-x|y|+y^2>0$ ដូច្នេះ

$$\frac{x+y}{x^2-xy+y^2} \le \frac{x+|y|}{x^2-x|y|+y^2}$$

តាមសម្រាយបញ្ជាក់ករណី $y \ge 0$ យើងទាញបាន

$$\frac{x+y}{x^2-xy+y^2} \le \frac{x+|y|}{x^2-x|y|+y^2} \le \frac{2\sqrt{2}}{\sqrt{x^2+y^2}}$$

ពិត ។

**250.▲ ❶** តាមវិសមភាពកូស៊ី– ស្វាត យើងមាន

$$\left(\sum_{i=1}^{n}\frac{s}{s-a_i}\right)\left(\sum_{i=1}^{n}\frac{s-a_i}{s}\right) \ge n^2$$

យើងមាន

$$\sum_{i=1}^{n}\frac{s-a_i}{s}=\sum_{i=1}^{n}1-\frac{1}{s}\sum_{i=1}^{n}a_i=n-1 \Rightarrow \left(\sum_{i=1}^{n}\frac{s}{s-a_i}\right)\geq\frac{n^2}{n-1}$$ ពិត ។

❷ ម្យ៉ាងវិញទៀត

$$\sum_{i=1}^{n}\frac{s-a_i}{a_i}=-n+\sum_{i=1}^{n}\frac{s}{a_i} \quad (*)$$

តាមវិសមភាពកូស៊ី–ស្វាត

$$\left(\sum_{i=1}^{n}\frac{s}{a_i}\right)\left(\sum_{i=1}^{n}\frac{a_i}{s}\right)\geq n^2$$

ដោយ

$$\left(\sum_{i=1}^{n}a_i/s\right)=1 \Rightarrow \left(\sum_{i=1}^{n}\frac{s}{a_i}\right)\geq n^2\ ;(*) \Rightarrow \sum_{i=1}^{n}\frac{s-a_i}{a_i}\geq -n+n^2 = n(n-1)$$

ពិត ។

❸ យើងមាន

$$\left(\sum_{i=1}^{n}1\right)\left(\sum_{i=1}^{n}a_i^2\right)\geq\left(\sum_{i=1}^{n}a_i\right)^2 \Rightarrow \left(\sum_{i=1}^{n}a_i^2\right)\geq\frac{s^2}{n}$$

តែថា

$$\left(\sum_{i=1}^{n}[a_i(s-a_i)]\right)\left(\sum_{i=1}^{n}\frac{a_i}{s-a_i}\right)\geq\left(\sum_{i=1}^{n}a_i\right)^2=s^2$$

$$\Rightarrow \left(\sum_{i=1}^{n}\frac{a_i}{s-a_i}\right)\geq\frac{s^2}{\left(\sum_{i=1}^{n}[a_i(s-a_i)]\right)}=\frac{s^2}{s\sum_{i=1}^{n}a_i-\sum_{i=1}^{n}a_i^2}$$

$$\geq\frac{s^2}{s^2-\frac{s^2}{n}}=\frac{n}{n-1}$$

ពិត ។

**251.▲** ក) សំនួរនេះគ្មានលក្ខណៈពិសេសណាលើលំដាប់ $a_1;a_2;a_3$ ទេ មានន័យថា បើយើងផ្លាស់ $a_1$ ទៅ $a_2$; $a_2$ ទៅ $a_1$ ។ល ។នោះសម្មតិកម្មនៅដដែលគ្មានប្រែប្រួល ។ តាម

លក្ខណៈនេះ យើងអាចសន្មតថា $a_1 \le a_2 \le a_3$ ។ ដូច្នេះ យើងគ្រាន់តែបង្ហាញថា $a_1 + a_2 > a_3$ ទៅបានហើយ ។ យើងមាន

$$(a_1^2 + a_2^2 + a_3^2)^2 > 2(a_1^4 + a_2^4 + a_3^4)$$
$$\Leftrightarrow \quad (a_1 + a_2 + a_3)(a_1 + a_2 - a_3)(-a_1 + a_2 + a_3)(a_1 - a_2 + a_3) > 0$$

កត្តានីមួយៗសុទ្ធតែវិជ្ជមាន លើកលែងតែ $(a_1 + a_2 - a_3)$ ដែលមិនទាន់ដឹង ។ តែ ផលគុណរបស់កត្តាទាំងអស់វិជ្ជមាន ដូច្នេះ$(a_1 + a_2 - a_3)$ ត្រូវតែវិជ្ជមាន ។

ខ) ករណី $n = 3$ បានស្រាយបញ្ជាក់រួចក្នុងសំនួរក) ។ យើងសន្មតថា $n \ge 4$ ។ តាមដូចរៀបរាប់ក្នុងសំនួរក) យើងគ្រាន់តែបង្ហាញថា $a_1; a_2; a_3$ ជារង្វាស់ជ្រុងនៃត្រីកោណ ជាការគ្រប់គ្រាន់ហើយ ។

តាមវិសមភាពកូស៊ី– ស្វាត

$$(n-1)(a_1^4 + a_2^4 + \cdots + a_n^4) < (a_1^2 + a_2^2 + \cdots + a_n^2)^2$$
$$= \left(\frac{a_1^2 + a_2^2 + a_3^2}{2} + \frac{a_1^2 + a_2^2 + a_3^2}{2} + \sum_{k=4}^{n} a_k^2\right)^2$$
$$\le (n-1)\left(\frac{(a_1^2 + a_2^2 + a_3^2)^2}{4} + \frac{(a_1^2 + a_2^2 + a_3^2)^2}{4} + \sum_{k=4}^{n} a_k^4\right)$$

$\Leftrightarrow \quad 2(a_1^4 + a_2^4 + a_3^4) < (a_1^2 + a_2^2 + a_3^2)^2$ ហើយតាម សំនួរ ក) យើងទាញបានថា សំណើពិត ។

**252.▲** តាមវិសមភាពកូស៊ី– ស្វាត ចំពោះគ្រប់ $i$ យើងមាន

$$S_2 - a_i^2 = a_1^2 + a_2^2 + \cdots + a_{i-1}^2 + a_{i+1}^2 + \cdots + a_n^2$$
$$\ge \frac{1}{n-1}(a_1 + a_2 + \cdots + a_{i-1} + a_{i+1} + \cdots + a_n)^2$$
$$= \frac{1}{n-1}(S_1 - a_i)^2$$
$$\Leftrightarrow \frac{S_2 - a_i^2}{S_1 - a_i} \ge \frac{1}{n-1}(S_1 - a_i)$$
$$\Rightarrow \quad \sum_{k=1}^{n} \frac{S_2 - a_i^2}{S_1 - a_i} \ge \frac{1}{n-1}\sum_{k=1}^{n}(S_1 - a_k) = S_1$$

**253.▲** តាង $E=\{(a,b,c,d)\in\mathbb{R}^+/a^2+b^2=(c^2+d^2)^3\}$ និង $f$ ជាអនុគមន៍កំណត់លើ $E$ ដោយ

$$f(a,b,c,d)=\frac{c^3}{a}+\frac{d^3}{b}-1$$

យើងឃើញថា ចំពោះ $\forall\lambda\in\mathbb{R}^+:(a,b,c,d)\in E$ និង $f(a,b,c,d)\geq 0$

$$a^2+b^2=(c^2+d^2)^3 \iff (\lambda^3a)^2+(\lambda^3b)^2=[(\lambda c)^2+(\lambda d)^2]^3$$
$$\iff a_1^3+b_1^3=(c_1^2+d_1^2)^3$$
$$f(a,b,c,d)=\frac{c^3}{a}+\frac{d^3}{b}-1=\frac{(\lambda c)^3}{\lambda^3a}+\frac{(\lambda d)^3}{\lambda^3b}-1=f(\lambda^3a,\lambda^3b,\lambda c,\lambda d)$$
$$=f(a_1,b_1,c_1,d_1)$$

នោះ $(a_1=\lambda^3a,b_1=\lambda^3b,c_1=\lambda c,d_1=\lambda d)\in E$ និង $f(a,b,c,d)\geq 0\iff f(a_1,b_1,c_1,d_1)\geq 0$ ។ លក្ខណៈខាងលើនេះពិតចំពោះ$\forall\lambda\in\mathbb{R}^+$ ដូច្នេះយើងអាចជ្រើសរើសយក $\lambda$ ដែលផ្ទៀងផ្ទាត់ $a_1^2+b_1^2=1$ ។ តែយើងអាចជំនួសសំណេរ $a_1,b_1,c_1,d_1$ ដោយ $a,b,c,d$ ដោយគ្មានបញ្ហាអ្វីទាំងអស់ ។ ដូច្នេះ មានន័យថាយើងអាចយក $(a,b,c,d)\in E$ និង $a^2+b^2=1$ ដោយមិនធ្វើឱ្យបាត់ភាពទូទៅឡើយ ។ ដូច្នេះ $c^2+d^2=1$ ។

តាមវិសមភាពកូស៊ី– ស្វាត នាំឱ្យ

$$\left(\frac{c^3}{a}+\frac{d^3}{b}\right)(ac+bd)\geq(c^2+d^2)^2=1$$

តែយើងមាន

$$ac+bd\leq\frac{a^2+c^2}{2}+\frac{b^2+d^2}{2}=\frac{1}{2}(a^2+b^2+c^2+d^2)=1$$
$$\Rightarrow\quad \frac{c^3}{a}+\frac{d^3}{b}\geq\frac{1}{ac+bd}\geq 1$$

**254.▲** តាមវិសមភាពកូស៊ី– ស្វាត

$$\left(\sqrt{x-1}+\sqrt{y-1}+\sqrt{z-1}\right)^2\leq(x+y+z)\left(\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}\right)$$
$$\iff\sqrt{x-1}+\sqrt{y-1}+\sqrt{z-1}\leq\sqrt{x+y+z}\sqrt{\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}}$$

យើងមាន

$$\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}=3-\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}\right)=1$$

ដូច្នេះ

$$\sqrt{x-1}+\sqrt{y-1}+\sqrt{z-1}\le\sqrt{x+y+z}\sqrt{\frac{x-1}{x}+\frac{y-1}{y}+\frac{z-1}{z}}$$
$$=\sqrt{x+y+z}$$

វិសមភាពពិត ។

យើងមានសមភាព លុះត្រាតែ

$$\frac{x-1}{x^2}=\frac{z-1}{z^2}=\frac{z-1}{z^2};\frac{1}{x}+\frac{1}{y}+\frac{1}{z}=2 \implies x=y=z=\frac{3}{2}$$

**255.▲** តាង $a=1/x\,;b=1/y\,;c=1/z$ ។ លក្ខខណ្ឌ

$$xyz\ge xy+yz+zx \iff \frac{1}{x}+\frac{1}{y}+\frac{1}{z}\le 1 \implies a+b+c\le 1$$

វិសមភាព

$$xyz\ge 3(x+y+z) \iff ab+bc+ca\le\frac{1}{3}$$

យើងមាន

$$1\ge(a+b+c)^2=a^2+b^2+c^2+2(ab+bc+ca)$$

ហើយតាមវិសមភាពកូស៊ី– ស្វាត យើងមាន

$$ab+bc+ca\le\sqrt{a^2+b^2+c^2}\sqrt{b^2+c^2+a^2}\implies a^2+b^2+c^2$$
$$\ge ab+bc+ca$$

ដូច្នេះ នាំឱ្យ $1\ge 3(ab+bc+ca)$ ពិត ។

**256.▲** តាង $a=\tan x\,;b=\tan y\,;c=\tan z$ នោះ $x,y,z$ ជាមុំនៃត្រីកោណស្រួច ។ ដូច្នេះវិសមភាពសមមូលនឹង $\max(\tan x,\tan y,\tan z)\ge\sqrt{3}$ ។ តែថា មានមុំមួយរបស់ត្រីកោណ ឧទាហរណ៍ $x$ ដែលធំជាងឬស្មើ $\pi/3$ (បើ តូចជាង $\pi/3$ ទាំងអស់គ្នា នោះ ផលបូកមុំក្នុងត្រីកោណ មានតំលៃតូចជាង $\pi$) ។ ដោយអនុគមន៍ tan កើនលើ $[0,\pi/2)$ នោះ $\tan x\ge\tan\frac{\pi}{3}=\sqrt{3}$ ។

**257.▲** យើងមាន

$$(x_1+x_2+\cdots+x_n)^4=[(x_1^2+x_2^2+\cdots+x_n^2)+(2x_1x_2+2x_1x_3+\cdots)]^2$$
$$\geq 4(x_1^2+x_2^2+\cdots+x_n^2)(2x_1x_2+2x_1x_3+\cdots)\quad \left(\text{វិសមភាពកូស៊ី}\right)\quad (1)$$
$$=8\,(x_1^2+x_2^2+\cdots+x_n^2)\left(\sum_{i<j}x_ix_j\right)$$
$$=8\sum_{i<j}\left[x_ix_j(x_1^2+x_2^2+\cdots+x_n^2)\right]$$
$$\geq 8\sum_{i<j}\left[x_ix_j\left(x_i^2+x_j^2\right)\right]\quad (2)$$

យើងមានសមភាព (2) ទាល់តែនិងមានតែ មានយ៉ាងហោចណាស់ $x_i$ ចំនួន $(n-2)$ ដែលស្មើសូន្យ ។ ឧទាហរណ៍ $x_3=\cdots=x_n=0$ ។ ក្នុងលក្ខខណ្ឌនេះ យើងមានសមភាព (1) ទាល់តែនិងមានតែ $2x_1x_2=x_1^2+x_2^2$ មានន័យថា $x_1=x_2$ ។

ដូច្នេះ $C=1/8$ ដោយអង្គទាំងពីរស្មើគ្នា ទាល់តែនិងមានតែ មានយ៉ាងហោចណាស់ $x_i$ ចំនួន $(n-2)$ តួ ដែលស្មើសូន្យ ហើយតួពីរទៀតស្មើគ្នា ។

**258.▲** យើងមាន

$$P^2=(xy+yz+zt+tx)^2\leq(x^2+y^2+z^2+t^2)(y^2+z^2+t^2+x^2)\ =1$$

ដូច្នេះ $-1\leq P\leq 1$ ។

បើ $x=z=\frac{1}{2};y=t=-\frac{1}{2}$ នោះ $x+y+z+t=0;x^2+y^2+z^2+t^2=1$ ។

ហើយ $P=\frac{1}{2}.\left(-\frac{1}{2}\right)+\left(-\frac{1}{2}\right)\left(\frac{1}{2}\right)+\left(\frac{1}{2}\right)\left(-\frac{1}{2}\right)+\left(-\frac{1}{2}\right)\left(\frac{1}{2}\right)=-1$ ។ ដូច្នេះ $P_{\min}\ =-1$ ។

យើងមាន $P=(x+z)(y+t)=-(y+t)^2\leq 0$ ។ បើ $x=y=1/2\,;z=t=-1/2$ នោះ $P=0$ ។ ដូច្នេះ $P_{\max}\ =0$ ។

ជាសរុប $P_{\min}=-1$ ឧទាហរណ៍ត្រង់ $x=z=1/2\,;y=t=-1/2$ ។

$P_{\max}=0$ ឧទាហរណ៍ត្រង់ $x=y=1/2\,;z=t=-1/2$ ។

**259.▲** យើងតាង $x_1 = \tan\alpha_1, x_2 = \sec\alpha_1 \tan\alpha_2$ និង

$$x_k = \sec\alpha_1 \sec\alpha_2 \ldots \sec\alpha_{k-1} \tan\alpha_k$$

ដោយ $-\frac{\pi}{2} < \alpha_k < \frac{\pi}{2}, 1 \le k \le n$ ។ យើងគួរកត់សម្គាល់ថាការជំនួសនេះព្រោះលំដាប់របស់ $\tan\alpha$ គឺ $(-\infty, \infty)$ និង $\sec\alpha$ ខុសពីសូន្យជានិច្ច ។ ដូច្នេះតួទី $k$ របស់អង្គខាងឆ្វេងនៃវិសមភាពស្មើនឹង

$$\frac{\sec\alpha_1 \ldots \sec\alpha_{k-1} \tan\alpha_k}{1 + \tan^2\alpha_1 + \cdots + \sec^2\alpha_1 \ldots \sec^2\alpha_{n-1} \tan^2\alpha_n}$$
$$= \cos\alpha_1 \cos\alpha_2 \ldots \cos\alpha_k \sin\alpha_k$$

ដូច្នេះវិសមភាពដែលឱ្យ សមមូលនឹង

$$\cos\alpha_1 \sin\alpha_1 + \cos\alpha_1 \cos\alpha_2 \sin\alpha_2 + \cdots + \cos\alpha_1 \cos\alpha_2 \ldots \cos\alpha_n \sin\alpha_n < \sqrt{n}$$
$$\Leftrightarrow c_1 s_1 + c_1 c_2 s_2 + \cdots + c_1 c_2 \ldots c_n s_n < \sqrt{n}$$

ដែល $c_i = \cos\alpha_i$ និង $s_i = \sin\alpha_i$ ចំពោះ $1 \le i \le n$ ។ ចំពោះ $2 \le i \le n$ ដោយសារ $c_i^2 + s_i^2 = \cos^2\alpha_i + \sin^2\alpha_i = 1$ យើងទាញបានថា

យក $c=1;\frac{d}{c}=p=-1\Rightarrow d=-1$ ។ យក $q=3-2\sqrt{2}$ យើងទាញបាន

$$\frac{b}{c}=q=3-2\sqrt{2}\Rightarrow b=3-2\sqrt{2}$$
$$\frac{a}{b}=-1\ \Rightarrow a=-3+2\sqrt{2}$$

ដូច្នេះតម្លៃធំបំផុតស្មើ $-12$ ។ តម្លៃធំបំផុតនេះកើតមាន ឧទាហរណ៍នៅត្រង់ចំណុច

$$a=-3+2\sqrt{2};b=3-2\sqrt{2};c=1;d=-1$$

**304.** ▲ សន្មតថា $a\le b\le c$ ។ យើងមាន $c<a+b\ \Rightarrow 2c<a+b+c=2\ \Rightarrow$

$c<1$ ។

$$\begin{aligned}a^2+b^2+c^2+2abc&=(a+b+c)^2-2(ab+bc+ca)+2abc\\&=4-2(ab+bc+ca)+2abc\end{aligned}$$
$$2-2(1-a)(1-b)(1-c)=4-2(ab+bc+ca)+2abc$$

ដូច្នេះ $a^2+b^2+c^2+2abc=2-2(1-a)(1-b)(1-c)<2$ ព្រោះ

$a<1;b<1;c<1$ ។

ដោយ $a\le b\le c<1$ នោះ $1-a,1-b,1-c$ ជាចំនួនវិជ្ជមាន ។ តាមវិសមភាពកូ

ស៊ី យើងទាញបាន

$$\frac{(1-a)+(1-b)+(1-c)}{3}\ge\sqrt[3]{(1-a)(1-b)(1-c)}$$

$\Rightarrow (1-a)(1-b)(1-c)\le\dfrac{1}{27}$

$\Rightarrow\ a^2+b^2+c^2+2abc\ge 2-\dfrac{2}{27}=\dfrac{52}{27}$

សញ្ញាស្មើកើតមានពេល $a=b=c$ ។

**305.**▲ ចែកអង្គទាំងពីរនឹង $abc$ យើងទាញបាន

$$\sqrt{\left(\frac{a}{c}+\frac{b}{a}+\frac{c}{b}\right)\left(\frac{c}{a}+\frac{a}{c}+\frac{b}{c}\right)}\ge 1+\sqrt[3]{\left(\frac{a^2}{bc}+1\right)\left(\frac{b^2}{ca}+1\right)\left(\frac{c^2}{ab}+1\right)}$$

តាង $x=a/b\,,y=b/c\,,z=c/a\ \Rightarrow xyz=1$ ។ ដូច្នេះវិសមភាពទៅជា

$$\sqrt{(x+y+z)(xy+yz+zx)}\ge 1+\sqrt[3]{\left(\frac{x}{z}+1\right)\left(\frac{y}{x}+1\right)\left(\frac{z}{y}+1\right)}$$

$$\Leftrightarrow \sqrt{(x+y)(y+z)(z+x)+xyz} \geq 1+\sqrt[3]{\frac{(x+z)(y+x)(z+y)}{xyz}}$$
$$\Leftrightarrow \sqrt{(x+y)(y+z)(z+x)+1} \geq 1+\sqrt[3]{(x+z)(y+x)(z+y)}$$

តាង $p=\sqrt[3]{(x+z)(y+x)(z+y)}$ ។ វិសមភាពទៅជា

$\sqrt{p^3+1} \geq 1+p \Leftrightarrow p^3+1-(1+p)^2 \geq 0 \Leftrightarrow p(p+1)(p-2) \geq 0 \quad (*)$

យើងមាន

$$p \geq \sqrt[3]{2\sqrt{xz}.2\sqrt{yx}.2\sqrt{zy}}=2$$

ដូច្នេះ (*) ពិត ។

**306.▲** ❶ យក $p=\frac{m}{m+n}; q=\frac{n}{m+n}$ ដែល $m,n$ ជាចំនួនគត់វិជ្ជមាន ។ វិសមភាព

$$pa+qb \geq a^p b^q \quad \Leftrightarrow \quad \frac{ma+nb}{m+n} \geq \sqrt[m+n]{a^m b^n}$$

ពិត តាមវិសមភាពកូស៊ី ។

❷ យើងជ្រើសរើសស្វ៊ីតនៃចំនួនសនិទាន $a_1, a_2, \dots, a_n, ..$ ដែល $\lim_{n\to\infty} a_n = p$ ។

តាង $b_i = 1 - a_i$ យើងទាញបាន $\lim_{n\to\infty} b_n = q$ ។

តាមសំនួរទីមួយ យើងទាញបាន

$$a_n x + b_n y \geq x^{a_n} y^{b_n}$$
$$\Rightarrow \lim_{n\to\infty} a_n x + b_n y \geq \lim_{n\to\infty} x^{a_n} y^{b_n} \Leftrightarrow px+qy \geq x^p y^q$$

❸ តាមវិសមភាពយ៉ិនស៊ិន យើងមាន

$$\ln(a_1x_1+a_2x_2+\cdots+a_nx_n) \geq a_1\ln x_1 + a_2 \ln x_2 + \cdots + a_n \ln x_n$$
$$= \ln\left(x_1^{a_1} x_2^{a_2} \dots x_n^{a_n}\right)$$
$$\Rightarrow a_1x_1+a_2x_2+\cdots+a_nx_n \geq x_1^{a_1} x_2^{a_2} \dots x_n^{a_n}$$

❹ តាង

$$a_1+a_2+\cdots+a_n=a$$
$$b_1+b_2+\cdots+b_n=b$$
$$\dots$$
$$l_1+l_2+\cdots+l_n=l$$

ចែកវិសមភាពនឹង $a^\alpha b^\beta \dots l^\lambda$ យើងទទួលបាន

$$\left(\frac{a_1}{a}\right)^\alpha\left(\frac{b_1}{b}\right)^\beta\dots\left(\frac{l_1}{l}\right)^\lambda+\dots+\left(\frac{a_n}{a}\right)^\alpha\left(\frac{b_n}{b}\right)^\beta\dots\left(\frac{l_n}{l}\right)^\lambda\le 1$$

តាមវិសមភាពមធ-មធ ទូទៅ យើងមាន

$$\left(\frac{a_k}{a}\right)^\alpha\left(\frac{b_k}{b}\right)^\beta\dots\left(\frac{l_k}{l}\right)^\lambda\le\alpha\frac{a_k}{a}+\beta\frac{b_k}{b}+\dots+\lambda\frac{l_k}{l}$$

ដោយបូកវិសមភាពទាំងនេះបញ្ចូលគ្នា ចំពោះ $k=1,2,..,n$ យើងទទួលបាន

$$\begin{aligned}\left(\frac{a_1}{a}\right)^\alpha\left(\frac{b_1}{b}\right)^\beta\dots\left(\frac{l_1}{l}\right)^\lambda+\dots+\left(\frac{a_n}{a}\right)^\alpha\left(\frac{b_n}{b}\right)^\beta\dots\left(\frac{l_n}{l}\right)^\lambda\\
&\le\left(\alpha\frac{a_1}{a}+\beta\frac{b_1}{b}+\dots+\lambda\frac{l_1}{l}\right)+\dots+\left(\alpha\frac{a_n}{a}+\beta\frac{b_n}{b}+\dots+\lambda\frac{l_n}{l}\right)\\
&=\alpha\frac{a_1+\dots+a_n}{a}+\beta\frac{b_1+\dots+b_n}{b}+\dots+\lambda\frac{l_1+\dots+l_n}{l}\\
&=\alpha+\beta+\dots+\lambda=1\end{aligned}$$

ពិត ។

យើងមានសមភាព បើនិងទាល់តែបើ

$$k_1(a_1,b_1,\dots,l_1)=k_2(a_2,b_2,\dots,l_2)=k_n(a_n,b_n,\dots,l_n)$$

ដែល $k_1,k_2,\dots,k_n$ ជាចំនួនថេរ ។

**307.▲** តាមវិសមភាពមធ-មធទូទៅ យើងទាញបាន

$$\frac{1}{p}\,a^p+\frac{1}{q}\,b^q\ge(a^p)^{\frac{1}{p}}(b^q)^{\frac{1}{q}}=ab$$

**308.▲** តាង $H_n=1+\frac{1}{2}+\dots+\frac{1}{n}$ និង ចំពោះ $i=1,2,\dots,n$ តាង $w_i=1/(iH_n)$ ។

យើងមាន $w_i>0$ ហើយ

$$\sum_{i=1}^n w_i=\frac{1}{H_n}\sum_{i=1}^n\frac{1}{i}=\frac{1}{H_n}H_n=1$$

តាង $S=x_1+\frac{x_2^2}{2}+\dots+\frac{x_n^2}{n}$ ។ យើងមាន

$$\frac{S}{H_n}=\sum_{i=1}^n w_ix_i^i\ge\prod_{i=1}^n\left(x_i^i\right)^{w_i}\qquad(\text{តាមវិសមភាពមធ – មធទូទៅ})$$

$$=\prod_{i=1}^{n} x_i^{iw_i}=\prod_{i=1}^{n} x_i^{1/H_n}=\left[\prod_{i=1}^{n} x_i\right]^{1/H_n}$$

តាមវិសមភាពកូស៊ី

$$\prod_{i=1}^{n} x_i \geq \left(\frac{n}{\sum_{i=1}^{n}\frac{1}{x_i}}\right)^n=1$$

ដូច្នេះ $S/H_n \geq 1$ ហើយស្មើគ្នា ពេល $x_1=x_2=\cdots=x_n=1$ ។

**309.▲** តាមវិសមភាព Hölder ដោយយក $\alpha=\beta=\gamma=1/3$ និង

$$a_1=x, a_2=y, a_3=z$$
$$b_1=x, b_2=y, b_3=z$$
$$c_1=\frac{a^3}{x^2}, c_2=\frac{b^3}{y^2}, c_3=\frac{c^3}{z^2}$$

យើងទទួលបាន

$$(a_1+a_2+a_3)^{\alpha}(b_1+b_2+b_3)^{\beta}(c_1+c_2+c_3)^{\gamma}$$
$$\geq a_1^{\alpha}b_1^{\beta}c_1^{\gamma}+a_2^{\alpha}b_2^{\beta}c_2^{\gamma}+a_3^{\alpha}b_3^{\beta}c_3^{\gamma}$$
$$\Leftrightarrow (x+y+z)^{\frac{1}{3}}(x+y+z)^{\frac{1}{3}}\left(\frac{a^3}{x^2}+\frac{b^3}{y^2}+\frac{c^3}{z^2}\right)^{\frac{1}{3}}$$
$$\geq x^{\frac{1}{3}}x^{\frac{1}{3}}\left(\frac{a^3}{x^2}\right)^{\frac{1}{3}}+y^{\frac{1}{3}}y^{\frac{1}{3}}\left(\frac{b^3}{y^2}\right)^{\frac{1}{3}}+z^{\frac{1}{3}}z^{\frac{1}{3}}\left(\frac{c^3}{z^2}\right)^{\frac{1}{3}}$$
$$\Leftrightarrow (a+b+c)^2\left(\frac{a^3}{x^2}+\frac{b^3}{y^2}+\frac{c^3}{z^2}\right)\geq (a+b+c)^3$$
$$\Leftrightarrow \frac{a^3}{x^2}+\frac{b^3}{y^2}+\frac{c^3}{z^2}\geq a+b+c$$

ពិត ។

សមភាពកើតមាន បើនិងទាល់តែបើ

$$(x,y,z)=k^3\left(\frac{a^3}{x^2},\frac{b^3}{y^2},\frac{c^3}{z^2}\right)$$
$$\Leftrightarrow x=k^3\frac{a^3}{x^2};\ y=k^3\frac{b^3}{y^2};\ z=k^3\frac{c^3}{z^2}$$
$$\Leftrightarrow x=ka; y=kb; z=kc$$

តាមលក្ខខណ្ឌ $a+b+c=x+y+z\ \Rightarrow k=1$ ។ ដូច្នេះ សមភាពកើតមាន បើនិង ទាល់តែបើ $x=a, y=b, z=c$ ។

**310.▲** តាមវិសមភាព Hölder

$$a_1^{\alpha}b_1^{\beta}\dots l_1^{\lambda}+a_2^{\alpha}b_2^{\beta}\dots l_2^{\lambda}+\dots+a_n^{\alpha}b_n^{\beta}\dots l_n^{\lambda}$$
$$\le(a_1+a_2+\dots+a_n)^{\alpha}(b_1+b_2+\dots+b_n)^{\beta}\dots(l_1+l_2+\dots+l_n)^{\lambda}$$

ជំនួស

$$a_1=1; a_2=a_1$$
$$b_1=1; b_2=a_2;$$
$$\dots$$
$$\alpha=\beta=\dots=\frac{1}{n}$$

យើងទទួលបាន

$$(1+a_1)^{\frac{1}{n}}(1+a_2)^{\frac{1}{n}}\dots(1+a_n)^{\frac{1}{n}}\ge 1+a_1^{\frac{1}{n}}a_2^{\frac{1}{n}}\dots a_n^{\frac{1}{n}}$$
$$\Leftrightarrow(1+a_1)(1+a_2)\dots(1+a_n)\ge\left(1+\sqrt[n]{a_1a_2\dots a_n}\right)^n$$

ពិត ។ យើងមានសមភាព បើនិងទាល់តែបើ

$$k_1(1,a_1)=k_2(1,a_2)=\dots=k_n(1,a_n)\ \Leftrightarrow a_1=a_2=\dots=a_n$$

**311.▲** តាមវិសមភាព Hölder

$$a_1^{\alpha}b_1^{\beta}\dots l_1^{\lambda}+a_2^{\alpha}b_2^{\beta}\dots l_2^{\lambda}+\dots+a_n^{\alpha}b_n^{\beta}\dots l_n^{\lambda}$$
$$\le(a_1+a_2+\dots+a_n)^{\alpha}(b_1+b_2+\dots+b_n)^{\beta}\dots(l_1+l_2+\dots+l_n)^{\lambda}$$

ដោយយក $n=k$ និង

$$(a_1,a_2,..,a_k)=(a_1,b_1,\dots,l_1)$$
$$(b_1,b_2,..,b_k)=(a_2,b_2,\dots,l_2)$$
$$\dots$$
$$\alpha=\beta=\dots=\frac{1}{n}$$

យើងទទួលបាន

$$a_1^{\frac{1}{n}}a_2^{\frac{1}{n}}\dots a_n^{\frac{1}{n}}+b_1^{\frac{1}{n}}b_2^{\frac{1}{n}}\dots b_n^{\frac{1}{n}}+\dots+l_1^{\frac{1}{n}}l_2^{\frac{1}{n}}\dots l_n^{\frac{1}{n}}$$
$$\le(a_1+b_1+\dots+l_1)^{\frac{1}{n}}(a_2+b_2+\dots+l_2)^{\frac{1}{n}}\dots(a_n+b_n+\dots+l_n)^{\frac{1}{n}}$$
$$\Leftrightarrow\sqrt[n]{a_1a_2\dots a_n}+\sqrt[n]{b_1b_2\dots b_n}+\dots+\sqrt[n]{l_1l_2\dots l_n}$$
$$\le\sqrt[n]{(a_1+b_1+\dots+l_1)(a_2+b_2+\dots+l_2)\dots(a_n+b_n+\dots+l_n)}$$

ពិត ។ សមភាពកើតមាន បើនិងទាល់តែបើ

$$k_1.(a_1,b_1,\dots,l_1)=\cdots=k_n.(a_n,b_n,\dots,l_n)$$

**312.▲** តាង $q>0$ ដែល

$$\frac{1}{p}+\frac{1}{q}=1\ \Rightarrow (p-1)q=p$$

តាង $S_i=a_i+b_i+\cdots+l_i$ ដែល $i=1,2,\dots,n$ ។ ចំពោះគ្រប់ $i$ យើងមាន

$$\begin{aligned}|a_i+b_i+\cdots+l_i|^p&=|a_i+b_i+\cdots+l_i|^{p-1}|a_i+b_i+\cdots+l_i|\\&\le |a_i||S_i|^{p-1}+|b_i||S_i|^{p-1}+\cdots+|l_i||S_i|^{p-1}\quad(1)\end{aligned}$$

ដូច្នេះ

$$\begin{aligned}|S_1|^p+|S_2|^p+\cdots+|S_n|^p\le{}&|a_1||S_1|^{p-1}+|b_1||S_1|^{p-1}+\cdots+|l_1||S_1|^{p-1}+\\&+|a_2||S_2|^{p-1}+|b_2||S_2|^{p-1}+\cdots+|l_2||S_2|^{p-1}+\\&+\cdots\\&+|a_n||S_n|^{p-1}+|b_n||S_n|^{p-1}+\cdots+|l_n||S_n|^{p-1}\end{aligned}$$

តាមវិសមភាព Hölder ចំពោះ $\alpha=1/p\,;\beta=1/q$ យើងមាន

$$\begin{aligned}&|a_1||S_1|^{p-1}+|a_2||S_2|^{p-1}+\cdots+|a_n||S_n|^{p-1}\\&\le(|a_1|^p+|a_2|^p+\cdots+|a_n|^p)^{\frac{1}{p}}\left(|S_1|^{(p-1)q}+|S_2|^{(p-1)q}+\cdots+|S_n|^{(p-1)q}\right)^{\frac{1}{q}}\\&=(|a_1|^p+|a_2|^p+\cdots+|a_n|^p)^{\frac{1}{p}}(|S_1|^p+|S_2|^p+\cdots+|S_n|^p)^{\frac{1}{q}}\quad(2)\end{aligned}$$

ដូចគ្នា

$$\begin{aligned}&|b_1||S_1|^{p-1}+|b_2||S_2|^{p-1}+\cdots+|b_n||S_n|^{p-1}\\&\le(|b_1|^p+|b_2|^p+\cdots+|b_n|^p)^{\frac{1}{p}}(|S_1|^p+|S_2|^p+\cdots+|S_n|^p)^{\frac{1}{q}}\quad(3)\\&\dots\dots\dots\dots\dots\dots\end{aligned}$$

ដូច្នេះ

$$\begin{aligned}&|S_1|^p+|S_2|^p+\cdots+|S_n|^p\\&\le(|a_1|^p+|a_2|^p+\cdots+|a_n|^p)^{\frac{1}{p}}(|S_1|^p+|S_2|^p+\cdots+|S_n|^p)^{\frac{1}{q}}+\\&+(|b_1|^p+|b_2|^p+\cdots+|b_n|^p)^{\frac{1}{p}}(|S_1|^p+|S_2|^p+\cdots+|S_n|^p)^{\frac{1}{q}}+\\&+\cdots\\&+(|l_1|^p+|l_2|^p+\cdots+|l_n|^p)^{\frac{1}{p}}(|S_1|^p+|S_2|^p+\cdots+|S_n|^p)^{\frac{1}{q}}\end{aligned}$$

$$\begin{aligned}\Rightarrow(|S_1|^p+|S_2|^p+\cdots+|S_n|^p)^{1-\frac{1}{q}}\le{}&(|a_1|^p+|a_2|^p+\cdots+|a_n|^p)^{\frac{1}{p}}+\\&+(|b_1|^p+|b_2|^p+\cdots+|b_n|^p)^{\frac{1}{p}}\\&+\cdots\end{aligned}$$

$$+(|l_1|^p+|l_2|^p+\cdots+|l_n|^p)^{\frac{1}{p}}$$

$$\Rightarrow (|S_1|^p+|S_2|^p+\cdots+|S_n|^p)^{\frac{1}{p}} \le (|a_1|^p+|a_2|^p+\cdots+|a_n|^p)^{\frac{1}{p}}+$$
$$+(|b_1|^p+|b_2|^p+\cdots+|b_n|^p)^{\frac{1}{p}}$$
$$+\cdots$$
$$+(|l_1|^p+|l_2|^p+\cdots+|l_n|^p)^{\frac{1}{p}}$$

ពិត ។

យើងមាន (1) ក្លាយជាសមភាព បើ $a_i, b_i, \dots, l_i$ មានសញ្ញាដូចគ្នា ។

យើងមាន (2) ក្លាយជាសមភាព បើ

$$k_a.(|a_1|^p, |a_2|^p, \dots, |a_n|^p) = (|S_1|^p, |S_2|^p, \dots, |S_n|^p) \quad (*)$$

ដោយ $a_1, b_1, \dots, l_1$ ត្រូវតែមានសញ្ញាដូចគ្នា, ..., និង $a_n, b_n, \dots, l_n$ ត្រូវតែមានសញ្ញាដូចគ្នា នោះ (*) សមមូលនឹង

$$k_a.a_i^p = (a_i+b_i+\cdots+l_i)^p, \forall\, i$$

ដូចគ្នា និង តាម (3) យើងទាញបាន

$$k_b.b_i^p = (a_i+b_i+\cdots+l_i)^p, \forall\, i$$
$$\dots\dots\dots$$
$$k_l.l_i^p = (a_i+b_i+\cdots+l_i)^p, \forall\, i$$

ដូច្នេះ $m_a.a_i = m_b.b_i = \cdots = m_l.l_i$ ចំពោះគ្រប់ $i$ និង ដែល $m_a, \dots, m_l$ ជាចំនួនថេរ $> 0$ ។

ដូច្នេះសមភាពកើតមាន បើ និងទាល់តែបើ

$$m_a.(a_1, a_2, \dots, a_n) = m_b.(b_1, b_2, \dots, b_n) = \cdots = m_l.(l_1, l_2, \dots, l_n)$$

ចំពោះចំនួនថេរវិជ្ជមាន $m_a, m_b, \dots, m_l$ ។

**313.▲** គាង

$$S = \frac{x^{\frac{4}{3}}}{x^{\frac{4}{3}}+(x^2+y^2)^{\frac{1}{3}}(x+z)^{\frac{2}{3}}} + \frac{y^{\frac{4}{3}}}{y^{\frac{4}{3}}+(y^2+z^2)^{\frac{1}{3}}(y+x)^{\frac{2}{3}}}$$
$$+\frac{z^{\frac{4}{3}}}{z^{\frac{4}{3}}+(z^2+x^2)^{\frac{1}{3}}(z+y)^{\frac{2}{3}}}$$

$x=a^3; y=b^3; z=c^3$

តាមវិសមភាព Hölder យើងមាន

$$(x^2+y^2)^{\frac{1}{3}}(x+z)^{\frac{2}{3}}=[(a^2)^3+(b^2)^3]^{\frac{1}{3}}\left[(c^2)^{\frac{3}{2}}+(a^2)^{\frac{3}{2}}\right]^{\frac{2}{3}}\geq a^2c^2+b^2a^2$$
$$=(xy)^{\frac{2}{3}}+(xz)^{\frac{2}{3}}$$
$$\Longrightarrow \frac{x^{\frac{4}{3}}}{x^{\frac{4}{3}}+(x^2+y^2)^{\frac{1}{3}}(x+z)^{\frac{2}{3}}}\leq\frac{x^{\frac{4}{3}}}{x^{\frac{4}{3}}+(xy)^{\frac{2}{3}}+(xz)^{\frac{2}{3}}}=\frac{x^{\frac{2}{3}}}{x^{\frac{2}{3}}+y^{\frac{2}{3}}+z^{\frac{2}{3}}}$$

តាមរបៀបដូចគ្នា

$$\frac{y^{\frac{4}{3}}}{y^{\frac{4}{3}}+(y^2+z^2)^{\frac{1}{3}}(y+x)^{\frac{2}{3}}}\leq\frac{y^{\frac{2}{3}}}{x^{\frac{2}{3}}+y^{\frac{2}{3}}+z^{\frac{2}{3}}}$$
$$\frac{z^{\frac{4}{3}}}{z^{\frac{4}{3}}+(z^2+x^2)^{\frac{1}{3}}(z+y)^{\frac{2}{3}}}\leq\frac{z^{\frac{2}{3}}}{x^{\frac{2}{3}}+y^{\frac{2}{3}}+z^{\frac{2}{3}}}$$

បូកអង្គនឹងអង្គនៃវិសមភាពបញ្ចូលគ្នា យើងទាញបាន $S\leq 1$ ។

**314.▲** យើងមាន $a,b,c,d\in\mathbb{R}$ ។ តាង $s=a+b+c+d$ ។ តាមវិសមភាព Minkowski

$$S_1=\sqrt{(a+1)^2+2(b-2)^2+(c+3)^2}+\sqrt{(b+1)^2+2(c-2)^2+(d+3)^2}$$
$$\geq\sqrt{(a+b+2)^2+2(b+c-4)^2+(c+d+6)^2}$$
$$S_2=\sqrt{(c+1)^2+2(d-2)^2+(a+3)^2}+\sqrt{(d+1)^2+2(a-2)^2+(b+3)^2}$$
$$\geq\sqrt{(c+d+2)^2+2(d+a-4)^2+(a+b+6)^2}$$
$$S=S_1+S_2\geq\sqrt{(s+4)^2+2(s-8)^2+(s+12)^2}=\sqrt{4s^2+288}\geq\sqrt{288}$$
$$=12\sqrt{2}$$

ចំពោះ $a=b=c=d=0$ យើងមាន $S=12\sqrt{2}$ ។ ដូច្នេះតម្លៃតូចបំផុតរបស់ $S$ គឺ $12\sqrt{2}$ ។

**315.▲** ❶ តាង $x=\tan A, y=\tan B,\ z=\tan C$ ដែល $0<A,B,C<\pi/2$ ។

លក្ខខណ្ឌ

$$x+y+z=xyz\iff\tan A+\tan B+\tan C=\tan A\tan B\tan C$$
$$\iff\tan A+\tan B=(\tan A\tan B-1)\tan C$$
$$\Longrightarrow\tan C=\frac{\tan A+\tan B}{\tan A\tan B-1}=-\tan(A+B)=\tan(\pi-A-B)$$

$$\Longrightarrow C = \pi - A - B$$
$$\Longrightarrow A + B + C = \pi$$

ដោយ

$$\frac{\tan A}{\sqrt{1+\tan^2 A}} = \sin A\,;\ \frac{\tan B}{\sqrt{1+\tan^2 B}} = \sin B\,;\ \frac{\tan C}{\sqrt{1+\tan^2 C}} = \sin C$$

វិសមភាពដែលឱ្យសមមូលនឹង

$$\sin A + \sin B + \sin C \le \frac{3\sqrt{3}}{2}$$

អនុគមន៍ $y = \sin x$ ជាអនុគមន៍ប៉ោងលើ $\left[0;\frac{\pi}{2}\right]$ ។ ដូច្នេះ តាមវិសមភាពយិនសិន យើងទាញបាន

$$\frac{\sin A + \sin B + \sin C}{3} \le \sin\frac{A+B+C}{3} = \sin\frac{\pi}{3} = \frac{\sqrt{3}}{2}$$

នាំឱ្យវិសមភាពពិត ។

❷ តាង $x = \tan\frac{A}{2}; y = \tan\frac{B}{2}; z = \tan\frac{C}{2}$ ដែល $0 < A, B, C < \frac{\pi}{2}$ ។ លក្ខខណ្ឌសមមូលនឹង

$$\tan\frac{A}{2}\tan\frac{B}{2} + \tan\frac{B}{2}\tan\frac{C}{2} + \tan\frac{A}{2}\tan\frac{C}{2} = 1 \implies A + B + C = \pi$$

វិសមភាពសមមូលនឹង

$$\tan A + \tan B + \tan C \ge 3\sqrt{3}$$

ពិតតាមវិសមភាពយិនសិន ។

**316.▲** តាង $x_n = \tan a_n$ ដែល $0 < a_n < \pi/2$ ។ យើងមាន

$$x_{n+1} = \tan a_n + \sqrt{1+\tan^2 a_n} = \tan\left(\frac{\pi}{4} + \frac{a_n}{2}\right) = \tan a_{n+1}$$

ដូច្នេះ

$$a_{n+1} = \frac{1}{2}a_n + \frac{\pi}{4}$$

ចំពោះ $n = 1$ យើងមាន $x_1 = \tan a_1 = \sqrt{3} \Rightarrow a_1 = \pi/6$ ។ ជំនួស $n = 2,3,..,n$ យើងទទួលបាន

$$a_2 = \frac{1}{2}a_1 + \frac{\pi}{4} \qquad \times\left(\frac{1}{2}\right)^{n-2}$$

$$a_3 = \frac{1}{2}a_2 + \frac{\pi}{4} \qquad \times \left(\frac{1}{2}\right)^{n-3}$$
$$\cdots$$
$$a_{n-1} = \frac{1}{2}a_{n-2} + \frac{\pi}{4} \qquad \times \left(\frac{1}{2}\right)$$
$$a_n = \frac{1}{2}a_{n-1} + \frac{\pi}{4} \qquad \times 1$$

បូកសមភាពចូលគ្នា យើងទាញបាន

$$a_n = \left(\frac{1}{2}\right)^{n-1} a_1 + \frac{\pi}{4}\left(1 + \frac{1}{2} + \cdots + \left(\frac{1}{2}\right)^{n-1}\right) = \left(\frac{1}{2}\right)^{n-1}\frac{\pi}{6} + \frac{\pi}{4}\frac{1-\left(\frac{1}{2}\right)^n}{1-\frac{1}{2}}$$
$$= \frac{\pi}{2} - \frac{\pi}{6.2^{n-1}}$$

ដូច្នេះ $x_n = \cot\theta_n$ ដែល $\theta_n = \frac{\pi}{6.2^{n-1}}$ ។ ដូចគ្នាយើងទាញបាន $y_n = \tan 2\theta_n$ ។ ដូច្នេះ $x_n y_n = \frac{2}{1-\tan^2\theta_n}$ ។ ដោយ $0 < \theta_n < \frac{\pi}{4}$ នោះយើងមាន $0 < \tan^2\theta_n < 1$ និង $x_n y_n > 2$ ។ ចំពោះ $n > 1$ យើងមាន $\theta_n < \pi/6$ ដូច្នេះ $\tan^2\theta_n < 1/3$ និង $x_n y_n < 3$ ។

**317.▲** តាង $T_n$ ជាពហុធា Chebyshev ទី $n$ ។ យើងដឹងថា $T_n(\cos x) = \cos nx$ និង $T_n$ កំណត់ដោយ $T_{n+1}(x) = 2xT_n(x) - T_{n-1}(x), T_0(x) = 1$ និង $T_1(x) = x$ ។ ដូច្នេះមេគុណធំរបស់ $T_n$ ស្មើនឹង $2^{n-1}$ ចំពោះ $n \geq 1$ ។

ប្រើរូបមន្តអាំងទែរប៉ូឡាស្យុងរបស់ Lagrange ទៅលើពហុធាដឺក្រេទី $T_{n-1}(x)$ និងចំពោះចំណុច$x_1, x_2, \cdots, x_n$ យើងមាន

$$T_{n-1}(x) = \sum_{k=1}^{n} \frac{T_{n-1}(x_k)(x-x_1)\cdots(x-x_{k-1})(x-x_{k+1})\cdots(x-x_n)}{(x_k-x_1)\cdots(x_k-x_{k-1})(x_k-x_{k+1})\cdots(x_k-x_n)}$$

ផ្ទឹមមេគុណធំ យើងទាញបាន

$$2^{n-2} = \sum_{k=1}^{n} \frac{T_{n-1}(x_k)}{(x_k-x_1)\cdots(x_k-x_{k-1})(x_k-x_{k+1})\cdots(x_k-x_n)}$$

យើងយក $\theta_k$ ដែល $\cos\theta_k = x_k$ ។ ដូច្នេះ $|T_{n-1}(x_k)| = |\cos(n-1)\theta_k| \le 1$ ។
ដូច្នេះ

$$2^{n-2} \le \sum_{k=1}^{n} \frac{|T_{n-1}(x_k)|}{(x_k - x_1)\cdots(x_k - x_{k-1})(x_k - x_{k+1})\cdots(x_k - x_n)} = \sum_{k=1}^{n} \frac{1}{t_k}$$

នាំឱ្យវិសមភាពពិត ។

**318.▲** ចែកអង្គទាំងពីរនៃវិសមភាពនឹង 4 យើងទាញបាន

$$\left|\frac{a}{2}\sqrt{1-\left(\frac{b}{2}\right)^2} - \frac{b}{2}\sqrt{1-\left(\frac{a}{2}\right)^2}\right| \le \frac{1}{2}$$

យើងជំនួស $\frac{a}{2} = \sin x$ និង $\frac{b}{2} = \sin y$ ។ វិសមភាពក្រោយនេះទៅជា

$$|\sin(x-y)| = |\sin x\cos y - \sin y\cos x| \le \sin\frac{\pi}{6} \qquad (*)$$

យើងចង់បាន $t_1$ និង $t_2$ ដែល $\sin t_1 = \frac{\sqrt{2}-\sqrt{6}}{4}$ និង $\sin t_2 = \frac{\sqrt{2}+\sqrt{6}}{4}$ ។
យើងទាញបាន $\cos 2t_1 = 1 - 2\sin^2 t_1 = 1 - \frac{8-4\sqrt{3}}{8} = \frac{\sqrt{3}}{2} = \cos\left(\pm\frac{\pi}{6}\right)$ និង $\cos 2t_2 = -\frac{\sqrt{3}}{2} = \cos\frac{5\pi}{6}$ ។ ព្រោះ $y = \sin x$ ជាអនុគមន៍មួយទល់មួយពី $\left[-\frac{\pi}{2};\frac{\pi}{2}\right]$ ទៅ $[-1;1]$ នោះ $t_1 = -\frac{\pi}{12}$ និង $t_2 = \frac{5\pi}{12}$ ។
យើងចែកចន្លោះ $\left[-\frac{\pi}{12};\frac{5\pi}{12}\right]$ ជាចន្លោះដាច់បី ដែលនីមួយៗមានប្រវែង $\frac{\pi}{6}$ គឺ $I_1 = \left[-\frac{\pi}{12};\frac{\pi}{12}\right), I_2 = \left[\frac{\pi}{12};\frac{\pi}{4}\right)$ និង $I_3 = \left[\frac{\pi}{4};\frac{5\pi}{12}\right]$ ។ អនុគមន៍ $y = 2\sin x$ អនុវត្តចំពោះចន្លោះ $I_1, I_2, I_3$ មានរូបភាពមួយគត់លើចន្លោះ $I_1' = \left[\frac{\sqrt{2}-\sqrt{6}}{2}; 2\sin\frac{\pi}{12}\right), I_2' = \left[2\sin\frac{\pi}{12};\sqrt{2}\right), I_3' = \left[\sqrt{2};\frac{\sqrt{2}+\sqrt{6}}{2}\right]$ រៀងគ្នា ។ តាមគោលការណ៍រន្ធព្រាប ចន្លោះមួយនៃ $I_1', I_2', I_3'$ មានចំនួនពីរនៃចំនួនដែលឱ្យចំនួនបួន តាងដោយ $a$ និង $b$ ។ យើងទាញបានចន្លោះមួយក្នុងចំណោម $I_1, I_2, I_3$ មានចំនួនពិត $x$ និង $y$ ដែល $a = 2\sin x$ និង $b = 2\sin y$ ។ ដោយចន្លោះ $I_1, I_2, I_3$ មានរង្វាស់ស្មើ $\pi/6$ ដូចគ្នា នោះ $|x - y| \le \pi/6$ ។ យើងទាញបានវិសមភាព(*) ពិត ។

**319.▲** ចំពោះ $n=1: f(l_1x_1)\leq l_1f(x_1)$ សំណើពិត ។

ចំពោះ $n=2$ វាជានិយមន័យរបស់ភាពផត ។ សន្មតថាពិតរហូតដល់ $n$ ។

យើងមាន

$$\sum_{k=1}^{n+1} l_kx_k=\sum_{k=1}^{n} l_kx_k+l_{n+1}x_{n+1}=(1-l_{n+1})y+l_{n+1}x_{n+1}$$

ដែល

$$y=\sum_{k=1}^{n}\frac{l_k}{1-l_{n+1}}x_k;\ \sum_{k=1}^{n}\frac{l_k}{1-l_{n+1}}=1$$

ដូច្នេះ

$$\begin{aligned}f\left(\sum_{k=1}^{n+1} l_kx_k\right)&=f\big((1-l_{n+1})y+l_{n+1}x_{n+1}\big)\leq(1-l_{n+1})f(y)+l_{n+1}f(x_{n+1})\\&=(1-l_{n+1})f\left(\sum_{k=1}^{n}\frac{l_k}{1-l_{n+1}}x_k\right)+l_{n+1}f(x_{n+1})\\&\leq(1-l_{n+1})\left[\frac{l_1}{1-l_{n+1}}f(x_1)+\frac{l_2}{1-l_{n+1}}f(x_2)+\cdots\right.\\&\left.+\frac{l_n}{1-l_{n+1}}f(x_n)\right]+l_{n+1}f(x_{n+1})=\sum_{k=1}^{n+1}l_k\,f(x_k)\end{aligned}$$

**320.▲** តាង $a=\tan x, b=\tan y, c=\tan z$ ។ ដូច្នេះ $x,y,z$ ជាមុំក្នុងនៃត្រីកោណស្រួចមួយ ។ យើងមាន

$$\cos x+\cos y+\cos z\leq\frac{3}{2}$$

វិសមភាពនេះពិត តាមវិសមភាពយិនសិន ។ យើងមានសមភាពពេល $a=b=c=\sqrt{3}$ ។

**321.▲** អនុគមន៍ $f(x)=x^{1/3}$ ជាអនុគមន៍ប៉ោងលើ $(0;+\infty)$ ។ តាមវិសមភាពយិនសិន យើងមាន

$$\frac{a^{\frac{1}{3}}+b^{\frac{1}{3}}}{2}\leq\left(\frac{a+b}{2}\right)^{\frac{1}{3}}\ \Rightarrow\ a^{\frac{1}{3}}+b^{\frac{1}{3}}\leq\frac{2}{2^{\frac{1}{3}}}(a+b)^{\frac{1}{3}}$$

អង្គទាំងពីរស្មើគ្នា ទាល់តែ និងនាំឱ្យ $a = b$ ។ ដូច្នេះចំនួនថេរ $M$ តូចបំផុត គឺ $M = \frac{2}{2^{\frac{1}{3}}} = 4^{\frac{1}{3}}$ ។

**322.▲** អនុគមន៍ $f(x) = \frac{1}{\sqrt{1-x}}$ ផតលើ $(1;+\infty)$ ។ ដោយ $x_1 + x_2 + \cdots + x_n = 1$ នោះតាមវិសមភាពយិនសិន

$$x_1 f(x_1) + x_2 f(x_2) + \cdots + x_n f(x_n) \geq f(x_1.x_1 + x_2.x_2 + \cdots + x_n.x_n)$$

$$\Leftrightarrow\ x_1\frac{1}{\sqrt{1-x_1}} + x_2\frac{1}{\sqrt{1-x_2}} + \cdots + x_n\frac{1}{\sqrt{1-x_n}} \geq \frac{1}{\sqrt{1-(x_1^2+x_2^2+\cdots+x_n^2)}}$$

តាមវិសមភាពកូស៊ីស្វាត យើងមាន

$$x_1^2 + x_2^2 + \cdots + x_n^2 \geq \frac{1}{n}(x_1 + x_2 + \cdots + x_n)^2 = \frac{1}{n}$$

$$\Rightarrow \frac{x_1}{\sqrt{1-x_1}} + \frac{x_2}{\sqrt{1-x_2}} + \cdots + \frac{x_n}{\sqrt{1-x_n}} \geq \frac{1}{\sqrt{1-\frac{1}{n}}} = \sqrt{\frac{n}{n-1}}$$

អង្គទាំងពីរស្មើគ្នា ពេល $x_1 = x_2 = \cdots = x_n = 1/n$ ។

**323.▲** បើ $n \geq 0$ អនុគមន៍ $f(x) = x^n$ ជាអនុគមន៍ផតលើ $\mathbb{R}^{+*}$ ។ ដូច្នេះតាមវិសមភាពយិនសិន

$$\left(1+\frac{a}{b}\right)^n + \left(1+\frac{b}{a}\right)^n \geq 2\left(\frac{1+\frac{a}{b}+1+\frac{b}{a}}{2}\right)^n = 2\left(1+\frac{1}{2}\left(\frac{a}{b}+\frac{b}{a}\right)\right)^n$$

តែថា $\frac{a}{b} + \frac{b}{a} \geq 2$ នោះ

$$\left(1+\frac{a}{b}\right)^n + \left(1+\frac{b}{a}\right)^n \geq 2(2)^n = 2^{n+1}$$

បើ $n < -1$ តាង $p = -n > 1$

$$\Rightarrow\ \left(1+\frac{a}{b}\right)^n + \left(1+\frac{b}{a}\right)^n \geq 2^{n+1}\ \Leftrightarrow \frac{b^p}{(a+b)^p} + \frac{a^p}{(a+b)^p} \geq \frac{1}{2^{p-1}}$$

$$\Leftrightarrow \frac{a^p + b^p}{2} \geq \left(\frac{a+b}{2}\right)^p$$

អនុគមន៍ $f(x) = x^p$ ជាអនុគមន៍ផតលើ $\mathbb{R}^{+*}$ ។ ដូច្នេះតាមវិសមភាពយិនសិន

$$\frac{a^p + b^p}{2} \geq \left(\frac{a+b}{2}\right)^p$$

ដូច្នេះវិសមភាពពិត ។ យើងឃើញថា អង្គទាំងពីរនៃវិសមភាពស្មើគ្នា ទាល់តែ $n \in \{0;-1\}$ និង $a,b$ យ៉ាងម៉េចក៏បាន ឬ $n \notin \{0;-1\}$ និង $a=b$ ។

**324.▲** យើងឃើញថាវិសមភាពនៅដដែល បើយើងជំនួស $(a,b,c)$ ដោយ $(\alpha a,\alpha b,\alpha c)$ (វិសមភាពអូម៉ូសែន) ។ ដូច្នេះ យើងអាចសន្មតថា $a+b+c=1$ (*) ។ អនុគមន៍ $f(x)=1/\sqrt{x}$ ជាអនុគមន៍ផត ដូច្នេះតាមវិសមភាពយិនសិន និង (*) យើងទាញបាន

$$\begin{aligned} &af(a^2+\lambda bc)+bf(b^2+\lambda ca)+cf(c^2+\lambda ab)\\ &\qquad \geq f[a(a^2+\lambda bc)+b(b^2+\lambda ca)+c(c^2+\lambda ab)]\\ &\Rightarrow \frac{a}{\sqrt{a^2+\lambda bc}}+\frac{b}{\sqrt{b^2+\lambda ca}}+\frac{c}{\sqrt{c^2+\lambda ab}}\\ &\qquad \geq \frac{1}{\sqrt{a(a^2+\lambda bc)+b(b^2+\lambda ca)+c(c^2+\lambda ab)}} \end{aligned}$$

ដូច្នេះ យើងគ្រាន់តែបង្ហាញថា

$$\begin{aligned} &a(a^2+\lambda bc)+b(b^2+\lambda ca)+c(c^2+\lambda ab)\leq\frac{1+\lambda}{9}\\ &\Leftrightarrow a^3+b^3+c^3+3\lambda abc\leq\frac{1+\lambda}{9} \end{aligned}$$

យើងមាន

$$\begin{aligned} a^3+b^3+c^3&=(a+b+c)^3\\ &\quad-3(a^2b+a^2c+ab^2+ac^2+b^2c+bc^2+2abc) \end{aligned}$$

តាម(*) យើងទាញបាន

$$\begin{aligned} &a^3+b^3+c^3+3\lambda abc\\ &=1-3(a^2b+a^2c+ab^2+ac^2+b^2c+bc^2)+3(\lambda-2)abc\\ &\leq 1-3.6abc+3(\lambda-2)abc\ \ (\text{វិសមភាពកូស៊ី})\\ &=1+3(\lambda-8)abc\\ &\leq 1+3(\lambda-8)\left(\frac{a+b+c}{3}\right)^3\ \ (\text{វិសមភាពកូស៊ី និង ដោយសារ } \lambda\geq 8)\\ &=1+\frac{\lambda-8}{9}=\frac{1+\lambda}{9} \end{aligned}$$

ពិត ។ សមភាពកើតមានពេលវិសមភាពកូស៊ីទៅជាសមភាព មានន័យថា $a=b=c$ ។

**325.▲** ដោយអនុគមន៍ $f(x)=x^t$ ផតលើ $\mathbb{R}^+$នោះតាមវិសមភាពយិនសិន យើងទាញបាន

$$\sum_{i=1}^{n}\left(a_i^{\alpha}+\frac{1}{a_i^{\beta}}\right)^t \geq n\left[\frac{1}{n}\sum_{i=1}^{n} a_i^{\alpha}+\frac{1}{a_i^{\beta}}\right]^t = n\left[\frac{1}{n}\sum_{i=1}^{n} a_i^{\alpha}+\frac{1}{n}\sum_{i=1}^{n}\frac{1}{a_i^{\beta}}\right]^t \quad (*)$$

តែ

ក) ដោយ $\alpha \geq 1$ នោះអនុគមន៍ $f(x)=x^{\alpha}$ ផតលើ $\mathbb{R}^+$ ដូច្នេះ យើងទាញបាន

$$\frac{1}{n}\sum_{i=1}^{n} a_i^{\alpha} \geq \left[\frac{1}{n}\sum_{i=1}^{n} a_i\right]^{\alpha} = \frac{1}{n^{\alpha}}$$

ខ) ដោយ $\beta > 0$ នោះអនុគមន៍ $f(x)=1/x^{\beta}$ ផតលើ $\mathbb{R}^+$ ដូច្នេះ យើងទាញបាន

$$\frac{1}{n}\sum_{i=1}^{n}\frac{1}{a_i^{\beta}} \geq \left[\frac{n}{\sum_{i=1}^{n} a_i}\right]^{\beta} = n^{\beta}$$

តាម (*), ក) និង ខ) យើងទាញបាន

$$\sum_{i=1}^{n}\left(a_i^{\alpha}+\frac{1}{a_i^{\beta}}\right)^t \geq n\left(\frac{1}{n^{\alpha}}+n^{\beta}\right)$$

អង្គទាំងពីរស្មើគ្នា ទាល់តែ $a_1=a_2=\cdots=a_n$ ។ ដោយ $a_1+a_2+\cdots+a_n=1$

នោះ $a_1=a_2=\cdots=a_n=1/n$ ។

**326.▲** អនុគមន៍ $f(x)=\frac{1}{1+e^x}$ ផតលើ $\mathbb{R}^+$ ព្រោះ

$$f''(x)=\frac{e^{2x}-e^x}{(1+e^x)^3} \geq 0$$

ចំពោះ $i=1,2,\ldots,n$ តាង $x_i=e^{y_i}$ ។ ដោយ $x_i \geq 1$ នោះ $y_i \geq 0$ ។

តាមវិសមភាពយិនសិន

$$\frac{1}{n}\sum_{i=1}^{n}\frac{1}{x_i+1}=\frac{1}{n}\sum_{i=1}^{n}\frac{1}{e^{y_i}+1} \geq \frac{1}{e^{\frac{1}{n}\sum_{i=1}^{n} y_i}+1}=\frac{1}{(x_1x_2\ldots x_n)^{\frac{1}{n}}+1}$$

ដោយអង្គទាំងពីរស្មើគ្នា ពេល $x_1 = x_2 = \mathrm{L} = x_n$ ។

**327.▲** តាង

$$f(a)=\frac{a}{b+c+1}+\frac{b}{c+a+1}+\frac{c}{a+b+1}+(1-a)(1-b)(1-c)$$

ដោយចាត់ទុកថា $b,c$ ជាប៉ារ៉ាម៉ែត្រ ។ យើងឃើញថា $f$ ជាអនុគមន៍ផតធៀបនឹង $a$

ដូច្នេះ តម្លៃធំបំផុតរបស់វា គឺនៅត្រង់ $a=0$ ឬ $a=1$ ។ តាមវិចារដូចគ្នា យើងទាញ

បានថា $f$ មានតម្លៃធំបំផុត នៅត្រង់ចំណុចមួយ (ឬច្រើនជាងមួយ) ក្នុងចំណោមចំណុចទាំងប្រាំបី ដែលមាន
$(a,b,c) =$
$\{0;0;0\},\{0;0;1\},\{0;1;0\},\{0;1;1\},\{1;0;0\},\{1;1;0\},\{1;0;1\},\{1;1;1\})$ ។ យើងពិនិត្យឃើញថា ចំពោះត្រីធាតុនីមួយៗ តម្លៃរបស់អនុគមន៍ $f$ ស្មើ 1 ។ ដូច្នេះវិសមភាពពិត ។

**328.▲** អង្គខាងឆ្វេងជាអនុគមន៍ជត ចំពោះអថេរនីមួយៗ ដោយទប់អថេរផ្សេងទៀត ។ វាមានតម្លៃធំបំផុតនៅត្រង់ចំណុចមួយនៃបញ្ចធាតុ $(a,b,c,d,e)$ទាំង 32 ដែល $a,b,c,d,e \in \{p;q\}$ ។
តាង $n$ ជាចំនួនអថេរ ដែលស្មើ $p$ ហើយដូច្នេះអថេរចំនួន $5-n$ ផ្សេងទៀតស្មើ $q$ ដែល $n \in \{0;1;2;3;4;5\}$ ។ ដូច្នេះ យើងត្រូវរកតម្លៃធំបំផុតរបស់

$$f(n) = [np + (5-n)q]\left[\frac{n}{p} + \frac{5-n}{q}\right]$$

យើងមាន

$$\begin{aligned} f(n) &= n^2 + (5-n)^2 + n(5-n)\left(\frac{p}{q} + \frac{q}{p}\right) \\ &= n^2 + (5-n)^2 + n(5-n)\left(\frac{p}{q} + \frac{q}{p} - 2 + 2\right) \\ &= n^2 + (5-n)^2 + 2n(5-n) + n(5-n)\left(\sqrt{\frac{p}{q}} - \sqrt{\frac{q}{p}}\right)^2 \\ &= 25 + n(5-n)\left(\sqrt{\frac{p}{q}} - \sqrt{\frac{q}{p}}\right)^2 \end{aligned}$$

ដូច្នេះ $f(n)$ ធំបំផុត បើ

$$n(5-n) = \frac{25}{4} - \left(n - \frac{5}{2}\right)^2$$

មានតម្លៃធំបំផុត មានន័យថា $n = 2$ ឬ $n = 3$ ។ ដូច្នេះ

$$f_{\max} = 25 + 6\left(\sqrt{\frac{p}{q}} - \sqrt{\frac{q}{p}}\right)^2$$

**329.▲** តាង $A, B, C \in \left(0, \frac{\pi}{2}\right)$ និង $a = \sqrt{2}\tan A, b = \sqrt{2}\tan B$ និង $c = \sqrt{2}\tan C$ ។ តាមទំនាក់ទំនង $1 + \tan^2\theta = 1/\cos^2\theta$ វិសមភាពអាចសរសេរជា

$$\begin{aligned}&(a^2+2)(b^2+2)(c^2+2) \geq 9(ab+bc+ca)\\ &\Leftrightarrow (2\tan^2 A + 2)(2\tan^2 B + 2)(2\tan^2 C + 2)\\ &\qquad \geq 9(2\tan A\tan B + 2\tan B\tan C + 2\tan C\tan A)\\ &\Leftrightarrow \frac{4}{9} \geq \cos A\cos B\cos C\,(\sin A\sin B\cos C + \sin B\sin C\cos A\\ &\qquad + \sin C\sin A\cos B)\end{aligned}$$

យើងមាន

$$\begin{aligned}&\cos(A+B+C)\\ &\qquad = \cos A\cos B\cos C - \cos A\sin B\sin C - \sin A\cos B\sin C\\ &\qquad - \sin A\sin B\cos C\end{aligned}$$

ដូច្នេះវិសមភាពទៅជា

$$\frac{4}{9} \geq \cos A\cos B\cos C\,(\cos A\cos B\cos C - \cos(A+B+C))$$

តាង $q = \frac{A+B+C}{3}$ ។ តាមវិសមភាពកូស៊ី និង វិសមភាពយិនសិន យើងទាញបាន

$$\cos A\cos B\cos C \leq \left(\frac{\cos A + \cos B + \cos C}{3}\right)^3 \leq \cos^3 q$$

យើងត្រូវបង្ហាញថា

$$\frac{4}{9} \geq \cos^3 q\,(\cos^3 q - \cos 3q)$$

យើងមាន

$$\cos 3q = 4\cos^3 q - 3\cos q \implies \cos^3 q - \cos 3q = 3\cos q - 3\cos^3 q$$

ដូច្នេះវិសមភាពទៅជា

$$\frac{4}{27} \geq \cos^4 q\,(1 - \cos^2 q) \qquad (*)$$

តាមវិសមភាពកូស៊ី

$$\left[\frac{\cos^2 q}{2}.\frac{\cos^2 q}{2}.(1-\cos^2 q)\right]^{\frac{1}{3}} \leq \frac{1}{3}\left[\frac{\cos^2 q}{2} + \frac{\cos^2 q}{2} + (1-\cos^2 q)\right] = \frac{1}{3}$$

$\Longrightarrow$ (*) ពិត ។ សមភាពកើតមាន ទាល់តែ

$$\tan A = \tan B = \tan C = \frac{1}{\sqrt{2}} \Rightarrow a = b = c = 1$$

**330.▲** ❶ ដំណោះស្រាយទី ១

តាង $a = y + z, b = z + x, c = x + y$ ។

$$a + b > c \Rightarrow y + z + z + x > x + y \Rightarrow z > 0$$

ដូចគ្នា $x, y, z > 0$ ។

វិសមភាពខាងលើសមមូលនឹង

$$x^3z + y^3x + z^3y \geq x^2yz + xy^2z + xyz^2$$
$$\Leftrightarrow \frac{x^2}{y} + \frac{y^2}{z} + \frac{z^2}{x} \geq x + y + z$$

ដោយវិសមភាពខាងលើអូម៉ូសែន (បើយើងជំនួស $(x, y, z)$ ដោយ $tx, ty, tz$) នោះវិសមភាពនៅដដែល )នោះយើងអាចសន្មតថា $x + y + z = 1$ ។ ដូច្នេះវិសមភាពសមមូលនឹង

$$yf\left(\frac{x}{y}\right) + zf\left(\frac{y}{z}\right) + xf\left(\frac{z}{x}\right) \geq 1$$

ដែល $f(t) = t^2$ ។ ដោយ $f$ ផតលើ $\mathbb{R}$ តាមវិសមភាពយិនសិន យើងទាញបាន

$$yf\left(\frac{x}{y}\right) + zf\left(\frac{y}{z}\right) + xf\left(\frac{z}{x}\right) \geq f\left(y.\frac{x}{y} + z.\frac{y}{z} + x.\frac{z}{x}\right) = f(1) = 1$$

❷ ដំណោះស្រាយទី២

តាង $f(a, b, c) = a^2b(a - b) + b^2c(b - c) + c^2a(c - a)$ ។ យើងឃើញថា $f$ មិនប្រែប្រួលទេ ពេលយើងធ្វើចំលាស់ស៊ីគ្លិចនៃ $(a, b, c)$ មានន័យថា ដូរ $(a, b, c)$ ជា $(b, c, a)$ ឬ $(c, a, b)$ ។ ដូច្នេះ យើងអាចសន្មតថា $a = \max(a, b, c)$ (តែមិនអាចសន្មតថា $a \geq b \geq c$ បានទេ ព្រោះ $f$ មិនស៊ីមេទ្រី) ។ យើងទាញបាន

$$f(a, b, c) = a(b - c)^2(b + c - a) + b(a - b)(a - c)(a + b - c) \geq 0$$

សមភាពកើតមានពេល $a = b = c$ ។

**331.▲** បើគ្រប់ $a_i$ ស្មើគ្នាទាំងអស់ នោះអនុគមន៍ $M$ ថេរលើ $\mathbb{R}^*$ ។ ឥលូវនេះ យើងសន្មតថា បណ្តា $a_i$ មិនស្មើគ្នាទាំងអស់ទេ ។ តាង $f(\alpha) = \ln[l_1a_1^\alpha + l_2a_2^\alpha + \cdots + l_na_n^\alpha]$ ។

យើងមាន

$$\ln M(\alpha) = \frac{1}{\alpha}\ln[l_1a_1^\alpha + l_2a_2^\alpha + \cdots + l_na_n^\alpha] = \frac{f(\alpha)}{\alpha}$$

យើងមាន $\lim_{\alpha\to 0} a_i^\alpha = 1$ ចំពោះគ្រប់ $a_i > 0$ ដូច្នេះ $\lim_{\alpha\to 0} f(\alpha) = 0$ ។ ម្យ៉ាងវិញទៀត ដោយ

$$f'(\alpha) = \frac{l_1a_1^\alpha \ln a_1 + l_2a_2^\alpha \ln a_2 + \cdots + l_na_n^\alpha \ln a_n}{l_1a_1^\alpha + l_2a_2^\alpha + \cdots + l_na_n^\alpha}$$

$$\Longrightarrow \lim_{\alpha\to 0} f'(\alpha) = \frac{l_1 \ln a_1 + l_2 \ln a_2 + \cdots + l_n \ln a_n}{l_1 + l_2 + \cdots + l_n}$$

$$= l_1 \ln a_1 + l_2 \ln a_2 + \cdots + l_n \ln a_n = \ln\left(a_1^{l_1}a_2^{l_2} \dots a_n^{l_n}\right)$$

តាមក្បួន អូពីតាល់ យើងទាញបាន

$$\lim_{\alpha\to 0} \ln M(\alpha) = \ln\left(a_1^{l_1}a_2^{l_2} \dots a_n^{l_n}\right) \Longrightarrow \lim_{\alpha\to 0} M(\alpha) = a_1^{l_1}a_2^{l_2} \dots a_n^{l_n}$$

ដូច្នេះ ដោយយក $M(0) = a_1^{l_1}a_2^{l_2} \dots a_n^{l_n}$ យើងទាញបាន $M$ ជាប់ត្រង់ 0 ។

ក) ករណី $\alpha > 1$

អនុគមន៍ $f(x) = x^\alpha$ ផតដាច់ខាតលើ $\mathbb{R}^{+*}$ ។ ដូច្នេះ

$$l_1a_1^\alpha + l_2a_2^\alpha + \cdots + l_na_n^\alpha > (l_1a_1 + l_2a_2 + \cdots + l_na_n)^\alpha$$

វិសមភាពនេះ ដាច់ខាត ព្រោះ បណ្ដា $a_i$ មិនស្មើគ្នាទាំងអស់ទេ ។

ដូច្នេះ

$$M(\alpha) = (l_1a_1^\alpha + l_2a_2^\alpha + \cdots + l_na_n^\alpha)^{\frac{1}{\alpha}} > l_1a_1 + l_2a_2 + \cdots + l_na_n = M(1)$$

ខ) ករណី $\alpha, \beta \in \mathbb{R}$

ករណីទី១: $0 < \alpha < \beta$

តាង $t = \beta/\alpha > 1$ ។ ចំពោះគ្រប់ $i \in \{1, \dots, n\}$ យើងតាង $b_i = a_i^\alpha$ ។ តាម ក) យើងមាន

$$\left(\sum_{i=1}^n l_ib_i^t\right)^{\frac{1}{t}} > \sum_{i=1}^n l_ib_i \quad \Rightarrow \left(\sum_{i=1}^n l_ia_i^\beta\right)^{\frac{\alpha}{\beta}} > \sum_{i=1}^n l_ia_i^\alpha \quad \Rightarrow M(\beta) > M(\alpha)$$

ករណីទី២: $\alpha < \beta < 0$

តាង $t=\alpha/\beta>1$ ។ ចំពោះគ្រប់ $i\in\{1,\dots,n\}$ យើងតាង $b_i=a_i^{\beta}$ ។ តាម ក) យើងមាន

$$\left(\sum_{i=1}^{n} l_i b_i^t\right)^{\frac{1}{t}} > \sum_{i=1}^{n} l_i b_i \ \Rightarrow \left(\sum_{i=1}^{n} l_i a_i^{\alpha}\right)^{\frac{\beta}{\alpha}} > \sum_{i=1}^{n} l_i a_i^{\beta} \ \Rightarrow M(\beta)>M(\alpha)$$

ដូច្នេះ អនុគមន៍ $M$ កើនដាច់ខាតលើ $\mathbb{R}^{+*}$; $\mathbb{R}^{-*}$ ហើយជាប់ត្រង់ 0 ។ ដូច្នេះ វាកើនដាច់ខាតលើ $\mathbb{R}$ ។

**332.▲** ● ចំពោះ $\alpha>0$ :

តាមលក្ខណៈស៊ីមេទ្រី យើងអាចសន្មតថា $a_1=\max\{a_1,a_2,\dots,a_n\}$ ។

ដូច្នេះ

$\ln M(\alpha)=\frac{1}{\alpha}\ln[l_1a_1^{\alpha}+l_2a_2^{\alpha}+\cdots+l_na_n^{\alpha}]=\frac{1}{\alpha}\ln\left[a_1^{\alpha}\sum_{i=1}^{n}l_i\left(\frac{a_i}{a_1}\right)^{\alpha}\right]=\ln a_1+\frac{1}{\alpha}\ln\left[\sum_{i=1}^{n}l_i\left(\frac{a_i}{a_1}\right)^{\alpha}\right]$

ចំពោះគ្រប់ $i$ យើងមាន $0<\frac{a_i}{a_1}\le 1$ ។ ដូច្នេះ $0<\left(\frac{a_i}{a_1}\right)^{\alpha}\le 1$

$$\Rightarrow \sum_{i=1}^{n} l_i\left(\frac{a_i}{a_1}\right)^{\alpha} \le \sum_{i=1}^{n} l_i = 1$$

$$\ln M(\alpha)\le \ln a_1+\frac{1}{\alpha}\ln 1=\ln a_1$$

$$\Longrightarrow \lim_{\alpha\to+\infty}\ln M(\alpha)=\ln a_1$$

$$\Longrightarrow \lim_{\alpha\to+\infty} M(\alpha)=a_1=\max\{a_1,a_2,\dots,a_n\}$$

● ចំពោះ $\alpha<0$

លើកនេះយើងសន្មតថា $a_1=\min\{a_1,a_2,\dots,a_n\}$ ។ ដូចខាងលើ យើងមាន

$$\ln M(\alpha)=\ln a_1+\frac{1}{\alpha}\ln\left[\sum_{i=1}^{n} l_i\left(\frac{a_i}{a_1}\right)^{\alpha}\right]$$

ដែល $\frac{a_i}{a_1}\ge 1$ ចំពោះគ្រប់ $i$ ។ ដូច្នេះ $0<\left(\frac{a_i}{a_1}\right)^{\alpha}\le 1$ ។

តាមវិចារដូចករណីខាងលើ យើងទាញបាន

$$\lim_{\alpha\to-\infty} M(\alpha)=a_1=\min\{a_1,a_2,\dots,a_n\}$$

ដូច្នេះ

$$\lim_{\alpha\to+\infty} M(\alpha) = a_1 = \max\{a_1, a_2, \dots, a_n\}$$
$$\lim_{\alpha\to-\infty} M(\alpha) = a_1 = \min\{a_1, a_2, \dots, a_n\}$$

ហើយដោយអនុគមន៍ $M$ កើនដាច់ខាតលើ $\mathbb{R}$ ដូច្នេះ ចំពោះគ្រប់ $\alpha \in \mathbb{R}$ គេមាន

$$\min\{a_1, a_2, \dots, a_n\} < M(\alpha) < \max\{a_1, a_2, \dots, a_n\}$$

● យក $l_1 = l_2 = \cdots = l_n = \frac{1}{n}$ យើងទាញបាន

$$M(-1) = \left[\frac{1}{n}(a_1^{-1} + a_2^{-1} + \cdots + a_n^{-1})\right]^{-1} = \frac{n}{\frac{1}{a_1} + \frac{1}{a_2} + \cdots + \frac{1}{a_n}}$$
$$M(0) = (a_1 a_2 \dots a_n)^{\frac{1}{n}}$$
$$M(1) = \left[\frac{1}{n}a_1 + \frac{1}{n}a_2 + \cdots + \frac{1}{n}a_n\right]^1 = \frac{a_1 + a_2 + \cdots + a_n}{n}$$
$$M(2) = \left[\frac{1}{n}a_1^2 + \frac{1}{n}a_2^2 + \cdots + \frac{1}{n}a_n^2\right]^{\frac{1}{2}} = \sqrt{\frac{a_1^2 + a_2^2 + \cdots + a_n^2}{n}}$$

**333.▲** តាង $A = x_1^3 + x_2^3 + x_3^3 + x_4^3$ និង $A_i = A - x_i^3 \implies A = \frac{1}{3}\sum_{i=1}^4 A_i$ ។ តាមវិសមភាពកូស៊ី យើងទាញបាន

$$\frac{1}{3}A_1 \geq (x_2^3 x_3^3 x_4^3)^{1/3} = x_2 x_3 x_4 = 1/x_1$$

តាមរបៀបដូចគ្នា យើងទាញបាន

$$\frac{1}{3}A_i \geq \frac{1}{x_i};\ \ \forall i = 1,2,3,4$$
$$\implies A \geq \sum_{i=1}^4 1/x_i \qquad (1)$$

ម្យ៉ាងវិញទៀត

$$\frac{1}{4}A = \frac{1}{4}\sum_{i=1}^4 x_i^3 \geq \left(\frac{1}{4}\sum_{i=1}^4 x_i\right)^3 \qquad \text{(តាមវិសមភាពមធ្យមលំដាប់ 3 និង 1)}$$
$$= \left(\frac{1}{4}\sum_{i=1}^4 x_i\right)\left(\frac{1}{4}\sum_{i=1}^4 x_i\right)^2 \geq \left(\frac{1}{4}\sum_{i=1}^4 x_i\right)$$

ព្រោះ

$$\left(\frac{1}{4}\sum_{i=1}^{4} x_i\right) \geq (x_1x_2x_3x_4)^{\frac{1}{4}} = 1 \quad \left(\text{តាមវិសមភាពកូស៊ី}\right)$$

$$\Rightarrow A \geq \sum_{i=1}^{4} x_i \quad (2)$$

(1) និង (2) $\Rightarrow \sum_{i=1}^{4} x_i^3 \geq \max\{\sum_{i=1}^{4} x_i\,; \sum_{i=1}^{4} 1/x_i\}$ ។

**334.▲** បើមានចំនួនណាមួយស្មើសូន្យ ឧទាហរណ៍ $z = 0$ នោះ វិសមភាពសមមូលនឹង

$$8(x^6 + y^6 + 2x^3y^3) \geq 9x^3y^3$$

ពិត ហើយស្មើគ្នាពេល $x = y = z = 0$ ។

បើ $x, y, z > 0$ យើងមាន

$$\begin{aligned} 9(x^2 + yz)(y^2 + zx)(z^2 + xy) \\ &\leq \frac{9}{8}(2x^2 + y^2 + z^2)(x^2 + 2y^2 + z^2)(x^2 + y^2 + 2z^2) \\ &\leq \frac{9}{8}\left[\frac{4(x^2 + y^2 + z^2)}{3}\right]^3 \quad \left(\text{តាមវិសមភាពកូស៊ី}\right) \end{aligned}$$

$$= 9.8\left(\frac{x^2 + y^2 + z^2}{3}\right)^3 \leq 9.8\left(\frac{x^3 + y^3 + z^3}{3}\right)^2 \left(\text{តាម មធ្យមលំដាប់ពានិង២}\right)$$

$$= 8(x^3 + y^3 + z^3)^2$$

អង្គទាំងពីរស្មើគ្នា ទាល់តែនិងនាំឱ្យ $x = y = z$ ។

**335.▲** អនុគមន៍ $f(x) = \frac{x}{\sqrt{1-x}}$ ជាអនុគមន៍ផត ។ តាមវិសមភាពយិនសិន យើងទាញបាន

$$\frac{1}{n}\sum_{i=1}^{n} f(x_i) \geq f\left(\frac{1}{n}\sum_{i=1}^{n} x_i\right) = f\left(\frac{1}{n}\right) = \frac{1}{n}\sqrt{\frac{n}{n-1}} \Rightarrow \sum_{i=1}^{n}\frac{x_i}{\sqrt{1-x_i}} \geq \sqrt{\frac{n}{n-1}}$$

ម្យ៉ាងវិញទៀត តាមវិសមភាពមធ្យមលំដាប់ 1 និង 1/2 យើងទាញបាន

$$\frac{1}{n} = \frac{1}{n}\sum_{i=1}^{n} x_i \geq \left(\frac{1}{n}\sum_{i=1}^{n}\sqrt{x_i}\right)^2 \Rightarrow \sum_{i=1}^{n}\sqrt{x_i} \leq \sqrt{n} \Rightarrow \frac{\sum_{i=1}^{n}\sqrt{x_i}}{\sqrt{n-1}} \leq \sqrt{\frac{n}{n-1}}$$

$$\Rightarrow \sum_{i=1}^{n}\frac{x_i}{\sqrt{1-x_i}} \geq \sqrt{\frac{n}{n-1}} \geq \frac{\sum_{i=1}^{n}\sqrt{x_i}}{\sqrt{n-1}}$$

ពិត ។

**336.▲** តាង $S = x_1 + x_2 + \cdots + x_n$ ។ យើងមាន

$$\left(\sum_{i=1}^{n} \frac{x_i^5}{S - x_i}\right)\left(\sum_{i=1}^{n}(S - x_i)\right) \geq \left(\sum_{i=1}^{n}\sqrt{x_i^5}\right)^2 \quad \text{(តាមវិសមភាពកូស៊ីស្វាត)}$$

$$= n^2\left(\frac{1}{n}\sum_{i=1}^{n} x_i^{\frac{5}{2}}\right)^2 \geq n^2\left(\frac{1}{n}\sum_{i=1}^{n} x_i^2\right)^{\frac{5}{2}} \quad \text{(តាមវិសមភាពមធ្យមលំដាប់ } \tfrac{5}{2} \text{ និង } 2\text{)}$$

$$= \frac{n^2}{n^{\frac{5}{2}}} \qquad (*)$$

ដោយអង្គទាំងពីរស្មើគ្នា ពេល $x_1 = x_2 = \cdots = x_n = 1/\sqrt{n}$ ។

ម៉្យាងវិញទៀត

$$0 < \sum_{i=1}^{n}(S - x_i) = (n-1)\sum_{i=1}^{n} x_i = n(n-1)\sum_{i=1}^{n}\frac{x_i}{n}$$

$$\leq n(n-1)\left(\frac{1}{n}\sum_{i=1}^{n} x_i^2\right)^{\frac{1}{2}} \quad \text{(តាមវិសមភាពមធ្យមលំដាប់ 1 និង 2)}$$

$$= \frac{n(n-1)}{\sqrt{n}}$$

$$\Rightarrow 0 < \sum_{i=1}^{n}(S - x_i) \leq \frac{n(n-1)}{\sqrt{n}} \qquad (**)$$

ដោយអង្គទាំងពីរស្មើគ្នា ពេល $x_1 = x_2 = \cdots = x_n = 1/\sqrt{n}$ ។

(*) និង (**)

$$\left(\sum_{i=1}^{n}\frac{x_i^5}{S - x_i}\right)\frac{n(n-1)}{\sqrt{n}} \geq \frac{n^2}{n^{\frac{5}{2}}} \Rightarrow \sum_{i=1}^{n}\frac{x_i^5}{S - x_i} \geq \frac{1}{n(n-1)}$$

ដោយអង្គទាំងពីរស្មើគ្នា ពេល $x_1 = x_2 = \cdots = x_n = 1/\sqrt{n}$ ។

**337.▲** សន្មតថា $a \geq b \geq c$ ។ ដូច្នេះ

$$\frac{1}{b+c} \geq \frac{1}{a+c} \geq \frac{1}{a+b}$$

តាមវិសមភាព Chebyshev យើងមាន

$$\frac{a^n}{b+c} + \frac{b^n}{a+c} + \frac{c^n}{a+b} \geq \frac{1}{3}(a^n + b^n + c^n)\left(\frac{1}{b+c} + \frac{1}{a+c} + \frac{1}{a+b}\right) \qquad (1)$$

តាមវិសមភាព Cauchy-Schwarz យើងមាន

$$2(a+b+c)\left(\frac{1}{b+c}+\frac{1}{a+c}+\frac{1}{a+b}\right)\geq 9$$

និងតាមវិសមភាពមធ្យម យើងមាន

$$\frac{a^n+b^n+c^n}{3}\geq\left(\frac{a+b+c}{3}\right)^n$$

ដូច្នេះ វិសមភាព (1) នាំឱ្យ

$$\frac{a^n}{b+c}+\frac{b^n}{a+c}+\frac{c^n}{a+b}\geq\left(\frac{a+b+c}{3}\right)^n\frac{9}{2(a+b+c)}=\frac{3}{2}\left(\frac{a+b+c}{3}\right)^{n-1}$$
$$=\frac{3}{2}\left(\frac{2}{3}s\right)^{n-1}=\left(\frac{2}{3}\right)^{n-2}s^{n-1}$$

**338.▲** ដោយវិសមភាពស៊ីមេទ្រីធៀបនឹងអថេរទាំងបី យើងអាចសន្មតថា $x\geq y\geq z$ ដោយមិនបាត់បង់លក្ខណ:ទូទៅអ្វីទាំងអស់ ។ វិសមភាពដែលឱ្យ អាចសរសេរជា

$$x^r(x-y)(x-z)+y^r(y-z)(y-x)+z^r(z-x)(z-y)\geq 0$$
$$\Leftrightarrow (x-y)[x^r(x-z)-y^r(y-z)]+z^r(x-z)(y-z)\geq 0$$

ពិត ព្រោះតួនីមួយៗ សុទ្ធតែវិជ្ជមានទាំងអស់ ។ អង្គទាំងពីរស្មើគ្នា ទាល់តែ $x=y=z$ ។

**339.▲ ❶** វិសមភាពខាងឆ្វេងដែលឱ្យមក សមមូលនឹង

$$a^3+b^3+c^3+3abc\geq ab(a+b)+bc(b+c)+ca(c+a)$$
$$\Leftrightarrow a(a-b)(a-c)+b(b-c)(b-a)+c(c-a)(c-b)\geq 0$$

ពិត តាមវិសមភាព Schur ករណី $r=1$ ។ អង្គទាំងពីរស្មើគ្នា ទាល់តែនិងមានតែ

$a=b=c$ ។

វិសមភាពខាងស្តាំសមមូលនឹង

$$ab(a+b)+bc(b+c)+ca(c+a)\geq 2\left[(ab)^{\frac{3}{2}}+(bc)^{\frac{3}{2}}+(ca)^{\frac{3}{2}}\right]$$
$$\Leftrightarrow \sum_{\text{cyclic}}(a^2b+ab^2)\geq\sum_{\text{cyclic}}2(ab)^{\frac{3}{2}}$$

ពិតតាមវិសមភាពកូស៊ី ។

❷ តាង $x=a^{2/3}, y=b^{2/3}, z=c^{2/3}$ វិសមភាពសមមូលនឹង

$$(3-t)+t(abc)^{\frac{2}{t}}+a^2+b^2+c^2\ge 2(ab+bc+ca)$$
$$\Leftrightarrow (3-t)+t(xyz)^{3/t}+x^3+y^3+z^3\ge 2\left[(xy)^{\frac{3}{2}}+(yz)^{\frac{3}{2}}+(zx)^{\frac{3}{2}}\right]$$

តាមសំនួរទី❶ យើងមាន

$$x^3+y^3+z^3+3xyz\ge 2\left[(xy)^{\frac{3}{2}}+(yz)^{\frac{3}{2}}+(zx)^{\frac{3}{2}}\right]$$

ដូច្នេះ ពេលនេះ យើងគ្រាន់តែបង្ហាញថា

$$(3-t)+t(xyz)^{\frac{3}{t}}\ge 3xyz$$
$$\Leftrightarrow \frac{3-t}{3}.1+\frac{t}{3}(xyz)^{\frac{3}{t}}\ge 1^{\frac{3-t}{3}}.\left[(xyz)^{\frac{3}{t}}\right]^{\frac{t}{3}}=xyz$$

ពិត តាមវិសមភាពមធ-មធទូទៅ ។ យើងឃើញថាអង្គទាំងពីរស្មើគ្នា ពេល

$a=b=c=1$ ។

❸ ចំពោះ $t=\frac{1}{2};1;2$ យើងមាន

$$\frac{5}{2}+\frac{1}{2}(abc)^4+a^2+b^2+c^2\ge 2(ab+bc+ca)$$
$$2+(abc)^2+a^2+b^2+c^2\ge 2(ab+bc+ca)$$
$$1+2abc+a^2+b^2+c^2\ge 2(ab+bc+ca)$$

**340.▲** ❶ លក្ខខណ្ឌចាំបាច់

យក $a=0, b=c=1$ វិសមភាពដែលឱ្យទៅជា

$$k(k+1)^2\ge\left(k+\frac{1}{2}\right)^3$$
$$k^3+2k^2+k\ge k^3+\frac{3}{2}k^2+\frac{3}{4}k+\frac{1}{8}$$
$$\frac{1}{2}k^2+\frac{1}{4}k-\frac{1}{8}\ge 0$$
$$4k^2+2k-1\ge 0$$

ដូច្នេះជាចាំបាច់ត្រូវតែ $4k^2+2k-1\ge 0$ ។

❷ លក្ខខណ្ឌគ្រប់គ្រាន់

វិសមភាពដែលឱ្យសមមូលនឹង

$$[(b+c)k+a][(c+a)k+b][(a+b)k+c]$$
$$\ge (a+b)(b+c)(c+a)\left(k+\frac{1}{2}\right)^3$$

$$\Leftrightarrow \{(b+c)(c+a)k^2+[b(b+c)+a(c+a)]k+ab\}[(a+b)k+c] \geq (a+b)(b+c)(c+a)\left(k^3+\frac{3}{2}k^2+\frac{3}{4}k+\frac{1}{8}\right)$$

$$\Leftrightarrow \left[c(c+b)(c+a)+a(a+c)(a+b)+b(b+c)(b+a) - \frac{3}{2}(a+b)(b+c)(c+a)\right]k^2 + \left[bc(b+c)+ac(c+a)+ab(a+b) - \frac{3}{4}(a+b)(b+c)(c+a)\right]k+abc - \frac{1}{8}(a+b)(b+c)(c+a) \geq 0$$

$$\Leftrightarrow \frac{1}{2}[2(a^3+b^3+c^3)-(a^2b+a^2c+ac^2+ab^2+b^2c+bc^2)]k^2 + \frac{1}{4}[a^2b+a^2c+ac^2+ab^2+b^2c+bc^2-6abc]k+\frac{3}{4}abc - \frac{1}{8}(a^2b+a^2c+ac^2+ab^2+b^2c+bc^2) \geq 0$$

$$\Leftrightarrow \frac{1}{2}\left[\sum_{\text{sym}} a^3-\sum_{\text{sym}} a^2b\right]k^2+\frac{1}{4}\left[\sum_{\text{sym}} a^2b-\sum_{\text{sym}} abc\right]k - \frac{1}{8}\left[\sum_{\text{sym}} a^2b-\sum_{\text{sym}} abc\right] \geq 0 \quad (1)$$

តាមវិសមភាព Schur

$$a(a-b)(a-c)+b(b-a)(b-c)+c(c-a)(c-b) \geq 0$$

$$\Leftrightarrow a(a^2-ac-ab+bc)+b(b^2-bc-ab+ac)+c(c^2-bc-ac+ab) \geq 0$$

$$\Leftrightarrow a^3+b^3+c^3-a^2c-a^2b+3abc-b^2c-ab^2-bc^2-ac^2 \geq 0$$

$$\Leftrightarrow 2(a^3+b^3+c^3)-2(a^2c+a^2b+b^2a+b^2c+c^2a+c^2b)+6abc \geq 0$$

$$\Leftrightarrow 2(a^3+b^3+c^3)-(a^2c+a^2b+b^2a+b^2c+c^2a+c^2b) \geq (a^2c+a^2b+b^2a+b^2c+c^2a+c^2b)-6abc$$

$$\Rightarrow \sum_{\text{sym}}(a^3-a^2b) \geq \sum_{\text{sym}}(a^2b-abc) \quad (2)$$

និងតាមវិសមភាពកូស៊ី

$$(a^2b+a^2c+ac^2+ab^2+b^2c+bc^2)-6abc$$

$$\geq 6\sqrt[6]{a^2b.a^2c.ac^2.ab^2.b^2c.bc^2}-6abc=0$$

ដូច្នេះ វិសមភាព(2) ទៅជា

$$\sum_{\text{sym}}(a^3-a^2b)\geq\sum_{\text{sym}}(a^2b-abc)\geq 0$$

អង្គទាំងពីរស្មើគ្នាពេល $a=b=c$ ។ តាមវិសមភាព(2) អង្គខាងឆ្វេងនៃវិសមភាព

(1)ទៅជា

$$S=\frac{1}{2}\left[\sum_{\text{sym}}a^3-\sum_{\text{sym}}a^2b\right]k^2+\frac{1}{4}\left[\sum_{\text{sym}}a^2b-\sum_{\text{sym}}abc\right]k$$
$$-\frac{1}{8}\left[\sum_{\text{sym}}a^2b-\sum_{\text{sym}}abc\right]$$
$$\geq\frac{1}{8}\left[\sum_{\text{sym}}a^2b-\sum_{\text{sym}}abc\right](4k^2+2k-1)$$

បើ $4k^2+2k-1\geq 0$ នោះ $S\geq 0$ ចំពោះគ្រប់ $a,b,c$ ។

តើមានតម្លៃ$k$ ណាផ្សេងទៀតដែលផ្ទៀងផ្ទាត់លក្ខខណ្ឌដែរឬទេ? យើងដឹងថា ជាចាំបាច់ $k$ ត្រូវតែ $4k^2+2k-1\geq 0$ ហើយចំពោះ $k$ ផ្ទៀងផ្ទាត់ $4k^2+2k-1\geq 0$ យើងមាន វិសមភាពផ្ទៀងផ្ទាត់ចំពោះគ្រប់ $a,b,c$ ។ ដូច្នេះ $k$ ផ្ទៀងផ្ទាត់ $4k^2+2k-1\geq 0$ ជាចម្លើយ ។

យើងទាញបាន

$$k\leq\frac{-1-\sqrt{5}}{4};k\geq\frac{-1+\sqrt{5}}{4}$$

**341.▲ ❶** យើងមាន

$$\frac{1}{a}-\frac{b+c}{a^2+bc}=\frac{(a-b)(a-c)}{a(a^2+bc)}$$
$$\frac{1}{b}-\frac{c+a}{b^2+ca}=\frac{(b-c)(b-a)}{b(b^2+ca)}$$
$$\frac{1}{c}-\frac{a+b}{c^2+ab}=\frac{(c-a)(c-b)}{c(c^2+ab)}$$

ដូច្នេះវិសមភាពដែលឱ្យសមមូលនឹង

$$\frac{(a-b)(a-c)}{a(a^2+bc)}+\frac{(b-c)(b-a)}{b(b^2+ca)}+\frac{(c-a)(c-b)}{c(c^2+ab)}\geq 0 \quad (*)$$

វិសមភាពខាងលើស៊ីមេទ្រីធៀបនឹង $a,b,c$ ដូច្នេះ យើងអាចសន្មតថា $a\leq b\leq c$ ។

ដូច្នេះ

$$\frac{(c-a)(c-b)}{c(c^2+ab)}\geq 0$$

ដោយអង្គទាំងពីរស្មើគ្នា ពេល $c=a$ ឬ $c=b$ ។

បន្ទាប់មកទៀត

$$\frac{(a-b)(a-c)}{a(a^2+bc)}+\frac{(b-c)(b-a)}{b(b^2+ca)}=\frac{(b-a)^2(a+b)}{ab(a^2+bc)(b^2+ca)}[a(c-b)+cb]\geq 0$$

អង្គទាំងពីរស្មើគ្នា ពេល $a=b$ ។

ដូច្នេះវិសមភាព(*) ពិត ដោយ អង្គទាំងពីរស្មើគ្នា ពេល $a=b=c$ ។

❷ តាមវិសមភាព Schur ចំពោះ $r=-1$ និង តាង $x=a+b, y=b+c$ និង $z=c+a$ យើងទាញបាន

$$\begin{aligned}0&\leq\frac{1}{x}(x-y)(x-z)+\frac{1}{y}(y-z)(y-x)+\frac{1}{z}(z-x)(z-y)\\&=\frac{(a-c)(b-c)}{a+b}+\frac{(b-a)(c-a)}{b+c}+\frac{(c-b)(a-b)}{c+a}\\&=\frac{c^2+ab}{a+b}-c+\frac{a^2+bc}{b+c}-a+\frac{b^2+ca}{c+a}-b\\&\Longrightarrow\frac{c^2+ab}{a+b}+\frac{a^2+bc}{b+c}+\frac{b^2+ca}{c+a}\geq a+b+c\end{aligned}$$

អង្គទាំងពីរស្មើគ្នា ពេល $x=y=z$ ឬ $a=b=c$ ។

**342.▲** ❶ យើងអាចសន្មតថា $a_1\geq a_2; b_1\geq b_2; a_1\geq b_1$ ដោយមិនធ្វើឱ្យបាត់បង់លក្ខណៈទូទៅទេ ។ បើ $x$ ឬ $y$ ស្មើសូន្យ នោះវិសមភាពពិត ។ ដូច្នេះ សន្មតថា $x$ និង $y$ មិនសូន្យទាំងពីរ ។ បន្ទាប់មកទៀត វិសមភាពស៊ីមេទ្រីធៀបនឹង $x,y$ ដូច្នេះ សន្មតថា $x\geq y$ ។ ដោយ $a_1+a_2=b_1+b_2$ នោះ

$$a_1-a_2=(b_1-a_2)+(b_2-a_2)$$

$$\Longrightarrow x^{a_1}y^{a_2}+x^{a_2}y^{a_1}-x^{b_1}y^{b_2}-x^{b_2}y^{b_1}$$
$$=x^{a_2}y^{a_2}\left(x^{a_1-a_2}+y^{a_1-a_2}-x^{b_1-a_2}y^{b_2-a_2}-x^{b_2-a_2}y^{b_1-a_2}\right)$$
$$=x^{a_2}y^{a_2}\left(x^{b_1-a_2}-y^{b_1-a_2}\right)\left(x^{b_2-a_2}-y^{b_2-a_2}\right)$$
$$=x^{a_2}y^{a_2}\left(x^{a_1-b_2}-y^{a_1-b_2}\right)\left(x^{a_1-b_1}-y^{a_1-b_1}\right)$$
$$=x^{a_2}y^{a_2}y^{a_1-a_2}\left[\left(\frac{x}{y}\right)^{a_1-b_2}-1\right]\left[\left(\frac{x}{y}\right)^{a_1-b_1}-1\right]\geq 0$$

ពិត ។

❷ ក) ករណី $b_1\geq a_2$

ដោយ $a_1\geq a_1+a_2-b_1$ និង $a_1\geq b_1$ នោះ $a_1\geq \max(a_1+a_2-b_1,b_1)$

$\Longrightarrow \max(a_1,a_2)=a_1\geq \max(a_1+a_2-b,b_1)$ ។ យើងមាន $a_1+a_2-b_1\geq b_2\geq b_3$ និង $a_1+a_2-b_1\geq b_1+a_3-b_1=a_3$ ។

$$\Longrightarrow \max(a_1+a_2-b_1,a_3)\geq \max(b_2,b_3)$$

តាមសំនួរទី១ យើងទាញបាន

$$\sum_{\text{sym}}x^{a_1}y^{a_2}z^{a_3}=\sum_{\text{cyclic}}z^{a_3}(x^{a_1}y^{a_2}+x^{a_2}y^{a_1})$$
$$\geq\sum_{\text{cyclic}}z^{a_3}\left(x^{a_1+a_2-b_1}y^{b_1}+x^{b_1}y^{a_1+a_2-b_1}\right)$$
$$=\sum_{\text{sym}}x^{b_1}y^{a_1+a_2-b_1}z^{a_3}$$
$$=\sum_{\text{cyclic}}x^{b_1}\left(y^{a_1+a_2-b_1}z^{a_3}+y^{a_3}z^{a_1+a_2-b_1}\right)$$
$$\geq\sum_{\text{cyclic}}x^{b_1}\left(y^{b_2}z^{b_3}+y^{b_3}z^{b_2}\right)$$
$$=\sum_{\text{sym}}x^{b_1}y^{b_2}z^{b_3}$$

ខ) ករណី $b_1\leq a_2$

ដោយ $3b_1\geq b_1+b_2+b_3=a_1+a_2+a_3\geq b_1+a_2+a_3$ នោះ

$$b_1\geq a_2+a_3-b_1$$
$$a_1\geq a_2\geq b_1\geq a_2+a_3-b_1$$

ដូច្នេះ

$$\max(a_2,a_3)\geq \max(b_1,a_2+a_3-b_1)$$
$$\max(a_1,a_2+a_3-b_1)\geq \max(b_2,b_3)$$

តាមសំនួរទី១ យើងទាញបាន

$$\sum_{\text{sym}} x^{a_1}y^{a_2}z^{a_3} = \sum_{\text{cyclic}} x^{a_1}(y^{a_2}z^{a_3} + y^{a_3}z^{a_2})$$
$$\geq \sum_{\text{cyclic}} x^{a_1}\left(y^{b_1}z^{a_2+a_3-b_1} + y^{a_2+a_3-b_1}z^{b_1}\right)$$
$$= \sum_{\text{cyclic}} y^{b_1}\left(x^{a_1}z^{a_2+a_3-b_1} + x^{a_2+a_3-b_1}z^{a_1}\right)$$
$$\geq \sum_{\text{cyclic}} y^{b_1}\left(x^{b_2}z^{b_3} + x^{b_3}z^{b_2}\right)$$
$$= \sum_{\text{sym}} x^{b_1}y^{b_2}z^{b_3}$$

សមភាពកើតមាន ទាល់តែ និង មានតែ $x = y = z$ ។

**343.▲** វិសមភាពដែលឱ្យសមមូលនឹង

$$\frac{1}{a+b+(abc)^{\frac{1}{3}}} + \frac{1}{b+c+(abc)^{\frac{1}{3}}} + \frac{1}{c+a+(abc)^{\frac{1}{3}}} \leq \frac{1}{(abc)^{\frac{1}{3}}}$$

តាង $a = x^3, b = y^3, c = z^3$ ដែល $x, y, z > 0$ ។ វិសមភាពទៅជា

$$\frac{1}{x^3+y^3+xyz} + \frac{1}{y^3+z^3+xyz} + \frac{1}{z^3+x^3+xyz} \leq \frac{1}{xyz}$$
$$\Leftrightarrow xyz \sum_{\text{cyclic}} (x^3+y^3+xyz)(y^3+z^3+xyz)$$
$$\leq (x^3+y^3+xyz)(y^3+z^3+xyz)(z^3+x^3+xyz)$$
$$\Leftrightarrow \sum_{\text{sym}} x^6y^3 \geq \sum_{\text{sym}} x^5y^2z^2$$

ពិតតាមវិសមភាព Muirhead ព្រោះស្វ៊ីត (6,3,0) លប់លើស្វ៊ីត (5,2,2) ។

**344.▲** យើងមាន

$$\sum_{\text{sym}} a^3 = 6(a^3+b^3+c^3+d^3)$$
$$\sum_{\text{sym}} ab\sqrt{cd} = 4\left(ab\sqrt{cd} + ac\sqrt{bd} + ad\sqrt{bc} + bc\sqrt{da} + bd\sqrt{ca} + cd\sqrt{ab}\right)$$

ដូច្នេះវិសមភាព សមមូលនឹង

$$\sum_{\text{sym}} a^3 \geq \sum_{\text{sym}} ab\sqrt{cd} \quad \Leftrightarrow \sum_{\text{sym}} a^3b^0c^0d^0 \geq \sum_{\text{sym}} a^1b^1c^{\frac{1}{2}}d^{\frac{1}{2}}$$

ពិត តាមវិសមភាព Muirhead ព្រោះ (3,0,0,0) លប់លើ $\left(1,1,\frac{1}{2},\frac{1}{2}\right)$ ។

**345.▲** វិសមភាពដែលឱ្យសមមូលនឹង

$$4\sum_{\text{sym}} x^5y + 2\sum_{\text{cyclic}} x^4yz + 6x^2y^2z^2 - \sum_{\text{sym}} x^4y^2 - 6\sum_{\text{cyclic}} x^3y^3 - 2\sum_{\text{sym}} x^3y^2z \geq 0$$

$$\Leftrightarrow \left[\sum_{\text{sym}} x^5y - \sum_{\text{sym}} x^4y^2\right] + 3\left[\sum_{\text{sym}} x^5y - \sum_{\text{sym}} x^3y^3\right] + 2xyz\left[3xyz + \sum_{\text{cyclic}} x^3 - \sum_{\text{sym}} x^2y\right] \geq 0$$

តាមវិសមភាព Muirhead

$$\sum_{\text{sym}} x^5y - \sum_{\text{sym}} x^4y^2 \geq 0$$

$$\sum_{\text{sym}} x^5y - \sum_{\text{sym}} x^3y^3 \geq 0$$

តាមវិសមភាព Schur ចំពោះ $r = 1$

$$\sum_{\text{cyclic}} x(x-y)(x-z) \geq 0$$

$$\Leftrightarrow \sum_{\text{cyclic}} x(x^2 - xz - xy + yz) \geq 0$$

$$\Leftrightarrow \sum_{\text{cyclic}} (\mathrm{x}^3 - \mathrm{x}^2\mathrm{z} - \mathrm{x}^2\mathrm{y} + \mathrm{xyz}) \geq 0$$

$$\Leftrightarrow \sum_{\text{cyclic}} x^3 - \sum_{\text{cyclic}} (x^2z + x^2y) + \sum_{\text{cyclic}} xyz \geq 0$$

$$\Leftrightarrow \sum_{\text{cyclic}} x^3 - \sum_{\text{sym}} x^2y + 3\mathrm{xyz} \geq 0$$

ដូច្នេះវិសមភាពពិត ព្រោះអង្គខាងឆ្វេងជាផលបូកនៃតួមិនអវិជ្ជមាន ។

**346.▲** ដោយ $xy + yz + zx = 1$ យើងបំលែងវិសមភាពឱ្យទៅជាអូម៉ូសែន

$$\frac{1}{x+y} + \frac{1}{y+z} + \frac{1}{z+x} \geq \frac{5}{2}$$

$$\Leftrightarrow (xy + yz + zx)\left(\frac{1}{x+y} + \frac{1}{y+z} + \frac{1}{z+x}\right)^2 \geq \left(\frac{5}{2}\right)^2$$

$$\Leftrightarrow 4\sum_{\text{sym}} x^5y + \sum_{\text{sym}} x^4yz + 14\sum_{\text{sym}} x^3y^2z + 38x^2y^2z^2 \geq \sum_{\text{sym}} x^4y^2 + 3\sum_{\text{sym}} x^3y^3$$

$$\Leftrightarrow \left[\sum_{\text{sym}} x^5y - \sum_{\text{sym}} x^4y^2\right] + 3\left[\sum_{\text{sym}} x^5y - \sum_{\text{sym}} x^3y^3\right] + xyz\left[\sum_{\text{sym}} x^3 + 14\sum_{\text{sym}} x^2y + 38xyz\right] \geq 0$$

តាមវិសមភាព Muirhead វិសមភាពខាងលើពិត ។ អង្គទាំងពីរស្មើគ្នា ទាល់តែ $x = y, z = 0$ ឬ $y = z, x = 0$ ឬ $z = x, y = 0$ ។ តែដោយ $xy + yz + zx = 1$ នោះ វាស្មើគ្នាពេល $(x, y, z) = \{(1,1,0); (1,0,1), (0,1,1)\}$ ។

**347.▲** យើងមាន

$$(a^2 + ab + b^2)(b^2 + bc + c^2)(c^2 + ca + a^2) = \sum_{\text{sym}} \left[\frac{1}{2}a^3b^3 + \frac{1}{2}a^2b^2c^2 + \frac{1}{2}a^4bc + 2a^3b^2c + a^4b^2\right]$$

ហើយ

$$(ab + bc + ca)^3 = \sum_{\text{sym}} \left[\frac{1}{2}a^3b^3 + a^2b^2c^2 + 3a^3b^2c\right]$$

ដូច្នេះ

$\left\{\left(2\pi n\pm\arccos\frac{1}{a};\pi k-\arctan(a+2)\right)\middle| n,k\in\mathbb{Z}\right\}$ ចំពោះ $a\in(-3;-1]$;

$\left\{\left(2\pi n \pm \arccos\frac{1}{a+2}; \pi k - \arctan a\right)\middle| n, k \in \mathbb{Z}\right\}$ ចំពោះ $a \in (-1; 1)$

**874.** $\left\{\left(\frac{\pi k}{2} + (-1)^{k+1}\frac{\pi}{8}; \frac{\pi n}{5} - \frac{1}{5}\arctan\frac{1}{\sqrt{2}}\right)\middle| n, k \in \mathbb{Z}\right\}$

**875.▲** តាង $a = \tan x; b = \tan y; c = \tan z$ ។ យើងទាញបាន

$$\begin{cases} a^2 + b^2 + c^2 = m^2 & (1) \\ a^3 + b^3 + c^3 = m^3 & (2) \end{cases}$$

ក) បើ $m = 0$ នោះ $a = b = c = 0$ យើងទាញបាន $(x; y; z) = (p\pi; h\pi; k\pi)$

ខ) បើ $m \neq 0$ លើកសមីការទី(២)ជាការេ យើងទាញបាន

$$m^6 = (a^3 + b^3 + c^3)^2$$

តាមវិសមភាពកូស៊ីស្វាត យើងទាញបាន

$$\begin{aligned} & m^6 = (a^3 + b^3 + c^3)^2 \leq (a^2 + b^2 + c^2)(a^4 + b^4 + c^4) \\ & \Rightarrow \ m^6 \leq m^2(a^4 + b^4 + c^4) \\ & \Rightarrow \ m^4 \leq a^4 + b^4 + c^4 \qquad (4) \end{aligned}$$

សមីការទី(១) នាំឱ្យ

$$m^4 = (a^2 + b^2 + c^2)^2 = (a^4 + b^4 + c^4) + 2(a^2b^2 + b^2c^2 + c^2a^2)$$

ហើយតាម(៤) យើងទាញបាន

$$\begin{aligned} & (a^4 + b^4 + c^4) + 2(a^2b^2 + b^2c^2 + c^2a^2) \leq a^4 + b^4 + c^4 \\ & \Rightarrow a^2b^2 + b^2c^2 + c^2a^2 \leq 0 \\ & \Rightarrow \begin{cases} a^2b^2 = 0 \\ b^2c^2 = 0 \\ c^2a^2 = 0 \end{cases} \end{aligned}$$

$$\Rightarrow (a = m; b = c = 0); (a = 0; b = m; c = 0); (a = b = 0; c = m)$$

$$\Rightarrow \left[\begin{array}{l} x = \arctan m + p\pi; y = h\pi; z = k\pi \\ x = p\pi; y = \arctan m + h\pi; z = k\pi \\ x = p\pi; y = h\pi; z = \arctan m + k\pi \end{array}\right.$$

ដូច្នេះចំពោះគ្រប់ $m$ សមីការមានចម្លើយ

$$\left[\begin{array}{l} x = \arctan m + p\pi; y = h\pi; z = k\pi \\ x = p\pi; y = \arctan m + h\pi; z = k\pi \\ x = p\pi; y = h\pi; z = \arctan m + k\pi \end{array}\right.$$

# ៤.៥ វិសមភាព

**876.▲** ដោយ $\pi/6 < \alpha < \pi/3$ នោះ $1/\sin\alpha < 2$ និង $1/\cos\alpha < 2$ ។ ដូច្នេះ

$$0 \leq \frac{\pi \sin x}{4\sin\alpha} \leq \frac{\pi}{4\sin\alpha} < \frac{\pi}{2}; 0 \leq \frac{\pi\cos x}{4\cos\alpha} \leq \frac{\pi}{4\cos\alpha} < \frac{\pi}{2}$$

$$\Longrightarrow \ \tan\left(\frac{\pi\sin x}{4\sin\alpha}\right)\geq 0;\ \tan\left(\frac{\pi\cos x}{4\cos\alpha}\right)\geq 0$$

ករណី $x<\alpha$ នោះ $\cos x>\cos\alpha$ យើងទាញបាន

$$\tan\left(\frac{\pi\sin x}{4\sin\alpha}\right)+\tan\left(\frac{\pi\cos x}{4\cos\alpha}\right)\ \geq\tan\left(\frac{\pi\cos x}{4\cos\alpha}\right)\ >\tan\left(\frac{\pi\cos\alpha}{4\cos\alpha}\right)=1$$

ករណី $x=\alpha$ យើងទាញបាន

$$\tan\left(\frac{\pi\sin x}{4\sin\alpha}\right)+\tan\left(\frac{\pi\cos x}{4\cos\alpha}\right)\ =\tan\left(\frac{\pi\sin\alpha}{4\sin\alpha}\right)+\tan\left(\frac{\pi\cos\alpha}{4\cos\alpha}\right)=2>1$$

ករណី $x>\alpha$ នោះ $\sin x>\sin\alpha$ យើងទាញបាន

$$\tan\left(\frac{\pi\sin x}{4\sin\alpha}\right)+\tan\left(\frac{\pi\cos x}{4\cos\alpha}\right)\ \geq\tan\left(\frac{\pi\sin x}{4\sin\alpha}\right)\ >\tan\left(\frac{\pi\sin\alpha}{4\sin\alpha}\right)=1$$

**877.▲** វិសមភាពសមមូលនឹង

$$\begin{aligned}
&4\tan^2A\tan^2B\tan^2C-4(\tan^2A+\tan^2B+\tan^2C)-3\\
&\qquad\leq(1+\tan^2A)(1+\tan^2B)(1+\tan^2C)\\
&\Leftrightarrow 4\left(\frac{1}{\cos^2A}-1\right)\left(\frac{1}{\cos^2B}-1\right)\left(\frac{1}{\cos^2C}-1\right)\\
&\qquad-4\left(\frac{1}{\cos^2A}+\frac{1}{\cos^2B}+\frac{1}{\cos^2C}-3\right)-3\\
&\qquad\leq\frac{1}{\cos^2A}\frac{1}{\cos^2B}\frac{1}{\cos^2C}\\
&\Leftrightarrow\cos^2A+\cos^2B+\cos^2C\geq\frac{3}{4}\\
&\Leftrightarrow\frac{1+\cos2A}{2}+\frac{1+\cos2B}{2}+\cos^2C\geq\frac{3}{4}\\
&\Leftrightarrow 2(\cos2A+\cos2B)+4\cos^2C+1\geq0\\
&\Leftrightarrow 4\cos(A+B)\cos(A-B)+4\cos^2C+1\geq0\\
&\Leftrightarrow 4\cos^2C-4\cos C\cos(A-B)+1\geq0\\
&\Leftrightarrow[2\cos C-\cos(A-B)]^2+\sin^2(A-B)\geq0
\end{aligned}$$

ពិត ។

**878.▲** យើងមាន

$$\begin{aligned}
1-\sin\frac{\pi}{14}&=\sin\frac{3\pi}{14}-\sin\frac{\pi}{14}+\sin\frac{5\pi}{14}-\sin\frac{3\pi}{14}+\sin\frac{7\pi}{14}-\sin\frac{5\pi}{14}\\
&=2\sin\frac{\pi}{14}\left(\cos\frac{\pi}{7}+\cos\frac{2\pi}{7}+\cos\frac{3\pi}{7}\right)\qquad(1)
\end{aligned}$$

$$\Longrightarrow\ \frac{1-\sin\frac{\pi}{14}}{2\sin\frac{\pi}{14}}=\cos\frac{\pi}{7}+\cos\frac{2\pi}{7}+\cos\frac{3\pi}{7}\qquad(2)$$

$$\cos\frac{\pi}{7}=\frac{1}{2}\left(\cos\frac{\pi}{7}+\cos\frac{3\pi}{7}+\cos\frac{5\pi}{7}+\cos\frac{\pi}{7}+\cos\frac{4\pi}{7}+\cos\frac{2\pi}{7}\right)$$
$$=\cos\frac{\pi}{7}\cos\frac{2\pi}{7}+\cos\frac{3\pi}{7}\cos\frac{2\pi}{7}+\cos\frac{3\pi}{7}\cos\frac{\pi}{7}\qquad(3)$$

តាង $x=\cos\frac{\pi}{7};y=\cos\frac{2\pi}{7},z=\cos\frac{3\pi}{7}$ ។ តាម (២) និង (៣) វិសមភាពអាចសរសេរជា

$$x+y+z>\sqrt{3(xy+yz+zx)}\qquad(4)$$

ដោយ $x,y,z>0$ នោះ (៤) អាចសរសេរជា

$$(x+y+z)^2>3(xy+yz+zx)$$
$$\Leftrightarrow(x-y)^2+(y-z)^2+(z-x)^2>0\quad(5)$$

ដោយ $x,y,z$ មានតម្លៃខុសគ្នា នោះវិសមភាព (៥) ពិត ។

**879.▲** ដោយ $x_i\in\left[\frac{\pi}{6};\frac{\pi}{2}\right]$ នោះ

$$\frac{1}{2}\le\sin x_i\le1\ \Leftrightarrow\ (\sin x_i-1)\left(\sin x_i-\frac{1}{2}\right)\le0;\quad(i=1;2;\dots 2n)$$
$$\Leftrightarrow\sin^2x_i-\frac{3}{2}\sin x_i+\frac{1}{2}\le0$$
$$\Leftrightarrow\sin x_i+\frac{1}{2\sin x_i}\le\frac{3}{2}$$
$$\Rightarrow\sum_{i=1}^{2n}\sin x_i+\frac{1}{2}\sum_{i=1}^{2n}\frac{1}{\sin x_i}\le\frac{3}{2}2n=3n$$

តាមវិសមភាពកូស៊ី យើងមាន

$$\sum_{i=1}^{2n}\sin x_i+\frac{1}{2}\sum_{i=1}^{2n}\frac{1}{\sin x_i}\ge2\sqrt{\frac{1}{2}Y}$$

យើងទាញបាន $Y\le\frac{9}{2}n^2$ ។ យើងមាន $Y=1800;\Rightarrow n\ge20$ ។ សញ្ញាស្មើកើតមានទាល់តែ $\sin x_i=1$ ឬ $\sin x_i=\frac{1}{2}$ និង $\sum_{i=1}^{2n}\sin x_i=\frac{1}{2}\sum_{i=1}^{2n}\frac{1}{\sin x_i}$ ។ តាង $\alpha$ ជាចំនួន $\sin x_i=1$ និង $\beta$ ជាចំនួន $\sin x_i=\frac{1}{2}$ ។ ដូច្នេះ

$$\alpha+\beta=2n;\alpha+\frac{1}{2}\beta=\frac{1}{2}\alpha+\beta\ \Rightarrow\alpha=\beta=n$$

ដូច្នេះ $n$ តូចបំផុតស្មើ $n=20$ ។

**880.▲** យើងមាន

$$\tan\frac{A}{4}=\tan\left(\frac{\pi}{4}-\frac{B+C}{4}\right)$$

$$\Longrightarrow \tan\frac{A}{4}+\tan\frac{B}{4}+\tan\frac{C}{4}+\tan\frac{A}{4}\tan\frac{B}{4}+\tan\frac{B}{4}\tan\frac{C}{4}+\tan\frac{C}{4}\tan\frac{A}{4} = 1+\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}$$

តាមវិសមភាពកូស៊ីយើងទាញបាន

$$\tan\frac{A}{4}+\tan\frac{B}{4}+\tan\frac{C}{4}\geq 3\sqrt[3]{\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}}$$

$$\tan\frac{A}{4}\tan\frac{B}{4}+\tan\frac{B}{4}\tan\frac{C}{4}+\tan\frac{C}{4}\tan\frac{A}{4}\geq 3\sqrt[3]{\left(\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}\right)^2}$$

ដូច្នេះ

$$1+\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}\geq 3\sqrt[3]{\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}}+3\sqrt[3]{\left(\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}\right)^2}$$

តាង $t=\sqrt[3]{\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}}>0$ ។ ដូច្នេះ

$$1+t^3\geq 3t+3t^2$$
$$\Longrightarrow t\leq 2-\sqrt{3};\text{ ឬ } t\geq 2+\sqrt{3}$$

ដោយ $A,B,C$ ជារង្វាស់មុំក្នុងនៃត្រីកោណ នោះ $0<t<1$ ដូច្នេះ $t\leq 2-\sqrt{3}$ ។ មានន័យថា

$$\tan\frac{A}{4}\tan\frac{B}{4}\tan\frac{C}{4}\leq\left(2-\sqrt{3}\right)^3$$

សញ្ញាស្មើកើតមានពេល $\tan\frac{A}{4}=\tan\frac{B}{4}=\tan\frac{C}{4}=2-\sqrt{3}$ ឬពេល $A=B=C=\frac{\pi}{3}$ ។ ដូច្នេះតម្លៃធំបំផុតគឺ $\max T=\left(2-\sqrt{3}\right)^3$ ។

**881.▲** យើងមាន $0<(n+1)x<\pi/2$ ដូច្នេះ $0<nx<\frac{\pi}{2};0<x<\pi/2$ ។ វិសមភាពអាចសរសេរជា

$$\tan nx\sin x+\cos^{2n}x>1$$

តាង $f(n)=\tan nx\sin x+\cos^{2n}x$ ។ យើងនឹងបង្ហាញថា

$$f(k+1)>f(k),\forall k=0,1,2,\dots,n-1$$

យើងមាន $$f(k+1)>f(k)$$

$$\Longleftrightarrow \tan(k+1)x\sin x+\cos^{2(k+1)}x>\tan kx\sin x+\cos^{2k}x$$
$$\Longleftrightarrow \cos^{2k}x-\cos^{2k+2}x<\sin x\left(\tan(k+1)x-\tan kx\right)$$

$$\Leftrightarrow \cos^{2k} x \sin^2 x < \frac{\sin x \sin x}{\cos(k+1)x \cos kx}$$
$$\Leftrightarrow \cos^{2k} x < \frac{1}{\cos(k+1)x \cos kx}$$
$$\Leftrightarrow \cos^{2k} x \cos(k+1)x \cos kx < 1$$

ពិត ។ ដូច្នេះ $f(n) > f(n-1) > \cdots > f(0) = 1$ ពិត ។

**882.▲** បើ $A, B, C$ ជាមុំក្នុងនៃត្រីកោណ នោះ

$$\cot\frac{A}{2} + \cot\frac{B}{2} + \cot\frac{C}{2} = \cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2};$$
$$\tan\frac{A}{2}\tan\frac{B}{2} + \tan\frac{B}{2}\tan\frac{C}{2} + \tan\frac{C}{2}\tan\frac{A}{2} = 1$$

វិសមភាពសមមូលនឹង

$$27\left(\tan\frac{A}{2}\tan^2\frac{B}{2} + \tan\frac{B}{2}\tan^2\frac{C}{2} + \tan\frac{C}{2}\tan^2\frac{A}{2}\right) < 4\left(\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\right)$$
$$\Leftrightarrow \tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}\left(\tan\frac{A}{2}\tan^2\frac{B}{2} + \tan\frac{B}{2}\tan^2\frac{C}{2} + \tan\frac{C}{2}\tan^2\frac{A}{2}\right) < \frac{4}{27}$$

តាង $x = \tan\frac{B}{2}\tan\frac{C}{2}; y = \tan\frac{C}{2}\tan\frac{A}{2}; z = \tan\frac{A}{2}\tan\frac{B}{2}$ ។ ដូច្នេះ $x, y, z > 0; x + y + z = 1$ ហើយវិសមភាពសមមូលនឹង

$$x^2y + y^2z + z^2x < \frac{4}{27} \qquad (1)$$

តាង $P = x^2y + y^2z + z^2x$ ។ សន្មតថា $x \geq y > 0; x \geq z > 0 \implies y^2z \leq xyz; z^2x \leq x^2z$ ។ ដូច្នេះ

$$P = x^2y + y^2z + z^2x \leq x^2y + xyz + \frac{1}{2}z^2x + \frac{1}{2}x^2z$$
$$= xy(x+z) + \frac{1}{2}xz(x+z)$$
$$= x(x+z)\left(y + \frac{z}{2}\right) = 4.\frac{x}{2}\left(\frac{x+z}{2}\right)\left(y + \frac{z}{2}\right)$$

ប្រើវិសមភាពកូស៊ី ចំពោះគូ $\frac{x}{2}, \left(\frac{x+z}{2}\right), \left(y + \frac{z}{2}\right)$ ហើយដោយដឹងថា $\frac{x}{2} \neq \frac{x+z}{2}$ យើងទាញបាន

$$P < 4\left(\frac{\frac{x}{2} + \frac{x+z}{2} + y + \frac{1}{2}z}{3}\right)^3 = 4\left(\frac{x+y+z}{3}\right)^3 = \frac{4}{27}$$

**883.▲** តាង $a, b, c$ ជារង្វាស់ជ្រុងឈមនឹងមុំ $A, B, C$ ។ តាមទ្រឹស្តីបទស៊ីនុស យើងមាន

$$\sin A = \frac{a}{2R}; \sin B = \frac{b}{2R}; \sin C = \frac{c}{2R}$$
$$\Rightarrow \quad \frac{a^2+b^2}{c^2} = m$$

តាមទ្រឹស្តីបទកូស៊ីនុស យើងទាញបាន

$$a^2+b^2 = m(a^2+b^2+2ab\cos C)$$
$$\Rightarrow |\cos C| = \frac{|m-1|}{m}\frac{a^2+b^2}{2ab} \geq \frac{|m-1|}{m}$$
$$\Rightarrow \sin^2 C = 1-\cos^2 C \leq 1-\frac{(m-1)^2}{m^2} = \frac{2m-1}{m^2}$$
$$\Rightarrow \sin C \leq \frac{\sqrt{2m-1}}{m}$$

សញ្ញាស្មើកើតមានពេល $a=b$ ឬ $A=B$ ។ ដូច្នេះ $\max\sin C = \frac{\sqrt{2m-1}}{m}$ ។

**884.▲** យើងមាន

$$\begin{aligned} f(\tan 2x) &= \tan^4 x + \cot^4 x = (\tan^2 x + \cot^2 x)^2 - 2\tan^2 x\cot^2 x \\ &= ((\tan x + \cot x)^2 - 2\tan x\cot x)^2 - 2 \\ &= \left(\frac{1}{\sin^2\cos^2 x} - 2\right)^2 - 2 \\ &= \left(\frac{4}{\sin^2 2x} - 4 + 2\right)^2 - 2 \\ &= \left(4\frac{\cos^2 2x}{\sin^2 2x} + 2\right)^2 - 2 \\ &= \left(\frac{4}{\tan^2 2x} + 2\right)^2 - 2 \\ &= \frac{16}{\tan^4 2x} + \frac{16}{\tan^2 2x} + 2 \end{aligned}$$

តាង $t = \tan 2x \implies f(t) = 16/t^4 + 16/t^2 + 2$ ។ ដូច្នេះ

$$\begin{aligned} f(\sin x) + f(\cos x) &= 16\left[\frac{1}{\sin^4 x} + \frac{1}{\cos^4 x} + \frac{1}{\sin^2 x} + \frac{1}{\cos^2 x}\right] + 4 \\ &= 16[4 + 3(\cot^2 x + \tan^2 x) + \cot^4 x + \tan^4 x] + 4 \end{aligned}$$

តាមវិសមភាពកូស៊ី យើងមាន

$$\cot^2 x + \tan^2 x \geq 2$$
$$\cot^4 x + \tan^4 x \geq 2$$

សញ្ញាស្មើកើតមានពេល $\tan^2 x = 1$ ។ ដូច្នេះ

$$f(\sin x) + f(\cos x) \geq 16[4 + 3.2 + 2] + 4 = 196$$

សញ្ញាស្មើកើតមានពេល $x = \frac{\pi}{4} + k\frac{\pi}{2}\ \ (k \in \mathbb{Z})$ ។

**885.▲** ជាដំបូងយើងបង្ហាញថាវិសមភាព

$$\frac{a}{b} \geq \frac{a-t}{b-t} \qquad (1)$$

ពិតចំពោះគ្រប់ $a,b,t \in \mathbb{R}$ ដែល $a < b; b > t \geq 0$ ។ យើងមាន

$$\begin{aligned} \frac{a}{b} \geq \frac{a-t}{b-t} &\Leftrightarrow \quad a(b-t) \geq (a-t)b \\ &\Leftrightarrow \; ab - at \geq ab - bt \\ &\Leftrightarrow \; at \leq bt \\ \Leftrightarrow \quad 0 &\leq t(b-a) \end{aligned}$$

ពិត ។

ក្នុងត្រីកោណ$ABC$ មួយ បើ $A > B > C$ នោះ $a > b > c$ ដែល $a,b,c$ ជារង្វាស់ជ្រុងឈមនឹងមុំ $A,B,C$ ។ យើងមាន $a = 2R\sin A > b = 2R\sin B > c = 2R\sin C$

ដូច្នេះ $\sin A > \sin B > \sin C$ ។

ដែនកំណត់របស់$y$ :

$$\begin{cases} \dfrac{x-\sin A}{x-\sin C} \geq 0 \\ \dfrac{x-\sin B}{x-\sin C} \geq 0 \end{cases} \Leftrightarrow \begin{cases} \left[\begin{array}{l} x \geq \sin A \\ x < \sin C \end{array}\right. \\ \left[\begin{array}{l} x \geq \sin B \\ x < \sin C \end{array}\right. \end{cases} \Leftrightarrow \left[\begin{array}{l} x \geq \sin A \\ x < \sin C \end{array}\right.$$

ចំពោះ $x \geq \sin A$ :

ប្រើវិសមភាព(១)ចំពោះ $t = x - \sin A \geq 0$

$$\frac{x-\sin A}{x-\sin C} \geq \frac{x-\sin A-(x-\sin A)}{x-\sin C-(x-\sin A)} = 0$$

$$\frac{x-\sin B}{x-\sin C} \geq \frac{x-\sin B-(x-\sin A)}{x-\sin C-(x-\sin A)} = \frac{\sin A-\sin B}{\sin A-\sin C}$$

$$\Rightarrow \quad y \geq 0 + \sqrt{\frac{\sin A-\sin B}{\sin A-\sin C}} - 1$$

សញ្ញាស្មើកើតមានពេល $x = \sin A$ ។ ហើយ

$$\sqrt{\frac{\sin A-\sin B}{\sin A-\sin C}} - 1 \leq 1 \quad \Leftrightarrow \frac{\sin A-\sin B}{\sin A-\sin C} \leq 4$$

$$\begin{aligned} &\Leftrightarrow \; \sin A - \sin B \leq 4\sin A - 4\sin C \\ &\Leftrightarrow 0 \leq 3\sin A + \sin B - 4\sin C \\ &\Leftrightarrow 0 \leq 3\,(\sin A - \sin B) + (\sin B - \sin C) \end{aligned}$$

ពិត ។

ចំពោះ $x < \sin C$: យើងមាន

$$y > \sqrt{1} + \sqrt{1} - 1 = 1$$

ដូច្នេះ $\min y = \sqrt{\frac{\sin A - \sin B}{\sin A - \sin C}} - 1$ ពេល $x = \sin A$ ។

**886.▲** យើងមាន

$$\cos x + \cos\left(x + \frac{2\pi}{3}\right) + \cos\left(x + \frac{4\pi}{3}\right) = 0; \quad \forall x \in \mathbb{R}$$
$$\Longrightarrow \quad \cos 2x + \cos 2\left(x + \frac{2\pi}{3}\right) + \cos 2\left(x + \frac{4\pi}{3}\right) =$$
$$= \cos 2x + \cos\left(2x + \frac{4\pi}{3}\right) + \cos\left(2x + \frac{2\pi}{3}\right) = 0; \quad \forall x \in \mathbb{R}$$

ម្យ៉ាងវិញទៀតយើងមាន

$$f(x) = \frac{2000}{2001}\cos 2x + \frac{2003}{2000}\cos(x - \phi) + 1$$
$$f\left(x + \frac{2\pi}{3}\right) = \frac{2000}{2001}\cos\left(2x + \frac{4\pi}{3}\right) + \frac{2003}{2000}\cos\left(x - \phi + \frac{2\pi}{3}\right) + 1$$
$$f\left(x + \frac{4\pi}{3}\right) = \frac{2000}{2001}\cos\left(2x + \frac{2\pi}{3}\right) + \frac{2003}{2000}\cos\left(x - \phi + \frac{4\pi}{3}\right) + 1$$
$$\Longrightarrow \quad f(x) + f\left(x + \frac{2\pi}{3}\right) + f\left(x + \frac{4\pi}{3}\right) = 3$$

ដោយ $f\left(x + \frac{2\pi}{3}\right) \geq 0;\ f\left(x + \frac{4\pi}{3}\right) \geq 0$ នោះ $f(x) \leq 3$ ។

**887.▲** ចំពោះ $a > 1$ អនុគមន៍ $y = a^x$ ជាអនុគមន៍កើន ។ ចំពោះ $0° < \theta < 45°$ យើងមាន $\cot\theta > 1 > \tan\theta > 0$ ។ ដូច្នេះ $t_3 = (\cot\theta)^{\tan\theta} < (\cot\theta)^{\cot\theta} = t_4$ ។

ចំពោះ $a < 1$ អនុគមន៍ $y = a^x$ ជាអនុគមន៍ចុះ ។ ដោយ $\cot\theta > 1 > \tan\theta > 0$ នោះ $t_1 = (\tan\theta)^{\tan\theta} > (\tan\theta)^{\cot\theta} = t_2$ ។

ដោយ $\cot\theta > 1 > \tan\theta > 0$ នោះ $t_1 = (\tan\theta)^{\tan\theta} < (\cot\theta)^{\tan\theta} = t_3$ ។

ដូច្នេះ $t_4 > t_3 > t_1 > t_2$ ។

**888.▲** តាងអនុគមន៍ $f\colon \left[0, \frac{\pi}{2}\right] \to \mathbb{R}$ ដែលកំណត់ដោយ

$$f(x) = 1 - \frac{x^2}{2} + \frac{x^4}{16} - \cos x$$

យើងមាន

$$f'(x) = -x + \frac{1}{4}x^3 + \sin x\,; f'(0) = 0$$
$$f''(x) = -1 + \frac{3}{4}x^2 + \cos x\,;\; f''(0) = 0$$
$$f'''(x) = \frac{3}{2}x - \sin x\,;\; f'''(0) = 0$$
$$f''''(x) = \frac{3}{2} - \cos x$$

ដោយ $f''''(x) > 0$ នោះ $f'''(x)$ កើន ។ ដោយ $f'''(0) = 0$ នោះ $f'''(x) > 0$ ចំពោះគ្រប់ $x > 0$ ។

ដូច្នេះ $f''(x)$ កើនចំពោះគ្រប់ $x \geq 0$ ។ ដោយ $f''(0) = 0$ នោះ $f''(x) > 0$ ចំពោះគ្រប់ $x > 0$ ។

ដូច្នេះ $f'(x)$ កើនចំពោះគ្រប់ $x \geq 0$ ។ ដោយ $f'(0) = 0$ នោះ $f'(x) > 0$ ចំពោះគ្រប់ $x > 0$ ។

ដូច្នេះ $f(x)$ កើនចំពោះគ្រប់ $x \geq 0$ ។ ដូច្នេះ ចំពោះគ្រប់ $0 < x < \pi/2$ យើងមាន

$$f(0) < f(x) \;\Leftrightarrow 0 < 1 - \frac{x^2}{2} + \frac{x^4}{16} - \cos x \;\Rightarrow \cos x < 1 - \frac{x^2}{2} + \frac{x^4}{16}$$

**889.▲** តាមទ្រឹស្តីបទស៊ីនុស

$$\frac{a}{\sin A} = \frac{b}{\sin B} = \frac{c}{\sin C}$$
$$\Rightarrow \frac{a}{\sin A} = \frac{b + c}{\sin B + \sin C}$$
$$\Rightarrow \frac{a}{b + c} = \frac{\sin A}{\sin B + \sin C} = \frac{2\sin\frac{A}{2}\cos\frac{A}{2}}{2\sin\frac{B + C}{2}\cos\frac{B - C}{2}}$$
$$= \frac{\sin\frac{A}{2}\cos\frac{A}{2}}{\sin\frac{\pi - A}{2}\cos\frac{B - C}{2}} = \frac{\sin\frac{A}{2}\cos\frac{A}{2}}{\cos\frac{A}{2}\cos\frac{B - C}{2}} = \frac{\sin\frac{A}{2}}{\cos\frac{B - C}{2}}$$

យើងមាន $0 \leq |B - C| < 180°$ ដូច្នេះ $0 < \cos\frac{B-C}{2} \leq 1$ ។ ដូច្នេះ

$$\frac{a}{b+c}=\frac{\sin\frac{A}{2}}{\cos\frac{B-C}{2}}\geq\sin\frac{A}{2}$$

**890.▲** យើងមាន

$$\left(1+\frac{a}{\sin x}\right)\left(1+\frac{b}{\cos x}\right)\geq\left(1+\sqrt{2ab}\right)^2$$
$$\Leftrightarrow 1+\frac{a}{\sin x}+\frac{b}{\cos x}+\frac{ab}{\sin x\cos x}\geq 1+2ab+2\sqrt{2ab}$$
$$\Leftrightarrow \frac{a}{\sin x}+\frac{b}{\cos x}+\frac{ab}{\sin x\cos x}\geq 2ab+2\sqrt{2ab}$$

តាមវិសមភាពកូស៊ី

$$\frac{a}{\sin x}+\frac{b}{\cos x}\geq\frac{2\sqrt{ab}}{\sqrt{\sin x\cos x}}$$

យើងមាន

$$\sin x\cos x=\frac{1}{2}\sin 2x\leq\frac{1}{2}$$

ដូច្នេះ

$$\frac{a}{\sin x}+\frac{b}{\cos x}\geq\frac{2\sqrt{ab}}{\sqrt{\sin x\cos x}}\geq\frac{2\sqrt{ab}}{\sqrt{\frac{1}{2}}}=2\sqrt{2ab}$$

និង

$$\frac{ab}{\sin x\cos x}\geq\frac{ab}{\frac{1}{2}}=2ab$$

ដូច្នេះ

$$\frac{a}{\sin x}+\frac{b}{\cos x}+\frac{ab}{\sin x\cos x}\geq 2\sqrt{2ab}+2ab$$

ពិត ។

**891.▲** (a) យើងមាន

$$\tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2}=1$$
$$\Leftrightarrow \tan\frac{C}{2}\left(\tan\frac{B}{2}+\tan\frac{A}{2}\right)=1-\tan\frac{A}{2}\tan\frac{B}{2}$$

$$\Leftrightarrow \tan\frac{C}{2}=\frac{1-\tan\frac{A}{2}\tan\frac{B}{2}}{\tan\frac{B}{2}+\tan\frac{A}{2}}=\frac{1}{\tan\frac{A+B}{2}}=\cot\frac{A+B}{2}$$
$$\Leftrightarrow \tan\frac{C}{2}=\cot\frac{\pi-C}{2}=\tan\frac{C}{2}$$

ពិត ។

(b) តាម (a) និង តាមវិសមភាពកូស៊ី យើងមាន

$$\begin{aligned}1&=\tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2}\\&\geq 3\sqrt[3]{\left(\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}\right)^2}\\&\Longrightarrow \tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}\leq\frac{1}{\sqrt{27}}=\frac{\sqrt{3}}{9}\end{aligned}$$

ពិត ។

**892.▲** ដោយមុំទាំងអស់របស់ត្រីកោណសុទ្ធតែជាមុំស្រួច ដូច្នេះ $0<A,B,C<90^\circ$ ដូច្នេះ $\tan A,\tan B,\tan C$ សុទ្ធតែជាចំនួនកំណត់ និងមានតម្លៃវិជ្ជមាន ។

(a) យើងមាន

$$\begin{aligned}&\tan A+\tan B+\tan C=\tan A\tan B\tan C\\&\Leftrightarrow \tan A+\tan B=(\tan A\tan B-1)\tan C\\&\Leftrightarrow \frac{\tan A+\tan B}{\tan A\tan B-1}=\tan C\\&\Leftrightarrow -\tan(A+B)=\tan C\\&\Leftrightarrow -\tan(\pi-C)=\tan C\\&\Leftrightarrow \tan C=\tan C\end{aligned}$$

ពិត ។

(b) តាមសមភាព (a) និង វិសមភាពកូស៊ី

$$\begin{aligned}&\tan A\tan B\tan C=\tan A+\tan B+\tan C\\&\geq 3\sqrt[3]{\tan A\tan B\tan C}\\&\Longrightarrow (\tan A\tan B\tan C)^3\geq 27\tan A\tan B\tan C\\&\Longrightarrow \tan A\tan B\tan C\geq 3\sqrt{3}\end{aligned}$$

**893.▲** យើងមាន $(x-y)^2\geq 0$ ពិតចំពោះគ្រប់ចំនួនពិត $x,y$ ។ ដូច្នេះ

$$xy\leq\frac{x^2+y^2}{2}$$

ចំពោះគ្រប់ចំនួនពិត $x,y$ ។ ដូច្នេះ

$$\sin\alpha_1\cos\alpha_2 \le \frac{\sin^2\alpha_1+\cos^2\alpha_2}{2}$$
$$\sin\alpha_2\cos\alpha_3 \le \frac{\sin^2\alpha_2+\cos^2\alpha_3}{2}$$
$$\dots$$
$$\sin\alpha_{2007}\cos\alpha_{2008} \le \frac{\sin^2\alpha_{2007}+\cos^2\alpha_{2008}}{2}$$
$$\sin\alpha_{2008}\cos\alpha_1 \le \frac{\sin^2\alpha_{2008}+\cos^2\alpha_1}{2}$$

ដូច្នេះ

$$\sin\alpha_1\cos\alpha_2+\sin\alpha_2\cos\alpha_3+\cdots+\sin\alpha_{2007}\cos\alpha_{2008}+\sin\alpha_{2008}\cos\alpha_1$$
$$\le \frac{\sin^2\alpha_1+\cos^2\alpha_1}{2}+\frac{\sin^2\alpha_2+\cos^2\alpha_2}{2}+\cdots$$
$$+\frac{\sin^2\alpha_{2008}+\cos^2\alpha_{2008}}{2}=1004$$

អង្គទាំងពីរស្មើគ្នា ពេល

$$\sin\alpha_1=\cos\alpha_2\,;\sin\alpha_2=\cos\alpha_3\,;\dots;\ \sin\alpha_{2008}=\cos\alpha_1$$

លក្ខខណ្ឌនេះ អាចផ្ទៀងផ្ទាត់ ឧទាហរណ៍ នៅត្រង់ $\alpha_1=\alpha_2=\cdots=\alpha_{2008}=\pi/4$ ។ ដោយសារសំនួរ សួររកតែតម្លៃធំបំផុត ដោយមិនសួររកតម្លៃ $\alpha_i$ ដូច្នេះ យើងមិនចាំបាច់រកលក្ខខណ្ឌលើ $\alpha_i$ ផ្សេងពីនេះទៀតទេ ។ដូច្នេះតម្លៃធំបំផុត គឺ 1004 ។

**894.▲** យើងមាន

$$\cos^2 x\cot x+\sin^2 x\tan x\ge 1$$
$$\Leftrightarrow \cos^2 x\,\frac{\cos x}{\sin x}+\sin^2 x\frac{\sin x}{\cos x}\ge 1$$
$$\Leftrightarrow \cos^4 x+\sin^4 x\ge \sin x\cos x$$
$$\Leftrightarrow 1-2\sin^2 x\cos^2 x\ge \sin x\cos x$$
$$\Leftrightarrow\ -2\sin^2 x\cos^2 x-\sin x\cos x+1\ge 0$$
$$\Leftrightarrow -\frac{1}{2}\sin^2 2x-\frac{1}{2}\sin 2x+1\ge 0$$
$$\Leftrightarrow \sin^2 2x+\sin 2x-2\le 0$$

ពិត ព្រោះ $\sin 2x \le 1, \sin^2 2x \le 1$ ។ សមភាពកើតមាន ពេល $\sin 2x = 1 \Rightarrow 2x = \pi/2 + 2k\pi \Rightarrow x = \pi/4 + k\pi$ ។ ដោយ $0 < x < \pi/2$ ដូច្នេះ យកតែ $x = \pi/4$ ។

# ៤.៦ វិសមីការ

**895.** $\left(\frac{\pi}{3} + 2\pi n; \frac{2\pi}{3} + 2\pi n\right); n \in \mathbb{Z}$ ;
**896.** $[2\pi n - 2\pi/3\,; 2\pi n + 2\pi/3]; n \in \mathbb{Z}$;
**897.** $(\pi n - \arctan 2\,; \pi n + \pi/3); n \in \mathbb{Z}$;
**898.** $(\pi n; \pi n + \pi/2] \cup [\pi n + 3\pi/4\,; \pi(n+1)); n \in \mathbb{Z}$
**899.** $(-\pi/4 + 2\pi n; \pi/6 + 2\pi n) \cup (5\pi/6 + 2\pi n; 5\pi/4 + 2\pi n); n \in \mathbb{Z}$
**900.** $\left(2n - \frac{1}{8}; 2n + 7/8\right); n \in \mathbb{Z}$
**901.** $\left(\frac{\pi n}{2} + \frac{5\pi}{24}; \frac{\pi(n+1)}{2} + \frac{\pi}{24}\right); n \in \mathbb{Z}$ ● $\cos^3 x \sin 3x + \cos 3x \sin^3 x = \frac{3}{4}\sin 4x$
**902.** $\left\{\frac{\pi}{2} + \pi n\right\} \cup \left[\pi n - \frac{\pi}{4}; \pi n - \pi/6\right] \cup \left[\pi n + \frac{\pi}{6}; \pi n + \pi/4\right]; n \in \mathbb{Z}$ ●
$\cos x \cos 2x \cos 3x = \cos 2x \frac{\cos 2x + \cos 4x}{2} = \frac{\cos 2x(2\cos^2 2x + \cos 2x - 1)}{2}$
**903.** $\{\mathbb{R}\} \setminus \left\{\frac{3\pi}{4} + \frac{3\pi n}{2}\right\}; n \in \mathbb{Z}$
**904.** $\left(-\frac{\pi}{8} + \frac{\pi n}{2}; \frac{\pi}{8} + \frac{\pi n}{2}\right); n \in \mathbb{Z}$ ● $\sin^6 x + \cos^6 x = \left(\frac{1 - \cos 2x}{2}\right)^2 + \left(\frac{1 + \cos 2x}{2}\right)^2 = \frac{5}{8} + \frac{3}{8}\cos 4x$
**905.** $\left(\pi n + \frac{1}{2}\arccos\frac{1}{3}; \pi(n+1) - \frac{1}{2}\arccos\frac{1}{3}\right); n \in \mathbb{Z}$ ● $8\sin^6 x - \cos^6 x = (2\sin^2 x - \cos^2 x)(4\sin^4 x + 2\sin^2 x \,.\cos^2 x + \cos^4 x)$ បន្ទាប់មកទៀត

$$4\sin^4 x + 2\sin^2 x \,.\cos^2 x + \cos^4 x > 0, \qquad \forall x \in \mathbb{R}$$

**906.** $\left(\pi n - \frac{\pi}{4}; \pi n - \frac{\pi}{6}\right) \cup \left(\pi n + \frac{\pi}{6}; \pi n + \frac{\pi}{4}\right); n \in \mathbb{Z}$
**907.** $\left(2\pi n - \frac{\pi}{4} + \arcsin\frac{2\sqrt{2}}{3}; 2\pi n + \frac{3\pi}{4} - \arcsin\frac{2\sqrt{2}}{3}\right) \cup \left(\pi(2n+1); 2\pi n + \frac{3\pi}{2}\right); n \in \mathbb{Z}$ ● តាង $\sin x + \cos x = y$
**908.** $\left(\arctan(\sqrt{2} - 1); \frac{\pi}{4}\right) \cup \left(\pi + \arctan(\sqrt{2} - 1)\,; \frac{5\pi}{4}\right)$
**909.** $\left(\pi n + \arcsin\frac{\sqrt{5}-1}{2}; \pi(n+1) - \arcsin\frac{\sqrt{5}-1}{2}\right); n \in \mathbb{Z}$
**910.** $[2\pi n - 7\pi/6\,; 2\pi n + \pi/6]; n \in \mathbb{Z}$
**911.** $(\pi/4 + \pi n; \pi/2 + \pi n); n \in \mathbb{Z}$
**912.** $[n + 1/4\,; n + 3/4]; n \in \mathbb{Z}$

**913.** ▲ ជាបឋម យើងនឹងកំណត់ $x \in (0, 2\pi]$ ដែលផ្ទៀងផ្ទាត់វិសមភាពពិតគ្រប់ $n$ ។
❶ សន្មតថា $0 < x < 2\pi/3$ ។ បើ $n$ ជាចំនួនគត់ធំបំផុត ដែល $nx \le {}^{2\pi}/_{3}$ ឬ $n = \left\lfloor \frac{2\pi}{3x} \right\rfloor$ នោះ $\frac{2\pi}{3} - x < nx \le 2\pi/3$ ។ បើ $x > \pi/3$ នោះ $nx > \pi/3$ ។ បើ $x < \pi/3$ នោះ $2\pi/3 - x > \pi/3 \implies nx > \pi/3$ ។ បើ $x = \pi/3$ នោះ $nx > 2\pi/3 - x = \pi/3$ ។ ដូច្នេះ យើងទាញបាន $\pi/3 < nx \le 2\pi/3$ ។ ដូច្នេះ $\sin nx \ge \sqrt{3}/2$ ។ នាំឱ្យ $\sin x + \sin 2x + \cdots + \sin nx > \sqrt{3}/2$ ។
❷ សន្មតថា $\frac{2\pi}{3} \le x \le 2\pi$ ។ យើងមាន

$$\begin{aligned}
&\sin x \sin\frac{x}{2} = \frac{1}{2}\left[\cos\frac{x}{2} - \cos\frac{3x}{2}\right]\\
&\sin 2x \sin\frac{x}{2} = \frac{1}{2}\left[\cos\frac{3x}{2} - \cos\frac{5x}{2}\right]\\
&\vdots\\
&\sin nx \sin\frac{x}{2} = \frac{1}{2}\left[\cos\frac{2n-1}{2}x - \cos\frac{2n+1}{2}x\right]
\end{aligned}$$

$$\implies \sin x + \sin 2x + \cdots + \sin nx = \frac{\cos\frac{x}{2} - \cos\frac{2n+1}{2}x}{2\sin\frac{x}{2}}$$

ដោយ $2\pi/3 \le x \le 2\pi \implies \pi/3 \le x/2 \le \pi \implies \cos\frac{2n+1}{2}x \ge -1$ និង $\cot\frac{x}{4} \le \sqrt{3}$ ។ ដូច្នេះ

$$\sin x + \sin 2x + \cdots + \sin nx = \frac{\cos\frac{x}{2} - \cos\frac{2n+1}{2}x}{2\sin\frac{x}{2}} \le \frac{\cos\frac{x}{2} + 1}{2\sin\frac{x}{2}} = \frac{\cot\frac{x}{4}}{2} \le \frac{\sqrt{3}}{2}$$

ដូច្នេះវិសមភាពពិតចំពោះគ្រប់ $n$ នោះ $2\pi/3 + 2k\pi \le x \le 2\pi + 2k\pi$ ចំពោះចំនួនគត់ $k$ និងច្រាសមកវិញ ។

**914.** ▲ ១) បើ $x = 0$ នោះវិសមីការផ្ទៀងផ្ទាត់ចំពោះគ្រប់ $y$ ។ បើ $x > 0$ នោះ $\cos y + \sin y \ge -\frac{1+x^2}{2x}$ ។ អនុគមន៍ $f(y) = \cos y + \sin y$ មានតម្លៃធំបំផុតស្មើ $\sqrt{2}$ និងតម្លៃតូចបំផុតស្មើ $-\sqrt{2}$ ។ ដូច្នេះ

$$\begin{aligned}
&-\sqrt{2} \ge -\frac{1+x^2}{2x} \iff x^2 - 2\sqrt{2}x + 1 \ge 0\\
&\implies 0 < x \le \sqrt{2} - 1; x \ge \sqrt{2} + 1
\end{aligned}$$

បើ $x<0 \;\Rightarrow \cos y+\sin y\le -\frac{1+x^2}{2x} \;\Rightarrow \sqrt{2}\le -\frac{1+x^2}{2x} \;\Rightarrow x\le -\sqrt{2}-1;\ -\sqrt{2}+1\le x<0$

ដូច្នេះជាសរុបគឺ $|x|\ge \sqrt{2}+1; |x|\le \sqrt{2}-1$ ។

២) យើងមាន $\Delta' = (\cos y+\sin y)^2-1=\sin 2y$ ។

ក) បើ $\sin 2y\le 0$ នោះ $f(x)\ge 0;\forall x\in\mathbb{R}$ ។ យើងទាញបាន $\frac{\pi}{2}+k\pi\le y\le (k+1)\pi;\quad (k\in\mathbb{Z})$ ។

ខ) បើ $\sin 2y>0$ នោះ $f(x)$ មានឫសពីរ តាងដោយ $x_1;x_2$ ដែល $x_1+x_2=-2(\cos y+\sin y); x_1x_2=1$ ។ យើងមាន $f(x)<0$ ចំពោះ $x$ ស្ថិតនៅចន្លោះ $x_1$ និង $x_2$ ដូច្នេះ ដើម្បីឱ្យ $f(x)\ge 0;\forall x\ge 0$ នោះ $x_1\le 0; x_2\le 0 \;\Rightarrow\; -2(\cos y+\sin y)\le 0 \;\Rightarrow \cos y+\sin y\ge 0 \Rightarrow 2k\pi<y<\frac{\pi}{2}+2k\pi$ ។

ផ្សំចូលគ្នារវាងក) និងខ) យើងទាញបាន

$$-\frac{\pi}{2}+2n\pi\le y\le (2n+1)\pi;\quad (n\in\mathbb{Z})$$

**915.▲** តាង $S=\left|\sqrt{1+\sin 2x}-\sqrt{1-\sin 2x}\right|$ ។ យើងមាន $S^2=2-2\sqrt{1-\sin^2 2x}=2-2|\cos 2x|\le 2$ ។ យើងទាញបាន $S\le\sqrt{2}$ ។ ដូច្នេះវិសមីការខាងស្តាំពិតចំពោះគ្រប់ $x$ ។

បើ $\pi/2\le x\le 3\pi/2$ នោះ $\cos x\le 0$ ដូច្នេះវិសមភាពខាងឆ្វេងពិត ។ សន្មតថា $\cos x>0$ នោះវិសមភាពខាងឆ្វេងសមមូលនឹង

$$2+2\cos 2x=4\cos^2 x\le S^2=2-2|\cos 2x| \;\Leftrightarrow\; \cos 2x\le 0$$
$$\Rightarrow x\in\left[\frac{\pi}{4},\frac{\pi}{2}\right]\cup\left[\frac{3\pi}{2},\frac{7\pi}{4}\right]$$

ដូច្នេះសំណុំចម្លើយកំណត់ដោយ $\pi/4\le x\le 7\pi/4$ ។

# ៤.៧ ប្រព័ន្ធវិសមីការ

**916.** ▲ ដោយ $0 \leq x \leq \pi/4$ នោះ $\cos x \neq 0$ ។ ចែកសមីការទីមួយនឹង $\cos^3 x$ និង

តាង $\tan x = t$ យើងទាញបាន

$$(4-6m)t^3 + 3(2m-1)t(t^2+1) + 2(m-2)t^2 - (4m-3)(t^2+1) = 0$$
$$(4-6m)t^3 + (6m-3)t^3 + (6m-3)t + (2m-4)t^2 - (4m-3)t^2 - 4m + 3 = 0$$
$$t^3 - (1+2m)t^2 + 3(2m-1)t - 4m + 3 = 0$$
$$(t-1)(t^2 - 2mt + 4m - 3) = 0$$

យើងទាញបាន $t = 1$ ដែលត្រូវនឹង $x = \frac{\pi}{4}$ ជាឫសមួយនៃប្រព័ន្ធ ។ ដូច្នេះប្រព័ន្ធមានឫស

តែមួយគត់បើ លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ

១) សមីការ $t^2 - 2mt + 4m - 3 = 0$ មាន $\Delta = m^2 - 4m + 3 < 0 \Rightarrow 1 < m < 3$

២) សមីការ $t^2 - 2mt + 4m - 3 = 0$ មានឫសមួយគត់ស្មើ 1 ។ ដូច្នេះ

$1 - 2m + 4m - 3 = 0; m = 1$ ។ បើ $m = 1$ នោះ $\Delta = 0$ សមីការមានឫសមួយ

គត់ ។

៣) សមីការ $t^2 - 2mt + 4m - 3 = 0$ មានឫស $t_1 \leq t_2 < 0$ ដូច្នេះ

$$\Delta > 0; t_1 t_2 = 4m - 3 > 0; S = t_1 + t_2 = 2m < 0$$

វិសមីការនេះគ្មានឫស ។

ដូច្នេះដើម្បីឱ្យប្រព័ន្ធមានឫសមួយគត់ $1 \leq m < 3$ ។

# ៤.៨ អាំងតេក្រាល

**917.** ▲ យើងមាន

$$\sin x - \cos x + 1 = (A - 2B)\sin x + (2A + B)\cos x + 3A + C$$
$$\Rightarrow \begin{cases} A - 2B = 1 \\ 2A + B = -1 \\ 3A + C = 1 \end{cases}$$
$$A = -\frac{1}{5}; B = -\frac{3}{5}; C = \frac{8}{5}$$

យើងទាញបាន

$$\frac{\sin x-\cos x+1}{\sin x+2\cos x+3}=A+B\frac{(\sin x+2\cos x+3)'}{\sin x+2\cos x+3}+C\frac{1}{\sin x+2\cos x+3}$$

$$\int_0^{\frac{\pi}{2}}\frac{\sin x-\cos x+1}{\sin x+2\cos x+3}dx$$

$$=\left(-\frac{x}{5}-\frac{3}{5}\ln|\sin x+2\cos x+3|+\frac{8}{5}\arctan\frac{1+\tan\frac{x}{2}}{2}\right)\Bigg|_0^{\frac{\pi}{2}}$$

$$=\frac{3\pi}{10}+\frac{3}{5}\ln\frac{5}{4}-\frac{8}{5}\arctan\frac{1}{2}$$

# ៥

# ពហុធា

**918.** ▲ លក្ខខណ្ឌដែលឱ្យសមមូលនឹង

$$P(xy) = P(x).P(y);\ \forall x, y \in \mathbb{R} \qquad (1)$$

ក្នុង (1) យើងយក $x = y = 0$ យើងទាញបាន

$$P(0) = P^2(0)$$

ដូច្នេះ $P(0) = 1$ ឬ $P(0) = 0$ ។

១) បើ $P(0) = 1$ នោះ ក្នុង(1) យក $y = 0$ យើងទាញបាន $P(0) = P(x).P(0)$ នោះ

$$P(x) = 1;\ \forall x \in \mathbb{R}$$

២) បើ $P(0) = 0$ នោះ $P(x) = xQ(x)$ ដែល $Q(x)$ ជាពហុធាមានដឺក្រេទាបជាង $P(x)$ មួយឯកតា ។ លក្ខខណ្ឌ(1) ទៅជា

$$xyQ(xy) = xyQ(x).Q(y), \forall x, y \in \mathbb{R}$$

នោះ $Q(xy) = Q(x).Q(y);\ \forall x, y \in \mathbb{R}$ ។ ដូច្នេះយើងទាញបាន $Q(x) = 1$ ឬ $Q(x) = x\,Q_1(x)$ ដែល $Q_1(x)$ ជាពហុធាមានដឺក្រេទាបជាង $Q(x)$ មួយឯកតា ។ ដូច្នេះ ជាសរុបយើងទាញបាន

$$P(x) = 1;\ \forall x \in \mathbb{R}$$
$$P(x) = x^n;\ \ \forall x \in \mathbb{R}$$

ដែល $n$ ជាចំនួនគត់វិជ្ជមាន ។

**919.** ▲ ដោយដឹងថា $2x + 1 = (x + 1)^2 - x^2$ នោះលក្ខខណ្ឌដែលឱ្យសមមូលនឹង

$$P(x + 1) - (x + 1)^2 = P(x) - x^2$$

តាង $Q(x) = P(x) - x^2$ ។ ដូច្នេះ $Q(x) = Q(x + 1) = \cdots = Q(x + n) = \cdots$ ។

ដូច្នេះ $Q(0) = Q(1) = \cdots = Q(n) = \cdots$ ។ យើងទាញបាន $Q(x) - Q(0) \equiv 0$

ចំពោះ $x = 0, x = 1, \ldots, x = n, \ldots$ ។ ដូច្នេះ $Q(x) - Q(0) \equiv 0, \forall x \in \mathbb{R}$ ។ យើងទាញបាន

$$P(x) = x^2 + C$$

ដែល $C = Q(0) = P(0)$ ។ ជំនួសទំនាក់ទំនងដែលបានចូលលក្ខខណ្ឌដើម យើងទាញបាន

$$(x+1)^2 + C = x^2 + 2x + 1 + C$$

ពិតចំពោះគ្រប់ $C$ ។ ដូច្នេះ

$$P(x) = x^2 + C$$

ដែល $C$ ជាចំនួនថេរណាមួយ ។

**920.** ▲ យើងមាន

$$P((x+1)^2) - (x+1)^2 = P(x^2) - x^2$$

តាង $Q(t) = P(t) - t$ ។ យើងទាញបាន $Q(0) = Q(1) = \cdots = Q(n^2) = \cdots$ ។ ដូច្នេះ $Q(x) = Q(0)$ ។ យើងទាញបាន $P(x) = x + C$ ដែល $C = Q(0) = P(0)$ ។ ជំនួសចូលលក្ខខណ្ឌដើម យើងទាញបាន $P(x) = x + C$ ដែល$C$ ជាចំនួនថេរណាមួយ ។

**921.** ▲ ពហុធា $f(x) - 5$ មានឫសជាចំនួនគត់ $a, b, c, d$ ។ ដូច្នេះ

$$f(x) - 5 = (x-a)(x-b)(x-c)(x-d)g(x)$$

ដែល $g(x) = x^m + b_1 x^{m-1} + \cdots + b_m$ និង $b_1, b_2, \ldots, b_m$ ជាចំនួនគត់ ។ សមីការ $f(x) = 8$ សមមូលនឹង

$$(x-a)(x-b)(x-c)(x-d)g(x) = 3$$

ដូច្នេះបីក្នុងចំណោមចំនួនគត់បួន $x-a, x-b, x-c, x-d$ ស្មើ $1$ ឬ $-1$ ។ ដូច្នេះត្រូវមានពីរដែលស្មើគ្នា ដែលករណីនេះមិនអាច ព្រោះចំនួនទាំងបួនខុស ។

**922.** ▲ តាង $P(X) = a_0 + a_1 X + a_2 X^2 + \cdots + a_n X^n$ ដោយ $a_i \geq 0$ ចំពោះ $i < n$ និង $a_n > 0$ ។ យើងមាន $x_1, x_2, \ldots, x_n > 0$ ។

តាង $x_{n+1} = x_1$ ។

បើ $n = 1$ យើងទាញបាន $[P(1)]^2 = 1.[P(1)]^2$ ពិត ។

បើ $n \geq 2$ យើងមាន

$$P^2(X) = \sum_{i=0}^{n} a_i^2 X^{2i} + 2\sum_{i<j} a_i a_j X^{i+j}$$

ចំពោះ $p \in \mathbb{N}^*$ តាង

$$S_p = \frac{1}{n}\sum_{k=1}^{n}\left(\frac{x_{k+1}}{x_k}\right)^p$$

តាមវិសមភាពកូស៊ី

$$S_p \geq \left[\prod_{k=1}^{n}\left(\frac{x_{k+1}}{x_k}\right)^p\right]^{\frac{1}{n}} = 1$$

តែថា

$$\frac{1}{n}\sum_{k=1}^{n} P^2\left(\frac{x_{k+1}}{x_k}\right) = \sum_{i=0}^{n} a_i^2 S_{2i} + 2\sum_{i<j} a_i a_j S_{i+j} \geq \sum_{i=0}^{n} a_i^2 + 2\sum_{i<j} a_i a_j = P^2(1)$$

$$\Rightarrow \sum_{k=1}^{n} P^2\left(\frac{x_{k+1}}{x_k}\right) \geq nP^2(1)$$

ស្មើគ្នា លុះត្រាតែ $x_1 = x_2 = \cdots = x_n$ ។

**923.** ▲ យើងមាន

$$\begin{aligned} P(x) &= (1 + x + x^2 + \cdots + x^{2010})^2 - (x^{1005})^2 \\ &= (1 + x + x^2 + \cdots + x^{2010} - x^{1005})(1 + x + x^2 + \cdots + x^{2010} + x^{1005}) \\ &= (1 + x + x^2 + \cdots + x^{1004} + x^{1006} + \cdots + x^{2010})(1 + x + x^2 + \cdots \\ &\qquad + 2x^{1005} + \cdots + x^{2010}) \\ &= Q(x)R(x) \end{aligned}$$

**924.** ▲ តាង

$$(1 - 3x + 3x^2)^{743}(1 + 3x - 3x^2)^{744} = A_0 + A_1 x + A_2 x^2 + \cdots + A_n x^n \quad (1)$$

យើងចង់គណនា $A_0 + A_1 + A_2 + \cdots + A_n$ (ដឺក្រេ $n$ របស់ពហុធានេះស្មើនឹង $743.2 + 744.2 = 2974$ ) ។ ក្នុងទំនាក់ទំនង (1) យើងយក $x = 1$ យើងទាញបាន

$$1^{743}.1^{744} = A_0 + A_1 + A_2 + \cdots + A_n$$

ដូច្នេះផលបូកដែលចង់បានស្មើ 1 ។

**925.** ▲ សន្មតថាយើងពន្លាតកន្សោមពីរនេះរួចហើយ ហើយទទួលបានពហុធានៃ $x$ ពីរ ។ បើយើងប្តូររបស់ $x$ ទៅជា $-x$ នៅក្នុងពហុធាទាំងពីរ នោះមេគុណរបស់តួដែលស្វ័យគុណរបស់ $x$ ជាចំនួនសេស ដូរសញ្ញា និង តួដែលមានស្វ័យគុណគូ នៅរក្សាសញ្ញាដដែល ។ តួ $x^{20}$ មានស្វ័យគុណគូ ដូច្នេះវានៅរក្សាសញ្ញាដដែល ។ ដូច្នេះសញ្ញានិងតម្លៃរបស់មេគុណរបស់ $x^{20}$ ក្រោយពន្លាត $(1+x^2-x^3)^{1000}$ ដូចគ្នានឹងពន្លាតរបស់កន្សោម $(1+x^2+x^3)^{1000}$ ដែរ ; សញ្ញានិងតម្លៃរបស់មេគុណរបស់ $x^{20}$ ក្រោយពន្លាត $(1-x^2+x^3)^{1000}$ ដូចគ្នានឹងពន្លាតរបស់កន្សោម $(1-x^2-x^3)^{1000}$ ដែរ ។ កន្សោម $(1+x^2+x^3)^{1000}$ មានមេគុណទាំងអស់វិជ្ជមាន ដូច្នេះមេគុណរបស់ $x^{20}$ ក្រោយពន្លាតរួចក៏វិជ្ជមានដែរ ។ កន្សោម $(1-x^2-x^3)^{1000}$ មានមេគុណខ្លះវិជ្ជមាន ខ្លះអវិជ្ជមាន ដូច្នេះមេគុណរបស់ $x^{20}$ ក្រោយពន្លាតរួច ត្រូវមានតម្លៃតូចដោយវាត្រូវស៊ីសងគ្នារវាងមេគុណវិជ្ជមាននិង អវិជ្ជមាន ។ ដូច្នេះ មេគុណរបស់ $x^{20}$ របស់ $(1+x^2-x^3)^{1000}$ ធំជាងរបស់ $(1-x^2+x^3)^{1000}$ ។

**926.** ▲ យើងមាន

$$\begin{aligned}
&(1-x+x^2-x^3+\cdots-x^{99}+x^{100})(1+x+x^2+x^3+\cdots+x^{99}+x^{100})\\
&\qquad=[(1+x^2+x^4+\cdots+x^{100})-x(1+x^2+x^4+\cdots+x^{98})]\\
&\qquad\times[(1+x^2+x^4+\cdots+x^{100})+x(1+x^2+x^4+\cdots+x^{98})]\\
&\qquad=(1+x^2+x^4+\cdots+x^{100})^2-x^2(1+x^2+x^4+\cdots+x^{98})^2
\end{aligned}$$

**927.** ▲ a) តាមរូបមន្តផលបូកស៊ីតធរណីមាត្រ យើងទាញបាន

$$\begin{aligned}
&(1+x)^{1000}+x(1+x)^{999}+x^2(1+x)^{998}+\cdots+x^{1000}\\
&=\frac{\frac{x^{1001}}{1+x}-(1+x)^{1000}}{\frac{x}{1+x}-1}=\frac{x^{1001}-(1+x)^{1001}}{x-1-x}=(1+x)^{1001}-x^{1001}\\
&\qquad=1+1001x+\binom{1001}{2}x^2+\binom{1001}{3}x^3+\cdots+1001x^{1000}
\end{aligned}$$

ដូច្នេះមេគុណរបស់ $x^{50}$ ស្មើនឹង

$$\binom{1001}{50}=\frac{1001!}{50!\,951!}$$

b) តាង $P(x) = (1+x) + 2(1+x)^2 + 3(1+x)^3 + \cdots + 1000(1+x)^{1000}$ ។

យើងមាន

$$\begin{aligned}(1+x)P(x) - P(x) &= [(1+x)^2 + 2(1+x)^3 + \cdots + 999(1+x)^{1000} \\ &+ 1000(1+x)^{1001}] \\ &- [(1+x) + 2(1+x)^2 + 3(1+x)^3 + \cdots + 1000(1+x)^{1000}] \\ &= 1000(1+x)^{1001} \\ &- [(1+x) + (1+x)^2 + (1+x)^3 + \cdots + (1+x)^{1000}] \\ &= 1000(1+x)^{1001} - \frac{(1+x)^{1001} - (1+x)}{1+x-1} \\ &= 1000(1+x)^{1001} - \frac{(1+x)^{1001} - (1+x)}{x}\end{aligned}$$

$$\begin{aligned}\Rightarrow P(x) &= \frac{1000(1+x)^{1001}}{x} - \frac{(1+x)^{1001} - (1+x)}{x^2} \\ &= 1000\left(1001 + \binom{1001}{2}x + \binom{1001}{3}x^2 + \cdots + 1001x^{999} \right. \\ &\left. + x^{1000}\right) \\ &- \left(\binom{1001}{2} + \binom{1001}{3}x + \binom{1001}{4}x^2 + \cdots + 1001x^{998} \right. \\ &\left. + x^{999}\right)\end{aligned}$$

ដូច្នេះមេគុណរបស់ $x^{50}$ ស្មើនឹង

$$\begin{aligned}1000\binom{1001}{51} - \binom{1001}{52} &= \frac{1000.1001!}{51!\,950!} - \frac{1001!}{52!\,950!} \\ &= \frac{1001!}{52!\,950!}[52.1000 - 950] = \frac{51050.1001!}{52!\,950!}\end{aligned}$$

**928.** ▲ តាង

$$\begin{aligned}P_n(x) &= \underbrace{(\ldots(((x-2)^2-2)^2-2)^2 - \cdots - 2)^2}_{n \text{ ដង}} \\ &= Q_n(x)x^3 + B_n x^2 + A_n x + C_n\end{aligned}$$

ដែល $Q_n(x)$ ជាពហុធានៃ $x$ ។ យក $x = 0$ យើងទាញបាន

$$C_n = \underbrace{(\dots(((0-2)^2-2)^2-2)^2-\dots-2)^2}_{n \text{ ដង}} = \underbrace{(\dots((4-2)^2-2)^2-\dots-2)^2}_{n \text{ ដង}}$$
$$= \underbrace{(\dots(4-2)^2-\dots-2)^2}_{(n-1) \text{ ដង}} = \dots = ((4-2)^2-2)^2 = (4-2)^2$$
$$= 4$$

ដូច្នេះ

$$\underbrace{(\dots(((x-2)^2-2)^2-2)^2-\dots-2)^2}_{n \text{ ដង}} = Q_n(x)x^3 + B_nx^2 + A_nx + 4$$

យើងមាន

$$\underbrace{(\dots(((x-2)^2-2)^2-2)^2-\dots-2)^2}_{n \text{ ដង}}$$
$$= \left[\underbrace{(\dots((x-2)^2-2)^2-\dots-2)^2}_{n-1 \text{ ដង}} - 2\right]^2$$
$$= [(Q_{n-1}x^3 + B_{n-1}x^2 + A_{n-1}x + 4) - 2]^2$$
$$= [Q_{n-1}x^3 + B_{n-1}x^2 + A_{n-1}x + 2]^2$$
$$= Q_{n-1}^2x^6 + 2Q_{n-1}B_{n-1}x^5 + (2Q_{n-1}A_{n-1}B_{n-1}^2)x^4$$
$$+ (4Q_{n-1} + 2B_{n-1}A_{n-1})x^3 + (4B_{n-1} + A_{n-1}^2)x^2 + 4A_{n-1}x$$
$$+ 4$$
$$\Longrightarrow \; A_n = 4A_{n-1}$$
$$B_n = A_{n-1}^2 + 4B_{n-1}$$

ដោយ $P_1(x) = (x-2)^2 = x^2 - 4x + 4 \Rightarrow A_1 = -4; B_1 = 1$ ។ យើងទាញបាន

$A_2 = -4.4 = -4^2; A_3 = -4^3; \dots.$ ហើយជាទូទៅ $A_n = -4^n$ ។ យើងមាន

$$B_n = A_{n-1}^2 + 4B_{n-1} = A_{n-1}^2 + 4(A_{n-2}^2 + 4B_{n-2}) = A_{n-1}^2 + 4A_{n-2}^2 + 4^2B_{n-2}$$
$$= A_{n-1}^2 + 4A_{n-2}^2 + 4^2(A_{n-3}^2 + 4B_{n-3})$$
$$= A_{n-1}^2 + 4A_{n-2}^2 + 4^2A_{n-3}^2 + 4^3B_{n-3} = \cdots$$
$$= A_{n-1}^2 + 4A_{n-2}^2 + 4^2A_{n-3}^2 + \cdots + 4^{n-3}A_2^2 + 4^{n-2}A_1^2$$
$$+ 4^{n-1}B_1$$
$$= 4^{2n-2} + 4.4^{2n-4} + 4^2.4^{2n-6} + \cdots + 4^{k-2}.4^2 + 4^{n-1}.1$$
$$= 4^{2n-2} + 4^{2n-3} + 4^{2n-4} + \cdots + 4^{n+1} + 4^{n-1}$$
$$= \frac{4^{2n-1} - 4^{n-1}}{3}$$

**929.** ▲ a) របៀបទី ១ ៖ យើងដឹងថា $x^k - 1$ ចែកដាច់នឹង $x-1$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $k$ ។ យើងមាន

$$x + x^3 + x^9 + x^{27} + x^{81} + x^{243}$$
$$= (x-1) + (x^3-1) + (x^9-1) + (x^{27}-1) + (x^{81}-1)$$
$$+ (x^{243}-1) + 6$$

ដូច្នេះពេលចែកពហុធានេះនឹង $(x-1)$ គេសល់សំណល់ស្មើ 6 ។

របៀបទី ២ ៖ តាង $q(x)$ ជាផលចែក និង $r$ ជាសំណល់ ។ យើងទាញបាន

$$x+x^3+x^9+x^{27}+x^{81}+x^{243}=(x-1)q(x)+r$$

យក $x=1$ យើងទាញបាន $r=6$ ។

b) តាង $q(x)$ ជាផលចែក និង $r_1x+r_2$ ជាសំណល់ ។ យើងទាញបាន

$$x+x^3+x^9+x^{27}+x^{81}+x^{243}=q(x)(x^2-1)+r_1x+r_2$$

យក $x=1 \Rightarrow r_1+r_2=6$

យក $x=-1 \Rightarrow -r_1+r_2=-6$

ដូច្នេះ $r_1=6$ និង $r_2=0$ ។ សំណល់ស្មើ $6x$ ។

**930.** ▲ តាង $P(x)$ ជាពហុធាក្នុងសម្មតិកម្ម ។ តាង $q(x)$ ជាផលចែក និង $r(x)=ax+b$ ជាសំណល់ចែករវាងពហុធានេះនឹង $(x-1)(x-2)$ ។ យើងមាន

$$P(x)=(x-1)(x-2)q(x)+ax+b \quad (*)$$

តាមសម្មតិកម្ម យើងមាន

$$P(x)=(x-1)q_1(x)+2$$
$$P(x)=(x-2)q_2(x)+1$$

ដូច្នេះ $P(1)=2; P(2)=1$ ។ ជំនួស $x=1$ និង $x=2$ ចូលក្នុង (*) យើងទាញបាន

$$2=P(1)=a+b$$
$$1=P(2)=2a+b$$

ដូច្នេះ $a=-1, b=3$ ។ សំណល់ស្មើនឹង $-x+3$ ។

**931.**▲ យើងមាន

$$x^4+x^3+2x^2+x+1=(x^2+1)(x^2+x+1)$$
$$x^{12}-1=(x^6-1)(x^6+1)=(x^3-1)(x^3+1)(x^2+1)(x^4-x^2+1)$$
$$=(x-1)(x^2+x+1)(x^3+1)(x^2+1)(x^4-x^2+1)$$
$$\Rightarrow x^4+x^3+2x^2+x+1=\frac{x^{12}-1}{(x-1)(x^3+1)(x^4-x^2+1)}$$
$$=\frac{x^{12}-1}{x^8-x^7-x^6+2x^5-2x^3+x^2+x-1}$$

ដូច្នេះ ចែក $x^{1951}-1$ នឹង $x^4+x^3+2x^2+x+1$ គឺដូចគ្នានឹងចែក $x^{1951}-1$ នឹង $x^{12}-1$ រួចគុណនឹង $x^8-x^7-x^6+2x^5-2x^3+x^2+x-1$ ដែរ ។ យើងមាន

$$\frac{x^{1951}-1}{x^{12}-1}=\frac{x^7[(x^{12})^{162}-1]+x^7-1}{x^{12}-1}$$
$$=x^{1939}+x^{1927}+x^{1915}+x^{1903}+\cdots+x^{19}+x^7+\frac{x^7-1}{x^{12}-1}$$

ដូច្នេះមេគុណរបស់ $x^{14}$ របស់ផលចែកស្មើនឹងមេគុណរបស់ $x^{14}$ នៅក្នុងផលគុណ

$$\left(x^{1939}+x^{1927}+x^{1915}+x^{1903}+\cdots+x^{19}+x^7+\frac{x^7-1}{x^{12}-1}\right)$$
$$\times(x^8-x^7-x^6+2x^5-2x^3+x^2+x-1)$$

ដែលស្មើនឹង $-1$ ។

**932.▲** a) តាង $x=\sqrt{2}+\sqrt{3}$ ។ ដូច្នេះ

$$x^2=2+2\sqrt{2}.\sqrt{3}+3=5+2\sqrt{6}$$
$$\Rightarrow x^2-5=2\sqrt{6}$$
$$\Rightarrow x^4-10x^2+25=24$$
$$\Rightarrow x^4-10x^2+1=0$$

b) តាង $x=\sqrt{2}+\sqrt[3]{3}$ ។ ដូច្នេះ

$$x=\sqrt{2}+\sqrt[3]{3}$$
$$\Rightarrow x^2=2+2\sqrt{2}.\sqrt[3]{3}+\sqrt[3]{9}$$
$$\Rightarrow x^3=2\sqrt{2}+3.2.\sqrt[3]{3}+3.\sqrt{2}.\sqrt[3]{9}+3 \quad (*)$$

$$x=\sqrt{2}+\sqrt[3]{3} \ \Rightarrow\ \sqrt[3]{3}=x-\sqrt{2}$$
$$\Rightarrow\ \sqrt[3]{9}=x^2-2-2\sqrt{2}.\sqrt[3]{3}=x^2-2-2\sqrt{2}\left(x-\sqrt{2}\right)=x^2+2-2\sqrt{2x}$$

(*) $\Rightarrow x^3=2\sqrt{2}+3.2\left(x-\sqrt{2}\right)+3.\sqrt{2}.\left(x^2+2-2\sqrt{2x}\right)+3$

$$\Rightarrow x^3+6x-3=\sqrt{2}(3x^2+2)$$
$$\Rightarrow x^6+36x^2+9+12x^4-6x^3-36x=18x^4+24x^2+8$$
$$\Rightarrow x^6-6x^4-6x^3+12x^2-36x+1=0$$

**933.▲** តាមទ្រឹស្តីបទវៀត

$$\alpha+\beta=-p,\alpha\beta=1$$
$$\gamma+\delta=-q,\gamma\delta=1$$

ដូច្នេះ

$$(\alpha-\gamma)(\beta-\gamma)(\alpha+\delta)(\beta+\delta)=[(\alpha-\gamma)(\beta+\delta)][(\beta-\gamma)(\alpha+\delta)]$$
$$=(\alpha\beta+\alpha\delta-\beta\gamma-\gamma\delta)(\alpha\beta+\beta\delta-\alpha\gamma-\gamma\delta)$$
$$=(\alpha\delta-\beta\gamma)(\beta\delta-\alpha\gamma)=\alpha\beta\delta^2-\alpha^2\gamma\delta-\beta^2\gamma\delta+\alpha\beta\gamma^2$$
$$=\delta^2-\alpha^2-\beta^2+\gamma^2=[(\delta+\gamma)^2+2\delta\gamma]-[(\alpha+\beta)-2\alpha\beta]$$
$$=(q^2-2)-(p^2-2)=q^2-p^2$$

**934.▲** ដោយ $\alpha$ និង $\beta$ ជាឫសរបស់សមីការ $x^2+px+q=0$ នោះ $(x-\alpha)(x-\beta)=x^2+px+q$ ។ ដូច្នេះ

$$\begin{aligned}(\alpha-\gamma)(\beta-\gamma)(\alpha-\delta)(\beta-\delta)&=[(\alpha-\gamma)(\beta-\gamma)][(\alpha-\delta)(\beta-\delta)]\\&=[(\gamma-\alpha)(\gamma-\beta)][(\delta-\alpha)(\delta-\beta)]\\&=(\gamma^2+p\gamma+q)(\delta^2+p\delta+q)\end{aligned}$$

ម្យ៉ាងវិញទៀត

$$\gamma+\delta=-P;\gamma\delta=Q$$

ដូច្នេះ

$$\begin{aligned}(\alpha-\gamma)(\beta-\gamma)(\alpha-\delta)(\beta-\delta)&=(\gamma^2+p\gamma+q)(\delta^2+p\delta+q)\\&=\gamma^2\delta^2+p\gamma^2\delta+q\gamma^2+p\gamma\delta^2+p^2\gamma\delta+pq\gamma+q\delta^2+pq\delta\\&\quad+q^2\\&=(\gamma\delta)^2+p\gamma\delta(\gamma+\delta)+q[(\gamma+\delta)^2-2\gamma\delta]+p^2\gamma\delta\\&\quad+pq(\gamma+\delta)+q^2\\&=Q^2-pPQ+q(P^2-2Q)+p^2Q-pqP+q^2\\&=Q^2+q^2-pP(Q+q)+qP^2+p^2Q-2qQ\end{aligned}$$

**935.▲** សមីការទី២នាំឱ្យ $a=-(x^2+x)$ ។ ជំនួសចូលសមីការទី១ យើងទាញបាន

$$\begin{aligned}&x^2-(x^2+x)x+1=0\\&\Rightarrow x^3-1=0\\&\Rightarrow (x-1)(x^2+x+1)=0\\&\Rightarrow x_1=1;x_{2,3}=\frac{-1\pm i\sqrt{3}}{2}\end{aligned}$$

បើ $x=1\Rightarrow a=-(x^2+x)=-2$

បើ $x=\frac{-1\pm i\sqrt{3}}{2}\Rightarrow x^2+x=-1\Rightarrow a=1$

ដូច្នេះ $a\in\{-2,1\}$ ។

**936.▲** ជំនួស $x=-b$ ចូល យើងទាញបាន $(b+a)(b+10)+1=0$ ។ ដូច្នេះ ជាចាំបាច់ត្រូវតែ $(b+a)(b+10)=-1$ ។ ដោយ $a,b$ ជាចំនួនគត់ នោះ $(b+a)$ និង $(b+10)$ ជាចំនួនគត់ដែរ ។ តែ $-1=(1)(-1)=(-1)(1)$ នោះ

i) $b+10=1,b+a=-1\Rightarrow b=-9,a=8$ ។ យើងទាញបាន

$$(x-8)(x-10)+1=(x-9)^2$$

ii) $b+10=-1,b+a=1\Rightarrow b=-11,a=12$ ។ យើងទាញបាន

$$(x-12)(x-10)+1=(x-11)^2$$

**937.▲** ជំនួស $x=-m$ ចូល យើងទាញបាន

$$(m+p)(m+2011)+1=0$$

ដូច្នេះជាចាំបាច់ត្រូវតែ $(m+p)(m+2011)=-1$ ។ ដោយ $m,p$ ជាចំនួនគត់ នោះ $(m+p)$ និង $(m+2011)$ ជាចំនួនគត់ដែរ ។ តែ $-1=(1)(-1)=(-1)(1)$ នោះ

i) $m+2011=1, m+p=-1 \Rightarrow m=-2010, p=2009$

ii) $m+2011=-1, m+p=1 \Rightarrow m=-2012, p=2013$

**938.▲** ពហុធាដឺក្រេទីបួនអាចដាក់ជាកត្តាផលគុណរវាងពហុធាដឺក្រេទីមួយ និងទីបី ឬរវាងពហុធាដឺក្រេទីពីរចំនួនពីរ ។ ដំបូងយើងពិនិត្យករណីទីមួយ ។ យើងមាន

$$x(x-a)(x-b)(x-c)+1=(x+p)(x^3+qx^2+rx+s) \quad (1)$$

សម្គាល់ ៖ ដោយមេគុណរបស់ $x^4$ នៅអង្គខាងឆ្វេងស្មើ $+1$ នោះមេគុណរបស់ $x$ និង $x^3$ នៃអង្គខាងស្តាំ អាចស្មើ $+1$ ឬ $-1$ ។ តែករណី $(-x+p_1)(-x^3+q_1x^2+r_1x+s_1)$ យើងនៅតែអាចបំលែងពហុធានេះឱ្យមានរាង $(x+p)(x^3+qx^2+rx+s)$ ដដែល ។

ជំនួស $x=0, x=a, x=b, x=c$ ចូលក្នុងសមភាព (1) យើងទាញបាន

$$\begin{cases}(0+p)(s)=1\\(a+p)(a^3+qa^2+ra+s)=1\\(b+p)(b^3+qb^2+rb+s)=1\\(c+p)(c^3+qc^2+rc+s)=1\end{cases} \quad (*)$$

ដោយដឹងថា $1=(1)(1)$ ឬ $1=(-1)(-1)$ មានន័យថា $1$ អាចបំបែកជាផលគុណដែលកត្តាផលគុណរបស់វា មានតែពីរបែបតែប៉ុណ្ណោះ គឺ $1$ ឬ $-1$ ។ តែតាម (*) ដោយ $p, a+p; b+p, c+p$ សុទ្ធតែមានតម្លៃខុសៗគ្នា ដូច្នេះតាម(*) យើងទទួលបានកត្តាផលគុណរបស់ $1$ មានចំនួនច្រើនលើសពីពីរ : $p, a+p; b+p, c+p, \ldots$ ។ ដូច្នេះ (*) មិនអាចមានចម្លើយបានទេ ។

យើងពិនិត្យករណីទីពីរ ។ យើងមាន

$$x(x-a)(x-b)(x-c)+1=(x^2+px+q)(x^2+rx+s)$$

ជំនួស $x=0, x=a, x=b, x=c$ ចូល យើងទាញបាន $(x^2+px+q)(x^2+rx+s)=1$ ចំពោះតម្លៃបួនផ្សេងគ្នានៃ $x$ គឺ $x=0, x=a, x=b, x=c$ ។ ដូច្នេះ

$$\begin{cases} x^2+px+q=1 \\ x^2+rx+s=1 \end{cases} \vee \begin{cases} x^2+px+q=-1 \\ x^2+rx+s=-1 \end{cases}$$

ចំពោះ $x=0, x=a, x=b, x=c$ ។

យើងដឹងថា $x^2+px+q$ មិនអាចស្មើ $1$ ចំពោះតម្លៃ $x$ ចំនួនបួនផ្សេងគ្នាបានទេ ព្រោះសមីការ $x^2+px+q=1$ មានឫសយ៉ាងច្រើនចំនួនពីរ ។ ដូចគ្នា $x^2+px+q$ មិនអាចស្មើ $-1$ ចំពោះតម្លៃ $x$ ចំនួនបួនផ្សេងគ្នាបានទេ ព្រោះសមីការ $x^2+px+q=-1$ មានឫសយ៉ាងច្រើនចំនួនពីរ ។ ដូច្នេះចំពោះ $x$ ចំនួនពីរ យើងមាន $x^2+px+q=1$ និងចំពោះ $x$ ពីរទៀត យើងមាន $x^2+px+q=-1$ ។

- សន្មតថា ចំពោះ $x=0$ និង $x=a$ យើងមាន $x^2+px+q=1$ ។ ដូច្នេះ យើងទាញបាន $q=1$ និង $a=-p$ ។ ដូច្នេះចំពោះ $x=b$ និង $x=c$ ពហុធា $x^2+px+q$ ត្រូវតែស្មើ $-1$ ។ យើងទាញបាន

$$\begin{cases} b^2+pb+q=-1 \\ c^2+pc+q=-1 \end{cases} \Rightarrow \begin{cases} b^2-ab+1=-1 \\ c^2-ac+1=-1 \end{cases} \Rightarrow \begin{cases} b(b-a)=-2 \\ c(c-a)=-2 \end{cases}$$

យកសមីការទីមួយដកសមីការទីពីរ យើងទាញបាន

$$\begin{aligned} & b(b-a)-c(c-a)=0 \\ \Leftrightarrow\ & b^2-ab-c^2+ac=0 \\ \Leftrightarrow\ & (b-c)(b+c)-a(b-c)=0 \\ \Leftrightarrow\ & (b-c)(b+c-a)=0 \\ \Rightarrow\ & b+c-a=0 \\ \Rightarrow\ & b-a=-c; c-a=-b \end{aligned}$$

ដូច្នេះ

$$b(b-a)=-2 \Rightarrow b(-c)=-2 \Rightarrow bc=2$$

- បើ $b=1$ នោះ $c=2; a=b+c=3$

$$\begin{aligned} x(x-a)(x-b)(x-c)+1 &= x(x-3)(x-1)(x-2)+1 \\ &= (x^2-3x+1)^2 \end{aligned}$$

- បើ $b=-1$ នោះ $c=-2; a=b+c=-3$

$$x(x-a)(x-b)(x-c)+1 = x(x+3)(x+1)(x+2)+1 = (x^2-3x+1)^2$$

- សន្មតថា ចំពោះ $x=0$ និង $x=a$ យើងមាន $x^2+px+q=-1$ និងចំពោះ $x=b$ និង $x=c$ យើងមាន $x^2+px+q=1$ ។ ដូច្នេះ

$$\begin{aligned}
&q=-1\\
&a^2+pa-1=-1\\
&b^2+pb-1=1\\
&c^2+pc-1=1
\end{aligned}$$

យើងទាញបាន

$$\begin{aligned}
&p=-a\\
&b(b-a)=2 \quad \text{(i)}\\
&c(c-a)=2 \quad \text{(ii)}\\
\text{(i)\& (ii)} &\Rightarrow (b-c)(b+c-a)=0\\
&\Rightarrow a=b+c \quad \text{(iii)}\\
\text{(i)\&(iii)} &\Rightarrow bc=-2
\end{aligned}$$

ដូច្នេះ

$$\begin{aligned}
&b=2\\
&c=-1\\
&a=b+c=1\\
&x(x-a)(x-b)(x-c)+1=x(x-1)(x-2)(x+1)+1\\
&=(x^2-x-1)^2
\end{aligned}$$

ឬ

$$\begin{aligned}
&b=1\\
&c=-2\\
&a=b+c=-1\\
&x(x-a)(x-b)(x-c)+1=x(x+1)(x-1)(x+2)+1\\
&=(x^2+x-1)^2
\end{aligned}$$

**939.▲** (a) សន្មតថា

$$(x-a_1)(x-a_2)(x-a_3)\dots(x-a_n)-1=p(x)q(x)$$

ដែល $p(x)$ និង $q(x)$ ជាពហុធាពីរដែលមានដឺក្រេ $\geq 1$ ហើយមានមេគុណជាចំនួនគត់ និងផលបូកដឺក្រេនៃពហុធាពីរនេះបូកគ្នាស្មើ $n$ ។ យើងសន្មតថា មេគុណរបស់តួនាំមុខ (តួមានដឺក្រេខ្ពស់បំផុត)របស់ពហុធាទាំងពីរស្មើ $+1$ ព្រោះមេគុណរបស់ $x^n$ ស្មើ $+1$ ដែរ (វាអាចស្មើ $-1$ ទាំងពីរដូចគ្នា តែយើងនៅតែអាចបំលែងមកជា $+1$ ទាំងពីរបានដដែល ឧទាហរណ៍ $(x+1)(x+2)\equiv(-x-1)(-x-2)$) ។ បើយើងជំនួស $x=a_1, x=$

$a_2, x = a_3, \ldots, x = a_n$ ចូល ហើយដោយដឹងថា $-1$ អាចបំបែកជាកត្តាផលគុណបានតែ $-1 = 1(-1)$ នោះយើងឃើញថា ចំពោះតម្លៃ $x$ នីមួយៗទាំងនេះ, យើងមាន $p(x) = 1$ និង $q(x) = -1$ ឬមិនអ៊ីចឹងទេ $p(x) = -1$ និង $q(x) = 1$ ។ ដូច្នេះផលបូក $p(x) + q(x) = 0$ ត្រង់ $x = a_1, a_2, a_3, \ldots, a_n$ ហើយសមីការ $p(x) + q(x) = 0$ មានឫសចំនួន $n$ ផ្សេងគ្នា គឺ $x_1 = a_1, x_2 = a_2, x_3 = a_3, \ldots, x_n = a_n$ ។ ដូច្នេះ $p(x) + q(x)$ ចែកដាច់នឹង $x - a_1, x - a_2, \ldots, x - a_n$ ហើយនាំឱ្យចែកដាច់នឹង $(x - a_1)(x - a_2) \ldots (x - a_n)$ ។ តែដឺក្រេរបស់ពហុធា $p(x) + q(x)$ មានតម្លៃត្រឹមតែដឺក្រេធំបំផុតរវាង $p(x)$ និង $q(x)$ តែប៉ុណ្ណោះ ហើយដឺក្រេរបស់ពហុធា $p(x)$ និង $q(x)$ មានតម្លៃតូចជាង $n$ ដែល $n$ ជាដឺក្រេរបស់ $(x - a_1)(x - a_2)(x - a_3) \ldots (x - a_n) - 1$ ។ ដូច្នេះ $p(x) + q(x)$ មិនអាចចែកដាច់នឹងផលគុណ $(x - a_1)(x - a_2) \ldots (x - a_n)$ បានទេ ។ ដោយសារភាពផ្ទុយគ្នានេះ យើងសន្និដ្ឋានបានថាពហុធាមិនអាចបំបែកជាកត្តាផលគុណបានដូចការសន្មតទេ ។

(b) សន្មតថា

$$(x - a_1)(x - a_2)(x - a_3) \ldots (x - a_n) + 1 = p(x)q(x)$$

ដែល $p(x)$ និង $q(x)$ ជាពហុធាពីរដែលមានដឺក្រេ $\geq 1$ ហើយមានមេគុណជាចំនួនគត់ និងផលបូកដឺក្រេនៃពហុធាពីរនេះចូលគ្នាស្មើ $n$ ។ យើងសន្មតថា មេគុណរបស់តួនាំមុខរបស់ពហុធាទាំងពីរស្មើ $+1$ ។ បើយើងជំនួស $x = a_1, x = a_2, x = a_3, \ldots, x = a_n$ ចូល ហើយដោយដឹងថា $1$ អាចបំបែកជាកត្តាផលគុណបានតែ $1 = 1.1 = (-1).(-1)$ នោះយើងឃើញថា ចំពោះតម្លៃ $x$ នីមួយៗទាំងនេះ, យើងមាន $p(x) = 1$ និង $q(x) = 1$ ឬមិនអ៊ីចឹងទេ $p(x) = -1$ និង $q(x) = -1$ ។

ដោយ $p(x) - q(x)$ ស្មើសូន្យចំពោះតម្លៃ $x$ ចំនួន $n$ ផ្សេងគ្នា នោះយើងទាញបានថា $p(x) - q(x) \equiv 0 \Rightarrow p(x) \equiv q(x)$ ហើយនាំឱ្យ $n$ ត្រូវតែជាចំនួនគូ ។ ដូច្នេះ $n = 2k$ ដែល $k$ ជាដឺក្រេរបស់ $p(x)$ និង $q(x)$ ។ ដូច្នេះយើងអាចសរសេរសមភាពជា

$$(x - a_1)(x - a_2)(x - a_3) \ldots (x - a_n) = p^2(x) - 1$$

$$\Leftrightarrow\ (x-a_1)(x-a_2)(x-a_3)\dots(x-a_n)=[p(x)+1][p(x)-1]$$

ពេលនេះផលគុណ $[p(x)+1][p(x)-1]$ មានតម្លៃស្មើសូន្យត្រង់ $x=a_1, x=a_2,\dots,x=a_{2k}$ ។ ដូច្នេះ ចំពោះតម្លៃ $x$ នីមួយៗ, ត្រូវមានពហុធាយ៉ាងតិចមួយក្នុងចំណោម $p(x)+1$ និង $p(x)-1$ ដែលត្រូវស្មើសូន្យ ។ ដូច្នេះមានន័យថា $p(x)+1$ ឬមិនអ៊ីចឹងទេ $p(x)-1$ ឬទាំងពីរ ចែកដាច់នឹង $x-a_1$ ហើយដូចគ្នា យើងទាញបានភាពចែកដាច់នឹង $x-a_2, x-a_3,\dots$ ។ ពហុធាដឺក្រេ $k$ មិនអាចចែកដាច់នឹងផលគុណដែលមានចំនួនកត្តាដែលមានរាង $x-a_i$ លើសពី $k$ បានទេ ។ ដូច្នេះ ពហុធា $p(x)+1$ មានដឺក្រេ $k$ ត្រូវមានចំនួនកត្តាស្មើ $k$ ។ ដោយ $p(x)+1$ មានមេគុណនាំមុខស្មើ 1 ដូច្នេះ $p(x)+1$ ត្រូវតែស្មើនឹងផលគុណកត្តាដែលមានរាង $(x-a_i)$ ចំនួន $k$ ។ ដូច្នេះ $p(x)+1$ ជាផលគុណនៃកត្តាចំនួន$k$ ក្នុងចំណោម $(x-a_1),(x-a_2),\dots,(x-a_{2k})$ និង $p(x)-1$ ត្រូវស្មើនឹងផលគុណនៃកត្តាចំនួន $k$ ទៀតដែលនៅសល់ ។ យើងសន្មតថា

$$p(x)+1=(x-a_1)(x-a_3)\dots(x-a_{2k-1})$$
$$p(x)-1=(x-a_2)(x-a_4)\dots(x-a_{2k})$$

យើងយកសមីការទីមួយដកសមីការទីពីរ យើងទទួលបានសមភាព

$$2=(x-a_1)(x-a_3)\dots(x-a_{2k-1})-(x-a_2)(x-a_4)\dots(x-a_{2k})$$

ពេលនេះយើងពិនិត្យករណីពិសេសមួយ បើយើងជំនួស $x=a_2$ យើងទាញបាន 2 ជាផលគុណនៃកត្តាចំនួន $k$ ផ្សេងគ្នា

$$2=(a_2-a_1)(a_2-a_3)\dots(a_2-a_{2k-1}) \quad (1)$$

តែដោយ 2 អាចដាក់ជាផលគុណនៃកត្តាយ៉ាងច្រើនចំនួន 3 ផ្សេងគ្នាតែប៉ុណ្ណោះ ឧទាហរណ៍ $2=1.(-1)(-2)$ ដូច្នេះត្រូវតែ $k\le 3$ ។ តែករណី $k=3$ មិនអាចផ្ទៀងផ្ទាត់ (1) បានទេព្រោះ បើ $k=3$ និងឧបមាថា $a_1<a_2<a_3$ នោះ $2=(a_2-a_1)(a_2-a_3)(a_2-a_5)$ ដែល $a_2-a_1>a_2-a_3>a_2-a_5$ ហើយដូច្នេះ $a_2-a_1=1, a_2-a_3=-1, a_2-a_5=-2$ ។ ជំនួស $x=a_4$ ចូលក្នុង

$$2=(x-a_1)(x-a_3)(x-a_5)-(x-a_2)(x-a_4)(x-a_6)$$

យើងទាញបាន

$$2=(a_4-a_1)(a_4-a_3)(a_4-a_5)$$

ដែលដោយ $a_4-a_1>a_4-a_3>a_4-a_5$ នោះ $a_4-a_1=1, a_4-a_3=-1, a_4-a_5=-2 \Rightarrow a_4=a_2$ ផ្ទុយពីសម្មតិកម្ម ។

ដូច្នេះមានតែករណីចំនួនពីរតែប៉ុណ្ណោះដែលអាចគឺ $k=2$ និង $k=1$ ។

បើ $k=1$ យើងមាន

$$2(x-a_1)-(x-a_2) \ \Rightarrow a_2=a_1+2$$

តាង $a=a_2$ យើងបាន

$$\begin{aligned}(x-a_1)(x-a_2)+1&=(x-a)(x-a-2)+1\\&=(x-a-1)^2\end{aligned}$$

បើ $k=2$ យើងមាន

$$2=(x-a_1)(x-a_3)-(x-a_2)(x-a_4)$$

ដោយយើងនឹងសន្មតថា $a_1<a_3$ និង $a_2<a_4$ ។ យើងជំនួស $x=a_2$ ចូលក្នុងសមីការនេះ ហើយបន្ទាប់មកជំនួស $x=a_4$ ចូល យើងទទួលបាន

$$\begin{aligned}2=(a_2-a_1)(a_2-a_3), a_2-a_1>a_2-a_3\\2=(a_4-a_1)(a_4-a_3), a_4-a_1>a_4-a_3\end{aligned}$$

តែ 2 អាចបំបែកជាផលគុណបានតែពីរបែបតែប៉ុណ្ណោះ $2=2.1$ និង $2=(-1).(-2)$ ។ ដោយ $a_2-a_1<a_4-a_1$ នោះ

$$\begin{aligned}a_2-a_1=-1, a_2-a_3=-2\\a_4-a_1=2, a_4-a_3=1\end{aligned}$$

តាង $a=a_1$ យើងទាញបាន

$$\begin{aligned}a_2&=a-1\\a_3&=a+1\\a_4&=a+2\end{aligned}$$

និង

$$\begin{aligned}&(x-a_1)(x-a_2)(x-a_3)(x-a_4)+1\\&\quad=(x-a)(x-a+1)(x-a-1)(x-a-2)+1\\&\quad=[x^2-(2a-1)x+a^2+a-1]^2\end{aligned}$$

**940.▲** សន្មតថា

$$(x-a_1)^2(x-a_2)^2\dots(x-a_n)^2+1\equiv p(x)\,q(x) \qquad (1)$$

ដែល $p(x)$ និង $q(x)$ ជាពហុធាមានមេគុណជាចំនួនគត់ និងមានមេគុណនាំមុខស្មើ 1 ។ ដោយជំនួស $x = a_1, a_2, \ldots, a_n$ ចូលក្នុង (1) យើងទាញបាន $p(x) = 1$ និង $q(x) = 1$ ឬ $p(x) = -1$ និង $q(x) = -1$ ចំពោះ $x = a_1, a_2, \ldots, a_n$ ។

សន្មតថា $p(x) = 1$ ចំពោះ $x = a_i$ និង $p(x) = -1$ ចំពោះ $x = a_j$ ដែល $i \neq j$ ។ ដូច្នេះចំពោះតម្លៃ $x$ ខ្លះដែលឋិតនៅចន្លោះ $a_i$ និង $a_j$ យើងមានពហុធា $p(x)$ មានតម្លៃស្មើសូន្យ ព្រោះ ពហុធាជាអនុគមន៍ជាប់ វាត្រូវតែកើតពី $-1$ ទៅ $+1$ ដោយកាត់តាមអ័ក្ស $y = 0$ ។ តែករណីនេះមិនអាចទេ ព្រោះអង្គខាងឆ្វេងនៃសមីការ (1) ធំជាង 1 ជានិច្ច ដូច្នេះមិនអាចស្មើ 0 បានទេ ដូច្នេះ $p(x)$ ត្រូវតែខុសពីសូន្យដែរ ។ ដូច្នេះ $p(x)$ មានតម្លៃថេរស្មើ $+1$ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ឬ $p(x)$ មានតម្លៃថេរស្មើ $-1$ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ។ ដូចគ្នា $q(x)$ មានតម្លៃថេរស្មើ $+1$ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ឬ $q(x)$ មានតម្លៃថេរស្មើ $-1$ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ។ ដូច្នេះ $p(x)$ និង $q(x)$ មានតម្លៃថេរស្មើ $+1$ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ឬ $p(x)$ និង $q(x)$ មានតម្លៃថេរស្មើ $-1$ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ។

សន្មតថា $p(x)$ និង $q(x)$ មានតម្លៃថេរស្មើ $+1$ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ។ ក្នុងករណីនេះ $p(x) - 1$ និង $q(x) - 1$ មានតម្លៃស្មើសូន្យ ចំពោះគ្រប់ $x = a_1, a_2, \ldots, a_n$ ។ដូច្នេះ $p(x) - 1$ និង $q(x) - 1$ ចែកដាច់នឹង $(x - a_1)(x - a_2)\ldots(x - a_n)$ ។ តែដោយផលបូកដឺក្រេរបស់ពហុធា $p(x)$ និង $q(x)$ ត្រូវមានតម្លៃស្មើដឺក្រេរបស់ពហុធា $(x - a_1)^2(x - a_2)^2 \ldots (x - a_n)^2 + 1$, ដែលស្មើ $2n$, នោះយើងសន្និដ្ឋានបានថា $p(x) - 1 = (x - a_1)(x - a_2)\ldots(x - a_n)$ និង $q(x) - 1 = (x - a_1)(x - a_2)\ldots(x - a_n)$ ។ យើងទាញបានសមភាព

$$\begin{aligned}
&(x - a_1)^2(x - a_2)^2 \ldots (x - a_n)^2 + 1 \equiv p(x)\, q(x) \\
&\equiv [(x - a_1)(x - a_2)\ldots(x - a_n) + 1][(x - a_1)(x - a_2)\ldots(x - a_n) + 1] \\
&\equiv [(x - a_1)(x - a_2)\ldots(x - a_n) + 1]^2 \\
&\equiv (x - a_1)^2(x - a_2)^2 \ldots (x - a_n)^2 + 2(x - a_1)(x - a_2)\ldots(x - a_n) + 1 \\
&\qquad \Longrightarrow\ (x - a_1)(x - a_2)\ldots(x - a_n) \equiv 0
\end{aligned}$$

សមភាពនេះមិនអាចពិតចំពោះគ្រប់ $x \in \mathbb{R}$ បានទេ ។ ដូច្នេះ $p(x)$ និង $q(x)$ មិនអាចមានតម្លៃស្មើ 1 ចំពោះគ្រប់ $x = a_1, a_2, \dots, a_n$ បានទេ ។ ដូចគ្នា $p(x)$ និង $q(x)$ មិនអាចមានតម្លៃស្មើ $-1$ ចំពោះគ្រប់ $x = a_1, a_2, \dots, a_n$ បានទេ ។

ដូច្នេះ គេមិនអាចបំបែក

$$(x-a_1)^2(x-a_2)^2 \dots (x-a_n)^2 + 1$$

ជាផលគុណនៃពហុធាពីរដែលមានមេគុណជាចំនួនគត់បានទេ ។

**941.▲** បើពហុធាដឺក្រេទី៧អាចដាក់ជាផលគុណនៃពហុធាពីរតាងដោយ p(x) និង q(x) ដែលមានមេគុណជាចំនួនគត់ នោះដឺក្រេរបស់ពហុធាមួយក្នុងចំណោមនេះធំមិនលើសពី 3 ទេ ។ សន្មតថា p(x) មានដឺក្រេធំមិនលើសពី 3 ។ យើងមាន $P(x) = p(x)q(x) = \pm 1$ ចំពោះតម្លៃ x គត់ចំនួនប្រាំពីរ ។ ដោយមេគុណរបស់ពហុធាសុទ្ធតែជាចំនួនគត់ នោះ p(x) មានតម្លៃ +1 ឬ −1 ចំពោះតម្លៃ x គត់ចំនួនប្រាំពីរដែរ ។ ក្នុងចំណោមតម្លៃ x គត់ទាំង 7 ត្រូវមានតម្លៃ x យ៉ាងតិចចំនួន 4 ដែល p(x) មានតម្លៃ +1 ឬមិនអ៊ីចឹងទេ ត្រូវមានតម្លៃ x យ៉ាងតិចចំនួន 4 ដែល p(x) មានតម្លៃ −1 ។ បើ $p(x) = +1$ ចំពោះតម្លៃ x យ៉ាងតិចចំនួន 4 នោះមិនពិត ព្រោះ $p(x)$ ជាពហុធាដឺក្រេទីបី ដែលយ៉ាងច្រើនមានឫសយ៉ាងច្រើនចំនួនបី ។ ករណី $p(x) = -1$ ដូចគ្នា ។ ដូច្នេះយើងមិនអាចបំបែក $P(x) = p(x)q(x)$ ។

**942.▲** តាង $p$ និង $q$ ជាចំនួនគត់ពីរដែលគូទាំងពីរឬសេសទាំងពីរ ។ យើងមាន $p-q$ ជាចំនួនគូ និង

$$P(p) - P(q) = a_0(p^n - q^n) + a_1(p^{n-1} - q^{n-1}) + \dots + a_{n-2}(p^2 - q^2) + a_{n-1}(p-q)$$

ចែកដាច់នឹងចំនួនគូ $(p-q)$ ដូច្នេះ $P(p) - P(q)$ ជាចំនួនគូដែរ ។

ដូចគ្នាដែរ បើ $p$ គូ នោះ $P(p) - P(0)$ គូដែរ ។ តែ $P(0)$ សេស ដូច្នេះ $P(p)$ ត្រូវតែសេសដែរ ព្រោះ $P(p) - P(0)$ គូ ។ ដោយ $P(p)$ សេស នោះត្រូវតែ $P(p) \neq 0$ ។

ដូចគ្នាដែរ បើ $p$ សេស នោះ $P(p)-P(1)$ គូ ។ តែ $P(1)$ សេស ដូច្នេះ $P(p)$ ត្រូវតែសេសដែរ ព្រោះ $P(p)-P(1)$ គូ ។ ដោយ $P(p)$ សេស នោះត្រូវតែ $P(p)\neq 0$ ។ ដូច្នេះ P(x) មិនអាចស្មើសូន្យចំពោះទាំង x គូនិងសេស មានន័យថាពហុធានេះគ្មានឫស ។

**943.▲** សន្មតថាសមីការ $P(x)=0$ មានឫសសនិទាន $x=\frac{k}{l}$ គឺ $P\left(\frac{k}{l}\right)=0$ ដែលក្នុងនេះសន្មតថាប្រភាគ $\frac{k}{l}$ ជាប្រភាគបង្រួមរួចហើយ ( $k$ បឋមនឹង $l, l>0$ ) ។ យើងសរសេរ P(x) ជាស្វ័យគុណនៃ (x − p) ក្រោមទម្រង់

$$P(x)=c_0(x-p)^n+c_1(x-p)^{n-1}+c_2(x-p)^{n-2}+\cdots+c_{n-1}(x-p)+c_n$$

ដែល $c_0, c_1, c_2, \ldots, c_n$ ជាចំនួនគត់អាស្រ័យនឹង $a_0, a_1, \ldots, a_n$ (យើងមាន $c_0=a_0, c_1=$ មេគុណរបស់ $x^{n-1}$ នៃ $P(x)-c_0(x-p)^n, \ldots$) ។ យក $x=p$ យើងទាញបាន $c_n=P(p)=\pm 1$ ។

យក $x=\frac{k}{l}$ យើងទាញបាន

$$l^nP\left(\frac{k}{l}\right)=c_0(k-pl)^n+c_1l(k-pl)^{n-1}+c_2l^2(k-pl)^{n-2}+\cdots+c_{n-1}l^{n-1}(k-pl)+c_nl^n=0$$

ដោយ $P\left(\frac{k}{l}\right)=0$ នោះ

$$c_nl^n=-c_0(k-pl)^n-c_1l(k-pl)^{n-1}-c_2l^2(k-pl)^{n-2}-\cdots-c_{n-1}l^{n-1}(k-pl)$$

$$\Leftrightarrow \frac{c_nl^n}{k-pl}=\frac{\pm l^n}{k-pl}=-c_0(k-pl)^{n-1}-c_1l(k-pl)^{n-2}-c_2l^2(k-pl)^{n-3}-\cdots-c_{n-2}l^{n-2}(k-pl)-c_{n-1}l^{n-1}$$

ជាចំនួនគត់ ។ ដោយ pl ចែកដាច់នឹង l ហើយ k បឋមនឹង l នោះ $k-pl$ បឋមនឹង l ដូច្នេះ k − pl បឋមនឹង $l^n$ ។ ដូច្នេះ $\frac{\pm l^n}{k-pl}$ អាចជាចំនួនគត់បាន មានតែ $k-pl=\pm 1$ ។ តាមរបៀបដូចគ្នា យើងទាញបាន $k-ql=\pm 1$ ។

ដកសមភាព $k-pl=\pm1$ ជាមួយ $k-ql=\pm1$ យើងទាញបាន $(p-q)l=0$ ឬ $(p-q)l=\pm2$ ។ តែដោយ $(p-q)l>0$ ព្រោះ $p>q$ និង $l>0$ យើងទាញបាន $(p-q)l=2, k-pl=-1$ និង $k-ql=1$ ។

បើ $p-q>2$ នោះ $(p-q)l=2$ មិនអាចទៅរួច ដូច្នេះ $P(x)=0$ មិនអាចមានឫសសនិទានបានទេ ។

បើ $p-q=2$ នោះ $l=1, k=p-1$ ។ ដូច្នេះយើងអាចរកបាន $k,p,q,l$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌបាន មានន័យថា $P(x)=0$ មានឫសសនិទាន ។ ដូចគ្នាចំពោះករណី $p-q=1$ ។

បូកសមភាព $k-pl=-1$ និង $k-ql=1$ ចូលគ្នា យើងទាញបាន

$$2k-(p+q)l=0$$
$$\Rightarrow a=\frac{k}{l}=\frac{p+q}{2}$$

ពិត ។

**944.▲** (ក) សន្មតថាយើងបំបែកពហុធាជាផលគុណកត្តានៃពហុធាពីរមានមេគុណជាចំនួនគត់

$$x^{2222}+2x^{2220}+4x^{2218}+6x^{2216}+8x^{2214}+\cdots+2218x^4+2220x^2+2222$$
$$=(a_nx^n+a_{n-1}x^{n-1}+a_{n-2}x^{n-2}+\cdots+a_0)(b_mx^m+b_{m-1}x^{m-1}+b_{m-2}x^{m-2}+\cdots+b_0)$$

ដែល $m+n=2222$ និង $a_nb_m=1$ ។ ដូច្នេះ $a_0b_0=2222$ : $a_0$ និង $b_0$ មិនអាចសេសទាំងពីរបានទេ ព្រោះ 2222 គូ ។ $a_0$ និង $b_0$ មិនអាចគូទាំងពីរបានទេ ព្រោះ 2222 គូតែចែកមិនដាច់នឹង 4 ។ ដូច្នេះក្នុងចំណោម $a_0$ និង $b_0$ ត្រូវមានមួយគូ មួយទៀតសេស ។ សន្មតថា $a_0$ គូ និង $b_0$ សេស ។ យើងនឹងបង្ហាញថា មេគុណទាំងអស់របស់ពហុធា $a_nx^n+a_{n-1}x^{n-1}+\cdots+a_0$ ត្រូវតែជាចំនួនគូ ។ សន្មតផ្ទុយថា មានមេគុណខ្លះជាចំនួនសេស ហើយសន្មតថា $a_k$ ជាមេគុណសេសទីមួយរាប់ពីស្តាំមកឆ្វេង មានន័យថា

$a_0, a_1, \dots, a_{k-1}$ សុទ្ធតែគូ ។ $a_k$ ជាមេគុណរបស់ $x^k$ ក្នុងពហុធា $a_n x^n + a_{n-1}x^{n-1} + \cdots + a_k x^k + \cdots + a_0$ ។ ដូច្នេះមេគុណរបស់ $x^k$ នៃពន្លាតរបស់ផលគុណ

$$(a_n x^n + a_{n-1}x^{n-1} + a_{n-2}x^{n-2} + \cdots + a_0)(b_m x^m + b_{m-1}x^{m-1} + b_{m-2}x^{m-2} + \cdots + b_0)$$

កំណត់ដោយ

$$a_k b_0 + a_{k-1}b_1 + a_{k-2}b_2 + \cdots + a_0 b_k \tag{1}$$

(បើ $k > m$ នោះមេគុណនេះស្មើនឹង $a_k b_0 + a_{k-1}b_1 + a_{k-2}b_2 + \cdots + a_{k-m}b_m$) ។ មេគុណរបស់ $x^k$ នេះស្មើនឹងមេគុណរបស់ $x^k$ របស់ពហុធា

$$x^{2222} + 2x^{2220} + 4x^{2218} + 6x^{2216} + 8x^{2214} + \cdots + 2218x^4 + 2220x^2 + 2222$$

ដូច្នេះមេគុណនេះស្មើសូន្យ បើ $k$ សេស និងជាចំនួនគូ បើ $k$ គូ (មានតែមេគុណរបស់ $x^{2222}$ ប៉ុណ្ណោះដែលសេស តែ $k \le n < 2222$) ។ តែយើងបានសន្មតថា $a_0, a_1, \dots, a_{k-1}$ សុទ្ធតែគូ នោះតួទាំងអស់ក្នុង (1) សុទ្ធតែគូ លើកលែងតែតួទី១ ។ តែដោយសារផលបូកនេះគូ នោះតួទីមួយនេះគឺ $a_k b_0$ ត្រូវតែគូដែរ តែមិនអាចព្រោះ $a_k$ និង $b_0$ សុទ្ធតែសេស ។ ដូច្នេះមេគុណទាំងអស់របស់

$$a_n x^n + a_{n-1}x^{n-1} + \cdots + a_k x^k + \cdots + a_0$$

សុទ្ធតែគូ តែករណីនេះវាផ្ទុយនឹងលក្ខខណ្ឌដែល $a_n b_m$ ត្រូវតែស្មើ 1 ។ ដូច្នេះការសន្មតដែលថាពហុធាដើមអាចដាក់ជាផលគុណកត្តាបាន ជាការសន្មតមិនត្រឹមត្រូវ ។

(២) តាង $x = y + 1$ ។ ដូច្នេះ

$$\begin{aligned} x^{250} + x^{249} + x^{248} + \cdots + x^2 + x + 1 &= (y+1)^{250} + (y+1)^{249} + \cdots + (y+1) + 1 \\ &= \frac{(y+1)^{251} - 1}{(y+1) - 1} = \frac{1}{y}[(y+1)^{251} - 1] \\ &= y^{250} + 251y^{249} + \binom{251}{2}y^{248} + \binom{251}{3}y^{247} + \cdots \\ &\quad + \binom{251}{2}y + 251 \quad (*) \end{aligned}$$

យើងមាន

$$\binom{251}{k} = \frac{251.250.249 \ldots (251-k+1)}{1.2.3 \ldots k}$$

ជាចំនួនគត់ចែកដាច់នឹងចំនួនបឋម 251 ។ ដូច្នេះមេគុណទាំងអស់របស់ពហុធាលើកលែងតែតួទីមួយ សុទ្ធតែចែកដាច់នឹង 251 ។ តាង

$$P(y) = c_{250}y^{250} + c_{249}y^{249} + \cdots + c_1 y + c_0$$
$$\equiv y^{250} + 251y^{249} + \binom{251}{2}y^{248} + \binom{251}{3}y^{247} + \cdots$$
$$+ \binom{251}{2}y + 251$$

សន្មតថា

$$P(y) \equiv (a_n x^n + a_{n-1}x^{n-1} + a_{n-2}x^{n-2} + \cdots + a_0)(b_m x^m + b_{m-1}x^{m-1} + b_{m-2}x^{m-2} + \cdots + b_0)$$

ដែល $a_n b_m = 1, m+n = 250, a_0 b_0 = 251$ ។ ដោយ 251 ជាចំនួនបឋម នោះត្រូវមានមួយក្នុងចំណោម $a_0$ និង $b_0$ ដែលចែកដាច់នឹង 251 ។ សន្មតថា $a_0$ ចែកដាច់នឹង 251 ។ យើងនឹងបង្ហាញថាគ្រប់ $a_0, a_1, \ldots, a_n$ ត្រូវតែចែកដាច់នឹង 251 ។ តែជំនួសយើងសន្មតថាមាន $a_i$ ខ្លះដែលចែកមិនដាច់នឹង 251 ។ សន្មតថា $a_k$ ចែកមិនដាច់នឹង 251 ដោយ $a_0, a_1, \ldots, a_{k-1}$ សុទ្ធតែចែកដាច់នឹង 251 ។

យើងមានមេគុណ $c_k$ នៃ $y^k$ របស់ពហុធា $P(y)$ កំណត់ដោយ

$$c_k = a_k b_0 + a_{k-1}b_1 + \cdots + a_0 b_k \qquad (2)$$

ឬបើ $k > m$ យើងមាន $c_k = a_k b_0 + a_{k-1}b_1 + \cdots + a_{k-m}b_m$ ។ តួទាំងអស់ក្នុងផលបូក (2) សុទ្ធតែចែកដាច់នឹង 251 លើកលែងតែតួទីមួយ $a_k b_0$ ។ ដោយ $k \le n < 250$ នោះ $c_k$ ចែកដាច់នឹង 251 ។ ដូច្នេះក្នុង (2), $a_k b_0$ ត្រូវតែចែកដាច់នឹង 251 ដែរ ។ ដោយ $b_0$ ចែកមិនដាច់នឹង 251 នោះត្រូវតែ $a_k$ ចែកដាច់នឹង 251 : ផ្ទុយពីការសន្មតដែល $a_k$ ចែកមិនដាច់នឹង 251 ។ ដូច្នេះមានន័យថា $a_0, a_1, \ldots, a_n$ សុទ្ធតែចែកដាច់នឹង 251 ។ យើងមាន $a_n b_m = 1$ ដែល $a_n$ ចែកដាច់នឹង 251 : លក្ខខណ្ឌនេះមិនអាចទៅរួចទេ ។ ដូច្នេះពហុធាដើមមិនអាចបំបែកជាផលគុណកត្តាបានទេ ។

**945.▲** តាង

$$A(x) = a_0 + a_1 x + a_2 x^2 + \cdots + a_n x^n$$

$$B(x) = b_0 + b_1x + b_2x^2 + \cdots + b_mx^m$$

ដោយមេគុណរបស់ពហុធា $P(x) = A(x)B(x)$ ចែកមិនដាច់នឹង 4 គ្រប់គ្នា នោះមេគុណរបស់ $A(x)$ និង $B(x)$ មិនអាចគូទាំងអស់គ្នាបានទេ ។ ដូច្នេះត្រូវតែមានពហុធាមួយក្នុងចំណោមនេះមិនមានមេគុណរបស់វាជាចំនួនគូទាំងអស់ព្រមគ្នា សន្មតថាពហុធានោះជា $B(x)$ ។ ដំបូងយើងសន្មតថា ពហុធា $A(x)$ មានមេគុណខ្លះជាចំនួនសេស ។ សន្មតថា $a_s$ ជាមេគុណសេសទីមួយរបស់ $A(x)$ ដោយ $a_0, a_1, \ldots, a_{s-1}$ សុទ្ធតែគូ ។ សន្មតថា $b_k$ ជាមេគុណសេសទីមួយរបស់ $B(x)$ ដោយ $b_0, b_1, .., b_{k-1}$ សុទ្ធតែគូ ។ យើងពិនិត្យមេគុណរបស់ $x^{k+s}$ របស់ពហុធា $P(x)$ តាមរយៈការគុណពន្លាតពហុធា $A(x)B(x)$ ; មេគុណនោះស្មើនឹងផលគុណមេគុណរបស់តួ $x$ ដែលពេលគុណគ្នាបានស្វ័យគុណស្មើ $k + s$ ។ យើងទាញបាន មេគុណនោះស្មើនឹង

$$a_0b_{k+s} + a_1b_{k+s-1} + \cdots + a_{s-1}b_{k+1} + a_sb_k + a_{s+1}b_{k-1} + \cdots + a_{s+k}b_0$$

ក្នុងផលបូកនេះ គ្រប់តួទាំងអស់ដែលនៅមុខ $a_sb_k$ សុទ្ធតែគូ ព្រោះ $a_0, a_1, \ldots, a_{s-1}$ សុទ្ធតែគូ ។ គ្រប់តួទាំងអស់ដែលនៅបន្ទាប់ពី $a_sb_k$ សុទ្ធតែគូ ព្រោះ $b_0, b_1, \ldots, b_{k-1}$ សុទ្ធតែគូ ។ តែផលគុណ $a_sb_k$ សេស ព្រោះ $a_s$ និង $b_k$ សុទ្ធតែសេស ។ ដូច្នេះផលបូកនេះជាចំនួនសេស តែនេះផ្ទុយពីលក្ខខណ្ឌដែលមេគុណរបស់ $P(x)$ ទាំងអស់សុទ្ធតែគូ ។ ដូច្នេះការសន្មតថាពហុធា $A(x)$ មានមេគុណសេស ជាការសន្មតមិនត្រឹមត្រូវ ។ ដូច្នេះមេគុណរបស់ $A(x)$ ត្រូវតែជាចំនួនគូទាំងអស់ ។

**946.▲** តាង $x = \frac{p}{q}$ ដែល $p$ បឋមនឹង $q$ មានន័យថាប្រភាគ $p/q$ ត្រូវបានបង្រួមរួចហើយ ។ យើងមាន

$$\begin{aligned}
P(x) &= x^n + a_1x^{n-1} + a_2x^{n-2} + \cdots + a_{n-1}x + a_n \\
&= \frac{p^n}{q^n} + a_1\frac{p^{n-1}}{q^{n-1}} + a_2\frac{p^{n-2}}{q^{n-2}} + \cdots + a_{n-1}\frac{p}{q} + a_n \\
&= \frac{p^n + a_1p^{n-1}q + a_2p^{n-2}q^2 + \cdots + a_{n-1}pq^{n-1} + a_nq^n}{q^n} \\
&= \frac{p^n + q(a_1p^{n-1} + a_2p^{n-2}q + \cdots + a_{n-1}pq^{n-2} + a_nq^{n-1})}{q^n}
\end{aligned}$$

យើងមាន $p^n$ និង $p$ សុទ្ធតែបឋមនឹង $q$ ហើយ $q(a_1p^{n-1}+a_2p^{n-2}q+\cdots+a_{n-1}pq^{n-2}+a_nq^{n-1})$ ចែកដាច់នឹង $q$ ។ ដូច្នេះ $p^n+q(a_1p^{n-1}+a_2p^{n-2}q+\cdots+a_{n-1}pq^{n-2}+a_nq^{n-1})$ ចែកមិនដាច់នឹង $q \Rightarrow$ ចែកមិនដាច់នឹង $q^n$ ។ ដូច្នេះ $P\left(\frac{p}{q}\right)$ មិនអាចជាចំនួនគត់បានទេ ហើយក៏មិនអាចស្មើសូន្យដែរ ។ ដូច្នេះបើ $p/q$ មិនអាចបង្រួមទៅជាចំនួនគត់ទេ វាក៏មិនអាចជាឫសរបស់ពហុធាដែរ ។

**947.▲** តាង $N$ ជាចំនួនគត់មួយ និង $P(N)=M$ ។ ចំពោះគ្រប់ចំនួនគត់ $k$ យើងមាន

$$\begin{aligned}P(N+kM)-P(N)\\&=a_0[(N+kM)^n-N^n]+a_1[(N+kM)^{n-1}-N^{n-1}]+\cdots\\&+a_{n-1}[(N+kM)-N]\end{aligned}$$

ចែកដាច់នឹង $kM$ ,ព្រោះ $(N+kM)^i-N^i$ ចែកដាច់នឹង $[(N+kM)-N=kM]$, ដូច្នេះចែកដាច់នឹង $M$ ដែរ ។ ដូច្នេះចំពោះគ្រប់ចំនួនគត់ $k$, យើងមាន $P(N+kM)$ ចែកដាច់នឹង $M$ ។

ដើម្បីបង្ហាញថា $P(N+kM)$ មិនមែនជាចំនួនបឋម យើងត្រូវបង្ហាញថាក្នុងចំណោមតម្លៃ $P(N+kM),(k=0,1,2,\dots)$ មានតម្លៃខ្លះដែលខុសពី $\pm M$ (ព្រោះបើ $M$ បឋម ហើយ $P(N+kM)=\pm M$ នោះ $P(N+kM)$ បឋមដែរ) ។ យើងមាន $P(x)$ មានដឺក្រេ $n$ មានតម្លៃ $A$ ណាមួយ ចំពោះបណ្ដាតម្លៃ $x$ ខុសៗគ្នាចំនួន $n$ យ៉ាងច្រើន (មានន័យថាសមីការ $P(x)-A=0$ មិនអាចមានឫសច្រើនជាង $n$ ទេ) ។ ដូច្នេះក្នុងចំណោមបណ្ដាតម្លៃចំនួន $2n+1$ ដំបូងនៃ $P(N+kM)$ ដែល $k=0,1,2,\dots,2n$, ត្រូវតែមានតម្លៃយ៉ាងហោចមួយ ដែលខុសពី $M$ ឬ $-M$ ។

**948.▲** ក) ដំបូងយើងបង្ហាញថាគ្រប់ពហុធា $P(x)$ ដឺក្រេ $n$ សុទ្ធតែអាចសរសេរជាផលបូកនៃបណ្ដាពហុធា

$$\begin{aligned}&P_0(x)=1,\\&P_1(x)=x,\\&P_2(x)=\frac{x(x-1)}{1.2},\dots,\\&P_n(x)=\frac{x(x-1)(x-2)\dots(x-n+1)}{1.2.3\dots n}\end{aligned}$$

សន្មតថា

$$
\begin{aligned}
P(x) &\equiv b_nP_n(x) + b_{n-1}P_{n-1}(x) + \cdots + b_1P_1(x) + b_0P_0(x) \\
&\equiv \frac{b_n}{n!}x(x-1)\dots(x-n+1) + \frac{b_{n-1}}{(n-1)!}x(x-1)\dots(x-n+2) + \cdots \\
&\qquad + \frac{b_2}{2!}x(x-1) + b_1x + b_0 \\
&\equiv \frac{b_n}{n!}\left(x^n + c_{n,n-1}x^{n-1} + \cdots + c_{n,1}x + c_{n,0}\right) \\
&\qquad + \frac{b_{n-1}}{(n-1)!}\left(x^{n-1} + c_{n-1,n-2}x^{n-2} + \cdots + c_{n-1,1}x + c_{n-1,0}\right) \\
&\qquad + \cdots + \frac{b_2}{2!}(x^2 - x) + b_1x + b_0
\end{aligned}
$$

(ដែល $c_{i,j}$ ជាមេគុណរបស់ពហុធា $i!\,P_i$ ក្រោយពន្លាតរួច)

ដោយយក $b_n/n!$ មានតម្លៃស្មើមេគុណនៃ $x^n$ របស់ $P(x)$ នោះយើងទាញបាន $P(x)$ និងពន្លាតនៃ $b_nP_n(x) + b_{n-1}P_{n-1}(x) + \cdots + b_1P_1(x) + b_0P_0(x)$ មានមេគុណរបស់ $x^n$ មានតម្លៃដូចគ្នា ។

ដោយយក $b_{n-1}/(n-1)!$ មានតម្លៃស្មើមេគុណនៃ $x^{n-1}$ របស់ $P(x) - b_nP_n(x)$ គឺ $A_1 - \frac{b_n}{n!}c_{n,n-1}$ នោះយើងទាញបាន $P(x)$ និងពន្លាតនៃ $b_nP_n(x) + b_{n-1}P_{n-1}(x) + \cdots + b_1P_1(x) + b_0P_0(x)$ មានមេគុណរបស់ $x^{n-1}$ មានតម្លៃដូចគ្នា ។

ដោយយក $b_{n-2}/(n-2)!$ មានតម្លៃស្មើមេគុណនៃ $x^{n-2}$ របស់ $P(x) - b_nP_n(x) - b_{n-1}P_{n-1}(x)$ គឺ $A_2 - \frac{b_n}{n!}c_{n,n-2} - \frac{b_{n-1}}{(n-1)!}c_{n-1,n-2}$ នោះយើងទាញបាន $P(x)$ និងពន្លាតនៃ $b_nP_n(x) + b_{n-1}P_{n-1}(x) + \cdots + b_1P_1(x) + b_0P_0(x)$ មានមេគុណរបស់ $x^{n-2}$ មានតម្លៃដូចគ្នា ។

យើងកំណត់មេគុណ $b_{n-3}, \dots, b_2, b_1, b_0$ តាមរបៀបដូចគ្នា ។ ដូច្នេះយើងអាចរកបាន $b_0, b_1, b_2, \dots, b_n$ ដែលផ្ទៀងផ្ទាត់ $P(x) \equiv b_nP_n(x) + b_{n-1}P_{n-1}(x) + \cdots + b_1P_1(x) + b_0P_0(x)$ ។

បន្ទាប់មកទៀតយើងនឹងសរសេរពហុធាដែលមានដឺក្រេ $n$ ហើយដែល

$P(0), P(1), \dots, P(n)$ ជាចំនួនគត់ ជារាង

$$P(x) \equiv b_n P_n(x) + b_{n-1} P_{n-1}(x) + \cdots + b_1 P_1(x) + b_0 P_0(x)$$

យើងមាន

$$\begin{aligned} P_1(0) &= P_2(0) = \cdots = P_n(0) \\ &= P_2(1) = P_3(1) = \cdots = P_n(1) = P_3(2) = \cdots = P_n(2) \\ &= \cdots = P_{n-1}(n-2) = P_n(n-2) = P_n(n-1) = 0 \\ P_0(0) &= P_1(1) = P_2(2) = \cdots = P_{n-1}(n-1) = P_n(n) = 1 \end{aligned}$$

$$x = 0 \implies P(0) = b_0 P_0(0) = b_0$$
$$\implies b_0 = P(0)$$
$$x = 1 \implies P(1) = b_0 P_0(1) + b_1 P_1(1) = b_0 P_0(1) + b_1$$
$$\implies b_1 = P(1) - b_0 P_0(1)$$
$$x = 2 \implies P(2) = b_0 P_0(2) + b_1 P_1(2) + b_2 P_2(2),$$
$$\implies b_2 = P(2) - b_0 P_0(2) - b_1 P_1(2)$$
$$\dots \dots$$

ដូច្នេះយើងទាញបាន

$$b_n = P(n) - b_0 P_0(n) - b_1 P_1(n) - \cdots - b_{n-1} P_{n-1}(n)$$

ដែលបណ្ដាមេគុណ $b_0, b_1, b_2, \dots, b_n$ ជាចំនួនគត់ ។

ខ) តាមសំនួរ ក) គ្រប់ពហុធាដែលមានតម្លៃគត់ចំពោះ $x = 0,1,2,..,n$ អាចសរសេរជារាង

$$P(x) \equiv b_n P_n(x) + b_{n-1} P_{n-1}(x) + \cdots + b_1 P_1(x) + b_0 P_0(x)$$

ដែល $b_0, b_1, b_2, .., b_n$ ជាចំនួនគត់ និង ពហុធា $P_0, P_1, \dots, P_n$ មានតម្លៃគត់ចំពោះគ្រប់ $x$ ។ ដូច្នេះ ពហុធា $P(x)$ នេះមានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ។

គ) បើពហុធា $P(x) = a_n x^n + a_{n-1} x^{n-1} + a_{n-2} x^{n-2} + \cdots + a_1 x + a_0$ មានតម្លៃគត់ចំពោះ $x = k, k+1, k+2, \dots, k+n$ នោះពហុធា

$$Q(x) = P(x-k) = a_n (x-k)^n + a_{n-1} (x-k)^{n-1} + \cdots + a_1 (x-k) + a_0$$

មានតម្លៃគត់ចំពោះ $x = 0,1,2,3, \dots, n$ ។ តាមសំនួរ ខ) យើងទាញបាន ពហុធា $Q(x)$ មានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ។ ច្រាសមកវិញ យើងទាញបាន $P(x) = Q(x-k)$ មានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ។

ឃ) សន្មតថាពហុធា $P(x) = a_n x^n + a_{n-1}x^{n-1} + \cdots + a_1 x + a_0$ មានតម្លៃគត់ចំពោះ $x = 0,1,4,9, \dots, n^2$ ។ ដូច្នេះពហុធា $Q(x) = P(x^2) = a_n(x^2)^n + a_{n+1}(x^2)^{n-1} + \cdots + a_1 x^2 + a_0$ មានដឺក្រេ $2n$, មានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ចំនួន $2n + 1$ បន្តបន្ទាប់គ្នា ដែលមាន

$x = -n, -(n-1), -(n-2), \dots, -1,0,1, \dots, n-1, n$ ព្រោះ

$$\begin{aligned}
&Q(0) = P(0),\\
&Q(1) = Q(-1) = P(1),\\
&Q(2) = Q(-2) = P(4),\\
&Q(3) = Q(-3) = P(9),\\
&\dots\\
&Q(n) = Q(-n) = P(n^2)
\end{aligned}$$

សុទ្ធតែជាចំនួនគត់ ។ ដូច្នេះតាមសំនួរខ) យើងទាញបាន $Q(x)$ មានតម្លៃគត់ចំពោះគ្រប់ចំនួនគត់ $x$ ។ យើងទាញបាន $P(k^2) = Q(k)$ , ចំពោះគ្រប់ចំនួនគត់ $k$, ក៏ជាចំនួនគត់ដែរ ។

ជាឧទាហរណ៍ យើងអាចយក $P(x) = \frac{x(x-1)}{12}$ ដែល

$$\begin{aligned}
Q(x) = P(x^2) &= \frac{x^2(x^2-1)}{12} = \frac{x^2(x-1)(x+1)}{12}\\
&= 2\frac{(x+2)(x+1)x(x-1)}{1.2.3.4} - \frac{(x+1)x(x-1)}{1.2.3}
\end{aligned}$$

ក្នុងនេះ $P(x)$ មានតំលៃជាចំនួនសនិទានចំព្រោះគ្រប់ចំនួនគត់ $x$ និង ដោយ $Q(x)$ មានតម្លៃគត់ នោះ $P(x^2)$ មានតម្លៃគត់ មានន័យថា $P(x)$ មានតម្លៃគត់ចំពោះគ្រប់ចំនួនការេ $x$ ។

**949.▲** យើងមាន $x = 1 - \sqrt[3]{2} + \sqrt[3]{4} \Rightarrow x(1 + \sqrt[3]{2}) = 1 - \sqrt[3]{4} + \sqrt[3]{4} + 2 = 3 \Rightarrow x\sqrt[3]{2} = 3 - x \Rightarrow 2x^3 = (3-x)^3 \Rightarrow x^3 - 3x^2 + 9x - 9 = 0$ ។ ដូច្នេះ $1 - \sqrt[3]{2} + \sqrt[3]{4}$ ជាឫសនៃសមីការ

$$f(x) = x^3 - 3x^2 + 9x - 9 = 0$$

បើ $f(x)$ មានឫសជាចំនួនសនិទាន តាងដោយ $\frac{m}{n}$ ។ សន្មតថាទម្រង់ $\frac{m}{n}$ ជាទម្រង់បង្រួមរួច មានន័យថា $m$ បឋមនឹង $n$ ។ ដូច្នេះ $m^3 - 3m^2n + 9mn^2 - 9n^3 = 0$ មិនអាចព្រោះតួទី១ ចែកមិនដាច់នឹង $n$ តែតួផ្សេងទៀតចែកដាច់ ។ ករណី $n = \pm 1$ សមីការគ្មានឫសជាចំនួនគត់ទេ ។ ដូច្នេះសមីការគ្មានឫសជាចំនួនសនិទានទេ ។

សន្មតថាមានពហុធាដឺក្រេទី២ តាងដោយ $g(x)$ ដែលមានឫសដូចខាងលើ ។ ដូច្នេះ $f(x) = g(x)q(x) + r(x)$ ដែល $\text{Deg}(r) < 2$ ហើយ $r(1 - \sqrt[3]{2} + \sqrt[3]{4}) = 0; \Rightarrow$ $r(x) = 0 \Rightarrow f(x) = g(x)q(x)$ ។ $q(x)$ មានដឺក្រេស្មើ1 ដូច្នេះមានឫសជាចំនួនសនិទាន ។ ដូច្នេះ $f(x)$ មានឫសជាចំនួនសនិទាន ផ្ទុយពីការសន្និដ្ឋានខាងលើ ។ ដូច្នេះ $f(x)$ ជាពហុធាដឺក្រេទីបី ជាចម្លើយនៃសំនួរ ។

**950.▲** តាង

$$f(x) = 1 + x + \frac{x^2}{2} + \cdots + \frac{x^n}{n}$$
$$\Rightarrow \; f'(x) = 1 + x + \cdots + x^{n-1}$$

ក) បើ $n$ គូ នោះយើងមាន

$$f'(x) = \frac{x^n - 1}{x - 1}$$

$f'(x) < 0$ ចំពោះគ្រប់ $x \in (-\infty; -1)$

$f'(x) > 0$ ចំពោះគ្រប់ $x \in (-1; +\infty)$

$f'(-1) = 0$

ដូច្នេះ $f(x)$ មានចំនុចអប្បបរមាត្រង់ $x = -1$ ។ យើងមាន

$$f(-1) = 1 - 1 + \frac{1}{2} - \frac{1}{3} + \frac{1}{4} - \frac{1}{5} + \cdots + \frac{1}{n} > 0$$
$$\Rightarrow \; f(x) > 0; \; \forall x \in \mathbb{R}$$

ដូច្នេះសមីការគ្មានឫស ។

ខ) បើ $n$ សេស នោះ $f'(x) > 0; \; \forall x \in \mathbb{R}$ ។ យើងមាន $\lim_{x\to-\infty} f(x) = -\infty$; $\lim_{x\to+\infty} f(x) = +\infty$ ។ ដូច្នេះសមីការមានឫសតែមួយគត់ ។

**951.▲** យើងឃើញថា បើ $P(x)$ ផ្ទៀងផ្ទាត់លក្ខខណ្ឌក្នុងសំនួរ នោះ $\pm P(\pm x)$ ក៏ផ្ទៀងផ្ទាត់លក្ខខណ្ឌដែរ ។ ដោយហេតុនេះ យើងអាចសន្មតថា $a, b \geq 0$ បាន (ឬនិយាយម្យ៉ាងទៀតថា ពិនិត្យតែករណី $a, b \geq 0$ ព្រោះថា ឧទាហរណ៍ បើ $P(x) = x^3 + x^2 + 2x + 1$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ នោះ ពហុធា $Q(x) = -P(x) = -x^3 - x^2 - 2x - 1$ និង $R(x) = -P(-x) = x^3 - x^2 + 2x - 1$ ក៏ផ្ទៀងផ្ទាត់លក្ខខណ្ឌដែរ ។) ។ យើងមាន 4 ករណី

1) $c \geq 0, d \geq 0$ នោះ $|a| + |b| + |c| + |d| = a + b + c + d = P(1) \leq 1 < 7$

2) $c \geq 0, d < 0$ នោះ $|a| + |b| + |c| + |d| = a + b + c - d = P(1) - 2P(0) \leq 3 < 7$

3) $c < 0, d \geq 0$ នោះ

$$\begin{aligned}|a| + |b| + |c| + |d| &= a + b - c + d \\ &= \frac{4}{3}P(1) - \frac{1}{3}P(-1) - \frac{8}{3}P\left(\frac{1}{2}\right) + \frac{8}{3}P\left(-\frac{1}{2}\right) \leq 7\end{aligned}$$

4) $c < 0, d < 0$ នោះ

$$\begin{aligned}|a| + |b| + |c| + |d| &= a + b - c + d \\ &= \frac{5}{3}P(1) - 4\,P\left(\frac{1}{2}\right) + \frac{5}{3}P\left(-\frac{1}{2}\right) \leq 7\end{aligned}$$

**952.▲** a) យើងមាន

$$\begin{aligned}(a+b+c)^3 - a^3 - b^3 - c^3 &= [(a+b+c)^3 - a^3] - (b^3 + c^3) \\ &= [(a+b+c) - a][(a+b+c)^2 + a(a+b+c) + a^2] \\ &\quad - (b+c)(b^2 - bc + c^2) \\ &= (b+c)\{[(a+b+c)^2 - b^2] + a(a+c) + (ab+bc) \\ &\quad + (a^2 - c^2)\} \\ &= (b+c)\{[(a+b+c) - b][(a+b+c) + b] + a(a+c) \\ &\quad + b(a+c) + (a+c)(a-c)\} \\ &= (b+c)(a+c)(a+b+c+b+a+b+a-c) \\ &= 3(b+c)(a+c)(a+b)\end{aligned}$$

b) តាមសំនួរ a) យើងមាន

$$(a+b+c)^3 - a^3 - b^3 - c^3 = 3(b+c)(a+c)(a+b)$$

យើងដឹងថា $b+c, a+c, a+b$ បឋមនឹងគ្នាពីរៗ ។ ដូច្នេះយើងគ្រាន់តែបង្ហាញថា

$$(a+b+c)^{333}-a^{333}-b^{333}-c^{333}$$

ចែកដាច់នឹង $(a+b), (a+c)$ និង $(b+c)$ ជាការគ្រប់គ្រាន់ ។ ជំនួស $a$ ដោយ $x$ យើងទាញបាន

$$(x+b+c)^{333}-x^{333}-b^{333}-c^{333}$$

ឱ្យ $x=-b$ យើងឃើញថាកន្សោមនេះស្មើសូន្យ ដូច្នេះ មានន័យថា $(x+b+c)^{333}-x^{333}-b^{333}-c^{333}$ ចែកដាច់នឹង $x+b$ ។ ជំនួស $x$ ដោយ $a$ ត្រលប់មកវិញ យើងទាញបាន $(a+b+c)^{333}-a^{333}-b^{333}-c^{333}$ ចែកដាច់នឹង $a+b$ ។ ដូចគ្នា យើងទាញបាន កន្សោមនេះ ចែកដាច់នឹង $b+c$ និង $c+a$ ។ ដូច្នេះសំណើពិត ។

**953.▲** យើងមាន

$$\begin{aligned} a^{10}+a^5+1 &= \frac{(a^5)^3-1}{a^5-1}=\frac{a^{15}-1}{a^5-1}=\frac{(a^3)^5-1}{(a-1)(a^4+a^3+a^2+a+1)} \\ &= \frac{(a^3-1)(a^{12}+a^9+a^6+a^3+1)}{(a-1)(a^4+a^3+a^2+a+1)} \\ &= \frac{(a^2+a+1)(a^{12}+a^9+a^6+a^3+1)}{a^4+a^3+a^2+a+1} \end{aligned}$$

យើងមាន

$$\begin{aligned} & a^{12}+a^9+a^6+a^3+1 \\ &= a^8(a^4+a^3+a^2+a+1)-a^8(a^3+a^2+a+1)+a^9 \\ &\quad +a^6+a^3+1 \\ &= a^8(a^4+a^3+a^2+a+1)-a^{11}-a^{10}-a^8+a^6+a^3+1 \\ &= a^8(a^4+a^3+a^2+a+1)-a^7(a^4+a^3+a^2+a+1) \\ &\quad +a^7(a^3+a^2+a+1)-a^{10}-a^8+a^6+a^3+1 \\ &= a^8(a^4+a^3+a^2+a+1)-a^7(a^4+a^3+a^2+a+1)+a^9+a^7+a^6 \\ &\quad +a^3+1 \\ &= a^8(a^4+a^3+a^2+a+1)-a^7(a^4+a^3+a^2+a+1) \\ &\quad +a^5(a^4+a^3+a^2+a+1)-a^5(a^3+a^2+a+1)+a^7 \\ &\quad +a^6+a^3+1 \\ &= a^8(a^4+a^3+a^2+a+1)-a^7(a^4+a^3+a^2+a+1) \\ &\quad +a^5(a^4+a^3+a^2+a+1)-a^8-a^5+a^3+1 \\ &= a^8(a^4+a^3+a^2+a+1)-a^7(a^4+a^3+a^2+a+1) \\ &\quad +a^5(a^4+a^3+a^2+a+1)-a^4(a^4+a^3+a^2+a+1) \\ &\quad +a^4(a^3+a^2+a+1)-a^5+a^3+1 \end{aligned}$$

$$
\begin{aligned}
&= a^8(a^4+a^3+a^2+a+1) - a^7(a^4+a^3+a^2+a+1) \\
&\qquad + a^5(a^4+a^3+a^2+a+1) - a^4(a^4+a^3+a^2+a+1) \\
&\qquad + a^7 + a^6 + a^4 + a^3 + 1 \\
&= a^8(a^4+a^3+a^2+a+1) - a^7(a^4+a^3+a^2+a+1) \\
&\qquad + a^5(a^4+a^3+a^2+a+1) - a^4(a^4+a^3+a^2+a+1) \\
&\qquad + a^3(a^4+a^3+a^2+a+1) - a^5 + 1 \\
&= a^8(a^4+a^3+a^2+a+1) - a^7(a^4+a^3+a^2+a+1) \\
&\qquad + a^5(a^4+a^3+a^2+a+1) - a^4(a^4+a^3+a^2+a+1) \\
&\qquad + a^3(a^4+a^3+a^2+a+1) - a(a^4+a^3+a^2+a+1) \\
&\qquad + a(a^3+a^2+a+1) + 1 \\
&= a^8(a^4+a^3+a^2+a+1) - a^7(a^4+a^3+a^2+a+1) \\
&\qquad + a^5(a^4+a^3+a^2+a+1) - a^4(a^4+a^3+a^2+a+1) \\
&\qquad + a^3(a^4+a^3+a^2+a+1) - a(a^4+a^3+a^2+a+1) \\
&\qquad + (a^4+a^3+a^2+a+1) \\
&= (a^4+a^3+a^2+a+1)(a^8-a^7+a^5-a^4+a^3-a+1)
\end{aligned}
$$

ដូច្នេះ

$$a^{10} + a^5 + 1 = (a^2+a+1)(a^8-a^7+a^5-a^4+a^3-a+1)$$

# ៦

# សមីការអនុគមន៍

**954.** ▲ តាមលក្ខខណ្ឌទី១យើងទាញបាន

$$f\big(f(f(x)+1)\big) = f(1-x)$$

តាមលក្ខខណ្ឌទី២ យើងទាញបាន

$$f(x)+1 = f(1-x), \qquad \forall x \in \mathbb{R} \qquad (1)$$

ជំនួស $t = 1-x$ យើងទាញបាន

$$f(1-t)+1 = f(t)$$

ដូច្នេះ $f(1-x)+1 = f(x), \forall x \in \mathbb{R}$ ជំនួសចូល(1) យើងទាញបានថា គ្មានអនុគមន៍ណាផ្ទៀងផ្ទាត់លក្ខខណ្ឌទេ ។

**955.** ▲ យើងអាចផ្ទៀងផ្ទាត់បានដោយងាយថា អនុគមន៍ $f(x) = x$ ចំពោះគ្រប់ $x \in \mathbb{R}$ ជាចម្លើយមួយ ។ យើងនឹងបង្ហាញថា សមីការនេះ មានចម្លើយតែមួយនេះគត់ ។ សន្មតថា $f$ ជាចម្លើយមួយ ។ សន្មតថា មានចំនួនពិត $a$ មួយដែល $f(a) \neq a$ ។

បើ $f(a) < a$, ដោយ $f$ កើនដាច់ខាត នោះយើងមាន $f\big(f(a)\big) < f(a) \Rightarrow a < f(a)$ ផ្ទុយពីការសន្មត ។

បើ $f(a) > a$ នោះ $f\big(f(a)\big) > f(a) \Rightarrow a > f(a)$ ផ្ទុយពីការសន្មត ។

ដូច្នេះ សមីការមិនអាចមានចម្លើយខុសពី $f(a) = a$ ទេ ។

**956.** ▲ យើងមាន $f(1)+f(2) = 4f(2) \Rightarrow f(2) = \frac{f(1)}{3} = \frac{2}{3}$ (1) ។ ចំពោះ $n \geq 3$ យើងមាន

$$\begin{cases} f(1)+f(2)+\cdots+f(n-1)+f(n) = n^2 f(n) \\ f(1)+f(2)+\cdots+f(n-1) = (n-1)^2 f(n-1) \end{cases}$$

យើងទាញបាន $$f(n)=n^2f(n)-(n-1)^2f(n-1)$$

$$\Rightarrow \quad f(n)=\frac{n-1}{n+1}f(n-1)$$

ដូច្នេះចំពោះ $n\geq 3$ យើងទាញបាន

$$f(n)=\frac{(n-1)(n-2)\dots 2}{(n+1)n\dots 4}f(2)=\frac{6}{n(n+1)}f(2)=\frac{4}{n(n+1)}$$

**957. ▲**- ចំពោះគ្រប់ $x\in\mathbb{R}$ យើងយក $y=0$ នោះលក្ខខណ្ឌទី១ទៅជា

$$f(2x)=2f\left(\sin\frac{\pi}{2}x\right)$$

- ជំនួស $y=2$ និង $x$ ដោយ $-x$ នោះលក្ខខណ្ឌទី១ទៅជា

$$f(-2x)=f\left(\sin\left(-\frac{\pi}{2}x+\pi\right)\right)+f\left(\sin\left(-\frac{\pi}{2}x-\pi\right)\right)=2f\left(\sin\frac{\pi}{2}x\right)=f(2x)$$

ដូច្នេះ $f$ ជាអនុគមន៍គូ ។

- យក $x=0$ និង ចំពោះ $y\in\mathbb{R}$, លក្ខខណ្ឌទី២សរសេរជា

$$f(-y^2)=yf(-y)-yf(y)=yf(y)-yf(y)=0$$

ដូច្នេះ មានន័យថា លើ $\mathbb{R}^-$, $f$ ជាអនុគមន៍ស្មើសូន្យ ។ ដោយ $f$ ជាអនុគមន៍គូ នោះ $f$ សូន្យលើ $\mathbb{R}$ ។

ច្រាសមកវិញ យើងឃើញថា $f\equiv 0$ ផ្ទៀងផ្ទាត់លក្ខខណ្ឌទាំង២ ។ ដូច្នេះវាជាចម្លើយ ។

**958. ▲** យើងនឹងបង្ហាញថា $f(x)=0$ ជាចម្លើយតែមួយគត់ ។ សន្មតថាចំណោទមានចម្លើយ $f(x)\neq 0$ ។ ដូច្នេះមានចំនួន $a\in\mathbb{R}$ ដែល $f(a)=b\neq 0$ ។ យើងយក $y=a$ យើងទាញបាន

$$f(xb)=x^nf(b)$$

តាង $t=xb$ ។ យើងទាញបាន

$$f(t)=\frac{f(b)}{b^n}t^n=Ct^n$$

ដែល $C$ ជាចំនួនថេរ ។ ជំនួស $f(x)=Cx^n$ ចូលក្នុងលក្ខខណ្ឌ យើងទាញបាន $C=0$ ដូច្នេះ $f(x)=0$ ។

**959.** ▲ លក្ខខណ្ឌ $af(x^2+yz)+bf(y^2+zx)+cf(z^2+xy)=0$ (1) មានលក្ខណៈឆ្លុះធៀបនឹង $x,y,z$ ។ ដូច្នេះដោយសារលក្ខណៈនេះ និងដោយសារ $a,b,c$ មិនសូន្យទាំងបីព្រមគ្នា យើងអាចសន្មតថា $a\neq 0$ ។

យក $y=z=0$ យើងបាន $af(x^2)+(b+c)f(0)=0 \;\Rightarrow f(x^2)=-\frac{(b+c)f(0)}{a}$ ចំពោះគ្រប់ $x$ ។

យក $x=0,z=1$ យើងបាន $af(y)+bf(y^2)+cf(0)=0$ ។ ដូច្នេះ

$$f(y)=-\frac{bf(y^2)+cf(0)}{a}=-\frac{-\frac{b+c}{a}f(0)+cf(0)}{a}=\frac{b^2+bc-ac}{a^2}.f(0)$$

ចំពោះគ្រប់ $y\in\mathbb{R}$

ដូច្នេះ $f$ ជាអនុគមន៍ថេរលើ $\mathbb{R}$ ។ តាង $f(x)=K$ ។ ជំនួសចូលក្នុង(1) យើងទាញបាន

$$(a+b+c)K=0$$

បើ $a+b+c\neq 0$ នោះ $K=0$ ដូច្នេះ $f(x)\equiv 0$ ។

បើ $a+b+c=0$ នោះ $K$ ជាចំនួនថេរណាមួយក៏បាន ។

**960.** ▲ យក $y=1$ យើងទាញបាន $f\big(xf(1)\big)=x^p$ ។ $f(1)$ មិនអាចស្មើសូន្យបានទេ ព្រោះបើស្មើសូន្យ នោះ $f(0)=x^p$ ចំពោះគ្រប់ $x$ មិនអាច ។ តាង $c=f(1)$ ដូច្នេះ $f(x)=x^p/c^p$ ។ ដូច្នេះ

$$x^py^q=f\big(xf(y)\big)=\frac{[xf(y)]^p}{c^p}=\frac{x^py^{p^2}}{c^{p+p^2}}$$

ពិតចំពោះគ្រប់ $x,y\in\mathbb{R}$ ។ ដូច្នេះ $c=1$ និង $q=p^2$ ។ បើ $q=p^2$ នោះយើងទាញបាន

$$f\big(xf(y)\big)=x^p[f(y)]^p=x^py^{p^2}=x^py^q$$

ចំពោះគ្រប់ $x,y\in\mathbb{R}^+$ ។

**961.** ▲ ពីលក្ខខណ្ឌទីមួយ ចំពោះគ្រប់ $m\in\mathbb{Z}$ និង $k\in\mathbb{N}$ យើងមាន

$$\begin{cases}f(m+k.19)\geq f(m)+k.19\\ f(m-k.19)\leq f(m)-k.19\end{cases}$$

ពីលក្ខខណ្ឌទីពីរ ចំពោះគ្រប់ $m \in \mathbb{Z}$ និង $k \in \mathbb{N}$ យើងមាន

$$\begin{cases} f(m+k.99) \leq f(m)+k.99 \\ f(m-k.99) \geq f(m)-k.99 \end{cases}$$

សមីការ $1 = 19x + 99y$ មានឫស $x = -26 + 99t; y = 5 - 19t, t \in \mathbb{Z}$ ។ ចំពោះ $t = 0; 1$ យើងទាញបាន $(x; y) = \{(-26; 5); (73; -14)\}$ ។

ចំពោះគ្រប់ $m \in \mathbb{Z}$ យើងមាន

$$\begin{aligned} f(m+1) &= f(m-19.26+99.5) \leq f(m+99.5)-19.26 \\ &\leq f(m)+99.5-19.26 = f(m)+1 \\ f(m+1) &= f(m+73.19-14.99) \geq f(m-14.99)+19.73 \\ &\geq f(m)-14.99+19.73 = f(m)+1 \end{aligned}$$

ដូច្នេះ $f(m+1) = f(m)+1$ ចំពោះ $m \in \mathbb{Z}$ ។ ដូច្នេះ $f(m+n) = f(m)+n$ ចំពោះគ្រប់ $m,n \in \mathbb{Z}$ ។ យក $m = 0$ យើងទាញបាន $f(n) = f(0)+n$ ។ តាង $a = f(0)$ ។ ដូច្នេះ $f(n) = a+n$ ។ ជំនួសចូលក្នុងលក្ខខណ្ឌដើមយើងទាញបាន $f(n) = n + a$ ផ្ទៀងផ្ទាត់ចំពោះគ្រប់ $a \in \mathbb{Z}$ ។

**962.** ▲ ឱ្យ $x = y = 0$ យើងទាញបាន $f(0) = 0$ ។ ឱ្យ $y = 0$ យើងទាញបាន $xf(x) = f^2(x) \implies f(x) = 0$ រឺ $f(x) = x$ ។ យើងឃើញថា $f(x) = 0$ ចំពោះគ្រប់ $x \in \mathbb{R}$ ឬ $f(x) = x$ ចំពោះគ្រប់ $x \in \mathbb{R}$ សុទ្ធតែផ្ទៀងផ្ទាត់លក្ខខណ្ឌដែលអោយ ។ បន្ទាប់មកទៀតយើងបង្ហាញថា បន្សំនៃអនុគមន៍ទាំងពីរមិនផ្ទៀងផ្ទាត់ទេ មានន័យថា អនុគមន៍

$$f(x) = \begin{cases} 0; x \in D_1 \\ x; x \in D_2 \end{cases}$$

ដែល $D_1 \cup D_2 = \mathbb{R}$ មិនផ្ទៀងផ្ទាត់លក្ខខណ្ឌទេ។ ឧបមាផ្ទុយពីនេះថា មាន $x_1 \in D_1; x_2 \in D_2$ ដែល $f(x_1) = 0$ និង $f(x_2) = x_2$ ។ ចំពោះ $x_1 \in D_1$ ដែល $x_1 \neq 0$ គេអាចរកបាន មេគុណ $a$ មួយដែល $ax_1 = x_2$ គឺ $a = x_2/x_1$ ។

ជំនួស$y$ ដោយ $x$ និង $x$ ដោយ $y$ យើងទាញបាន

$$\begin{aligned} xf(x+y)+yf(y-x) &= yf(x+y)+xf(x-y) \\ (x-y)f(x+y) &= (x-y)f(x-y) \end{aligned}$$

ពិតចំពោះគ្រប់ $x,y \in \mathbb{R}$ ។ ដូច្នេះ

$$f(x+y) = f(x-y)$$

តាង $t = x - y; \Rightarrow x = t + y$ ដូច្នេះ $f(t + 2y) = f(t)$ ចំពោះគ្រប់ $t, y \in \mathbb{R}$ ។

យក $y = bt$ ។ ដូច្នេះ $f\big((1 + 2b)t\big) = f(t)$ ។ តាង $K = 1 + 2b$ នោះ

$$f(Kt) = f(t)$$

ចំពោះគ្រប់ $K, t \in \mathbb{R}$ ។

ដូច្នេះ ដោយយក $K = a$; $f(ax_1) = f(x_1) \Rightarrow ax_1 = 0$ អាចតែករណី

$ax_1 = x_2 = 0$ មួយប៉ុណ្ណោះ ។ ដូច្នេះ

$$f(x) = 0 \text{ ចំពោះគ្រប់ } x \in \mathbb{R} \text{ ឬ } f(x) = x \text{ ចំពោះគ្រប់ } x \in \mathbb{R}$$

**963.** ▲ ឱ្យ $x = y$ យើងទាញបាន $f(0) = 0$ ។ ឱ្យ $y = 1$ យើងទាញបាន

$$f(x + 1)(f(x) - 1) = f(x - 1)[f(x) + 1] \qquad (1)$$

ឱ្យ $x = 2$ យើងទាញបាន $f(3)(f(2) - 1) = f(2) + 1$ ។ ដោយ $f(2) \neq 1$ នោះ

$$f(3) = \frac{f(2) + 1}{f(2) - 1} = 1 + \frac{2}{f(2) - 1}$$

ដោយ $f(2), f(3)$ ជាចំនួនគត់ នោះ $f(2) - 1$ ត្រូវតែជាតួចែកនៃ 2 ។ ដូច្នេះ

$f(2) - 1 = 2$ នោះ $f(2) = 3; f(3) = 2$

$f(2) - 1 = 1$ នោះ $f(2) = 2; f(3) = 3$

$f(2) - 1 = -1$ នោះ $f(2) = 0; f(3) = -1$

$f(2) - 1 = -2$ នោះ $f(2) = -1; f(3) = 0$

1) ករណី $f(2) = 3; f(3) = 2$

ក្នុង(១) ជំនួស $x = 3$ យើងទាញបាន $f(4) = 9$ ។ ជំនួស $x = 4$ យើងទាញបាន

$f(5) = \frac{5}{2}$ មិនយក ។

2) ករណី $f(2) = 2; f(3) = 3$ ។ តាមវិចារដោយកំណើន យើងទាញបាន

$$f(n) = n, \qquad \forall n \in \mathbb{Z}$$

3) ករណី $f(2) = 0; f(3) = -1$ ។ តាមវិចារដោយកំណើន យើងទាញបាន

$$f(n) = \begin{cases} 0, & n = 2k \\ 1, & n = 4k + 1 \quad (k \in \mathbb{Z}) \\ -1, & n = 4k - 1 \end{cases}$$

4) ករណី $f(2)=-1; f(3)=0$ ។ តាមវិចារដោយកំណើន យើងទាញបាន

$$f(n)=\begin{cases}0, & n=3k\\ 1, & n=3k+1 \quad (k\in\mathbb{Z})\\ -1, & n=3k-1\end{cases}$$

**964.** ▲ យើងមាន $f(1)=1; f(2)=2$ ។ សន្មតថា $f(k)=k$ ចំពោះ $k=1,2,\dots,n$ ។ យើងនឹងបង្ហាញថា $f(n+1)=n+1$ ។

បើ $n+1=2j$ នោះ $1\le j<n$ ហើយ

$$f(n+1)=f(2j)=f(2)f(j)=2j=n+1$$

បើ $n+1=2j+1$ នោះ $1\le j<n$ ហើយ

$$2j=f(2j)<f(2j+1)<f(2j+2)=f(2)f(j+1)=2j+2$$

ដូច្នេះ $2j<f(2j+1)<2j+2$ ។ ដោយ $f(2j+1)$ ជាចំនួនគត់ នោះ $f(2j+1)=2j+1=n+1$ ។

**965.** ▲ យក $x=y$ យើងទាញបាន $0<2f^2(x^2)\le 2f(x)f(x^3)$ ដូច្នេះ $f(x)$ និង $f(x^3)$ មានសញ្ញាដូចគ្នា ចំពោះគ្រប់ $x\in\mathbb{R}$ ។

យក $x=0$ យើងទាញបាន

$$0<2f^2(0)\le f(0)f(y^3)+f(0)f(y)$$
$$f(0)[2f(0)-f(y)-f(y^3)]\le 0$$

យើងទាញបាន

១) បើ $f(0)<0$ នោះ $0>2f(0)\ge f(y)+f(y^3)$ ហើយដោយ $f(y)$ និង $f(y^3)$ មានសញ្ញាដូចគ្នាចំពោះគ្រប់ $x\in\mathbb{R}$ នោះ $f(y)<0$ ចំពោះគ្រប់ $y\in\mathbb{R}$ ។ ផ្ទុយពីសម្មតិកម្មដែល $f(1999)>0$ ។

២) បើ $f(0)>0$ នោះ $0<2f(0)\le f(y)+f(y^3); \forall y\in\mathbb{R}$ ។ ដូច្នេះ $f(y)>0\,; \forall y\in\mathbb{R}$ ។ ដូច្នេះ $f(2000)>0$ ។

៣) បើ $f(0)=0$ នោះ តាង $f(x)=x^n g(x)$ ដែល $g(0)\ne 0$ ។ ដោយ $f(x)$ និង $f(x^3)$ មានសញ្ញាដូចគ្នា នោះ $x^n g(x)$ និង $(x^n)^3 g(x^3)$ មានសញ្ញាដូចគ្នា ។ ដោយ

$x^n$ និង $(x^n)^3$ មានសញ្ញាដូចគ្នា នោះ $g(x)$ និង $g(x^3)$ ក៏ត្រូវតែមានសញ្ញាដូចគ្នាដែរ ។ យើងមាន

$$0 < 2x^{4n}g^2(x^2) \leq 2x^n g(x)x^{3n}g(x^3) = 2x^{4n}g(x)g(x^3); \forall x \in \mathbb{R}$$

ដូច្នេះ អាច $g(x) > 0;\ \forall x \in \mathbb{R}$ ឬ $g(x) < 0;\ \forall x \in \mathbb{R}$ ។ តែដោយ $f(1999) > 0$ នោះ $g(x) > 0;\ \forall x \in \mathbb{R}$ ។

ដូច្នេះ $f(2000) = 2000^n g(2000) > 0$ ។

**966.** ▲ យក $x = y = 0$ យើងទាញបាន

$$f(0) = f(0)\lfloor f(0)\rfloor$$

1) ករណី $\lfloor f(0)\rfloor = 1 \Rightarrow f(0) \neq 0$ ។ យក $y = 0$ យើងទាញបាន

$$f(0) = f(x)\lfloor f(0)\rfloor \Rightarrow f(x) = f(0) = \text{ថេរ}, \forall x \in \mathbb{R}$$

ជំនួសចូលសមីការដើម យើងទាញបាន

$$f(0) = f(0)\lfloor f(0)\rfloor \Rightarrow \lfloor f(0)\rfloor = 1$$

ដូច្នេះ $f(0) = c$ ដែល $c$ ជាចំនួនថេរផ្ទៀងផ្ទាត់ $1 \leq c < 2$ ។ ដូច្នេះ $f(x) = c; 1 \leq c < 2, \forall x \in \mathbb{R}$ ។

2) ករណី $f(0) = 0$ ។ យក $x = y = 1$ យើងទាញបាន

$$f(1) = f(1)\lfloor f(1)\rfloor \Rightarrow f(1) = 0 \text{ ឬ } \lfloor f(1)\rfloor = 1$$

i) បើ $f(1) = 0$ ។ យក $x = 1$ យើងទាញបាន

$$f(\lfloor 1\rfloor y) = f(1)\lfloor f(y)\rfloor \Rightarrow f(y) = 0; \forall y \in \mathbb{R}$$

ii) បើ $\lfloor f(1)\rfloor = 1$

យក $y = 1$ យើងទាញបាន

$$f(\lfloor x\rfloor) = f(x)\lfloor f(1)\rfloor \Rightarrow f(\lfloor x\rfloor) = f(x) \quad (*)$$

យក $x = 2, y = \frac{1}{2}$ យើងទាញបាន

$$f\left(\lfloor 2\rfloor \frac{1}{2}\right) = f(2)\left\lfloor f\left(\frac{1}{2}\right)\right\rfloor \Rightarrow f(1) = f(2)\left\lfloor f\left(\frac{1}{2}\right)\right\rfloor \quad (**)$$

តាម (*) យើងមាន

$$f\left(\frac{1}{2}\right) = f\left(\left\lfloor\frac{1}{2}\right\rfloor\right) = f(0) = 0 \Rightarrow \left\lfloor f\left(\frac{1}{2}\right)\right\rfloor = 0$$

$(**) \Longrightarrow f(1) = 0$ តែ $\lfloor f(1) \rfloor = 1$ ដូច្នេះ មិនអាច ។

ដូច្នេះ

$$f(x) = \begin{cases} c, & \forall x \in \mathbb{R} \\ 0, & \forall x \in \mathbb{R} \end{cases}$$

ដែល $c$ ជាចំនួនថេរ ផ្ទៀងផ្ទាត់ $1 \le c < 2$ ។

**967.** ▲ (ក) ដើម្បីឱ្យសមីការមានន័យ នោះ ត្រូវតែ $\frac{1}{2} \le f(x) \le 1, \forall x \in \mathbb{R}$ ។ តាង $g(x) = f(x) - \frac{1}{2}$ ។ ដូច្នេះ $\forall x \in \mathbb{R}, 0 \le g(x) \le \frac{1}{2}$ ។ តាមសមីការអនុគមន៍ដែលឱ្យសមមូលនឹង

$$g(x+a) = \sqrt{\frac{1}{4} - \big(g(x)\big)^2}$$
$$g^2(x+a) = \frac{1}{4} - g^2(x)$$
$$g^2(x+2a) = \frac{1}{4} - g^2(x+a) = g^2(x)$$

ដោយ $g(x) \ge 0$ នោះ $g(x+2a) = g(x)$ មានន័យថា $f(x+2a) = f(x)$ ។ ដូច្នេះ $f$ ជាអនុគមន៍ខួបមានខួបស្មើ $2a$ ។

(ខ) ឧទាហរណ៍

$$f(x) = \frac{1}{2}\left|\sin\frac{\pi}{2}x\right| + \frac{1}{2}$$

**968.** ▲ យក $y = 0, x = a + f(0)$ យើងទាញបាន $f(a) = -a + 1 - f(0)$ ចំពោះគ្រប់ចំនួនពិត $a$ ។ ដូច្នេះ $f$ មានរាង $f(x) = -x + k$ ដែល $k$ ជាចំនួនពិតថេរ ។

$$\Longrightarrow \; f\big(x - f(y)\big) = -\big(x - f(y)\big) + k = -x - y + 2k \equiv -x - y + 1$$
$$\Longrightarrow k = \frac{1}{2}$$
$$\Longrightarrow f(x) = -x + \frac{1}{2}$$

**969.** ▲ យើងមាន $f(x)-f(y)=a(x-y)$ ។ យក $y=0$ យើងទាញបាន $f(x)=ax+f(0)$ ។ ដូច្នេះ $f$ មានរាង $f(x)=ax+b$ ដែល $b$ ជាចំនួនថេរ ។ ជំនួសចូលក្នុងលក្ខខណ្ឌដើម យើងទាញបាន

$$\frac{ax+b-(ay+b)}{x-y}=a$$

ពិតជានិច្ច ។ ដូច្នេះ $f(x)=ax+b$ ដែល $a,b\in\mathbb{R}$ ។

**970.** ▲ យក $y=0 \Rightarrow f(x)=x+f(0)$ ។ ដូច្នេះ $f$ មានរាង $f(x)=x+c$ ។ ជំនួសចូលត្រលប់មកវិញ

$$f(x+y)=x+y+c\equiv x+f(y)=x+y+c$$

ពិតជានិច្ច ។ ដូច្នេះ $f(x)=x+c$ ដែល $c\in\mathbb{R}$ ។

**971.** ▲ យក $x=y=0$ យើងទាញបាន $f(0)=2f(0) \Rightarrow f(0)=0$ ។ តាង $a=f(1)$ ។ យើងទាញបាន

$$\begin{aligned}&f(2)=f(1)+f(1)=2a\\&f(3)=f(2)+f(1)=3a\\&\dots\\&f(x+1)=f(x)+a, x\in\mathbb{Q}\end{aligned}$$

ដូច្នេះតាមវិចារដោយកំណើន យើងទាញបាន $f(n)=na$ ចំពោះគ្រប់ចំនួនគត់ $n\geq 0$ ។

យក $y=-x$ យើងទាញបាន $f(0)=f(x)+f(-x)\Rightarrow f(x)=-f(-x)$ ចំពោះគ្រប់ចំនួនសនិទាន $x$ ។ ដូច្នេះ $f$ ជាអនុគមន៍សេស ។ ដូច្នេះយើងទាញបាន $f(n)=an$ ពិតចំពោះគ្រប់ចំនួនគត់ $n$ ។

យក

$$\begin{aligned}&y=x, f(2x)=2f(x);\\&y=2x, f(3x)=f(x)+f(2x)=3f(x);\\&\dots.\end{aligned}$$

ដូច្នេះតាមវិចារដោយកំណើន យើងទាញបាន $f(nx)=nf(x)$ ចំពោះគ្រប់ចំនួនគត់ $n\geq 0$ និងចំនួនសនិទាន $x$ ។ ដូច្នេះចំពោះគ្រប់ចំនួនគត់ $p,q$ ដែល $q>0$ យើងមាន

$$f(p) = ap$$
$$f(p) = f\left(q \times \frac{p}{q}\right) = qf\left(\frac{p}{q}\right)$$
$$\Rightarrow f\left(\frac{p}{q}\right) = a\frac{p}{q}$$

ដូច្នេះ $f(x) = ax$ ចំពោះគ្រប់ $x \in \mathbb{Q}$ ។

**972.** ▲ យក $x = y = 0$ យើងទាញបាន $f(0) = 2f(0) \Rightarrow f(0) = 0$ ។ យក $y = -x$ យើងទាញបាន $f(x) = -f(-x)$ ។

យក $y = x, 2x, \ldots, (n-1)x$ យើងទាញបាន

$$f(2x) = 2f(x)$$
$$f(3x) = f(x) + f(2x) = 3f(x)$$
$$\vdots$$
$$f(nx) = f(x) + f\big((n-1)x\big) = nf(x)$$

យក $x = 1$ នោះ $f(n) = n\,f(1) = an$ ដែល $a = f(1)$ ចំពោះគ្រប់ចំនួនគត់ $n > 0$ ។ ដោយ $f$ ជាអនុគមន៍សេស ដូច្នេះ $f(n) = n\,f(1)$ ចំពោះគ្រប់ចំនួនគត់ $n$ ។

ក្នុងទំនាក់ទំនង $f(nx) = nf(x)$ យក $x = \frac{p}{n}$ យើងទាញបាន

$$f\left(n \times \frac{p}{n}\right) = n\,f\left(\frac{p}{n}\right) \Leftrightarrow f(p) = nf\left(\frac{p}{n}\right) \Rightarrow f\left(\frac{p}{n}\right) = a\frac{p}{n}$$

ដូច្នេះចំពោះគ្រប់ចំនួនសនិទាន $q$ យើងមាន $f(q) = aq$ ។

❶ ករណី $f$ ជាអនុគមន៍ជាប់

យើងដឹងថាចំពោះគ្រប់ចំនួនពិត $x$ គេអាចរកស្វ៊ីតនៃចំនួនសនិទាន $x_n$ មួយ ដែលរួមទៅ $x$ គឺ $\lim_{n\to\infty} x_n = x$ ។ ដោយ $x_n$ ជាចំនួនសនិទាន ដូច្នេះ $f(x_n) = ax_n \Rightarrow \lim_{n\to\infty} f(x_n) = ax$ ។ ដោយ $f$ ជាអនុគមន៍ជាប់ត្រង់ $x$ នោះយើងមាន $\lim_{n\to\infty} f(x_n) = f(x)$ ។ ដូច្នេះ យើងទាញបាន $f(x) = ax$ ចំពោះគ្រប់ $x \in \mathbb{R}$ ។

❷ ករណី $f$ ជាអនុគមន៍ម៉ូណូតូន

ចំពោះគ្រប់ចំនួនពិត $x$ គេអាចរកបានស្វ៊ីតនៃចំនួនសនិទានកើន $(x_n)$ មួយ និង ស្វ៊ីតនៃចំនួនសនិទានចុះ $(x'_n)$ មួយ ដែលរួមទៅរក $x$ គឺ $\lim_{n\to\infty} x_n = x$ និង $\lim_{n\to\infty} x'_n = x$ ។ ដូច្នេះចំពោះគ្រប់ចំនួនគត់ $n \geq 0$ គេមាន $x_n \leq x \leq x'_n$ ។

ករណី $f$ ជាអនុគមន៍កើន គេមាន

$$ax_n = f(x_n) \leq f(x) \leq f(x'_n) = ax'_n$$

ឱ្យ $n \to \infty$ យើងទាញបាន $ax \leq f(x) \leq ax$ ដូច្នេះ $f(x) = ax$ ។

ដូចគ្នាចំពោះករណី $f$ ជាអនុគមន៍ចុះ។

ច្រាសមកវិញ យើងឃើញថា $f(x) = ax$ ពិតជាផ្ទៀងផ្ទាត់ $f(x+y) = f(x) + f(y)$ ចំពោះគ្រប់ចំនួនពិត $a$ ។

**973.** ▲ បើ $f(x)$ ជាចម្លើយនៃសមីការ នោះចំពោះគ្រប់ចំនួនពិត $k$ អនុគមន៍ $f(x) + k$ ក៏ជាចម្លើយដែរ។ ដូច្នេះយើងអាចសន្មតជាបឋមថា $f(0) = 0$ ។

ចំពោះ $y = 0$ យើងទាញបាន $f\left(\frac{x}{2}\right) = \frac{1}{2}f(x)$ ចំពោះគ្រប់ចំនួនពិត $x$ ។ ដោយប្រើទំនាក់ទំនងនេះ យើងទាញបាន

$$\frac{f(x)+f(y)}{2} = f\left(\frac{x+y}{2}\right) = \frac{1}{2}f(x+y)$$
$$\Rightarrow \ f(x) + f(y) = f(x+y) \qquad (*)$$

យក $y = -x$ យើងទាញបាន $f(x) + f(-x) = f(0) = 0 \Rightarrow f(x) = -f(-x)$ ។ ដូច្នេះ $f$ ជាអនុគមន៍សេស។

តាម (*) យើងទាញបាន $f(nx) = nf(x)$ ចំពោះគ្រប់ចំនួនគត់ $n$ ។ យក $x = 1$ យើងទាញបាន $f(n) = nf(1)$ ។ យក $x = \frac{p}{n}$ ដែល $p$ ជាចំនួនគត់ យើងទាញបាន

$$f\left(n\frac{p}{n}\right) = n\,f\left(\frac{p}{n}\right) \Leftrightarrow f(p) = n\,f\left(\frac{p}{n}\right) \Leftrightarrow p\,f(1) = n\,f\left(\frac{p}{n}\right) \Rightarrow f\left(\frac{p}{n}\right) = \frac{p}{n}f(1)$$

ដូច្នេះចំពោះគ្រប់ចំនួនសនិទាន $q$ យើងមាន $f(q) = aq$ ដែល $a = f(1)$ ។

ចំពោះគ្រប់ចំនួនពិត $x$ គេអាចរកបានស្វីតសនិទាន $x_n$ មួយ ដែល $\lim_{n\to\infty} x_n = x$ ។ យើងមាន $f(x_n) = ax_n$ ព្រោះ $x_n$ ជាចំនួនសនិទាន ដូច្នេះ $\lim_{n\to\infty} f(x_n) = \lim_{n\to\infty} ax_n = ax$ ។ ដោយ $\lim_{n\to\infty} x_n = x$ និង $f$ ជាអនុគមន៍ជាប់ នោះ $\lim_{n\to\infty} f(x_n) = f(x)$ ។ ដូច្នេះ $f(x) = ax$ ចំពោះគ្រប់ $x \in \mathbb{R}$ ។ ដូច្នេះជាទូទៅ ចម្លើយរបស់សមីការ Jensen កំណត់ដោយ $f(x) = ax + k$ ដែល $k$ ជាថេរចំនួនពិតណាមួយ ។

**974.** ▲ តាង $a, b$ ជាចំនួនសនិទានពីរ និង $n > 0$ ជាចំនួនគត់មួយ ។ ចំពោះ $i \in \{0,1,\dots,n\}$ តាង

$$a_i = a + i\frac{b-a}{n}$$

យើងឃើញថា $a_i$ សុទ្ធតែជាចំនួនសនិទាន និង $a_{i+1} - a_i = \frac{b-a}{n}$ ចំពោះ $i \in \{0,1,\dots,n-1\}$ ។ យើងមាន

$$|f(a) - f(b)| = \left|\sum_{i=0}^{n-1} f(a_{i+1}) - f(a_i)\right|$$

តាមវិសមភាពត្រីកោណ ($|a+b| \le |a| + |b|$) យើងមាន

$$\left|\sum_{i=0}^{n-1} f(a_{i+1}) - f(a_i)\right| \le \sum_{i=0}^{n-1} |f(a_{i+1}) - f(a_i)|$$

តាមសម្មតិកម្ម យើងមាន

$$\sum_{i=0}^{n-1} |f(a_{i+1}) - f(a_i)| \le 7\sum_{i=0}^{n-1} (a_{i+1} - a_i)^2 = \frac{7(b-a)^2}{n}$$

ដូច្នេះ

$$|f(a) - f(b)| \le \frac{7(b-a)^2}{n}$$

ឱ្យ $n$ ខិតទៅរកអនន្ត យើងទាញបាន $|f(a) - f(b)| \le 0 \Rightarrow f(a) = f(b)$ ។ ដូច្នេះ $f$ ជាអនុគមន៍ថេរលើ $\mathbb{Q}$ ។

គាង់ $c \in \mathbb{R}$ ដែល $f(r) = c$ ចំពោះគ្រប់ចំនួនសនិទាន $r$ ។ ចំពោះចំនួនពិត $x$ ណាមួយ គាង់ $r_n = \frac{\lfloor 10^n x \rfloor + 1}{10^n}$ ។ ដោយ $r_n$ ជាចំនួនសនិទាន ដូច្នេះ $f(r_n) = c$ ។ យើងមាន

$$10^n x - 1 < \lfloor 10^n x \rfloor \le 10^n x \implies x < \frac{\lfloor 10^n x \rfloor + 1}{10^n} \le x + \frac{1}{10^n} \implies -\frac{1}{10^n} \le x - r_n < 0$$
$$\implies |x - r_n| \le 1/10^n$$

តាមសម្មតិកម្ម យើងមាន

$$|f(x) - c| = |f(x) - f(r_n)| \le 7\,(x - r_n)^2 \le \frac{7}{10^{2n}}$$

ឱ្យ $n$ ខិតទៅរក $+\infty$ យើងទាញបាន $|f(x) - c| \le 0 \implies f(x) = f(c)$ ។ ដូច្នេះ $f$ ជាអនុគមន៍ថេរលើ $\mathbb{R}$ ។

ប្រាសមកវិញ យើងផ្ទៀងផ្ទាត់ឃើញថា អនុគមន៍ថេរពិតជាផ្ទៀងផ្ទាត់សម្មតិកម្ម ។

**975.** ▲ យក $a = x - y$ តាម i) យើងទាញបាន

$$f(a + 2y) + f(a) = 2f(a + y)f(y)$$

យើងទប់ $a$ រួចឱ្យ $y$ ខិតទៅរក $\infty$ និង តាមលក្ខខណ្ឌ ii), យើងទាញបាន $f(a) = 0$ ។ ដូច្នេះ $f$ ជាអនុគមន៍សូន្យ ។

## ផ្ទៀងផ្ទាត់

ប្រាសមកវិញ យើងឃើញថា $f(x) \equiv 0$ ពិតជាផ្ទៀងផ្ទាត់សម្មតិកម្ម ។

**976.** ▲ យក

$n = 1 : f(2) - f(1) = f(1) - f(0)$

$n = 2 : f(3) - f(2) = f(2) - f(1)$

$n = 3 : f(4) - f(3) = f(3) - f(2)$

…

$n = k - 1 : f(k) - f(k - 1) = f(k - 1) - f(k - 2)$

បូកសមភាពទាំងនេះបញ្ចូលគ្នា យើងទាញបាន

$$f(k) = f(k-1) + f(1) - f(0)$$

យក

$$k = 1 : f(1) = f(0) + [f(1) - f(0)]$$
$$k = 2 : f(2) = f(1) + [f(1) - f(0)]$$
$$\dots$$
$$k = n : f(n) = f(n-1) + [f(1) - f(0)]$$

បូកសមភាពទាំងនេះបញ្ចូលគ្នា យើងទាញបាន

$$f(n) = [f(1) - f(0)]n + f(0)$$

ដូច្នេះ $f$ ជាអនុគមន៍អាភីន ។

ច្រាសមកវិញ បើ $f$ ជាអនុគមន៍អាភីន នោះ $f(n) = an + b$ ។ យើងទាញបាន

$$f(n+1) - f(n) = a(n+1) + b - [an + b] = a$$
$$f(n) - f(n-1) = a(n) + b - [a(n-1) + b] = a$$

ដូច្នេះ $f(n+1) - f(n) = f(n) - f(n-1)$ ពិត ។

**977.** ▲ យើងនឹងបង្ហាញថា $f$ ជាអនុវត្តន៍ប្រកាន់ មានន័យថាចំពោះគ្រប់ $m \neq n$ យើងមាន $f(m) \neq f(n)$ ។ សន្មតផ្ទុយថា មាន $m \neq n$ ដែល $f(m) = f(n)$ ។ ដូច្នេះ

$$f\big(f(n) + f(m)\big) = n + m$$
$$f\big(f(n) + f(m)\big) = f\big(f(n) + f(n)\big) = n + n$$
$$\Rightarrow n = m$$

មិនពិត ។

ចំពោះគ្រប់ចំនួនគត់ $n \geq 1$ យើងមាន $f\big(f(n) + f(n)\big) = 2n$ និង $f\big(f(n+1) + f(n-1)\big) = (n+1) + (n-1) = 2n$ ដែរ ។ ដោយ $f$ ជាអនុវត្តន៍ប្រកាន់ ដូច្នេះ $f(n) + f(n) = f(n+1) + f(n-1)$ ។ យើងទាញបាន

$$f(n+1) - f(n) = f(n) - f(n-1)$$

$n = 2 : f(3) - f(2) = f(2) - f(1)$

$n = 3 : f(4) - f(3) = f(3) - f(2)$

...

$n = k-1 : f(k) - f(k-1) = f(k-1) - f(k-2)$

បូកសមភាពទាំងនេះបញ្ចូលគ្នា យើងទាញបាន

$$f(k) = f(k-1) - f(1) + f(2)$$

$k = 2 : f(2) = f(1) + [f(2) - f(1)]$

$k = 3 : f(3) = f(2) + [f(2) - f(1)]$

...

$k = n : f(n) = f(n-1) + [f(2) - f(1)]$

បូកសមភាពទាំងនេះបញ្ចូលគ្នា យើងទាញបាន

$$\begin{aligned} f(n) = f(1) + (n-1)[f(2) - f(1)] &= [f(2) - f(1)]n + 2f(1) - f(2) \\ &= an + b \end{aligned}$$

ដែល $a = f(2) - f(1); b = 2f(1) - f(2)$ ។

ដូច្នេះ

$$\begin{aligned} & f\big(f(n) + f(n)\big) \equiv 2n \\ \Leftrightarrow\ & a[2f(n)] + b \equiv 2n \\ \Leftrightarrow\ & 2a[an + b] + b \equiv 2n \\ \Leftrightarrow\ & 2a^2n + 2ab + b \equiv 2n \end{aligned}$$

ដែលពិតចំពោះគ្រប់ $n$ ។ ដូច្នេះ

$$\begin{cases} a^2 = 1 \\ 2ab + b = 0 \end{cases} \Rightarrow a = \pm 1, b = 0$$

យើងមិនយកករណី $a = -1$ ទេ ព្រោះ $f(n) = -n$ នោះ $f(n) \notin \mathbb{N}^*$ ។ ដូច្នេះ $f(n) = n$ ។

**978.** ▲ យើងមាន $f$ មានតម្លៃជាចំនួនគត់ធម្មជាតិ និងកើនដាច់ខាត ដូច្នេះ $f(0) < f(1) < f(2) = 2 \Rightarrow f(0) = 0$ និង $f(1) = 1$ ។

តាង $f(3) = 3 + k$ ដែល $k \in \mathbb{N}$ ។ ដូច្នេះ $f(6) = f(3)f(2) = 6 + 2k$; ដោយ $f(5) < f(6) = 6 + 2k \Rightarrow f(5) \leq 5 + 2k$ ។ បន្ទាប់មកទៀត $f(10) = f(2)f(5) \leq 10 + 4k$ ។ ដូច្នេះ $f(9) \leq 9 + 4k$ និង $f(18) \leq 18 + 8k \Rightarrow f(17) \leq 17 + 8k; f(16) \leq 16 + 8k; f(15) \leq 15 + 8k$ ។ ដោយ $f(3) = 3 +$

$k \Rightarrow f(4) \geq 4 + k; f(5) \geq 5 + k$ ។ ដូច្នេះ $f(15) = f(3)f(5) \geq (3 + k)(5 + k) \Rightarrow (3 + k)(5 + k) \leq 15 + 8k \Rightarrow k = 0$ ។ ដូច្នេះ $f(3) = 3$ ។

យើងនឹងបង្ហាញតាមវិចារដោយកំណើនថា ចំពោះគ្រប់ $n \in \mathbb{N}^* : f(2^n + 1) = 2^n + 1$ ។

ចំពោះ $n = 1$ សំណើនេះពិត ព្រោះ $f(3) = 3$ ។ សន្មតថាពិតដល់ $n$ មានន័យថា $f(2^n + 1) = 2^n + 1$ ពិត ។ យើងមាន

$$f(2^{n+1} + 2) = f(2)f(2^n + 1) = 2^n + 2$$

ដោយ $f$ ជាអនុគមន៍កើនដាច់ខាត ដូច្នេះ $2^n + 1 < f(2^n + 2) < f(2^n + 3) < \cdots < f(2^n + 2^n) < f(2^n + 2^n + 1) < f(2^n + 2^n + 2) = 2^{n+1} + 2$ សុទ្ធតែខុសគ្នាពីរៗ ហើយមានតម្លៃក្នុងចំណោម $\{2^n + 2, 2^n + 3, \ldots, 2^{n+1} + 2\}$ ។ ដូច្នេះយើងទាញបាន $f(2^n + i) = 2^n + i$ ចំពោះគ្រប់ $i \in \{2,3, \ldots, 2^n + 2\}$ មានន័យថា $f(2^{n+1} + 1) = 2^{n+1} + 1$ ។ ដូច្នេះសំណើពិត ។

ដោយ $f$ ជាអនុគមន៍កើនដាច់ខាត ដូច្នេះ $f(1) = 1 < f(2) < f(3) < \cdots < f(2^n + 1) = 2^n + 1$ ដែលតម្លៃរបស់ $f$ ទាំងនេះសុទ្ធតែខុសគ្នាពីរៗ (មានចំនួនទាំងអស់ $2^n + 1$) ហើយឋិតនៅក្នុងចំណោម $\{1,2,3, \ldots, 2^n + 1\}$(មានចំនួនធាតុទាំងអស់ $2^n + 1$) ។ ដូច្នេះ $f(n) = n$ ចំពោះគ្រប់ $n \in \mathbb{N}$ ។

**979.** ▲ ក្នុងសំនួរនេះ ដំបូងយើងសន្មតផ្ទុយពីសំណើថា មានចំនួនគត់ $a$ មួយ ដែល $f(a) \neq g(a)$ ។

ដូច្នេះសំណុំ $A = \{n / f(n) \neq g(n)\}$ ជាសំណុំរងមិនទទេនៃ $\mathbb{N}$ ហើយដូច្នេះសំណុំ $B = \{g(n), n \in A\}$ ក៏ជាសំណុំរងមិនទទេនៃ $\mathbb{N}$ ដែរ ។ ដូច្នេះសំណុំ $B$ នេះត្រូវតែមានធាតុតូចបំផុត, តាងវាដោយ $g(b)$ , ដែល $b \in A$ ។ ដូច្នេះ $g(b) < f(b)$ ។

ដោយ $f$ ជាអនុវត្តន៍ពេញ នោះយើងអាចរកបានចំនួនគត់ $c$ មួយ ដែល $f(c) = g(b) < f(b)$ ។ ដូច្នេះ $c \neq b$ ។ ដោយ $g$ ជាអនុវត្តន៍ប្រកាន់ ដូច្នេះ

$g(c) \neq g(b) = f(c) \Rightarrow c \in A$ ដែរ ។ ដូច្នេះ $g(c) < f(c) = g(b)$ : តែនេះផ្ទុយពីការសន្មតដែលថា $g(b)$ តូចបំផុត ។

ដូច្នេះមានតែចំពោះគ្រប់ចំនួនគត់ $a$, យើងមាន $f(a) = g(a)$ ។

**980.** ▲ ដោយ $f$ ជាអនុវត្តន៍ប្រកាន់ ដូច្នេះ មាន $n \in \mathbb{N}$ ដែល $f(0) < f(n)$ (ព្រោះបើមិនអ៊ីចឹង តើយើងអាចបាន $k \in \mathbb{N}$ ដែល $f(k) = f(0) + 1$ ពីណាមក? ព្រោះថាបើ $f$ អនុវត្តន៍ប្រកាន់ នោះត្រូវតែមាន $k$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌនេះ) ។

ដូច្នេះសំណុំ $E = \{n \in \mathbb{N} / f(0) < f(n)\}$ ជាសំណុំរងមិនទទេនៃ $\mathbb{N}^*$ ។ ដូច្នេះ $E$ ត្រូវមានធាតុតូចបំផុត តាងដោយ $b$ ។ យើងទាញបាន $0 < b$ និង $f(0) < f(b)$ ។

តាង $n = 2f(b) - f(0)$ ។ ដោយ $f$ ជាអនុវត្តន៍មួយទល់មួយ នោះមានចំនួនគត់ $c$ មួយ ដែល $f(c) = n$ ។ ដូច្នេះ $f(c) = 2f(b) - f(0) \Rightarrow f(c) + f(0) = 2f(b)$ ។ ដូច្នេះ $f(c) = f(b) + \big(f(b) - f(0)\big) > f(b) > f(0) \Rightarrow c \in E$ ។ ដោយ $b$ តូចបំផុត ដូច្នេះ $b < c$ ។

ដោយ យក $a = 0$ យើងទាញបាន $a < b < c$ និង $f(a) + f(c) = 2f(b)$ ។

**981.** ▲ យើងឃើញថា $f$ ជាអនុគមន៍គូ ព្រោះ $f(x) = f(-x) = f\left(x^2 + \frac{1}{4}\right)$ ។

តាង $g(x) = x^2 + \frac{1}{4}$ ។ យើងមាន

$$\forall a \in \left[-\frac{1}{2}, \frac{1}{2}\right], a \leq g(a) \leq \frac{1}{2} \qquad (1)$$

$$\forall a \geq \frac{1}{2}, g(a) \geq a \geq \frac{1}{2} \qquad (2)$$

ចំពោះ $x \in \left[-\frac{1}{2}, \frac{1}{2}\right]$ យើងពិនិត្យស្វ៊ីត $(x_n)$ មួយកំណត់ដោយ $x_0 = x$ និង $x_{n+1} = g(x_n)$ ចំពោះគ្រប់ $n \in \mathbb{N}$ ។ យើងមាន $f(x) = f\left(x^2 + \frac{1}{4}\right) \Rightarrow f(x_{n+1}) = f(x_n)$ ចំពោះគ្រប់ $n \in \mathbb{N}$ ។ ដូច្នេះ ស្វ៊ីត $\big(f(x_n)\big)$ ជាស្វ៊ីតថេរ ។

ម្យ៉ាងវិញទៀត តាម (1) យើងមាន $(x_n)$ ជាស្វ៊ីតកើនហើយទាល់ត្រឹម $1/2$ ។ ដូច្នេះស្វ៊ីតនេះរួមទៅរកលីមីត $L$ មួយ : $\lim_{n\to\infty} x_n = L$ និង $\lim_{n\to\infty} x_{n+1} = L$ ។ ដោយ $g$ ជា

អនុគមន៍ជាប់ នោះ អនុគមន៍ $g$ ក៏ជាប់ត្រង់ $x = L$ ដែរ ។ ដូច្នេះ $\lim_{n\to\infty} g(x_n) = g(L) = \lim_{n\to\infty} x_{n+1} = L \Rightarrow g(L) = L \Rightarrow L = 1/2$ ។ ដោយ $f$ ជាអនុគមន៍ជាប់ ដូច្នេះវាជាប់ត្រង់ $x = 1/2$ ។ ដូច្នេះ $\lim_{n\to\infty} f(x_n) = f(1/2)$ ។ ដោយ $\left(f(x_n)\right)$ ជាស្វ៊ីតថេរ ដូច្នេះ $f(x) = f(x_0) = f(1/2)$ ។ យើងទាញបាន $f$ ជាអនុគមន៍ថេរលើ $[-1/2, 1/2]$ ។

ស្រាយបញ្ជាក់ដូចគ្នា យើងទាញបាន $f(x) = f(1/2)$ ថេរលើ $[1/2, +\infty)$ ។ យើងទាញបាន $f(x) = f(1/2)$ ចំពោះគ្រប់ $x \in [-1/2, +\infty)$ ។

ដោយសារ $f$ ជាអនុគមន៍គូ ដូច្នេះ $f$ ថេរលើ $\mathbb{R}$ ។

ច្រាសមកវិញ យើងឃើញថា ចំពោះគ្រប់អនុគមន៍ថេរ លក្ខខណ្ឌ $f(x) = f(x^2 + 1/4)$ ផ្ទៀងផ្ទាត់ជានិច្ច ។

**982.** ▲ តាង $g(x) = x^3 + x$ ។ អនុគមន៍ $g$ ជាប់និងកើនដាច់ខាតលើ $\mathbb{R}$ និង $g(\mathbb{R}) = \mathbb{R}$ ។ ដូច្នេះ $g$ ជាអនុវត្តន៍មួយទល់មួយពី $\mathbb{R}$ ទៅ $\mathbb{R}$ ។ តាង ចម្រាសរបស់វាដោយ $g^{-1}$ ។

យើងមាន

$$f\left(g(x)\right) \le x \le g\left(f(x)\right)$$

បើ $X = g(x) \Rightarrow x = g^{-1}(X)$ ។ ដូច្នេះ

$$f\left(g(x)\right) \le x \Rightarrow f(X) \le g^{-1}(X), \forall X \in \mathbb{R} \quad (*)$$

យើងអាចជំនួស $X$ ក្នុង (*) ដោយ $x$ បានព្រោះ វិសមភាព (*) ពិតចំពោះគ្រប់ $X \in \mathbb{R}$ ។

ដូច្នេះ $f(x) \le g^{-1}(x)$ ។

បើ $X = g^{-1}(x) \Rightarrow x = g(X) = g\left(g^{-1}(x)\right)$ ។ ដូច្នេះ

$$x \le g\left(f(x)\right) \Rightarrow g\left(g^{-1}(x)\right) \le g\left(f(x)\right)$$

ដោយ $g$ ជាអនុគមន៍កើនដាច់ខាត នោះ $g^{-1}(x) \le f(x)$ ។

ដូច្នេះយើងទាញបាន $g^{-1}(x) \le f(x) \le g^{-1}(x) \Rightarrow f(x) = g^{-1}(x)$ ។

ច្រាសមកវិញ បើ $f(x) = g^{-1}(x)$ នោះ $f(x^3 + x) = g^{-1}(x^3 + x)$ ។

$g(x) = x^3 + x = X \Rightarrow x = g^{-1}(X) = g^{-1}(x^3 + x)$ ។ ដូច្នេះ $f(x^3 + x) = x$ ។ ដូច្នេះវិសមភាពទីមួយពិត ។

យើងមាន $g(f(x)) = [f(x)]^3 + f(x)$ និង $g(f(x)) = g(g^{-1}(x)) = x \Rightarrow x = [f(x)]^3 + f(x)$ ដូច្នេះវិសមភាពទីពីរពិត ។

ដូច្នេះ $f(x) \equiv g^{-1}(x)$ ជាអនុគមន៍ដែលចង់បាន ដែលក្នុងនោះ $g(x) \equiv x^3 + x$ ។

**983.** ▲ បើ $f \equiv 0$ នោះលក្ខខណ្ឌផ្ទៀងផ្ទាត់ ។ ដូច្នេះសំណើពិត ។

យើងនឹងបង្ហាញថា បើ $f \not\equiv 0$ នោះគ្មាន $x$ ដែល $f(x) = 0$ ទេ ។ តាង $f$ ជាអនុគមន៍ដែលមិនមែនជាអនុគមន៍ដែលស្មើសូន្យចំពោះគ្រប់ $x \in \mathbb{R}$ ។

ចំពោះ $x = y$ យើងទាញបាន

$$f(2x)f(0) = [f(x)]^2, \forall x \in \mathbb{R} \quad (*)$$

បើ $f(0) = 0$ នោះ (*) $\Rightarrow f(x) \equiv 0$ ផ្ទុយពីការសន្មត ។ ដូច្នេះ $f(0) \neq 0$ ។ យើងសន្មតផ្ទុយពីការពិតថា មាន $a \in \mathbb{R}$ មួយដែល $f(a) = 0$ ។

យក $x = y = \frac{a}{2}$ យើងទាញបាន

$$0 = f(a)f(0) = \left[f\left(\frac{a}{2}\right)\right]^2 \Rightarrow f\left(\frac{a}{2}\right) = 0$$

យក $x = y = \frac{a}{2^2}$ យើងទាញបាន

$$0 = f\left(\frac{a}{2}\right)f(0) = \left[f\left(\frac{a}{2^2}\right)\right]^2 \Rightarrow f\left(\frac{a}{2^2}\right) = 0$$

ដូច្នេះតាមវិចារដោយកំណើន យើងទាញបាន $f\left(\frac{a}{2^n}\right) = 0$ ចំពោះគ្រប់ចំនួនគត់ $n \geq 0$ ។

យើងមាន $\lim_{n\to\infty} \frac{a}{2^n} = 0$ និង $f$ ជាអនុគមន៍ជាប់ ដូច្នេះ $f(0) = \lim_{n\to\infty} f\left(\frac{a}{2^n}\right) = 0$ ។ តែនេះផ្ទុយពីការពិតដែល $f(0) \neq 0$ ។ ដូច្នេះមិនអាចមាន $a \in \mathbb{R}$ ដែល $f(a) = 0$ ទេ ។ ដូច្នេះសំណើពិត ។

**984.** ▲ យើងដឹងថា មានអនុគមន៍ $f$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ ឧទាហរណ៍ $f = k$ ថេរ ដែល $k \in [-1,1]$ ។

តាង $g(x) = f(x + 1/6) - f(x)$ ។ តាមសម្មតិកម្ម ចំពោះគ្រប់ចំនួនពិត $x$ គេមាន

$$g\left(x + \frac{1}{7}\right) = f\left(x + \frac{13}{42}\right) - f\left(x + \frac{1}{7}\right) = f\left(x + \frac{1}{6}\right) - f(x) = g(x)$$

ដូច្នេះ អនុគមន៍ $g$ មានខួបស្មើ $1/7$ ។ យើងទាញបានថា $1$ ក៏ជាខួបរបស់ $g$ ដែរ ព្រោះ $1 = 7 \times \frac{1}{7}$ ។ ដូច្នេះ ចំពោះគ្រប់ចំនួនពិត $x$ យើងមាន $g(x + 1) = g(x)$ មានន័យថា

$$f\left(x + 1 + \frac{1}{6}\right) - f(x + 1) = f\left(x + \frac{1}{6}\right) - f(x)$$

$$\Leftrightarrow f\left(x + 1 + \frac{1}{6}\right) - f\left(x + \frac{1}{6}\right) = f(x + 1) - f(x)$$

យើងទាញបានថា អនុគមន៍ $h(x) = f(x + 1) - f(x)$ មានខួបស្មើ $1/6$ ។ ដូច្នេះ $h(x)$ ក៏មានខួបស្មើ $1$ ដែរ ។ យើងទាញបាន $h(x + 1) = h(x)$

$$\Longrightarrow\ f(x + 2) - f(x + 1) = f(x + 1) - f(x)$$

យក $x = a \in \mathbb{R}$ ហើយយើងទុក $a$ មិនឱ្យប្រែប្រួល យើងទាញបាន

$$f(a + 1) - f(a) = f(a + 2) - f(a + 1) = \cdots = f(a + n) - f(a + n - 1)$$

ដែល $n$ ជាចំនួនគត់វិជ្ជមាន ។ យើងឃើញថា $f(a + n) - f(a + n - 1)$ មិនអាស្រ័យនឹង $n$ ទេ ។ តាង $c = f(a + n) - f(a + n - 1)$ ជាចំនួនថេរមួយ ។ យើងទាញបាន

$$\begin{aligned}
&f(a + 1) - f(a) = c\\
&f(a + 2) - f(a + 1) = c\\
&f(a + 3) - f(a + 2) = c\\
&\dots\\
&f(a + n) - f(a + n - 1) = c
\end{aligned}$$

បូកអង្គទាំងពីរនៃសមភាពខាងលើចូលគ្នា យើងទាញបាន $f(a + n) - f(a) = cn \Longrightarrow f(a + n) = cn + f(a)$ ។ យើងដឹងថា $f$ ជាអនុគមន៍ទាល់ គឺ $-1 \leq f \leq 1$ ។ បើយើងឱ្យ $n \to +\infty$ នោះ $cn \to \infty$ បើ $c \neq 0$ ។ ករណីនេះ $f$ មិនមែនជាអនុគមន៍ទាល់ទេ ។ ដូច្នេះមានតែ $c = 0$ ។ យើងទាញបាន $f(a + 1) - f(a) = 0 \Rightarrow f(a + 1) =$

$f(a)$ ចំពោះគ្រប់ចំនួនពិត $a$ ។ ដូច្នេះមានន័យថា $f$ ជាអនុគមន៍ខួប ដែលមានខួបស្មើ 1 ។

**985.** ▲ តាម (ii) យើងទាញបាន

$$f(2^2) = [f(2)]^2, f(2^3) = f(2^2)f(2) = [f(2)]^2 f(2) = [f(2)]^3, \dots, f(2^n) = [f(2)]^n$$

ដូចគ្នា $f(3^n) = [f(3)]^n; f(5^n) = [f(5)]^n$ ។

- យើងមាន $2^4 = 4^2$ ដូច្នេះតាម (iii) យើងទាញបាន $f(2) = 4$ ឬ $f(4) = 2$ ។

  តាម (ii) យើងមាន $f(2)f(2) = f(4) \Rightarrow [f(2)]^2 = f(4)$ ។

  បើ $f(4) = 2 \Rightarrow f(2) = \sqrt{2} \notin \mathbb{N}$ ដូច្នេះ $f(4) \neq 2$ ។

  ដូច្នេះ $f(2) = 4$ ។ ដូច្នេះ $f(2^n) = [f(2)]^n = 4^n = 2^{2n}$ ។

- ដោយ $9 > 8$ នោះតាម (i) យើងទាញបាន $f(9) > f(8) = f(2^3) = 2^6$ ។

  យើងមាន $f(9) = f(3)f(3) = [f(3)]^2$ ។ ដូច្នេះ

  $$[f(3)]^2 > 2^6 \Rightarrow f(3) > \sqrt{2^6} = 8$$

  តាម (ii) យើងទាញបាន $f(3^8) = [f(3)]^8$ ។

  តាម (i) ដោយ $3^8 < 2^{13} \Rightarrow f(3^8) < f(2^{13}) = 2^{2(13)} = 2^{26}$

  $$\Rightarrow [f(3)]^8 < 2^{26} \Rightarrow f(3) < 2^{\frac{26}{8}} = 2^{3,25} \cong 9,51 < 10$$
  $$\Rightarrow f(3) < 10$$

  ដូច្នេះ $8 < f(3) < 10$ ហើយដោយ $f(3) \in \mathbb{N}$ ដូច្នេះ $f(3) = 9$ ។ ដូច្នេះ

  $f(3^n) = [f(3)]^n = 9^n = 3^{2n}$ ។

- យើងមាន $5^3 < 2^7 \Rightarrow f(5^3) < f(2^7) = 2^{14} \Rightarrow f(5) < (2^{14})^{\frac{1}{3}} \Rightarrow$

  $f(5) < 26$ ។

- យើងមាន $5^{11} > 3^{16} \Rightarrow f(5^{11}) = [f(5)]^{11} > f(3^{16}) = 3^{2\times 16} \Rightarrow$

  $f(5) > 3^{\frac{32}{11}} \cong 24,43$ ។

- ដូច្នេះ $24 < f(5) < 26 \Rightarrow f(5) = 25$ ។ ដូច្នេះ $f(5^n) = [f(5)]^n = 25^n = 5^{2n}$ ។

ដូច្នេះ $f(2^n) = 2^{2n}\,; f(3^n) = 3^{2n}\,; f(5^n) = 5^{2n}$ ។ យើងទាញបាន

$$f(6^n) = f(2^n.3^n) = f(2^n)f(3^n) = 6^{2n}$$
$$f(30^n) = f(6^n.5^n) = f(6^n)f(5^n) = 6^{2n}5^{2n} = 30^{2n}$$

ដូច្នេះ

$$f(30) = 30$$
$$f\left(30^{30^{30^{30}}}\right) = 30^{2\left(30^{30^{30}}\right)}$$

**986.** ▲ យក $x = 0, y = 0$ យើងទាញបាន

$$f(1) = f(0)f(0) - f(0) - 0 + 2 \Rightarrow f(1) = 2$$

យក $y = 1$

$$f(x+1) = f(x)f(1) - f(1) - x + 2 = 2f(x) - x \quad (1)$$

យក $x = 1$

$$f(y+1) = f(1)f(y) - f(y) - 1 + 2 = f(y) + 1 \Rightarrow f(x+1) = f(x) + 1 \;\; (2)$$

ជំនួសចូល (2) ចូលក្នុង (1) យើងទាញបាន

$$f(x) + 1 = 2f(x) - x \quad \Rightarrow f(x) = x + 1$$
$$f(2010) = 2011$$

**987.** ▲ យើងមាន

$$f(m+1,n) = f(m,n) + m$$
$$m \leftarrow 1: f(2,n) = f(1,n) + 1$$
$$m \leftarrow 2: f(3,n) = f(2,n) + 2$$
$$m \leftarrow 3: f(4,n) = f(3,n) + 3$$
$$\dots\dots\dots$$
$$m \leftarrow m-1: f(m,n) = f(m-1,n) + m - 1$$

$$\Rightarrow f(m,n) = f(1,n) + [1 + 2 + 3 + \cdots + (m-1)] = f(1,n) + \frac{(m-1)m}{2}$$

យើងមាន

$$f(1,n+1) = f(1,n) - n$$
$$n \longleftarrow 1: f(1,2) = f(1,1) - 1$$

$$n \longleftarrow 2: f(1,3) = f(1,2) - 2$$
$$n \longleftarrow 3: f(1,4) = f(1,3) - 3$$
$$\dots\dots\dots$$
$$n \longleftarrow n-1: f(1,n) = f(1,n-1) - (n-1)$$
$$\Rightarrow f(1,n) = f(1,1) - [1+2+3+\dots+(n-1)] = 2 - \frac{(n-1)n}{2}$$

ដូច្នេះ

$$f(m,n) = 2 + \frac{(m-1)m}{2} - \frac{(n-1)n}{2}$$
$$\Rightarrow f(a,b) = 2 + \frac{(a-1)a}{2} - \frac{(b-1)b}{2}; f(a,b) = 2013$$
$$\Rightarrow \frac{(a-1)a}{2} - \frac{(b-1)b}{2} = 2011$$
$$\Leftrightarrow a^2 - a - b^2 + b = 2(2011)$$
$$\Leftrightarrow (a-b)(a+b) - (a-b) = 2(2011)$$
$$\Leftrightarrow (a-b)(a+b-1) = 2(2011)$$

យើងមាន 2011 ជាចំនួនបឋម, $a > b, a+b-1 > a-b$ ។ តាង $d = \mathrm{PGCD}(a-b, a+b-1)$ ដូច្នេះ $a-b = kd, a+b-1 = pd$ ដែល $k$ បឋមនឹង $p$ ។ ដូច្នេះ

$$kpd^2 = 2 \times 2011 \ (*)$$

អង្គខាងស្តាំនៃ $(*)$ គ្មានកត្តាមួយណា ដែលមានស្វ័យគុណធំជាងឬស្មើ 2 ទេ ដូច្នេះ $d = 1$ ។ ដូច្នេះ

$$kp = 2 \times 2011$$

ដែលក្នុងនោះ $k$ បឋមនឹង $p$ ។ យើងមាន $(2)(2011) = (1)(2 \times 2011)$ ។ ដូច្នេះ

$$\begin{cases} k = 1 \\ p = 2 \times 2011 \end{cases} \vee \begin{cases} k = 2 \\ p = 2011 \end{cases}$$

ករណីទីមួយ យើងទាញបាន $a = b + 1 \Rightarrow 2b = 2 \times 2011 \Rightarrow b = 2011, a = 2012$ ។

ករណីទីមួយ យើងទាញបាន $a = b + 2 \Rightarrow 2b + 1 = 2 \times 2011$ មិនអាច ។

ដូច្នេះ $a = 2012; b = 2011$ ។

**988.** ▲ តើ $f(1,n)$ ជាចំនួនគត់ឬទេ?

យើងមាន

$$f(0;n)=1+n\ \ (*)$$
$$f(1;0)=f(0;1)=2$$
$$f(1;n+1)=f\big(0;f(1;n)\big)\ (**)$$

តាម (*) & (**) យើងទាញបាន $f(1;n+1)$ ជាចំនួនគត់ បើ $f(1;n)$ ជាចំនួនគត់ ។

ដោយ$f(1,1)=f\big(0;f(1;0)\big)=2$ ជាចំនួនគត់ នោះ $f(1;n)$ ជាចំនួនគត់ ។

តាម (*) & (**) យើងទាញបាន $f(1;n+1)=f\big(0;f(1;n)\big)=1+f(1;n)$ ។ ដូច្នេះ

$$f(1;2)=1+f(1;1)=3;$$
$$f(1;3)=1+f(1;2)=4;$$
$$\dots\dots$$
$$f(1;n)=n+1$$

❶ គណនា f(2; n)

$$f(2;n+1)=f\big(1;f(2;n)\big)$$

យើងទាញបាន $f(2;n+1)$ គត់ បើ $f(2;n)$ គត់ ។ ដោយ $f(2;0)=f(1;1)=$ $2; f(2;1)=f\big(1;f(2;0)\big)=f(1;2)=3$ ជាចំនួនគត់ នោះ $f(2;n)$ ជាចំនួនគត់ ។

ដូច្នេះ

$$f(2;n+1)=f\big(1;f(2;n)\big)=1+f(2;n)$$
$$\Longrightarrow\ f(2;1)=1+f(2;0)=3;$$
$$f(2;2)=1+f(2;1)=4;$$
$$\dots.$$
$$f(2;n)=n+2$$

❷ គណនា $f(3;n)$

$$f(3;n+1)=f\big(2;f(3;n)\big)=f(3;n)+2$$
$$f(3;0)=f(2;1)=3$$
$$f(3;1)=f(3;0)+2=3+2$$
$$f(3;2)=f(3;1)+2=3+2.2$$
$$\dots.$$
$$f(3;n)=f(3;n-1)+2=3+2n$$

❸ គណនា f(4; 2009)

$$f(4;n+1)=f\big(3;f(4;n)\big)=3+2f(4;n)$$
$$f(4;0)=f(3;1)=5$$

$f(4;1) = 3 + 2f(4;0)$ ………………….$\times 2^{2008}$
$f(4;2) = 3 + 2f(4;1)$ ………………….$\times 2^{2007}$
$f(4;3) = 3 + 2f(4;2)$ ………………….$\times 2^{2006}$
…
$f(4;2007) = 3 + 2f(4;2006)$ ………………….$\times 2^{2}$
$f(4;2008) = 3 + 2f(4;2007)$ ………………….$\times 2$
$f(4;2009) = 3 + 2f(4;2008)$

$$\Longrightarrow \; f(4;2009) = 3 + 3.2 + 3.2^2 + \cdots + 3.2^{2007} + 3.2^{2008} + 2^{2009}f(4;0)$$
$$= 3\left(\frac{2^{2009}-1}{2-1}\right) + 2^{2009}.5 = 8.2^{2009} - 3 = 2^{2012} - 3$$

**989.** ▲ យើងដឹងថា អនុគមន៍ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌពិតជាមាន ឧទាហរណ៍ $f(n) = n$ ។ តាង $f$ ជាអនុគមន៍មួយក្នុងចំណោមនោះ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ ។ ចំពោះ $a = 2$ និង $b = 3$ និងតាមលក្ខខណ្ឌ (i) យើងទាញបាន $f(6) = f(2)f(3)$ ។ ចំពោះចំនួនបឋម $p = 3$ និង $q = 3$ លក្ខខណ្ឌទី (ii) ទៅជា $f(6) = 2f(3)$ ។ ដោយ $f(3) \neq 0$ (ព្រោះ $f: \mathbb{N}^* \to \mathbb{N}^*$) នោះ យើងទាញបាន

$$f(6) = f(2)f(3) \Leftrightarrow 2f(3) = f(2)f(3) \Rightarrow f(2) = 2$$

ចំពោះ $p = 2$ និង $q = 2$ លក្ខខណ្ឌទី (ii) ទៅជា $f(4) = 2f(2) = 4$ ។

ចំពោះ $p = 2$ និង $q = 3$ លក្ខខណ្ឌទី (ii) ទៅជា $f(5) = f(2) + f(3) = 2 + f(3)$ ។

ចំពោះ $p = 5$ និង $q = 2$ លក្ខខណ្ឌទី (ii) ទៅជា $f(7) = f(5) + 2 = f(3) + 4$ ។

ចំពោះ $p = 5$ និង $q = 7$ លក្ខខណ្ឌទី (ii) ទៅជា $f(12) = f(7) + f(5) = 2f(3) + 6$ ។ ចំពោះ $a = 4$ និង $b = 3$ លក្ខខណ្ឌទី (i) ទៅជា $f(12) = 4f(3)$ ។ ដូច្នេះ $4f(3) = 2f(3) + 6 \Rightarrow f(3) = 3$ ។ យើងទាញបាន $f(5) = 5, f(7) = 7, f(12) = 12$ ។

យើងដឹងថា 1999 ជាចំនួនបឋម និង $1999 + 3 = 2002 = 2 \times 7 \times 11 \times 13$ ។

ដូច្នេះ

$$f(2002) = f(1999 + 3) = f(1999) + f(3)$$
$$f(2002) = f(2 \times 7 \times 11 \times 13) = f(2)f(7)f(11)f(13)$$

ចំពោះ $a=5$ និង $b=3$ តាមលក្ខខណ្ឌទី (i) យើងទាញបាន $f(15)=f(3)f(5)=15$ ។

ចំពោះ $p=13$ និង $q=2$ តាមលក្ខខណ្ឌទី (ii) យើងទាញបាន $f(15)=f(13)+f(2)\Rightarrow f(13)=13$ ។

ចំពោះ $p=11$ និង $q=2$ តាមលក្ខខណ្ឌទី (ii) យើងទាញបាន $f(13)=f(11)+f(2)\Rightarrow f(11)=11$ ។

ដូច្នេះ $f(2002)=2002$ ។ យើងទាញបាន $f(1999)=f(2002)-f(3)=1999$ ។

**990.** ▲ ❶ យើងដឹងថា $f(1)\geq 1$ ព្រោះ $f$ ជាអនុវត្តន៍ពីសំណុំចំនួនគត់វិជ្ជមានទៅសំណុំចំនួនគត់វិជ្ជមាន ។ សំណុំចំនួនគត់វិជ្ជមានជាសំណុំចំនួនគត់ដែល $\geq 1$ ។

បើ $f(1)=1+m>1$ នោះយក $x=1$ យើងទាញបាន $1, f(y), f(y+f(1)-1)=f(y+m)$ ជារង្វាស់ជ្រុងនៃត្រីកោណមិនស្ងួនមួយ ។ដូច្នេះ

$$\begin{aligned} &1+f(y+m)>f(y) \Rightarrow f(y+m)\geq f(y)\\ &1+f(y)>f(y+m) \Rightarrow f(y)\geq f(y+m)\\ &\Rightarrow f(y)=f(y+m)\end{aligned}$$

ដូច្នេះ $f$ ជាអនុគមន៍ខួបមានខួបស្មើ $m$ ។ ដោយ $x, f(y), f(y+f(x)-1)$ ជារង្វាស់ជ្រុងនៃត្រីកោណចំពោះគ្រប់ $x, y$ នោះ យើងយកចំណុច $y$ ដែល $f(y)=f(y+m)\leq B$ និង $x=1+km>2B$ ដែល $k, B$ ជាចំនួនគត់ណាមួយ ។ យើងទាញបាន $f(y+f(x)-1)=f(y+f(1+km)-1)=f(y+f(1)-1)=f(y+m)\leq B$ ។ ដូច្នេះ $x>2B\geq f(y)+f(y+f(x)-1)$ នោះ $x, f(y), f(y+f(x)-1)$ មិនមែនជារង្វាស់ជ្រុងនៃត្រីកោណ $\Rightarrow$ផ្ទុយពីសម្មតិកម្ម ។

ដូច្នេះមានតែ $f(1)=1$ ។

❷ ដោយ $x, f(y), f(y+f(x)-1)$ ជារង្វាស់ជ្រុងនៃត្រីកោណចំពោះគ្រប់ $x, y$ នោះ យក $x=z$ និង $y=1$ យើងទាញបាន $z, f(1), f(1+f(z)-1)$ ឬ $z, 1, f\big(f(z)\big)$ ជារង្វាស់ជ្រុងនៃត្រីកោណ ។ដូច្នេះ

$$\begin{aligned}&z+1>f\big(f(z)\big) \Rightarrow z \geq f\big(f(z)\big)\\&f\big(f(z)\big)+1>z \Rightarrow f\big(f(z)\big) \geq z\\&\Rightarrow f\big(f(z)\big)=z\end{aligned}$$

❸ យើងនឹងបង្ហាញថាគ្មានចំនួនគត់វិជ្ជមាន $t$ ដែល

$$f(t)>\frac{z-1}{w} t+M \qquad (1)$$

ទេ ។ ដំបូងយើងសន្មតផ្ទុយទៅវិញថាមានចំនួនគត់វិជ្ជមាន $t$ ដែលផ្ទៀងផ្ទាត់វិសមភាព (1) ។ ក្នុងចំណោមចំនួនគត់ $t$ ដែលផ្ទៀងផ្ទាត់វិសមភាព (1) តាង $t=t_0$ ជាតម្លៃ $t$ ដែលតូចជាងគេបង្អស់ ។ យើងមាន $M=\max\{f(1), f(2), \ldots, f(w)\}$ និង $f(t_0)>M$ ដូច្នេះមានតែ $t_0>w$ ។យក $x=z$ និង $y=t_0-w$ ហើយដោយ $x, f(y), f(y+f(x)-1)$ ជារង្វាស់ជ្រុងនៃត្រីកោណ យើងទាញបាន

$$\begin{aligned}&x+f(y)>f(y+f(x)-1) \Leftrightarrow z+f(t_0-w)>f(t_0-w+f(z)-1)\\&\qquad\qquad=f(t_0-w+w+1-1)=f(t_0)\\&\Rightarrow f(t_0-w)>f(t_0)-z\\&\Rightarrow f(t_0-w) \geq f(t_0)-(z-1)>\frac{z-1}{w} t_0+M-(z-1)\\&\qquad\qquad=\frac{z-1}{w}(t_0-w)+M\end{aligned}$$

ដូច្នេះមានន័យថា មានតម្លៃ $t=t_0-w<t_0$ ដែលផ្ទៀងផ្ទាត់វិសមភាព(1) ៖ តែនេះផ្ទុយពីសម្មតិកម្មដែលថា $t_0$ តូចជាងគេ ក្នុងចំណោមបណ្ដាតម្លៃ $t$ ដែលផ្ទៀងផ្ទាត់វិសមភាព(1) ។

ដូច្នេះវិសមភាព(1) មិនពិតគ្រប់ $t \geq 1$ ។ ដូច្នេះ

$$f(t) \leq \frac{z-1}{w} t+M \qquad (2)$$

❹ យើងនឹងបង្ហាញថា $f(z) \leq z$ ចំពោះគ្រប់ចំនួនគត់ $z \geq 1$ ។

យើងសន្មតផ្ទុយទៅវិញថាមានចំនួនគត់ $z = z_0 \geq 1$ មួយដែល $f(z_0) > z_0$ ។ តាង $f(z_0) = w + 1 > z_0$ ។ ដោយ $f(1) = 1$ ដូច្នេះ បើ $f(z_0) > z_0$ នោះត្រូវតែ $z_0 \neq 1$ ដូច្នេះ $z_0 \geq 2$ ។ ដោយ $w + 1 > z_0 \Rightarrow w \geq z_0$ ។ ដូច្នេះ $w \geq z_0 \geq 2$ ។ តាង $M = \max\{f(1), f(2), \dots, f(w)\}$ ។ ចំពោះ $z_0 \leq w \Rightarrow z_0 - 1 < w \Rightarrow (z_0 - 1)/w < 1$ ។ ដូច្នេះយើងអាចរកបានចំនួនគត់ t ដែលធំគ្រប់គ្រាន់មួយដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$\left(\frac{z_0 - 1}{w}\right)^2 t + \left(\frac{z_0 - 1}{w} + 1\right) M < t$$

ប្រើវិសមភាព(2) ពីរដងយើងទាញបាន

$$f\big(f(t)\big) \leq \frac{z_0 - 1}{w} f(t) + M \leq \frac{z_0 - 1}{w}\left[\frac{z_0 - 1}{w} t + M\right] + M < t$$

តែវិសមភាពដែលទទួលបាននេះ ផ្ទុយនឹងអ្វីដែលយើងបានស្រាយបញ្ជាក់ក្នុងសំនួរទី២ ។ ដូច្នេះមានន័យថា គ្មានចំនួនគត់ $z_0$ ដែល $f(z_0) > z_0$ ទេ ។

❺ យោងតាមអ្វីដែលយើងបានស្រាយបញ្ជាក់ក្នុងជំហានទី២និងទី៤ យើងទាញបាន $z = f\big(f(z)\big) \leq f(z) \leq z \Rightarrow f(z) = z$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន z ។

ផ្ទៀងផ្ទាត់ ៖ អនុគមន៍ $f(x) = x, \forall x \in Z^+$ ជាចម្លើយមួយនៃចំណោទនេះ ព្រោះ

- ចំពោះគ្រប់ $x, y \in \mathbb{Z}^+$ យើងមាន $x, y = f(y)$ និង $z = f(y + f(x) - 1) = x + y - 1$ ជារង្វាស់ជ្រុងនៃត្រីកោណមិនសូន្យ ព្រោះ
- ដោយ $x \geq 1, y \geq 1$ នោះ $z \geq \max\{x, y\} > |x - y|$ និង $z < x + y$ ។

**991.** ▲ តាមវិសមភាពកូស៊ី ចំពោះគ្រប់ចំនួនពិត $x > 0$ យើងមាន $x + 1/x \geq 2$ ។ ចំពោះ $x > 0$ តាង $y = \frac{x + \frac{1}{x}}{2}$ ដែលត្រូវនឹង $x = y + \sqrt{y^2 - 1}$ បើ $x \geq 1$ និង $x = y - \sqrt{y^2 - 1}$ បើ $x \leq 1$ ។ យើងដឹងថា $\frac{1}{y - \sqrt{y^2 - 1}} = y + \sqrt{y^2 - 1}$ ។ យកអនុគមន៍ $u(t) = f\big(t + \sqrt{t^2 - 1}\big)$ ដែល $t \in [1; +\infty[$ ។ យើងទាញបាន

- ចំពោះ $x \geq 1$ យើងមាន

$$u\left(\frac{x+\frac{1}{x}}{2}\right)=f\left(y+\sqrt{y^2-1}\right)=f(x)$$

- ចំពោះ $x\leq 1$ យើងមាន

$$u\left(\frac{x+\frac{1}{x}}{2}\right)=f\left(y+\sqrt{y^2-1}\right)=f\left(\frac{1}{x}\right)=f(x)$$

ដូច្នេះ យើងឃើញថា យ៉ាងហោចណាស់ មានអនុគមន៍ $u$ មួយ ដូចខាងលើ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌចង់បាន ។

**992.** ▲ - តាង $t=\frac{x-3}{x+1}$ ដូច្នេះ $t\neq\pm 1$ និង $x=\frac{3+t}{1-t}$ ។ សមីការអនុគមន៍ទៅជា

$$f(t)+f\left(\frac{t-3}{t+1}\right)=\frac{3+t}{1-t}\quad(*)$$

ចំពោះគ្រប់ $t\neq\pm 1$ ។

- តាង $t=\frac{x+3}{1-x}$ ដូច្នេះ $t\neq\pm 1$ និង $x=\frac{t-3}{t+1}$ ។ សមីការអនុគមន៍ទៅជា

$$f\left(\frac{3+t}{1-t}\right)+f(t)=\frac{t-3}{t+1}\quad(**)$$

ចំពោះគ្រប់ $t\neq\pm 1$ ។

បូក (*) និង (**) ចូលគ្នា យើងទាញបាន

$$2f(t)+f\left(\frac{t-3}{t+1}\right)+f\left(\frac{3+t}{1-t}\right)=\frac{3+t}{1-t}+\frac{t-3}{t+1}$$

$$\Leftrightarrow 2f(t)+t=\frac{8t}{1-t^2}\Rightarrow f(t)=\frac{4t}{1-t^2}+\frac{t}{2}$$

ប្រាសមកវិញ អនុគមន៍ $f(x)=\frac{4x}{1-x^2}+\frac{x}{2}$ គឺពិតជាចម្លើយរបស់សមីការ ។

**993.** ▲តាមលក្ខខណ្ឌ (i) ចំពោះគ្រប់ចំនួនគត់ $m,n>0$ យើងមាន

$$f(m+n)\geq f(m)+f(n)\qquad(*)$$

ចំពោះ $m=n=1$ និងដឹងថា $f(2)=0$ យើងទាញបាន $f(2)\geq 2f(1)\ \Rightarrow f(1)\leq 0\ \Rightarrow f(1)=0$ ។ ចំពោះ $m=2$ និង $n=1$ យើងទាញបាន $f(3)=f(2)+f(1)+t=t$ ដែល $t\in\{0;1\}$ ។ តែដោយ $f(3)>0$ ដូច្នេះ $f(3)=1$ ។

យើងមាន

$$\begin{aligned}&f(3)=1\\&f(3\times 2)\geq f(3)+f(3)=2\\&f(3\times 3)\geq f(3\times 2)+f(3)\geq 2+1=3\\&\vdots\end{aligned}$$

សន្មតថាវិសមភាពទាំងនេះពិតរហូតដល់ $n$ គឺ $f(3n)\geq n$ ។ យើងមាន $f[3(n+1)]\geq f(3n)+f(3)\geq n+1$ ។ ដូច្នេះ $f(3n)\geq n$ ពិតរហូតដល់ $n+1$ មានន័យថាពិតគ្រប់ចំនួនគត់ $n>0$ ។

សន្មតថា ក្នុងចំណោម $n\in\{0;1;\dots;3\,333\}$ មាន $n$ ដែល $f(3n)>n$ ។ $n$ នោះត្រូវតែ $n<3\,333$ ព្រោះ $f(3\times 3\,333)=3\,333$ ។ តែបើ $f(3n)>n$ ចំពោះ $n<3\,333$ នោះ

$$\begin{aligned}&f[3(n+1)]\geq f(3n)+f(3)>n+1\\&f[3(n+2)]\geq f[3(n+1)]+f(3)>n+2\\&\vdots\\&\Rightarrow f(3\times 3\,333)>3\,333\end{aligned}$$

ផ្ទុយពីសម្មតិកម្ម ។ ដូច្នេះ ចំពោះគ្រប់ $n\in\{0;1;\dots;3\,333\}$ យើងមាន

$$f(3n)=n\quad (**)$$

តាម (*) និង (**) យើងទាញបាន $1982=f(3\times 1982)\geq f(2\times 1982)+f(1982)\geq 3f(1982)$ ។ ដូច្នេះ $f(1982)\leq \frac{1982}{3}\Rightarrow f(1982)\leq 660$ ។

តាម (*) និង (**) យើងមាន $f(1982)\geq f(1980)+f(2)=f(1980)=f(3\times 660)=660$ ។

ដូច្នេះ ជាបញ្ចប់ $f(1982)=660$ ។

**994.** ▲ ក្នុង (i) យើងជំនួស $m$ ដោយ $f(f(m))$ យើងទាញបាន

$$f\Big(f\big(f(m)\big)+f\big(f(n)\big)\Big)=-f\Big(f\big(f\big(f(m)\big)+1\big)\Big)-n \qquad (1)$$

ក្នុងទំនាក់ទំនងដែលទទួលបាននេះ យើងជំនួស $m$ ដោយ $n$ និង $n$ ដោយ $m$ យើងទាញបាន

$$f\Big(f\big(f(n)\big)+f\big(f(m)\big)\Big)=-f\Big(f\big(f\big(f(n)\big)+1\big)\Big)-m \qquad (2)$$

យកទំនាក់ទំនងទាំងពីរដែលទទួលបានខាងលើមកដកគ្នា យើងទទួលបាន

$$f\left(f\left(f\left(f(m)\right)+1\right)\right)-f\left(f\left(f\left(f(n)\right)+1\right)\right)=m-n \quad (3)$$

ក្នុង (i) យើងជំនួស $m=1$ យើងទាញបាន

$$f\left(f\left(f(n)\right)+1\right)=-n-f\left(f(2)\right)$$
$$\Rightarrow f\left(f\left(f\left(f(n)\right)+1\right)\right)=f\left(-n-f\left(f(2)\right)\right) \quad (4)$$

ជំនួស $n$ ដោយ $m$ ក្នុងទំនាក់ទំនង (4) យើងទាញបាន

$$\Rightarrow f\left(f\left(f\left(f(m)\right)+1\right)\right)=f\left(-m-f\left(f(2)\right)\right) \quad (5)$$

ជំនួស (4) និង (5) ចូលក្នុង (3) និង តាង $k=f\left(f(2)\right)$ យើងទាញបាន

$$f(-m-k)-f(-n-k)=m-n,\ \forall m,n\in\mathbb{Z} \quad (6)$$

ក្នុង (6) យក $-m-k=p;\ -n-k=0$ យើងទាញបាន $f(p)-f(0)=-p-k-(-k)=-p$ ។ ដូច្នេះ $f(p)=-p+f(0)$ ចំពោះគ្រប់ចំនួនគត់ $p$ ។ យើងទាញបាន

$$f(m)=-m+f(0);$$
$$f\left(f(m)\right)=f\left(-m+f(0)\right)=-\left(-m+f(0)\right)+f(0)=m$$

ជំនួសទំនាក់ទំនងទាំងពីរនេះ ចូលក្នុង (i) យើងទាញបាន

$$f\left(m+f\left(f(n)\right)\right)=-f\left(f(m+1)\right)-n \ \Leftrightarrow -m-f(f(n))+f(0)$$
$$=-[-f(m+1)+f(0)]-n$$
$$\Leftrightarrow\ -m-n+f(0)$$
$$=-(m+1)+f(0)-f(0)-n\Longrightarrow\ f(0)=-1$$

ដូច្នេះ $f(m)=-m-1$ ចំពោះគ្រប់ចំនួនគត់ $m$ ។

យើងទាញបាន $f(1991)=-1992$ ។

តាម (ii) យើងទាញបាន $g(n)=g(-n-1)$ ចំពោះគ្រប់ចំនួនគត់ $n$ ។ ដោយ $g$ ជាពហុធា នោះ ត្រូវតែ $g(x)=g(-x-1)$ ចំពោះគ្រប់ចំនួនពិត $x$ ។ យើងសរសេរ $g$ ជាពហុធានៃ $x+1/2$ គឺ $g(x)=h(x+1/2)$ ។ នោះ $h$ ផ្ទៀងផ្ទាត់ $h(x+1/2)=h(-x-1/2)$ ដែលមានន័យថា $h(y)=h(-y)$ ។ ដូច្នេះ $h$ ជាពហុធា នៃ $y^2$ ។ យើងទាញបាន $g$ ជាពហុធា នៃ $(x+1/2)^2=x^2+x+1/4$ ។ ដូច្នេះ យើង

ទាញបាន $g(n) = p(n^2+n)$ (ដែល $p$ ជាពហុធាដែលមានរាង៍ណាមួយ ) ជាទម្រង់ទូទៅរបស់ $g$ ។

**995.** ▲ យក $y = x^2$ យើង៍ទាញបាន $f(f(x)+x^2) = f(0) + 4x^2 f(x)$
យក $y = -f(x)$ យើង៍ទទួលបាន $f(0) = f\big(x^2 + f(x)\big) - 4\big(f(x)\big)^2$
បូកសមភាពទាំង៍ពីរដែលទទួលបានចូលគ្នា យើង៍ទាញបាន $\big(f(x)\big)^2 = x^2 f(x) \Leftrightarrow$ $f(x)(f(x)-x^2) = 0$ ចំពោះគ្រប់ $x \in \mathbb{R}$ ។ ដូច្នេះ $f(x) = 0$ ឬ $f(x) = x^2$ ។ យើង៍អាចផ្ទៀង៍ផ្ទាត់បានថា អនុគមន៍ទាំង៍ពីរនេះ សុទ្ធតែជាចម្លើយរបស់សមីការ ។ តែបន្ទាប់មកទៀត យើង៍ត្រូវបង្ហាញថា អនុគមន៍មួយ ដែលស្មើសូន្យចំពោះ $x \in D_1$ និង៍ស្មើ $x^2$ ចំពោះ $x \in D_2$ ដែល $D_1 \cup D_2 = \mathbb{R}$ ជាចម្លើយឬមិនមែនជាចម្លើយរបស់សមីការ ។ យក $\{0\} \in D_1$ និង៍ $\{0\} \notin D_2$ ។
សន្មតថា មាន $a \in D_1$ ដែល $f(a) = 0$ ។
ជំនួស $x = a$ ចូលក្នុង៍សមីការដើម យើង៍ទទួលបាន $f(y) = f(a^2 - y)$ ចំពោះគ្រប់ $y \in \mathbb{R}$ ។ បើ $y \in D_2$ នោះ $f(y) = y^2 = f(a^2-y) \neq 0$ ដូច្នេះ $a^2 - y \in D_2 \implies f(a^2-y) = (a^2-y)^2 \implies y^2 = (a^2-y)^2$ ។ បើ $y \neq a^2/2$ នោះ $y^2 \neq (a^2-y)^2$ ។ ដូច្នេះ មានតែ $D_2 = \{a^2/2\}$ ដែលមានន័យថា $f(y) = 0$ ចំពោះគ្រប់ $y \neq a^2/2$ ។
យើង៍ជ្រើសរើសចំនួនពិត $y \neq 0$ ដែល $f(a^2/2) + y \neq a^2/2$ និង៍ $(a^2/2)^2 - y \neq a^2/2$ ។ ជំនួស $x = a^2/2$ ចូលក្នុង៍សមីការដើម យើង៍ទាញបាន

$$f\left(f\left(\frac{a^2}{2}\right)+y\right) = f\left(\left(\frac{a^2}{2}\right)^2 - y\right) + 4yf\left(\frac{a^2}{2}\right) \Leftrightarrow 0 = 0 + 4yf\left(\frac{a^2}{2}\right)$$
$$\implies f\left(\frac{a^2}{2}\right) = 0$$

ដូច្នេះមានន័យថា បើមាន $a$ ដែល $f(a)=0$ នោះ គ្រប់ $x\in\mathbb{R}$ យើងមាន $f(x)=0$ ។

ដូច្នេះសមីការមានចម្លើយពីរ គឺ $f(x)\equiv 0;\forall x\in\mathbb{R}$ ឬ $f(x)\equiv x^2;\ \forall x\in\mathbb{R}$ ។

**996.** ▲ យក $x=0$ យើងទាញបាន $f(f(y))=y+\left(f(0)\right)^2$ ។ ចំពោះគ្រប់ $t\in\mathbb{R}$ បើ $f(x)=t$ នោះ $f(f(x))=f(t)=x+\left(f(0)\right)^2 \Rightarrow x=f(t)-\left(f(0)\right)^2$ ។ សមីការ $f(x)=t$ មានឫសជានិច្ចចំពោះគ្រប់ $t\in\mathbb{R}$ និងមានឫសតែមួយគត់ ដូច្នេះ $f$ ជាអនុវត្តន៍មួយទល់មួយ ។

ជំនួស $x$ ដោយ $-x$ យើងទាញបាន

$$\begin{aligned}
&f\left(x^2+f(y)\right)=y+\left(f(x)\right)^2\\
&f\left((-x)^2+f(y)\right)=y+\left(f(-x)\right)^2\\
&\Rightarrow y+\left(f(x)\right)^2=y+\left(f(-x)\right)^2\\
&\Rightarrow \left(f(x)\right)^2=\left(f(-x)\right)^2\\
&\Rightarrow f(x)=\pm f(-x)
\end{aligned}$$

តែដោយ $f$ ជាអនុវត្តន៍ប្រកាន់ នោះ $f(x)=-f(-x)$ ។

ដោយ $f$ ជាអនុវត្តន៍ពេញ ដូច្នេះ មាន $z\in\mathbb{R}$ ដែល $f(z)=0$ ។ ពីទំនាក់ទំនង $f(-z)=-f(z)=0$ និង ដោយ $f$ ជាអនុវត្តន៍ប្រកាន់ នោះត្រូវតែ $z=0$ ។ ដូច្នេះ $f(0)=0$ ។

ជំនួស $y=0$ យើងទាញបាន

$$f\left(x^2+f(0)\right)=\left(f(x)\right)^2 \quad \Leftrightarrow f(x^2)=\left(f(x)\right)^2$$

ចំពោះគ្រប់ $x\neq 0$ យើងមាន $\left(f(x)\right)^2>0$ ដូច្នេះ $f(x^2)>0$ ។ យើងទាញបាន $f(x)>0$ ចំពោះគ្រប់ $x>0$ ។ ដោយ $f(-x)=-f(x)$ នោះ $f(x)<0$ ចំពោះគ្រប់ $x<0$ ។ ដូច្នេះ យើងទាញបាន $f(x)$ មានសញ្ញាដូច $x$ ។

ជំនួស $x$ ដោយ $\sqrt{x}$ និង $y=-x$ ជំនួសចូលសមីការដែលឱ្យ យើងទាញបាន

$$f\left(x-f(x)\right)=-x+\left(f\left(\sqrt{x}\right)\right)^2=-x+f(x)=-\left(x-f(x)\right)$$

តែដោយ $f(x-f(x))$ មានសញ្ញាដូច $x-f(x)$ នោះ មានតែ $x-f(x)=0 \Rightarrow$ $f(x)=x$ ចំពោះ $x>0$ ។ ដោយ $f(x)=-f(-x)$ នោះយើងទាញបាន $f(x)=x$ ចំពោះគ្រប់ $x$ ។

ប្រាសមកវិញ ចំពោះ $f(x)=x$ យើងមាន

$$\begin{aligned} & f(x^2+f(y)) = x^2+f(y) = x^2+y \\ & y+(f(x))^2 = y+x^2 \\ & \Rightarrow (x^2+f(y)) = y+(f(x))^2 \end{aligned}$$

ពិត ។

**997.** ▲ យក $x=-a$ រួចគុណអង្គទាំងពីរនឹង $a$ យើងទាញបាន ចំពោះគ្រប់ចំនួនពិត $a\neq 0$

$$f(a)-a\,f\left(-\frac{1}{a}\right)=a^2 \qquad (1)$$

ជំនួស $x$ ដោយ $1/a$ យើងទាញបាន ចំពោះគ្រប់ $a\neq 0$,

$$af\left(-\frac{1}{a}\right)+f(a)=\frac{1}{a} \qquad (2)$$

បូក (1) និង (2) យើងទាញបាន

$$f(a)=\frac{1}{2}\left(a^2+\frac{1}{a}\right)=\frac{a^3+1}{2a}$$

ប្រាសមកវិញ បើ $f(x)=\frac{x^3+1}{2x}$ នោះ

$$\frac{1}{x}f(-x)+f\left(\frac{1}{x}\right)=\frac{1}{x}\left[\frac{-x^3+1}{-2x}\right]+\frac{\left(\frac{1}{x}\right)^3+1}{2\left(\frac{1}{x}\right)}=\frac{x^3-1}{2x^2}+\frac{x^3+1}{2x^2}=x$$

ពិត ។

ដូច្នេះ $f(x)=\frac{x^3+1}{2x}$ គឺពិតជាចម្លើយនៃសមីការ ។

**998.** ▲ យក $x=0; y=1$ យើងទាញបាន $f(1/3)=0$ ។ យក $x=1; y=0$ យើងទាញបាន $f(2/3)=0$ ។ យើងនឹងបង្ហាញថា $f\left(\frac{m}{3^k}\right)=0$ ចំពោះគ្រប់ចំនួនគត់ $k\geq 0$ និងចំពោះគ្រប់ $0\leq m\leq 3^k$ ។ យើងបានបង្ហាញរួចហើយថា សំណើនេះពិត

ចំពោះ $k=1$ និង $m=0;1;2;3$ ។ សន្មតថាសំណើពិតរហូតដល់ $k-1$ ។ យើងនឹងបង្ហាញថាសំណើពិតរហូតដល់ $k$ ។

បើ $m\equiv 0 \pmod 3$ នោះ

$$f\left(\frac{m}{3^k}\right)=f\left(\frac{\frac{m}{3}}{3^{k-1}}\right)=0$$

ពិត ព្រោះ $\frac{m}{3}$ ជាចំនួនគត់ និងតាមវិចារ ។

បើ $m\equiv 1 \pmod 3$ នោះ $1\le m\le 3^k-2$ និង

$$3f\left(\frac{m}{3^k}\right)=2f\left(\frac{\frac{m-1}{3}}{3^{k-1}}\right)+f\left(\frac{\frac{m+2}{3}}{3^{k-1}}\right)=0+0=0$$

$$\Longrightarrow\ f\left(\frac{m}{3^k}\right)=0$$

បើ $m\equiv 2 \pmod 3$ នោះ $2\le m\le 3^k-1$ និង

$$3f\left(\frac{m}{3^k}\right)=2f\left(\frac{\frac{m+1}{3}}{3^{k-1}}\right)+f\left(\frac{\frac{m-2}{3}}{3^{k-1}}\right)=0+0=0$$

$$\Longrightarrow\ f\left(\frac{m}{3^k}\right)=0$$

ចំពោះគ្រប់ចំនួនពិត $a\neq 0$ យើងមាន $a=\lfloor a\rfloor+\{a\}$ ដែល $0\le\{a\}<1$ ។ ដូច្នេះ

$$\frac{\lfloor a\rfloor}{a}+\frac{\{a\}}{a}=1\ \Rightarrow\ \lim_{a\to\infty}\frac{\lfloor a\rfloor}{a}=1$$

យក $a=3^kx$ ។ យើងទាញបាន

$$\lim_{k\to+\infty}\frac{\lfloor 3^kx\rfloor}{3^kx}=1\quad\Rightarrow\lim_{k\to+\infty}\frac{\lfloor 3^kx\rfloor}{3^k}=x$$

ដូច្នេះចំពោះគ្រប់ចំនួនពិត $x\in(0,1]$ យើងអាចរកបាននូវស្វ៊ីតមួយដែលមានរាង $\frac{m}{3^k}$ ដែលមានលីមីតស្មើ $x$ ។

ដូច្នេះ $f\left(\frac{m}{3^k}\right)=0$ និង $\lim_{k\to\infty}\frac{m}{3^k}=x$ ហើយដោយ $f$ ជាអនុគមន៍ជាប់ នោះ $f(x)=0$ ចំពោះគ្រប់ $x\in[0,1]$ ។

**999.** ▲ យើងសន្មតផ្ទុយពីការពិតថា មានអនុគមន៍ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌនោះ ។

ចំពោះ $x = 0$ យើងទាញបាន

$$f(f(y)) = -y + f(0) \qquad (*)$$

ចំពោះគ្រប់ $t \in \mathbb{Z}$ បើ $f(x) = t$ នោះ $f(f(x)) = f(t) = x + (f(0))^2 \Rightarrow x = f(t) - (f(0))^2$ ។ សមីការ $f(x) = t$ មានឫសជានិច្ចចំពោះគ្រប់ $t \in \mathbb{Z}$ និងមានឫសតែមួយគត់ ដូច្នេះ $f$ ជាអនុវត្តន៍មួយទល់មួយ ។

ក្នុង (*) យក $y = 0$ យើងទាញបាន $f(f(0)) = f(0)$ ។ ដោយ $f$ ជាអនុវត្តន៍មួយទល់មួយ នោះ $f(0) = 0$ ។ ដូច្នេះ $f(f(y)) = -y$ ចំពោះគ្រប់ចំនួនគត់ $y$ ។

ដោយ $f$ ជាអនុវត្តន៍មួយទល់មួយ នោះ មានចំនួនគត់ $a$ មួយ ដែល $f(a) = y$ ។ យើងទាញបាន $f(y) = f(f(a)) = -a$ ។ ដូច្នេះ

$$f(x + f(a)) = f(x) - a = f(x) + f(y)$$
$$f(x + f(a)) = f(x + y)$$
$$\Longrightarrow f(x + y) = f(x) + f(y)$$

ចំពោះគ្រប់ចំនួនគត់ $x, y$ ។ យក $y = -x$ យើងទាញបាន $f(x) = -f(-x)$ ។

យក $y = 1$ យើងទាញបាន $f(x + 1) = f(x) + f(1)$ ។ ដោយយក $x = 1,2,3, \dots, n$ យើងទាញបាន

$$\begin{aligned} &f(2) = f(1) + f(1) \\ &f(3) = f(2) + f(1) \\ &\vdots \\ &f(n) = f(n-1) + f(1) \end{aligned}$$

បូកអង្គនិងអង្គ យើងទាញបាន

$$f(n) = n\,f(1)$$

ចំពោះគ្រប់ចំនួនគត់ $n > 0$ ។

ដោយ $f(x) = -f(-x)$ នោះ $f(x) = xf(1)$ ចំពោះគ្រប់ចំនួនគត់ $x$ ។ ម្យ៉ាងវិញទៀត

$$\begin{aligned} &f(f(x)) = -x \iff f(x)f(1) = -x \\ &\iff x(f(1))^2 = -x \end{aligned}$$

$$\Rightarrow \left(f(1)\right)^2 = -1$$

មិនអាច ។

**1000.** ▲ យក $x \geq 0$ និង $y = 2$ ជំនួសចូលក្នុង (i) យើងទាញបាន $f(x+2) = f\left(2f(y)\right)f(2) \Rightarrow f(x+2) = 0$ ។ ដូច្នេះ $f(x)$ ស្មើសូន្យចំពោះគ្រប់ $x \in [2; +\infty)$ ។

ចំពោះគ្រប់ចំនួនពិត $0 \leq y < 2$ និងចំនួនពិត $x \geq 0$ យើងមាន $f\left(xf(y)\right)f(y) = 0$ ទាល់តែនិងមានតែ $f(x+y) = 0$ មានន័យថា $x + y \geq 2 \Rightarrow x \geq 2 - y$ ។ ម្យ៉ាងវិញទៀត $f\left(xf(y)\right)f(y) = 0$ ទាល់តែនិងមានតែ $f\left(xf(y)\right) = 0$ មានន័យថា $xf(y) \geq 2 \Rightarrow x \geq \frac{2}{f(y)}$ ។ ដូច្នេះយើងទាញបាន លក្ខខណ្ឌ $x \geq 2 - y$ និង $x \geq \frac{2}{f(y)}$ សមមូលគ្នា ។ ដូច្នេះមានន័យថា

$$2 - y = \frac{2}{f(y)} \Rightarrow f(y) = \frac{2}{2-y};\ \forall y \in [0; 2)$$

ដូច្នេះយើងទាញបានថាចម្លើយដែលអាចរបស់សមីការមានតែ

$$f(y) = \begin{cases} \dfrac{2}{2-y};\ 0 \leq y < 2 \\ 0;\ y \geq 2 \end{cases}$$

# ផ្ទៀងផ្ទាត់

ជំហានបន្ទាប់មកទៀត យើងត្រូវផ្ទៀងផ្ទាត់ថា ចម្លើយទាំងនេះពិតជាផ្ទៀងផ្ទាត់លក្ខខណ្ឌ (i) និង (ii) មែន ។

យើងឃើញថា លក្ខខណ្ឌទី (ii) ពិតជាផ្ទៀងផ្ទាត់មែន ។

តាង $x, y \geq 0$ ជាចំនួនពិតពីរ ។

❶ បើ $x + y \geq 2$ និង $xf(y) \geq 2$ នោះ អង្គខាងឆ្វេងនិងខាងស្តាំនៃ (i) សុទ្ធតែស្មើសូន្យទាំងពីរ ។ ដូច្នេះផ្ទៀងផ្ទាត់ ។

❷ បើ $x + y \geq 2$ និង $xf(y) < 2$ ។ បើ $y \geq 2$ អង្គខាងឆ្វេងនិងខាងស្តាំនៃ (i) សុទ្ធតែស្មើសូន្យទាំងពីរ ។ ដូច្នេះផ្ទៀងផ្ទាត់ ។ បើ $y < 2$ នោះ $xf(y) < 2 \Leftrightarrow$

$x\frac{2}{2-y}<2\ \Rightarrow x+y<2$ តែវិសមភាពនេះផ្ទុយពីការសន្មតថា $x+y\geq 2$ ។ ដូច្នេះ មានន័យថា ករណីនេះមិនអាចមាន ។

❸ បើ $x+y<2$ និង $xf(y)<2$ នោះ $y<2$ ។ ដូច្នេះ

$$f(y)=\frac{2}{2-y}f\big(xf(y)\big)=\frac{2}{2-xf(y)}=\frac{2}{2-\frac{2x}{2-y}}$$

$$\Rightarrow\ f\big(xf(y)\big)f(y)=\frac{2}{2-\frac{2x}{2-y}}\,\frac{2}{2-y}=\frac{2}{2-x-y}=f(x+y)$$

❹ បើ $x+y<2$ និង $xf(y)\geq 2$ នោះ $x\frac{2}{2-y}\geq 2\ \Rightarrow x+y\geq 2$ ផ្ទុយពីការសន្មត ។

ដូច្នេះយើងឃើញថា លក្ខខណ្ឌ (i) ក៏ផ្ទៀងផ្ទាត់ដែរ ។ ដូច្នេះ មានន័យថា $f$ ពិតជាចម្លើយនៃសមីការ ។

**1001.** ▲ តាមលក្ខខណ្ឌ (ii) $f(x)=0$ មានយ៉ាងតិចឫសមួយ និងមានឫសមួយដែលធំជាងគេបង្អស់ តាងឫសនោះ ដោយ $x_0$ ។ តាមលក្ខខណ្ឌ (v) យើងមាន

$$0=f(x)f(x_0)=f(x\,f(x_0)+x_0f(x)-xx_0)=f\big(x_0(f(x)-x)\big)\quad(*)$$

ដូច្នេះ $x_0\geq x_0(f(x)-x)$ ។

សន្មតថា $x_0>0$ ។ យើងមាន $f(x_0)=0<x_0\ \Rightarrow\ f(x_0)-x_0<0$ ។ តាម (iii), $f(0)=1>0$ ។ ដូច្នេះ $f(x_0)-x_0<0<f(0)-0$ នោះ តាម (i), គេមាន $z$ មួយ ឋិតនៅចន្លោះ 0 និង $x_0$ ដែល $f(z)=z$ ។ជំនួស $x=z$ ចូលក្នុង (*) , យើងទាញបាន $0=f\big(x_0(f(z)-z)\big)=f(0)=1$ តាម (iii) : មិនពិត ។

ដូច្នេះ $x_0<0$ ។ វិសមភាព $x_0\geq x_0\,(f(x)-x)$ នាំឱ្យ $f(x)-x\geq 1$ ចំពោះគ្រប់ $x$ ។ ដូច្នេះ $f(1987)\geq 1988$ ។ ដូច្នេះ $f(1987)=1988$ ។

**1002.** ▲ សន្មតថាមានអនុគមន៍បែបនេះ ។

❶ បង្ហាញថា $f(n)$ ជាអនុវត្តន៍ប្រកាន់

ឧបមាថា $m \neq n$ តែ $f(m) = f(n)$ នោះ

$$n + 1987 = f\big(f(n)\big) = f\big(f(m)\big) = m + 1987 \Rightarrow m = n$$

ផ្ទុយពីការសន្មត ។ ដូច្នេះ ចំពោះគ្រប់ $m \neq n$ យើងមាន $f(m) \neq f(n)$ ។

❷ យើងមាន

$$f(n + 1987) = f\Big(f\big(f(n)\big)\Big) = f(n) + 1987, \quad \forall\, n \in \mathbb{N}$$

ដូច្នេះ

$$\begin{aligned} &f(n + 1987) = f(n) + 1987 \\ &f(n + 2 \times 1987) = f(n + 1987) + 1987 = f(n) + 2 \times 1987 \\ &\vdots \\ &f(n + 1987t) = f(n) + 1987t \end{aligned}$$

ចំពោះគ្រប់ $n, t \in \mathbb{N}$ ។

ចំពោះគ្រប់ $r \in \{0,1, \dots, 1986\}$ តាង $f(r) = 1987k + l$ ដែល $k, l \in \mathbb{N}$ និង $l \leq 1986$ ។ យើងមាន

$$\begin{aligned} &r + 1987 = f\big(f(r)\big) = f(1987k + l) = f(l) + 1987k \\ &\Rightarrow r = f(l) + 1987(k - 1) \end{aligned}$$

យើងមាន $r \leq 1986$ ដូច្នេះ $k \leq 1$ ។ យើងមានពីរករណី

(i) $k = 1 \Rightarrow f(r) = 1987 + l$ និង $f(l) = r$ ។ ដូច្នេះ $r \neq l$ ។

(ii) $k = 0 \Rightarrow f(r) = l$ និង $f(l) = r + 1987$ ។ ដូច្នេះ $r \neq l$ ។

យើងបំបែកសំណុំ $\{0,1, \dots, 1986\}$ ជាសំណុំពីរគឺ $S_1$ និង $S_2$ ដែល បើ $r \in S_1$ នោះ $f(r) = 1987 + l$ និង $f(l) = r$ និង $r \in S_2$ នោះ $f(r) = l$ និង $f(l) = r + 1987$ ដែល $S_1 \cup S_2 = \{0,1, \dots, 1986\}$ និង $S_1 \cap S_2 = \emptyset$ ។ សន្មតថា $\mathrm{Card}(S_1) = k; \mathrm{Card}(S_2) = p$ ដែល $k + p = 1987$ ។

បើ $r_i \in S_1$ នោះ $f(r_i) = 1987 + l_i \geq 1987$ និង $f(l_i) = r_i \leq 1986$ ដែល $1 \leq i \leq k$ ។ យើងដឹងថា $l_i \neq r_i; \forall i = 1, .., k$ និង យើងមិនអាចរកបាន $j$ ដែល $l_i = r_j$ បានទេ ព្រោះ $f(l_i) \leq 1986$ និង $f(r_j) \geq 1987$ ដូច្នេះ មានតែ $l_i \in S_2$ ចំពោះគ្រប់ $i = 1, \dots, k$ ។ ដូច្នេះ $k \leq p$ ។

បើ $r_i \in S_2$ នោះ $f(r_i) = l_i \leq 1986$ និង $f(l_i) = r_i + 1987 \geq 1987$ ដែល $1 \leq i \leq p$ ។ យើងដឹងថា $l_i \neq r_i; \forall i = 1,..,p$ និង យើងមិនអាចរកបាន $j$ ដែល $l_i = r_j$ បានទេ ព្រោះ $f(l_i) \geq 1987$ និង $f(r_j) \leq 1986$ ដូច្នេះ មានតែ $l_i \in S_1$ ចំពោះគ្រប់ $i = 1, \dots, p$ ។ ដូច្នេះ $p \leq k$ ។

ដូច្នេះ យើងទាញបាន $k = p$ ។ នាំឱ្យ $k + p = 1987 \Leftrightarrow 2k = 1987 \Rightarrow k$ មិនមែនជាចំនួនគត់ ។

ដូច្នេះយើងមិនអាចរកបានអនុគមន៍ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌក្នុងសម្មតិកម្មបានទេ ។

**1003.** ▲ តាង $g(x) = f(x) - f(tx)$ ។ ដោយ $f$ ជាប់ត្រង់ 0 ដូច្នេះ $g(x)$ ក៏ជាប់ត្រង់ $x$ ដែរ ហើយយើងមាន $g(0) = 0$ ។ ចំពោះគ្រប់ $x \in \mathbb{R}$ យើងមាន

$$\begin{aligned} & f(x) - 2f(tx) + f(t^2x) = x^2 \\ \Leftrightarrow\ & f(x) - f(tx) - [f(tx) - f(t^2x)] = x^2 \\ \Leftrightarrow\ & g(x) - g(tx) = x^2 \end{aligned}$$

ចំពោះគ្រប់ចំនួនគត់ $n \geq 1$ :

$$\begin{aligned} & g(x) - g(tx) = x^2 \\ & g(tx) - g(t^2x) = t^2x \\ & \vdots \\ & g(t^{n-1}x) - g(t^nx) = t^{2(n-1)}x^2 \end{aligned}$$

បូកសមភាពទាំងនេះបញ្ចូលគ្នា និង ដោយដឹងថា $t^2 \neq 1$ , យើងទទួលបាន

$$g(x) - g(t^nx) = x^2\left(1 + t^2 + \cdots + t^{2(n-1)}\right) = x^2\frac{1 - t^{2n}}{1 - t^2} \qquad (*)$$

ដោយ $0 < t < 1$ នោះឱ្យ $n \to +\infty$ និង ដឹងថា $g$ ជាប់ត្រង់ 0 នោះ $\lim_{n\to+\infty} g(t^nx) = g(0) = 0$ ។ ក្នុង (*)ឱ្យ $n \to +\infty$ យើងទាញបាន

$$g(x) - g(0) = \frac{x^2}{1 - t^2} \Rightarrow g(x) = \frac{x^2}{1 - t^2}$$

$$\Rightarrow f(x) - f(tx) = \frac{x^2}{1 - t^2}$$

ដូច្នេះ

$$f(x) - f(tx) = x^2 \frac{1}{1-t^2}$$
$$f(tx) - f(t^2x) = x^2 \frac{t^2}{1-t^2}$$
$$\vdots$$
$$f(t^{n-1}x) - f(t^n x) = x^2 \frac{t^{2(n-1)}}{1-t^2}$$

បូកសមភាពចូលគ្នា យើងទាញបាន

$$f(x) - f(t^n x) = \frac{x^2}{1-t^2}\left(1 + t^2 + \cdots + t^{2(n-1)}\right) = x^2 \frac{1-t^{2n}}{(1-t^2)^2}$$

ឱ្យ $n \to +\infty$ យើងទទួលបាន $f(x) - f(0) = \frac{x^2}{(1-t^2)^2}$ ចំពោះគ្រប់ $x \in \mathbb{R}$ ។ ដូច្នេះ $f(x) = \frac{x^2}{(1-t^2)^2} + k$ ដែល $k$ ជាចំនួនថេរណាមួយ ។

ច្រាសមកវិញ បើ $f(x) = \frac{x^2}{(1-t^2)^2} + k$ នោះ

$$\begin{aligned} f(x) &- 2f(tx) + f(t^2x) \\ &= \left[\frac{x^2}{(1-t^2)^2} + k\right] - 2\left[\frac{t^2x^2}{(1-t^2)^2} + k\right] + \left[\frac{t^4x^2}{(1-t^2)^2} + k\right] \\ &= \frac{x^2 - 2t^2x^2 + t^4x^2}{(1-t^2)^2} = x^2 \end{aligned}$$

ពិត ។

**1004.** ▲ យើងកំណត់ស្វ៊ីត $(x_n)$ មួយដោយ $x_0 = x$ ដែល $x$ ជាចំនួនពិត និងចំពោះគ្រប់ចំនួនគត់ $n \geq 0$ : $x_{n+1} = f(x_n)$ ។ យើងមាន

$$x_{n+2} + ax_{n+1} - b(a+b)x_n = 0$$

សមីការ $X^2 + aX - b(a+b) = 0$ មានឫសពីរ គឺ $b$ និង $(-a-b)$ ។ ដូច្នេះ ចម្លើយទូទៅរបស់សមីការស្វ៊ីតកំណត់ដោយ $x_n = \lambda\, b^n + \mu(-a-b)^n$ ដែល $n \geq 0$ ជាចំនួនគត់ ។ ដោយ $a, b > 0$ នោះ $b^n < |(-a-b)^n|$ ដូច្នេះ បើ $\mu \neq 0$ នោះ ចំពោះ $n$ ធំគ្រប់គ្រាន់ណាមួយ គេនឹងបាន $\lambda\, b^n + \mu(-a-b)^n < 0 \Rightarrow x_n < 0$ តែ $x_n = f(x_{n-1}) \geq 0$ ។ ដូច្នេះ មានតែ $\mu = 0$ ។

ចំពោះ $n=0$ និង $n=1$ យើងទទួលបាន $x_0=\lambda=x$ និង $x_1=f(x)=\lambda b=bx$ ។ ដូច្នេះមានន័យថា $f(x)=bx$ ។

ច្រាសមកវិញ ចំពោះ $f(x)=bx$ នោះ

$$f\big(f(x)\big)+af(x)=b^2x+abx=b(a+b)x$$

ពិត ។

ដូច្នេះ សមីការអនុគមន៍មានឫសនិងមានឫសតែមួយគត់ កំណត់ដោយ $f(x)=bx$ ។

**1005.** ▲ យើងមាន $f$ កំណត់លើ $[0,1]$ ហើយ ដោយ $x\in[0,1]$ នោះ $2x-f(x)\in[0,1]$ ។ តាង $g(x)=2x-f(x)$ ។ ដូច្នេះអនុគមន៍ $g$ កំណត់លើ $[0,1]$ ។ តាមសម្មតិកម្ម ចំពោះគ្រប់ $x : f\big(g(x)\big)=x$ ។

ចំពោះគ្រប់ចំនួនគត់ $n\geq 0$ តាង

$g^2(x)=g\big(g(x)\big), g^3(x)=g\big(g^2(x)\big),\ldots,g^n(x)=g\big(g^{n-1}(x)\big)$ ។ ចំពោះគ្រប់ $x\in[0,1]$ គេមាន $g\big(g(x)\big)=2g(x)-f\big(g(x)\big)=2g(x)-x$ ។ តាមវិចារដោយកំណើន យើងទាញបានចំពោះគ្រប់ $x\in[0,1]$ និង $n\in\mathbb{N}$ : $g^n(x)=n(g(x)-x)+x$ ។

សន្មតថា មាន $x_0\in[0,1]$ ដែល $g(x_0)=x_0$ ។ បើ $g(x_0)-x_0>0$ នោះ $\lim_{n\to+\infty}g^n(x_0)=\lim_{n\to+\infty}n(g(x_0)-x_0)+x_0=+\infty$ តែលទ្ធផលនេះផ្ទុយពីលក្ខខណ្ឌដែល $g$ ជាអនុគមន៍ទាល់ ។ ដូចគ្នា ចំពោះករណី $g(x_0)-x_0<0$ ។ ដូច្នេះមានតែ ចំពោះគ្រប់ $x\in[0,1]$ គេមាន $g(x)=x$ ។ យើងទាញបាន $f(x)=x$ ចំពោះគ្រប់ $x\in[0,1]$ ។

ច្រាសមកវិញ អនុគមន៍ $f(x)=x$ ពិតជាផ្ទៀងផ្ទាត់ $f\big(2x-f(x)\big)=x$ ។

**1006.** ▲ ជំនួស $y=x$ ចូលក្នុង i) យើងទាញបាន $f\big(xf(x)\big)=xf(x)$ ។ តាង $z=x\,f(x)$ ដូច្នេះ $f(z)=z$ ។

យើងទាញបានថា $f(z) = z$ ចំពោះគ្រប់ $z = x\,f(x)$ ។ សន្មតថា $a$ ជាតម្លៃមួយនៃ $z$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌនេះ ។

យើងមាន $f(a^2) = f\big(af(a)\big) = af(a) = a^2$ ។ តាមវិចារដោយកំណើន យើងទាញបាន $f(a^n) = a^n$ ។ បើ $a > 1$ នោះ $a^n \to +\infty$ ពេល $n \to +\infty$ ដែលផ្ទុយពីលក្ខខណ្ឌ ii) ។

តាម i) យក $x = 1$ និង $y = a$ យើងទាញបាន $f\big(1.f(a)\big) = af(1) \Rightarrow f(a) = a\,f(1) \Rightarrow a = af(1) \Rightarrow f(1) = 1$ ។

តាម i) យក $x = 1/a\;; y = a$ យើងទាញបាន

$$f\left(\frac{1}{a}.f(a)\right) = af\left(\frac{1}{a}\right) \Leftrightarrow f\left(\frac{1}{a}.a\right) = a\,f\left(\frac{1}{a}\right)$$
$$\Leftrightarrow 1 = a\,f\left(\frac{1}{a}\right) \Rightarrow f\left(\frac{1}{a}\right) = \frac{1}{a}$$

តាមវិចារដោយកំណើន យើងទាញបាន $f(1/a^n) = 1/a^n$ ។ បើ $a < 1$ នោះ $\frac{1}{a^n} \to +\infty$ ពេល $n \to +\infty$ ដែលផ្ទុយពីលក្ខខណ្ឌ ii) ។

ដូច្នេះមានតែ $a = 1$ ។ ដូច្នេះ $xf(x) = 1 \Rightarrow f(x) = 1/x$ ។

ច្រាសមកវិញ យើងឃើញថា ចំពោះ $f(x) = 1/x$ យើងមាន

$$f\big(xf(y)\big) = \frac{1}{xf(y)} = \frac{y}{x}$$
$$yf(x) = \frac{y}{x}$$
$$\Rightarrow f\big(xf(y)\big) = yf(x)$$

និង $\lim_{x\to+\infty} f(x) = \lim_{x\to+\infty}\frac{1}{x} = 0$ ពិត ។

ដូច្នេះសមីការអនុគមន៍មានឫសមួយ គឺ $f(x) = 1/x$ ។

**1007.** ▲ យើងមាន

$$\frac{1}{2}f\left(\frac{2x}{3x-2}\right) + f(x) = 503x \quad (1)$$

ចំពោះគ្រប់ $x \in \mathbb{R} - \{2/3\}$ ។

គាង

$$u = \frac{2x}{3x-2} \Longrightarrow x = \frac{2u}{3u-2}$$

ដែល $u \in \mathbb{R} - \{2/3\}$ ។ យើងឃើញថាចំពោះគ្រប់ $u$ យើងអាចរកបាន $x$ ដែលផ្ទៀងផ្ទាត់ទំនាក់ទំនងនេះជានិច្ច ។

ដូច្នេះ

$$\frac{1}{2}f(u) + f\left(\frac{2u}{3u-2}\right) = 503\,\frac{2u}{3u-2}$$

ចំពោះគ្រប់ $u \in \mathbb{R} - \{2/3\}$ ។ ជំនួស $u$ ដោយ $x$ យើងទទួលបាន

$$\frac{1}{2}f(x) + f\left(\frac{2x}{3x-2}\right) = 503\frac{2x}{3x-2}$$

$$\Longrightarrow \frac{1}{4}f(x) + \frac{1}{4}f\left(\frac{2x}{3x-2}\right) = \frac{503x}{3x-2} \quad (2)$$

យក (1) ដក (2) យើងទទួលបាន

$$\frac{3}{4}f(x) = 503x - \frac{503x}{3x-2} = \frac{503x(3x-3)}{3x-2}$$

$$\Longrightarrow f(x) = \frac{2012x(x-1)}{3x-2}$$

ច្រាសមកវិញ បើ $f(x) = \frac{2012x(x-1)}{3x-2}$ នោះ

$$\frac{1}{2}f\left(\frac{2x}{3x-2}\right) + f(x) = \frac{1}{2}\left[\frac{2012.\frac{2x}{3x-2}\cdot\left(\frac{2x}{3x-2}-1\right)}{3.\frac{2x}{3x-2}-2}\right] + \frac{2012x(x-1)}{3x-2}$$

$$= \frac{1}{2}\frac{2012.2x.(2-x)}{4(3x-2)} + \frac{2012x(x-1)}{3x-2}$$

$$= \frac{503x}{3x-2}(2-x+4x-4)$$

$$= 503x$$

ពិត ។

ដូច្នេះ

$$f(x) = \frac{2012x(x-1)}{3x-2}, \forall x \in \mathbb{R} - \left\{\frac{2}{3}\right\}$$

**1008.** ▲ យើងមាន

$$\begin{aligned}[f(\sin 2x)]^2 &= (\sin x + \cos x)^2 \\ &= \sin^2 x + \cos^2 x + 2\sin x \cos x \\ &= 1 + \sin 2x\end{aligned}$$

យើងដឹងថា $\sin 2x$ ជាអនុវត្តន៍មួយទល់មួយពី $I$ ទៅ $[-1,1]$ ។ ដូច្នេះ ចំពោះគ្រប់ $-1 \le t \le 1$ គេមាន $x$ តែមួយគត់ក្នុង $I$ ដែល $\sin 2x = t$ ។ ដូច្នេះ ចំពោះ $-1 \le t \le 1$, $[f(t)]^2 = 1 + t$ ។ ចំពោះ $x \in I$ យើងមាន $\sin x + \cos x \ge 0$ ដូច្នេះ $f(t) \ge 0$ ។ ដូច្នេះ $f(t) = \sqrt{1+t}$ ចំពោះ $-1 \le t \le 1$ ។

ចំពោះ $-\frac{\pi}{4} \le x \le \frac{\pi}{4}$ យើងមាន $-1 \le \tan x \le 1$ និង ដូច្នេះ $0 \le \tan^2 x \le 1$ ដូច្នេះ

$$f(\tan^2 x) = \sqrt{1 + \tan^2 x} = \frac{1}{\cos x}$$

# ឯកសារដើម

លំហាត់ក្នុងសៀវភៅនេះ ត្រូវបានដកស្រង់ចេញពីសៀវភៅដូចតទៅនេះ ៖

1. Pierre Bornsztein, *Inégalité*, 2001

2. Hojoo Lee, *Topic in Inequalities-Theorems and Techniques*

3. A.I Prilepko, *Problem Book in High-School Mathematics*, MIR Moscow, 1985

4. D.O. Shklarsky, N.N. Chentzov, I. M. Yaglom, *The USSR Olympiad Problem Book*, Dover Publications, INC. New York, 1993.

5. Dusan Djukic, Vladimir Jankovic, Ivan Matic, Nikola Petrovic, *The IMO Compendium*, Springer, 2006

6. GS. PHAN ĐỨC CHÍNH, *101 Bài Toán Chọn lọc*, Nhà Xuất Bản Trẻ,1996

7. *Tuyển Tập Đề thi olympic 30-4,Môn Toán*, Nhà Xuất Bản Giáo Dục, 1999.

8. Pierre Bornsztein, Moubinool Omarjee, *Cours- Equations Fonctionnelles*, 2003

# កម្រងលំហាត់គណិតវិទ្យា

កម្រិតវិទ្យាល័យ

ភាគ ២- ពីជគណិត វិភាគ

ដោយ លឹម សុវណ្ណវិចិត្រ

សៀវភៅកំណែលំហាត់ផ្នែកពីជគណិត ដែលរួមមានសមភាព សមីការ វិសមភាព វិសមីការ នៃអនុគមន៍ធម្មតា អនុគមន៍ត្រីកោណមាត្រ និង អ៊ិចស្ប៉ូណង់ស្យែល ។ សៀវភៅនេះប្រជុំដោយលំហាត់ងាយ និងពិបាក ជាង ១០០០ លំហាត់ ដកស្រង់ចេញពីការប្រឡងសិស្សពូកែនៅក្នុងប្រទេសនានាជុំវិញពិភពលោក ។ បើអ្នកចង់ក្លាយជាសិស្សពូកែម្នាក់ សៀវភៅមួយក្បាលនេះ អ្នកគួរតែមាន ៕